# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារខ្លឹមសារលម្អិត
## សម្រាប់បណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបឋមសិក្សា
## (១២+២)
## តាមប្រព័ន្ធក្រេឌីត
# ភាសាខ្មែរ

ឆ្នាំ ២០២០

# អារម្ភកថា

ក្នុងនាមក្រុមចងក្រង "ឯកសារខ្លឹមសារលម្អិតភាសាខ្មែរ សម្រាប់កម្មវិធីបណ្ដុះបណ្ដាលគ្រូបឋមសិក្សា១២+២តាមប្រព័ន្ធក្រេឌីត" យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអស់លោក លោកស្រីជាគ្រូឧទ្ទេសនៅតាមសាលាគរុកោសល្យ ដែលបានប្រើប្រាស់សៀវភៅនេះ ជាទីគោរព និងរាប់អាន !

សៀវភៅនេះបង្កើតឡើងក្នុងគោលបំណង ដើម្បីជួយបំពេញបន្ថែមនូវកង្វះខាតដល់គ្រូឧទ្ទេសក្នុងការបង្រៀន និងរៀនដល់គរុសិស្សឱ្យមានប្រសិទ្ធិភាព ហើយក៏ជាទុនសម្រាប់គ្រូឧទ្ទេសក្នុងការសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារក្នុងកម្មវិធីបណ្ដុះបណ្ដាលគ្រូបឋមសិក្សា និងយកធ្វើជាឯកសារយោងបាន។ ម្យ៉ាងទៀតឯកសារនេះ ក៏ជួយគ្រូឧទ្ទេសឱ្យមានទំនុកចិត្តក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរកាន់តែប្រសើរឡើង។ ជាពិសេស ការចងក្រងឯកសារនេះឡើង ក្នុងគោលបំណងឱ្យមានការឯកភាពគ្នាលើការបង្រៀន និងរៀនលើមុខវិជ្ជាភាសាខ្មែរនៅតាមសាលាគរុកោសល្យ និងវិក្រឹតការ។

ក្រុមយើងខ្ញុំក៏សូមអភ័យទោសផងដែរ នូវរាល់កង្វះខាតទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធ ដែលអាចកើតមាននៅក្នុងសៀវភៅនេះ។ ក្រុមយើងខ្ញុំរង់ចាំទទួលនូវការរិះគន់ ដើម្បីកែលម្អពីសំណាក់អស់លោក លោកស្រីទាំងអស់ដោយក្ដីសោមនស្ស។

ជាទីបញ្ចប់ក្រុមយើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីបវរជូនដល់អស់លោក លោកស្រី គ្រូឧទ្ទេសទាំងអស់សូមបានប្រកបតែនឹងជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ក្រុមចងក្រងឯកសារខ្លឹមសារលម្អិតភាសាខ្មែរ**

# មាតិកា


ចំណេះដឹងមូលដ្ឋាន ........................................ 1
ទ្រឹស្តីអក្សរសិល្ប៍ ........................................ 2
១. វត្ថុបំណង ........................................ 2
២. ខ្លឹមសារមេរៀន ........................................ 2
២.១ និយមន័យអក្សរសិល្ប៍ ........................................ 2
២.២ ប្រភពនៃអក្សរសិល្ប៍ ........................................ 3
២.៣ កម្មវត្ថុរបស់អក្សរសិល្ប៍ ........................................ 5
២.៤ មុងងារអក្សរសិល្ប៍ ........................................ 5
២.៥ ចលនាអក្សរសិល្ប៍ ........................................ 8
២.៦ លក្ខណៈអក្សរសិល្ប៍ ........................................ 11
២.៧ ប្រភេទអក្សរសិល្ប៍ ........................................ 15
៣. សន្និដ្ឋាន ........................................ 20
អក្សរសិល្ប៍ប្រជាប្រិយ ........................................ 21
១. វត្ថុបំណង ........................................ 21
២. ខ្លឹមសារមេរៀន ........................................ 21
២.១ ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ប្រជាប្រិយ ........................................ 21
២.២ បញ្ញត្តិនិងនិយមន័យនៃពាក្យ « អក្សរសិល្ប៍ប្រជាប្រិយ » ........................................ 21
២.៣ ប្រភេទអក្សរសិល្ប៍ប្រជាប្រិយ ........................................ 23
អក្សរសិល្ប៍ខ្មែរសម័យមុនអង្គរ ........................................ 28
( សតវត្សទី១ ដល់សតវត្សទី៩ ) ........................................ 28
១. វត្ថុបំណង ........................................ 28
២. ខ្លឹមសារមេរៀន ........................................ 28

២.១ សម័យនគរភ្នំ ( ស.វ.ទី ១ ដល់ គ.ស. ៥៥០ ) ........................................ 28
២.២ អក្សរសិល្ប៍សម័យចេនឡា ( គ.ស.៥៥០ ដល់គ.ស.៨០២ ) ........................ 33
៣.សន្និដ្ឋាន ........................................ 37
អក្សរសិល្ប៍សម័យអង្គរ ........................................ 39
( សតវត្សទី៩ ដល់សតវត្សទី១៥ ) ........................................ 39
១. វត្ថុបំណងមេរៀន ........................................ 39
២.១ លក្ខណៈអក្សរសិល្ប៍ ........................................ 39
២.២ គោលបញ្ហានៃអក្សរសិល្ប៍ ........................................ 39
២.៣ អត្ថរូបនៃអក្សរសិល្ប៍ ........................................ 40
២.៤ អ្នកនិពន្ធល្បីៗ និងស្នាដៃ ........................................ 40
៣. សន្និដ្ឋាន ........................................ 41
អក្សរសិល្ប៍សម័យកណ្ដាល ........................................ 42
( សតវត្សទី១៦ - សតវត្សទី១៩ ) ........................................ 42
១. វត្ថុបំណង ........................................ 42
២. ខ្លឹមសារមេរៀន ........................................ 42
២.១ អក្សរសិល្ប៍សម័យលង្វែក ( ពីស.វ.ទី១៥ - ស.វ.ទី១៧ ) ........................ 42
២.២ អក្សរសិល្ប៍សម័យឧដុង្គ (សតវត្សទី១៧ ដល់ទី១៩) ........................ 42
អក្សរសិល្ប៍សម័យបុរាណ ........................................ 44
២.១ អក្សរសិល្ប៍ព្រាហ្មណ៍និយម ........................................ 44
២.២ អក្សរសិល្ប៍ពុទ្ធនិយម ........................................ 44
អក្សរសិល្ប៍សម័យទំនើប ........................................ 46
១. វត្ថុបំណងមេរៀន ........................................ 46
២ ខ្លឹមសារមេរៀន ........................................ 46

២.១ ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍សម័យទំនើប ....................................................................46

២.២ អក្សរសិល្ប៍សម័យអាណានិគមបារាំង (គ.ស.១៨៦៣ - ១៩៥៣ )......................................48

២.៣ អក្សរសិល្ប៍សម័យសង្គមរាស្ត្រនិយម (គ.ស.១៩៥៣ - ១៩៧០ ) .....................................48

២.៤ អក្សរសិល្ប៍សម័យសាធារណរដ្ឋ ( គ.ស.១៩៧០ - ១៩៧៥ ) ..............................................49

២.៥ អក្សរសិល្ប៍សម័យកម្ពុជាប្រជាធិបតេយ្យ ( គ.ស.១៩៧៥ - ១៩៧៩ )..................................49

២.៦ អក្សរសិល្ប៍សម័យក្រោយថ្ងៃ៧មករា ឆ្នាំ១៩៧៩ រហូតដល់បច្ចុប្បន្ន ...................................49

៣. សន្និដ្ឋាន ......................................................................................................................50

សិក្សាអត្ថបទអក្សរសិល្ប៍ ........................................................................................................52

១. វត្ថុបំណង៖ .....................................................................................................................52

២. ខ្លឹមសារមេរៀន ...............................................................................................................52

៣. សន្និដ្ឋាន ......................................................................................................................54

ភាសាវិទ្យា ...........................................................................................................................55

១. វត្ថុបំណង .......................................................................................................................55

២. ខ្លឹមសារមេរៀន ...............................................................................................................55

២.១ សញ្ញាណទូទៅអំពីភាសា ...............................................................................................55

២.២ ប្រវត្តិភាសាខ្មែរ .............................................................................................................56

២.៣ វិវត្តន៍នៃភាសាខ្មែរ .........................................................................................................57

២.៤ លក្ខណៈពិសេសនៃភាសាខ្មែរ..........................................................................................58

២.៥ សូរវិទ្យា .......................................................................................................................62

២.៥.១ អំពី « ស្រៈ » ..............................................................................................................62

២.៦ វចនវិទ្យា........................................................................................................................71

២.៧ ល្បះ...........................................................................................................................109

៣. សន្និដ្ឋាន ....................................................................................................................110

វិធីសាស្ត្របង្រៀន ........................................................................................111
សញ្ញាណដំបូងនៃការបង្រៀនភាសាខ្មែរ ...................................................................112
មេរៀនទី១...................................................................................................................115
បញ្ញត្តិមួយចំនួនស្តីពីភាសា និងការបង្រៀនភាសាខ្មែរ ...........................................115
**១.** វត្ថុបំណងមេរៀន ..........................................................................................115
**២.** ខ្លឹមសារមេរៀន ............................................................................................115
២.១ បញ្ញត្តិអំពីភាសា និងការបង្រៀនភាសាខ្មែរ ......................................................115
២.២ ការអនុវត្តបានត្រឹមត្រូវតាមដំណាក់ផ្សេងៗនៃការបង្រៀនភាសា ..........................116
៣. សន្និដ្ឋាន ........................................................................................................118
មេរៀនទី២ ..................................................................................................................119
វិធីសាស្ត្របង្រៀនភាសាខ្មែរថ្នាក់ដំបូង.......................................................................119
១. វត្ថុបំណងមេរៀន ............................................................................................119
**២.**ខ្លឹមសារមេរៀន ..............................................................................................119
២.១ ការណែនាំអំពីសៀវភៅណែនាំគ្រូ និងសៀវភៅជំនួយសិស្សថ្នាក់ទី១.....................119
៣. លំនាំបង្រៀន...................................................................................................125
៣.១ លំនាំបង្រៀនស្រះលម្អិតស្រះ ៃ...........................................................................125
៣.២ លំនាំបង្រៀនព្យញ្ជនៈ ក ផ្សំស្រះ ......................................................................132
៣.៣ លំនាំបង្រៀនសញ្ញាមូសិកទន្ត និងត្រីស័ព្ទ.......................................................135
៣.៤ លំនាំបង្រៀនមេរៀនប្រកប .............................................................................144
៣.៥ លំនាំបង្រៀនស្រះពេញតួ.................................................................................154
៣.៦ លំនាំបង្រៀនព្យញ្ជនៈ និងជើងព្យញ្ជនៈ ............................................................162
៣.៧ លំនាំបង្រៀនផ្ញើជើង........................................................................................163
៣.៨ លំនាំបង្រៀនមេរៀនព្យាង្គតម្រួត ង្ក ង្ខ ង្ស ង្គ ង្ឃ...................................................170

៣.៩ លំនាំបង្រៀនអំណាន ....175

៣.១០ លំនាំបង្រៀននិយាយ ....181

៣.១១ លំនាំបង្រៀនស្តាប់....185

៤. សន្និដ្ឋាន ....192

មេរៀនទី៣ ....195

វិធីបង្រៀនថ្នាក់ទី៤ ទី៥ ទី៦....195

១. វត្ថុបំណងមេរៀន ....195

២. ខ្លឹមសារមេរៀន ....195

២.១ លំនាំបង្រៀនសមត្ថភាពស្តាប់....195

២.២ លំនាំបង្រៀននិយាយ ....199

២.៣ លំនាំបង្រៀនសមត្ថភាពអាន ....202

២.៤ លំនាំបង្រៀនសមត្ថភាពសរសេរ....205

២.៥ លំនាំបង្រៀនវេយ្យាករណ៍ ....214

២.៦ លំនាំបង្រៀនបំណិន....215

៣. សន្និដ្ឋាន ....215

# ចំណេះដឹងមូលដ្ឋាន

# ទ្រឹស្តីអក្សរសិល្ប៍

## ១. វត្ថុបំណង

មេរៀននេះ បានផ្តល់ចំណេះដឹងអំពី៖

- គោលការណ៍ទូទៅរបស់អក្សរសិល្ប៍
- និយមន័យផ្សេងៗទាក់ទងនឹងអក្សរសិល្ប៍
- ប្រភពរបស់អក្សរសិល្ប៍
- កម្មវត្ថុរបស់អក្សរសិល្ប៍
- មុខងារអក្សរសិល្ប៍
- ចលនាអក្សរសិល្ប៍
- លក្ខណៈអក្សរសិល្ប៍
- បំណែងចែកប្រភេទអក្សរសិល្ប៍
- បណ្តុះស្មារតីស្រឡាញ់ ថែរក្សា និងលើកស្ទួយវិស័យអក្សរសិល្ប៍ជាតិឱ្យរីកចម្រើន ព្រោះអក្សរសិល្ប៍បានបង្កប់នូវតម្លៃមហាសាលដល់អ្នកអាន អ្នកសិក្សាបានក្លាយជាធនធានក្នុងសង្គម។

## ២. ខ្លឹមសារមេរៀន

ទ្រឹស្តីអក្សរសិល្ប៍ ជាវិទ្យាសាស្ត្រសិក្សាពីក្រឹត្យក្រមឆ្លុះបញ្ចាំងតថភាពនៃអក្សរសិល្ប៍ តាមរយៈការស្រាវជ្រាវអំពីសារជាតិសង្គម និងលក្ខណៈពិសេសនៃអក្សរសិល្ប៍។ ទ្រឹស្តីអក្សរសិល្ប៍បានធ្វើការសិក្សាស្រាវជ្រាវបញ្ហាទាំងឡាយ ដែលអក្សរសិល្ប៍បានជះឥទ្ធិពលទៅលើជីវភាពសង្គមលើដំណើរនិម្មិតកម្មរបស់អ្នកនិពន្ធ។ ទ្រឹស្តីអក្សរសិល្ប៍មានភារកិច្ចប្រមូលផ្តុំការសិក្សាស្រាវជ្រាវ រកឱ្យឃើញនូវក្រឹត្យក្រមទាំងឡាយ ដែលទាក់ទងទៅនឹងវិធីនិម្មិតកម្មអក្សរសិល្ប៍។

តាមទ្រឹស្តីវិទ្យាសាស្ត្រ " អក្សរសិល្ប៍ " ជាបាតុភូតពិសេសនៃតថភាពដែលទាមទារធ្វើការស្រាវជ្រាវតាមវិទ្យាវិធី ប៉ុន្តែសេចក្តីនេះ ពុំមានន័យថាត្រូវតែអនុវត្តតាមវិទ្យាវិធីបែបគណិតវិទ្យាក្នុងការសិក្សាអក្សរសិល្ប៍សិល្បៈនោះទេ។

នៅក្នុងវិទ្យាសាស្ត្រយើងប្រើវិធីពីរយ៉ាងគឺ វិធីពិសោធន៍ (ប្រើប្រាស់ក្នុងវិទ្យាសាស្ត្រ) និងវិធីសង្កេត (ប្រើប្រាស់ក្នុងវិទ្យាសាស្ត្រសង្គម )។

### ២.១ និយមន័យអក្សរសិល្ប៍

#### ២.១.១ តាមន័យជាតិសព្ទ

**អក្សរសិល្ប៍ = អក្សរ + សិល្ប៍**

- **អក្សរ៖** សំដៅស្នាមគំនូសដែលចារនៅលើផ្ទាំងថ្ម ស្បែកសត្វ ...សម្រាប់កត់ត្រានូវរាល់ពាក្យសម្តី ឬសកម្មភាពផ្សេងៗទុកជាគោលប្រវត្តិសាស្ត្រ។

- **សិល្បៈ** សំដៅលក្ខណៈច្នៃប្រឌិតធ្វើឱ្យមានសោភ័ណភាព មានភាពរស់រវើក គួរជាទីចាប់ចិត្ត បង្កើតនូវចិត្តរំភើប។

រួមមកអក្សរសិល្ប៍ ជាការយកតួអក្សរមកធ្វើជាមធ្យោបាយសម្រាប់រចនាបង្កើតជាប្រភេទស្នាដៃផ្សេងៗ ដូចជាសិល្បៈប្រើអក្សរជាពាក្យពាយ សិល្បៈប្រើអក្សរជាពាក្យកាព្យ សិល្បៈប្រើអក្សរជារឿងល្ខោនសម្រាប់សម្ដែងនៅលើឆាក សិល្បៈប្រើអក្សរសម្រាប់សម្ដែងវោហារជាដើម។

### ២.១.២ តាមន័យបច្ចេកសព្ទ

អក្សរសិល្ប៍ ជាវិទ្យាសាស្ត្រដែលលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយទៅតាមការពិតនៃសម័យកាលដែលគេរស់នៅដោយប្រើសិល្បវិធី។

### ២.១.៣ តាមគណៈកម្មាធិការជាតិភាសាខ្មែរ

អក្សរសិល្ប៍ គឺជាផ្នែកមួយនៃអក្សរសាស្ត្រ ដែលអ្នកនិពន្ធលើកពីបញ្ហាមនុស្ស បញ្ហាសង្គមមកចោទ និងដោះស្រាយ ដោយប្រើសិល្បវិធី។

### ២.១.៤ តាមទស្សនៈរបស់អ្នកប្រាជ្ញជាតិ និងអន្តរជាតិ

- **លោក កេង វ៉ាន់សាក់៖** អក្សរសិល្ប៍ គឺជាវិទ្យាស្បង់ដែលចោទ និងដោះស្រាយបញ្ហាមនុស្សទៅតាមសង្គមនីមួយៗ ដោយប្រើសិល្បវិធី។
- **លោក ជ័យ ចាប និងលោក ពន់ ឆាយ៖** អក្សរសិល្ប៍ គឺជាសិល្បៈនៃការសម្ដែងតាមអក្សរ ឬការប្រើអក្សរដើម្បីបញ្ចេញទស្សនៈ ឬចក្ខុសម្ផស្ស។
- **លោក គ័រគី ( Gorki )៖** អក្សរសិល្ប៍ គឺជាការសិក្សាអំពីមនុស្ស។
- **លោក ស្តង់ដាជ៍ ( Stendhad )៖** អក្សរសិល្ប៍ ជាកញ្ចក់ដែលគេដាក់នៅតាមដងផ្លូវ។
- **លោក អេថៃន ឡាប្លេនី៖** អក្សរសិល្ប៍ ជាមែកធាងមួយនៃសិល្បៈ។
- **លោក សង់ ប៉ូសាត៖** អក្សរសិល្ប៍គឺជាការបញ្ចេញគំនិតទាក់ទងដោយអារម្មណ៍មនោសញ្ចេតនាមតិ និងដោយពាក្យសម្ដី ជាសំឡេងកត់ត្រាទុកដើម្បីជាមធ្យោបាយធ្វើសកម្មភាពផង និងជាសិល្បៈផង។
- **លោក ម៉ាក្ស-លេនីន៖** អក្សរសិល្ប៍ជាមធ្យោបាយដ៏មុតស្រួច វិសេសវិសាល សម្រាប់យល់ដឹងពីតថភាពសង្គម និងជាកត្តាសំខាន់មួយនៃជីវភាពរស់នៅ។

## ២.២ ប្រភពនៃអក្សរសិល្ប៍

អក្សរសិល្ប៍បានកើតតាំងពីយូរយារមកហើយ។ មនុស្សចេះច្រៀង រាំ ចេះប្រើសិល្បៈដើម្បីកែច្នៃឧបករណ៍ប្រើប្រាស់។ ពីមួយថ្ងៃទៅមួយថ្ងៃកម្លាំងផលិតកម្មមានការរីកចម្រើនធ្វើឱ្យមានការបែងចែកពលកម្មជាពីរ គឺពលកម្មរូបរាងកាយ និងពលកម្មប្រាជ្ញា ហើយជីវភាពស្មារតីរបស់មនុស្សក៏កាន់តែរីកចម្រើន សម្បូរបែបនិងស្មុគស្មាញ ជាហេតុនាំឱ្យមានការលំបាកក្នុងការស្វែងរកប្រភពរបស់អក្សរសិល្ប៍។

មានទស្សនៈប្លែកគ្នាបួន ដែលបានលើកឡើងអំពីប្រភពអក្សរសិល្ប៍ សិល្បៈដូចជា៖

**ប្រភពទី១៖** អក្សរសិល្ប៍មានប្រភពពីសភាវៈកម្សាន្ត

ឆ្លងកាត់ការងារនឿយហត់ នាំឱ្យសភាវគតិចង់កម្សាន្តកើតឡើងឯកឯង។

ឧទាហរណ៍៖ ដើរឃ្វាលគោហាលថ្ងៃមានការនឿយហត់ នាំឱ្យអ្នកគង្វាល បន្លឺឡើងនូវបទចម្រៀងផ្សេងៗ។ មានន័យថាការនឿយហត់ បង្កើតឡើងនូវការចង់កម្សាន្តសប្បាយ។

មនុស្សនឿយណាយនឹងជីវភាពរស់នៅ និងគ្រោះធម្មជាតិ។ ពលកម្មលំបាកនឿយហត់នាំឱ្យមនុស្សយល់ថាគេបានសប្បាយនៅពេលគេឈប់សម្រាកពីពលកម្ម។ ពេលឈប់ចំណុះធម្មជាតិនាំឱ្យគេមានសេរីភាពនាំឱ្យមនុស្សចង់កម្សាន្តសប្បាយ។

ពួកគេយល់ថាការប្រមាញ់ ការនេសាទ ពុំមែនជាពលកម្មនោះទេ ប៉ុន្តែគឺជាការកម្សាន្តសប្បាយ ព្រោះការងារទាំងនេះទាមទារឱ្យយើងប្រើប្រាស់នូវលក្ខណៈទន់ភ្លន់។

ទស្សនៈនេះយល់ថាសភាវៈកម្សាន្តបង្កើតអក្សរសិល្ប៍ សិល្បៈ។

**ប្រភពទី២៖** អក្សរសិល្ប៍មានប្រភពពីសភាវគតិអនុកម្ម ( ការត្រាប់តាម )

អនុកម្មជាការត្រាប់តាម ការចម្លងតាមស្នាដៃសិល្បៈ អក្សរសិល្ប៍ដែលមានរួចមកហើយ មកពណ៌នាបង្ហាញ គូរ ឆ្លាក់ឱ្យឃើញឡើងវិញ។

ទស្សនៈនេះចាត់ទុកអក្សរសិល្ប៍ សិល្បៈ គ្រាន់តែជាការចម្លងតាមបាតុភូតទាំងឡាយ ដែលមាននៅក្នុងធម្មជាតិ និងក្នុងជីវភាពរស់នៅប៉ុណ្ណោះ។ ឧទាហរណ៍៖ សិល្បៈនៅអាហ្វ្រិកបានយកគោលការណ៍សភាវគតិអនុកម្មនេះទាំងស្រុង។ ចម្រៀងរបស់ពួកគេស្រែកឡូឡាដូចសត្វ។ សិល្បៈអាហ្វ្រិកជាសិល្បៈបែបសភាវគតិ។ សិល្បៈខ្មែរមួយចំនួនក៏បានយកគោលការណ៍អនុកម្មនេះដែរ ដូចជារបាំក្ងោក របាំស្នែងទន្សោងរបាំហនុមាន កាយវិការអ្នករាំត្រាប់តាមសត្វ។

ទស្សនៈនេះយល់ថា មនុស្សរស់នៅក្នុងធម្មជាតិ ត្រាប់តាមធម្មជាតិ បង្កើតអក្សរសិល្ប៍ សិល្បៈ។

**ប្រភពទី៣៖** អក្សរសិល្ប៍មានប្រភពពីសាសនា ឬមន្តអាគម

សាសនាជាទម្រង់សតិអារម្មណ៍មួយ ដែលត្រួសត្រាយផ្លូវមនុស្សតាំងពីយូរណាស់មកហើយ។ រហូតមកដល់បច្ចុប្បន្ន ប្រទេសមួយចំនួននៅតែប្រកាន់យកសាសនាមកគ្រប់គ្រងលើវាសនាមនុស្សជាតិដដែល។

សម័យបុព្វកាលមនុស្សរស់នៅដោយទទួលរងការគំរាមកំហែងពីធម្មជាតិ នាំឱ្យមនុស្សមានជំនឿទៅលើកម្លាំងក្រៅខ្លួន។ ពួកគេយល់ថាមានតែអាទិទេព ឬវត្ថុស័ក្តិសិទ្ធិប៉ុណ្ណោះ ដែលមានអំណាចលើធម្មជាតិ ជាហេតុនាំឱ្យពួកគេបង្កើតសិល្បៈឡើងដើម្បីច្រៀងអង្វរ និងសរសើរបន្ទន់ចិត្តអាទិទេព ដោយការសូត្រធម៌ធ្វើបែបបទ។ ឧទាហរណ៍៖ សិល្បករអ៊ីតាលីម្នាក់ឈ្មោះ " **តាសទីនី** " បាននិយាយថាក្នុងពេលដេកលក់ គាត់យល់សប្តិឃើញបិសាចម្នាក់ដេញបទភ្លេងឱ្យគាត់ស្តាប់។ គាត់អះអាងថាបទភ្លេងនោះគ្រាន់តែចម្លងតាមបិសាចនោះតែប៉ុណ្ណោះ។ ប្រការនេះនាំឱ្យអ្នកដែលកំពុងមានជំនឿលើអាទិទេព ស្រាប់តែជឿគាត់ទាំងស្រុង។ ឯនៅប្រទេសឥណ្ឌា គេយល់ថាព្រះព្រហ្មជាអ្នកបង្កើត " **បរាន្តិមហិ** " ឱ្យចេះតែងកំណាព្យ និងតន្ត្រី។ អ្នកនិពន្ធ " **វាល្មិកិ** " បានចម្លងរឿងរាមាយណៈ តាមការនិទានប្រាប់របស់ព្រះវិស្ណុនៅពេលគាត់ដេកលក់។

ទស្សនៈនេះយល់ថាអក្សរសិល្ប៍ សិល្បៈមានប្រភពមកពីសាសនា។

**ប្រភពទី៤៖** ពលកម្មជាប្រភពពិតរបស់អក្សរសិល្ប៍ សិល្បៈ

ទស្សនវិទូម្នាក់ពោលថា៖ " ដោយសារពលកម្មមនុស្សអាចកែប្រែពិភពលោកបាន "។ មនុស្សបានវិវត្តពីសត្វស្វាម្យ៉ាងដោយសារការធ្វើពលកម្ម មិនមែនអាទិទេពបង្កើតនោះឡើយ។ ក្រោយពេលបានក្លាយមកជាមនុស្ស ពួកគេខិតខំធ្វើពលកម្មដើម្បីចិញ្ចឹមជីវិត។ ក្នុងការរស់នៅជាក្រុម មនុស្សត្រូវធ្វើទំនាក់ទំនងនឹងគ្នា ដែលជាហេតុផុសឡើងនូវភាសា។ ភាសាជាមូលបទក្នុងការបង្កើតឱ្យមានអក្សរសិល្ប៍ សិល្បៈ។ ក្នុងពេលប្រកបរបរចិញ្ចឹមជីវិត មនុស្សបានជួបប្រទះនូវរឿងហេតុផ្សេងៗគួរឱ្យភ្ញាក់ផ្អើល ហើយបានយកហេតុការណ៍ទាំងនោះមកនិទានប្រាប់គ្នា។ រឿងរ៉ាវដែលនិទានតៗគ្នានេះបានវិវត្តមកជាអក្សរសិល្ប៍ប្រជាប្រិយ។ ក្រោយមកមនុស្សបានបង្កើតអក្សរសម្រាប់កត់ត្រាភាសានិយាយ ហើយអក្សរសិល្ប៍សំណេរក៏ចាប់ផ្ដើមមានរូបរាងឡើង។ សាក្សីនៃស្នាដៃអក្សរសិល្ប៍ សិល្បៈ ដែលបានបន្សល់ទុកដោយសារពលកម្មមានដូចជារឿងនិទាន ឧបករណ៍ពលកម្ម គ្រឿងអលង្ការ ក្បាច់ចម្លាក់តាមប្រាសាទ និងរូងភ្នំទាំងឡាយ...។

ដូច្នេះប្រភពកំណើតពិតរបស់អក្សរសិល្ប៍ សិល្បៈគឺពលកម្ម។

## ២.៣ កម្មវត្ថុរបស់អក្សរសិល្ប៍

និយាយអំពីកម្មវត្ថុអក្សរសិល្ប៍ត្រូវនិយាយដល់អ្វីដែលអក្សរសិល្ប៍ឆ្លុះបញ្ចាំង។ អក្សរសិល្ប៍ឆ្លុះបញ្ចាំងពីតថភាពសង្គមតាមលក្ខណៈសកល និងស្មុគស្មាញ។ ប្រការសំខាន់នៃតថភាពគឺមនុស្ស និងធម្មជាតិ។

អក្សរសិល្ប៍ឆ្លុះបញ្ចាំងពីជីវិតមនុស្សក្នុងសង្គម ពោលគឺអក្សរសិល្ប៍បានឆ្លុះបញ្ចាំងពីវាសនាមនុស្ស ចរិតលក្ខណៈរបស់មនុស្ស និងទំនាក់ទំនងរបស់មនុស្សក្នុងសង្គម។ ក្រៅពីមនុស្សអក្សរសិល្ប៍បានរៀបរាប់អំពីធម្មជាតិ ដើម្បីបំផុសទឹកចិត្តស្នេហាជាតិ ស្នេហាប្រជាជន និងមាតុភូមិ ព្រោះការរៀបរាប់ពី ធម្មជាតិបានបង្កប់នូវគោលគំនិតសំខាន់ៗរបស់អ្នកនិពន្ធ គឺនិយាយដល់ស្ថានភាព និងចរិតលក្ខណៈរបស់មនុស្សយ៉ាងពិតប្រាកដ។ ឧទាហរណ៍៖ ល្បើកចចកនិងកូនចៀម ល្បើកដុចនិងត្រី ( វិសេសដួង ) រឿងធ្មានិងចាបស្រុក ( សុត្តន្តប្រីជាឥន្ទ ) រឿងកញ្ជ្រោងនិងផ្លែទំពាំងបាយជូរ ( ឡាហ្វុងតែន ) រឿងរនិងស្រមោច រឿងមេអំបៅ និងជង្កូវ... សុទ្ធតែមានខ្លឹមសារទាក់ទងនឹងជីវភាពរស់នៅរបស់មនុស្សទាំងអស់។

## ២.៤ មុខងារអក្សរសិល្ប៍

កាលណាគេនិយាយអំពីមុខងារអក្សរសិល្ប៍ គេតែងសង្កត់ទៅលើបំណងនៃនិម្មិតកម្មសិល្បៈនៅលើបញ្ហាសំណេរ។ ជាទូទៅគេសង្កេតឃើញថាបញ្ហាបំណង និងតម្លៃសង្គមនៃស្នាដៃអក្សរសិល្ប៍ត្រូវបានបកស្រាយតាមរបៀបច្រើនបែបយ៉ាង និងស្ថិតនៅក្រោមទិដ្ឋភាពខុសគ្នា។

តាមន័យទូទៅបញ្ញត្តិមុខងារនៃអក្សរសិល្ប៍ គឺរួមផ្តុំទៅលើតម្លៃសង្គមទាំងមូលនៃស្នាដៃ និងទៅលើខ្លឹមសារនិម្មិតកម្មសិល្បៈរបស់ប្រធានវិស័យអ្នកនិពន្ធ។

**នៅសម័យបុរាណអក្សរសិល្ប៍មានមុខងារ៦គឺ៖**

- មុខងារចំណេះដឹង ឬផ្តល់ពុទ្ធិ
- មុខងារអប់រំ
- មុខងារកម្សាន្ត

- មុខងារតេថ
- មុខងារសោភ័ណ
- មុខងារផ្តល់ទំនាក់ទំនងរវាងអ្នកនិពន្ធនិងអ្នកអាន

**តែសម្រាប់អក្សរសិល្ប៍សម័យទំនើប គេបង្រួមនៅសល់តែ ៣គឺ៖**

- មុខងារពុទ្ធិ ឬចំណេះដឹង
- មុខងារអប់រំ
- មុខងារសោភ័ណ ឬសិល្បវិជ្ជា

### ២.៤.១ មុខងារពុទ្ធិ ឬមុខងារចំណេះដឹង

ពុទ្ធិក្នុងអក្សរសិល្ប៍ មានន័យថាជាការយល់ដឹងស្គាល់របស់អ្វីដែលប្លែក បានន័យថានៅពេលអានអត្ថបទអក្សរសិល្ប៍ គេរមែងយល់ដឹងច្រើនតាំងពីភាពពិស្តារនៃទេសភាពធម្មជាតិ ទំនៀមទម្លាប់ ប្រពៃណី សកម្មភាព ជនជាតិ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ព្រឹត្តិការណ៍សង្គមពីសម័យកាលមួយទៅសម័យកាលជាដើម។ ការរៀបរាប់ពិស្តារទាំងឡាយស្តីពីពិភពខាងក្រៅ តែងតែប្រាប់ឱ្យយើងដឹងនូវបញ្ហាគ្រប់បែបយ៉ាង។ ដូច្នេះ អក្សរសិល្ប៍ផ្តល់នូវពុទ្ធិជាព័ត៌មានទាំងឡាយ ដែលមនុស្សម្នាក់ទទួលបានតាមរយៈឥន្ទ្រីយ៍ទាំងប្រាំ (ប្លាតុង និងអារីស្តូត)។

ជាឧទាហរណ៍រឿង " ***ភូមិតិរច្ឆាន*** " បានផ្តល់ពុទ្ធិឱ្យអ្នកសិក្សាបានដឹងពីភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពិសេសក្នុងភូមិក្រាំងលាវ ស្រុករលាប្អៀរ ភ្នំតាបាំង។ ចំណែកពុទ្ធិទាក់ទងនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ រឿងនេះបានសរសេរយ៉ាងសំខាន់ទៅលើព្រឹត្តិការណ៍ឆ្នាំ១៩២៥ ដែលជាព្រឹត្តិការណ៍ដ៏ឈឺចាប់បំផុតរបស់អ្នកភូមិក្រាំងលាវ។ នៅមានពុទ្ធិជាច្រើនទៀតដែលអ្នកអាននឹងទទួលបានពីរឿងភូមិតិរច្ឆាននេះ ដូចជាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ បរិស្ថានធម្មជាតិ ច្បាប់លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស ការកេងប្រវញ្ច ការលោភលន់ ការកសាងសន្តិភាព សុវត្ថិភាព សុភមង្គល សាមគ្គីជាតិជាដើម។

ដូចនេះអក្សរសិល្ប៍បានផ្តល់ពុទ្ធិយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់អ្នកសិក្សា ដើម្បីឱ្យពួកគេក្លាយជាធនធានមនុស្សមួយដ៏ល្អក្នុងសង្គម។

### ២.៤.២ មុខងារអប់រំ

ការអប់រំមានន័យថា ជាការរៀនសូត្រ ការលើកកម្ពស់វប្បធម៌ ហើយការអប់រំក៏សំដៅលើការណែនាំការពន្យល់ ដើម្បីឱ្យមនុស្សម្នាក់ៗមានការប្រែប្រួលទាំងចំណេះជំនាញ សីលធម៌រស់នៅ រូបរាងកាយសុខភាព ដើម្បីក្លាយជាពលរដ្ឋល្អម្នាក់ក្នុងសង្គម។ តាមន័យនេះ អក្សរសិល្ប៍ដើរតួយ៉ាងសំខាន់បំផុត។ ដូច្នេះ អក្សរសិល្ប៍ពុំគ្រាន់តែមានគោលបំណងផ្តល់ឱ្យអ្នកអាននូវពុទ្ធិ អំពីជីវភាពរបស់មនុស្ស និងសង្គមប៉ុណ្ណោះទេ វាមានមុខងារអប់រំសីលធម៌ អប់រំគុណធម៌របស់មនុស្ស ដែលអ្នកខ្លះបានចាត់ទុកផ្នែកនេះជាមុខងារមួយផ្នែកទៀតដោយឡែក គឺមុខងារវប្បធម៌។

អក្សរសិល្ប៍ផ្តល់នូវការអប់រំទាំងសកម្មភាពវិជ្ជមាន និងអវិជ្ជមានតាមរយៈតួអង្គវិជ្ជមាន (យកតម្រាប់តាម) និងតួអង្គអវិជ្ជមាន ( ចៀសវាងឱ្យឆ្ងាយ )។ របៀបសម្តែងចេញនៃមុខងារអប់រំរបស់អក្សរសិល្ប៍មានលក្ខណៈអប់រំតាមវិធីសិល្បៈ ពុំមែនមានការបង្ខិតបង្ខំនោះឡើយ គឺជាសកម្មភាពភ្ញាក់រឭក បានន័យថាគ្មានអ្នកណាមួយមកចាប់បង្ខំយើងត្រូវតែទៅមើលភាពយន្ត ទស្សនាល្ខោន ឬគ្មានអ្នកណាមកចាប់បង្ខំយើងត្រូវតែអនុវត្តតាមសំឡេងអំពាវនាវរបស់អ្នកនិពន្ធ ឬតាមសម្តីរបស់តួអង្គទាំងឡាយនោះទេ។ ជាក់ស្តែងនៅក្នុងរឿងទាំងឡាយក្នុងចលនាពុទ្ធនិយមបានអប់រំមនុស្សជាតិ ជាពិសេសពុទ្ធសាសនិកឱ្យខិតខំកសាងអំពើកុសល ស្អប់ខ្ពើម និងចៀសវាងអំពើបាប។ រីឯអក្សរសិល្ប៍ឧបទេសបានអប់រំខាងផ្នែកសីលធម៌ ដោយប្រើប្រាស់វិធីអប់រំបែបត្រង់ៗមានច្បាប់ផ្សេងៗ បណ្តាំក្រមង៉ុយ ច្បាប់ប្រុស ច្បាប់ស្រីរបស់ព្រះបាទអង្គឌួងជាដើម បានអប់រំណែនាំកូនចៅជំនាន់នោះ និងជំនាន់ក្រោយៗឱ្យចេះរៀបចំប្រកាន់ឥរិយាបថថ្លៃថ្នូរ ឧស្សាហ៍ព្យាយាមអនុវត្តការងារ កសាងជីវភាពរាល់ថ្ងៃឱ្យបានល្អប្រសើរ ចៀសវាងឱ្យផុតពីគុណវិបត្តិផ្សេងៗ។

ក្នុងដំណាក់កាលខុសគ្នានៃប្រវត្តិសាស្រ្ត មុខងារអប់រំត្រូវបានសម្តែងឡើងក្រោមរូបភាពខុសគ្នាដូចជានៅសតវត្សទី១៦ សម័យកំណើតថ្មីនៃអក្សរសិល្ប៍មានទំនោរសំខាន់ទៅរកពិភពក្នុងចិត្ត និងជះឥទ្ធិពលទៅលើគំនិតមនុស្សនិយម។ នាសតវត្សទី១៧ អក្សរសិល្ប៍តន្តីនិយមមានតួនាទីសំខាន់ គឺអប់រំគំនិតសក្តិភូមិ និងឱ្យតម្លៃទៅលើវិចារណៈ លើកិត្តិយស កាតព្វកិច្ច និងគុណធម៌ផ្សេងៗ។

ជាទូទៅអក្សរសិល្ប៍បានផ្តល់តម្លៃអប់រំដល់អ្នកសិក្សាឱ្យ៖

- ធ្វើអំពើល្អ ស្រឡាញ់នូវកុសលទៀងត្រង់
- ជឿលើសមត្ថភាពផ្ទាល់ខ្លួន ដោយការដោះស្រាយបញ្ហា តាមរយៈបញ្ញាបែបអហិង្សា
- តស៊ូ ព្យាយាម អំណត់អត់ធន់ ប្រឹងប្រែង ស្មោះត្រង់ ក្លាហាន
- សាមគ្គីគ្នា ចេះរស់នៅជាមួយគ្នាដោយសុខដុម
- លុបបំបាត់នូវការរើសអើងភេទ វណ្ណៈ ពណ៌សម្បុរ ពូជសាសន៍ សាសនា
- ទទួលយកបទពិសោធពីអតីតកាលសម្រាប់បច្ចុប្បន្នកាល
- គោរពសិទ្ធិ គោរពច្បាប់សង្គម គោរពសមភាពយេនឌ័រ គោរពលិទ្ធប្រជាធិបតេយ្យ
- បំពេញទាន ធ្វើបុណ្យ ចែករំលែក តាមរូបភាពផ្សេងៗមានទ្រព្យសម្បត្តិ គំនិត បញ្ញា ស្មារតី ការជួយសង្គ្រោះ ដើម្បីឱ្យអ្នកក្រីក្រលំបាកវេទនា មានលទ្ធភាពរស់បានដូចគ្នា
- ស្អប់ខ្ពើមអំពើអយុត្តិធម៌ សង្គ្រាម ការកេងប្រវញ្ច ពោលគឺឱ្យស្រឡាញ់នូវសន្តិភាពយុត្តិធម៌
- មានភាពស្មោះត្រង់នឹងខ្លួនឯង គ្រួសារ និងសង្គម ជាពិសេសស្នេហា ដើម្បីកសាងសុភមង្គលមួយដ៏សុខដុមរមនា
- ស្រឡាញ់វប្បធម៌ ប្រពៃណី សាសនា ជាតិមាតុភូមិរបស់ខ្លួន ( អត្តសញ្ញាណជាតិ )

ដូច្នេះអក្សរសិល្ប៍បានចូលរួមចំណែកអប់រំមនុស្សគ្រប់ស្ថានភាព ដើម្បីឱ្យមនុស្សម្នាក់ៗគោរពច្បាប់ គោរពសិទ្ធិមនុស្ស ដើម្បីរស់នៅក្នុងសង្គមប្រកបដោយសេចក្តីថ្លៃថ្នូរ។

### ២.៤.៣ មុខងារសិល្បវិទ្យា ឬសោភ័ណ

អត្ថន័យនៃពាក្យ « សោភ័ណ » អាចប្រែប្រួលទៅតាមផ្នែក ឬទៅតាមទស្សនៈរបស់អ្នកប្រាជ្ញទស្សនវិទូ។ ចំពោះលោកប្លាតុង បានផ្ដល់ន័យដល់ពាក្យសោភ័ណ សំដៅលើសណ្ដាប់ធ្នាប់របៀបរៀបរយ ហើយវាកើតឡើងបានដោយសារការហ្វឹតហាត់សមត្ថភាពរបស់ពួកគេ។

សោភ័ណក្នុងអក្សរសិល្ប៍សំដៅទៅលើ៖

- សិល្បវិទ្យា គឺវិជ្ជានៃការតាក់តែងនិពន្ធរបស់អ្នកនិពន្ធ កវី
- ការពិចារណា ការវិភាគទៅលើស្នាដៃនិម្មិតកម្មអក្សរសិល្ប៍
- សំណេរក្នុងអក្សរសិល្ប៍ ពោលគឺរចនាបថក្នុងការតែង មានផ្ដើម មានតួ មានបញ្ចប់ មានវគ្គ មានឃ្លា ល្បះត្រឹមត្រូវ។

មុខងារសិល្បវិទ្យាសម្ដែងចេញជាលើកដំបូងក្នុងក្របខណ្ឌបំពេញតួនាទីស្វែងរក និងបំពេញតម្រូវការផ្នែកសោភ័ណ។ តម្រូវការសោភ័ណជាតម្រូវការសំខាន់បំផុតរបស់មនុស្ស។ ក្នុងក្របខណ្ឌសារជាតិនៃសិល្បៈ តម្រូវការសោភ័ណនេះ គឺជាតម្រូវការចំពោះអ្វីដែលជាឧត្តមគតិ ជាភាសាសុក្រឹត។

## ២.៥ ចលនាអក្សរសិល្ប៍

ចលនាអក្សរសិល្ប៍ គឺជាក្រុមអក្សរសិល្ប៍ ដែលទទួលនូវមនោគមវិជ្ជាពីសាសនា ទស្សនវិជ្ជា នយោបាយ និងឥទ្ធិពលសង្គម ដែលជាហេតុនាំឱ្យអក្សរសិល្ប៍មានទម្រង់ខុសគ្នា។ ចលនាអក្សរសិល្ប៍ខ្មែរមានន័យថា ជាទម្រង់ផ្សេងៗគ្នានៃអក្សរសិល្ប៍ខ្មែរ ដែលស្ថិតនៅក្រោមឥទ្ធិពលនៃលទ្ធិ ឬលោកទស្សនៈណាមួយ។

**គេអាចចែកចលនាអក្សរសិល្ប៍ខ្មែរចេញជាបួនគឺ៖**

- ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម
- ចលនាអក្សរសិល្ប៍ពុទ្ធនិយម
- ចលនាអក្សរសិល្ប៍ខេមរនិយម ឬខ្មែរនិយម
- ចលនាអក្សរសិល្ប៍បរទេស

### ២.៥.១ ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម

ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម គឺជាក្រុមអក្សរសិល្ប៍ទាំងឡាយណា ដែលទទួលឥទ្ធិពលពីសាសនាព្រាហ្មណ៍។ រឿងក្នុងគោលព្រាហ្មណ៍និយម គឺជារឿងមានលក្ខណៈអស្ចារ្យ ឬអច្ឆរិយៈហួសពីសមត្ថភាពមនុស្សដែលអាចធ្វើបាន។ អក្សរសិល្ប៍នេះចូលមកប្រទេសកម្ពុជា តាមរយៈសាសនាព្រាហ្មណ៍នាសតវត្សទី១ដល់សតវត្សទី១៤។

**លក្ខណៈសម្គាល់អក្សរសិល្ប៍បែបព្រាហ្មណ៍និយមមាន៖**

**ក. ផ្ដើមរឿង៖** ចាប់ផ្ដើមឡើងដោយការបង្ហាញពីឈ្មោះអាទិទេពធំៗទាំងបី ឬរៀបរាប់ពីពិធីបូជាយញ្ញ ឬក៏ពិធីផ្សេងៗទៀត ឬពីឫទ្ធិបារមីរបស់អាទិទេពទាំងបីក្នុងសាសនាព្រាហ្មណ៍។

**ខ. តួរឿង៖** ដំណើររាំងជល់គ្នារវាងសភាវៈល្អ និងសភាវៈអាក្រក់

- តួអង្គ៖ តួអង្គឯកប្រុសជាបុរសអស្ចារ្យ ជាអាទិទេព ឬជាកំពូលបុរស ឬក៏ជាអវតាមកចាប់កំណើតជាមនុស្ស។ តួអង្គឯកស្រីជានារីអស្ចារ្យ ឬកំពូលនារីមានសម្រស់ល្អឯកលើសនារីក្នុងភពទាំងបី។
- ដំណើររឿង៖ ច្បាំងមិនចេះចប់ដោយសិល្ប៍សាស្ត្រអស្ចារ្យ។ ដំណើររឿងមានភាពអច្ឆរិយៈហួសហេតុ។
- ទីកន្លែង៖ ព្រៃហេមពាន្ត ក្រុងព្រហ្មយុធ្យា ស្ថានសួគ៌ ពោលគឺឋានទាំងបី។
- ចំណោទបញ្ហា ឬទំនាស់៖ រវាងសភាវៈល្អនឹងសភាវៈអាក្រក់។
- ដំណោះស្រាយ៖ ដោយប្រើសិល្ប៍មន្តអាគម ឫទ្ធិអំណាច សងសឹកធ្វើចម្បាំងនឹងគ្នាដោះស្រាយដោយយុទ្ធវិធី។
- ស្នេហា៖ អ្នកឈ្នះ ឬអ្នកខ្លាំង គឺបានទទួលស្នេហា។
- ឧត្តមគតិរឿង៖ អប់រំមនុស្សឱ្យជឿលើអាទិទេព ដោយជឿថាសុខ ទុក្ខ ល្អ អាក្រក់របស់ខ្លួនសុទ្ធតែបានមកពីអាទិទេពជាអ្នកកំណត់។

**គ.បញ្ចប់រឿង៖** សភាវៈល្អមានជ័យជម្នះលើសភាវៈអាក្រក់។

**២.៥.២ ចលនាអក្សរសិល្ប៍ពុទ្ធនិយម**

ចលនាអក្សរសិល្ប៍ពុទ្ធនិយម ជាអក្សរសិល្ប៍ដែលបានទទួលឥទ្ធិពលពុទ្ធសាសនា។ អក្សរសិល្ប៍នេះចូលមកប្រទេសកម្ពុជា តាមរយៈសាសនាព្រះពុទ្ធនិកាយមហាយាននាសតវត្សទី១៤ ក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ តែមុនព្រះអង្គ គឺព្រះបាទយសោវរ្ម័នទី១ បន្ទាប់មកព្រះបាទសូរ្យវរ្ម័នទី១ រហូតមកដល់សម័យបច្ចុប្បន្ន( តែស្ថិតនៅក្នុងនិកាយហីនយានវិញ )។ រឿងក្នុងគោលពុទ្ធនិយមមានលក្ខណៈខុសប្លែកពីរឿងក្នុងគោលព្រាហ្មណ៍និយម ដោយគោលគំនិតធំ ឬមូលបញ្ហានៃរឿងពុទ្ធនិយម គឺការសាងបារមីរបស់ព្រះពោធិសត្វ ដើម្បីត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។

**ចលនាអក្សរសិល្ប៍ពុទ្ធនិយមត្រូវបានចែកចេញជាបីប្រភេទគឺ៖**

- **អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ៖** សម្រាប់សម្គាល់លើស្នាដៃនៅក្នុងរឿងទសជាតក ដែលគេចាត់ទុកជាគម្ពីរដ៏សំខាន់នៃលទ្ធិព្រះពុទ្ធសាសនា ព្រោះទាំងដប់នៃរឿងជាតកនេះ បានលើកឡើងពីការតស៊ូរបស់ព្រះពុទ្ធ ពេលដែលព្រះអង្គយោនយកកំណើតជាសត្វផ្សេងៗ ក្នុងការកសាងបារមី ដើម្បីសម្រេចបំណងដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ គឺការបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។
- **អក្សរសិល្ប៍ពុទ្ធនិយមក្លាយ៖** ជាអក្សរសិល្ប៍ពុទ្ធនិយមដែលពុំមែនជាគម្ពីរសាសនាដូចរឿងទសជាតក ដែលកើតឡើងតាំងពីសម័យពុទ្ធកាលនោះឡើយ។ អក្សរសិល្ប៍ពុទ្ធនិយមក្លាយនេះបានស្តែងចេញតាមរយៈស្នាដៃអក្សរសិល្ប៍បញ្ញាសជាតក។
- **អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ ឬអក្សរសិល្ប៍ផ្លូម៖** ជាអក្សរសិល្ប៍ពុទ្ធនិយមមួយបែបដែលពុំមែនជារឿងទសជាតក និងរឿងបញ្ញាសជាតក។ វាគឺជាស្នាដៃអក្សរសិល្ប៍ខ្មែរ ដែល

កើតឡើងនៅសម័យកណ្ដាល ( លង្វែក ឬឧត្ដុង្គ ) ហើយទទួលឥទ្ធិពលច្រើន ឬតិចពីព្រះពុទ្ធសាសនាដែរ ជាពិសេសអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុភាគច្រើនជាសាស្ត្រាល្បែង ដែលកើតឡើងនៅសតវត្សទី១៨ ឬទី១៩ ដែលមានឈ្មោះអ្នកនិពន្ធច្បាស់លាស់។

**លក្ខណៈសម្គាល់អក្សរសិល្ប៍បែបពុទ្ធនិយមមាន៖**

**ក.ផ្ដើមរឿង៖** រឿងផ្ដើមឡើងដោយធ្វើបទនមស្ការមានតំណាលថា ព្រះពុទ្ធគង់នៅក្នុងអារាមណាមួយទ្រង់សម្ដែងឡើងនូវរឿងអតីតជាតិរបស់ព្រះអង្គទៅកាន់ពុទ្ធបរិស័ទ។

**ខ.តួរឿង៖** បង្ហាញពីដំណើរសាងបារមីរបស់ព្រះពោធិសត្វដើម្បីត្រាស់ជាព្រះសម្មាសម្ពុទ្ធ។

- **តួអង្គ៖** តួអង្គឯកប្រុសជាព្រះពោធិសត្វ ឯតួអង្គឯកស្រីជាកន្សែសារពេជ្ជ។
- **ទីកន្លែង៖** ព្រៃហេមពាន្ត នគរពារាណសី តក្កសីលា ពោលគឺឋានទាំងបី
- **ចំណោទបញ្ហា ឬទំនាស់៖** ជាទំនាស់រវាងព្រះពោធិសត្វនឹងសង្គមមនុស្ស ទំនៀមទម្លាប់កម្មពៀរ អំពើបាបជាដើម។
- **ដំណោះស្រាយ៖** ព្យាយាមតស៊ូប្រឹងប្រែងដោយយកសីលធម៌ ទៅអប់រំតាមសន្តិវិធី ធម៌ខន្តីអហិង្សា។
- **ស្នេហា៖** ស្នេហាបរិសុទ្ធរវាងកន្សែសារពេជ្ជនឹងពោធិសត្វ។
- **ឧត្ដមគតិរឿង៖** អប់រំមនុស្សឱ្យស្គាល់បុណ្យ បាប ល្អ អាក្រក់ ឱ្យធ្វើអំពើល្អ ខំប្រឹងតស៊ូព្យាយាមដោយជឿជាក់លើខ្លួនឯង ព្រមទាំងជឿជាក់ដោយការគោរពប្រតិបត្តិចំពោះពុទ្ធសាសនា។

**គ.បញ្ចប់រឿង៖** ការសរជាតិរបស់តួអង្គសំខាន់ៗក្នុងរឿង។

### ២.៥.៣.ចលនាអក្សរសិល្ប៍ខេមរនិយម ឬខ្មែរនិយម

ចលនាអក្សរសិល្ប៍ខេមរនិយម ឬខ្មែរនិយមជាស្នាដៃអក្សរសិល្ប៍ដែលបានបង្ហាញពីផ្នត់គំនិត ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ មុខរបរ បញ្ហាសង្គម សិល្បៈ ការសិក្សាអប់រំ ទស្សនៈ ចំណង់ចំណូលចិត្ត និងបង្ហាញពីជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សខ្មែរ មកធ្វើការឆ្លុះបញ្ចាំងតាមរយៈសិល្បវិធីរបស់ខ្លួន។ ចលនាអក្សរសិល្ប៍ខេមរនិយមបានចូលមកកម្ពុជា តាមរយៈឥទ្ធិពលមនោគមវិជ្ជារបស់ពួកអាណានិគមបារាំង (ការតែងនិពន្ធអក្សរសិល្ប៍មានលក្ខណៈតាមបែបពួកបស្ចិម)។ នៅពេលដែលចលនានេះចូលមកអក្សរសិល្ប៍ពុទ្ធនិយមត្រូវបានថយចុះ។ អក្សរសិល្ប៍ខេមរនិយម គឺជាអក្សរសិល្ប៍ទំនើបមួយដែលបានកើតឡើងនៅសតវត្សទី២០។ អក្សរសិល្ប៍នេះបានផ្ដោតសំខាន់ទៅលើចរិតលក្ខណៈមនុស្សនិយម ហើយបានរួមចំណែកកសាងធនធានមនុស្ស ដោយបានផ្ដល់នូវចំណេះដឹងជាច្រើនដូចជាភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ បរិស្ថានធម្មជាតិ ការគោរពសិទ្ធិមនុស្ស ការកសាងសាមគ្គីភាព សុវត្ថិភាព សេរីភាពជាដើម ទាំងនេះជារបស់ខ្មែរពិតៗ។ មិនតែប៉ុណ្ណោះវាបានបន្ថែមនូវបំណិនជីវិតជូនដល់អ្នកអានអ្នកសិក្សាថែមទៀតផង។ ឧទាហរណ៍៖ រឿងទុំទាវផ្ដល់នូវតម្លៃខាងសីលធម៌ រឿងជាតិស្ត្រីផ្ដល់នូវតម្លៃខាងបំណិនវិជ្ជាជីវៈ រឿងភូមិតិរច្ឆាន និងរឿងគូលីកំណែនផ្ដល់នូវតម្លៃខាងស្មារតីតស៊ូ ដើម្បីសេរីភាព គ្មានការកេងប្រវ័ញ្ច រឿងកុលាបប៉ៃលិន

ផ្តល់នូវតម្លៃខាងការងារពលកម្ម និងស្មារតីតស៊ូក្នុងជីវិត រឿងគ្រូបង្រៀនស្រុកស្រែ ផ្តល់នូវតម្លៃខាងការគោរពច្បាប់លទ្ធិប្រជាធិបតេយ្យជាដើម។

**លក្ខណៈសម្គាល់រឿងចលនាអក្សរសិល្ប៍ខេមរនិយមមាន៖**

**ក.ផ្តើមរឿង៖** មិនកំណត់ពីរបៀបតែង គឺស្របទៅតាមការនឹកឃើញរបស់អ្នកនិពន្ធ ដោយគ្មានការឯកភាពគ្នាជារួម ដូចក្នុងចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម និងពុទ្ធនិយមឡើយ។

**ខ.តួរឿង៖** អ្នកនិពន្ធច្រើនតែនិទានតាមបែបបុរសទី៣ ដែលលើកយកពីបញ្ហាមនុស្សរួមមានស្នេហា នយោបាយ ប្រពៃណី ទំនៀមទម្លាប់ ផ្នត់គំនិត ទស្សនៈ មកចោទ និងស្រាយស្របតាមបរិបទសង្គម។

- **តួអង្គ៖** មនុស្សធម្មតា មិនមែនជាទេវៈឬពោធិសត្វឡើយ។
- **ទីកន្លែង៖** ប្រព្រឹត្តទៅក្នុងសង្គមមនុស្សខ្មែរជាក់ស្តែង។
- **បញ្ហាចោទ ឬទំនាស់៖** រវាងមនុស្សនិងមនុស្ស មនុស្សនិងជីវភាពរស់នៅប្រចាំថ្ងៃ មនុស្ស និងបញ្ហាសង្គម មនុស្ស និងមនសិការ ឧត្តមគតិ ឆន្ទៈរបស់មនុស្សខ្មែរ។
- **ដំណោះស្រាយ៖** ស្រាយទៅតាមបរិបទរបស់សង្គមខ្មែរតាមសម័យនីមួយៗ។
- **ស្នេហា៖** មានភាពស្មោះស្ម័គ្រ និងផិតក្បត់។
- **តម្លៃអប់រំ៖** ពឹងលើសមត្ថភាពចំណេះប្រាជ្ញាផ្ទាល់ខ្លួនក្នុងការដោះស្រាយបញ្ហា មិនពឹងពរលើអាទិទេពអង្គណាមួយជួយសង្គ្រោះឡើយ។

**គ.បញ្ចប់រឿង៖** មិនកំណត់ គឺបញ្ចប់ស្របទៅតាមបរិបទសង្គម និងតាមមនោគតិរបស់អ្នកនិពន្ធ។ ជួនបញ្ចប់រឿងដោយឱ្យតួអង្គបានជួបជុំគ្នា ជួនបញ្ចប់ដោយឱ្យតួអង្គព្រាត់ប្រាស់គ្នាជាដើម។

## ២.៦ លក្ខណៈអក្សរសិល្ប៍

លក្ខណៈអក្សរសិល្ប៍ ជាគ្រឿងសម្គាល់ចរិតលក្ខណៈទាំងឡាយ ដែលមាននៅក្នុងអក្សរសិល្ប៍ដូចជា លក្ខណៈមនុស្ស លក្ខណៈសង្គម លក្ខណៈប្រជាជន លក្ខណៈតថៈ លក្ខណៈប្រវត្តិ លក្ខណៈវណ្ណៈ លក្ខណៈជាតិ លក្ខណៈអន្តរជាតិ។

### ២.៦.១ លក្ខណៈមនុស្ស

អក្សរសិល្ប៍ដែលមានលក្ខណៈមនុស្ស គឺអត្ថបទអក្សរសិល្ប៍ទាំងឡាយណាដែលលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយ។ ទោះបីជាអ្នកនិពន្ធបានលើកយកតួអង្គសត្វក៏ដោយ គឺសុទ្ធតែតំណាងឱ្យមនុស្សណាមួយ ឬក្រុមមនុស្សណាមួយជាដរាប។ ឧទាហរណ៍៖ អក្សរសិល្ប៍ប្រជាប្រិយ តួអង្គទន្សាយតំណាងឱ្យតួអង្គមនុស្សមានប្រាជ្ញាប្រកបដោយគតិបណ្ឌិត យុត្តិធម៌ ឯតួអង្គសត្វខ្លាឃ្មុំ ក្រពើតំណាងឱ្យតួអង្គមនុស្សល្ងង់ខ្លៅ រមិលគុណជាដើម។ ឯរឿងរាមកេរ្តិ៍ តួអង្គក្រុងរាពណ៍តំណាងឱ្យតួអង្គមនុស្ស អាជ្ញានិយម ស្រីនិយម តួអង្គកុម្ភការណ៍តំណាងឱ្យតួអង្គវីរជនស្នេហាជាតិ តួអង្គពាលីតំណាងឱ្យតួអង្គស្នេហាជាតិមាតុភូមិ...។

### ២.៦.២ លក្ខណៈវណ្ណៈ

បើយើងចាត់ទុកថា អក្សរសិល្ប៍ជាវិទ្យាស្បង់ (សិក្សាអំពីមនុស្ស) និងមានទស្សនៈណាមួយកំណត់អំពីសីលធម៌ ដូចនេះអក្សរសិល្ប៍ដាច់ខាតត្រូវតែមានលក្ខណៈវណ្ណៈ ដែលលក្ខណៈវណ្ណៈពុំអាចនៅជាអមតៈក្នុងគ្រប់អក្សរសិល្ប៍នោះទេ។ ប៉ុន្តែសម្រាប់អក្សរសិល្ប៍ចាប់ពីសង្គមឈានចូលរបបទាសភាពមកដល់បច្ចុប្បន្ន អក្សរសិល្ប៍ក៏ចាប់ផ្តើមមានលក្ខណៈវណ្ណៈ។ ម្យ៉ាងទៀតអក្សរសិល្ប៍ក្នុងក្របខណ្ឌជាកញ្ចក់ឆ្លុះបញ្ចាំងតថភាព ពុំអាចបដិសេធថាគ្មានលក្ខណៈវណ្ណៈនោះបានទេ។ ចរិតវណ្ណៈនេះបានស្តែងឡើងតាមរយៈរបៀបរបបរស់នៅ ទឹកចិត្ត ស្មារតី សញ្ចេតនា ផលប្រយោជន៍សេដ្ឋកិច្ចផ្ទាល់របស់មនុស្សដែលស្ថិតនៅក្នុងស្រទាប់វណ្ណៈសង្គមខុសគ្នា។ ស្នាដៃអក្សរសិល្ប៍សុទ្ធតែមានលក្ខណៈវណ្ណៈ ដូចនេះអ្នកនិពន្ធដែលជាអ្នកបង្កើតអក្សរសិល្ប៍ត្រូវតែស្ថិតនៅក្នុងវណ្ណៈណាមួយជាកំណត់។ ហេតុនេះស្នាដៃអក្សរសិល្ប៍ណាក៏ដោយ ខឿនអក្សរសិល្ប៍ណាក៏ដោយ សុទ្ធតែមានលក្ខណៈវណ្ណៈជានិច្ច។

ដើម្បីកំណត់លក្ខណៈវណ្ណៈរបស់អក្សរសិល្ប៍ យើងត្រូវពិនិត្យទៅលើគំនិត សញ្ចេតនា ឧត្តមគតិ សោភ័ណ ដែលផុសចេញពីស្នាដៃនោះ តើស្ថិតនៅក្នុងវណ្ណៈណា? លក្ខណៈវណ្ណៈនេះវាស្តែងតាមរយៈវិធីផ្សេងៗពីគ្នា។ វិធីនិម្មិតរបស់អ្នកនិពន្ធទៅតាមរចនាបថវិធី និងកម្លាំងទឹកចិត្តនៅលើវណ្ណៈរបស់គេ។ រវាងជំហរវណ្ណៈរបស់អ្នកនិពន្ធ និងលក្ខណៈវណ្ណៈរបស់ស្នាដៃ គឺមានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធិបំផុត។ ប៉ុន្តែសិល្បករ អ្នកនិពន្ធ មិនមែនសុទ្ធតែចំណុះឱ្យវណ្ណៈរបស់ខ្លួនគ្រប់បញ្ហា និងគ្រប់ពេលនោះទេ។ ការទទួលឥទ្ធិពលពីការសង្កេតពិនិត្យជាក់ស្តែង ពីបទពិសោធក្នុងតថភាពនៃជីវិត កវី អ្នកនិពន្ធ សិល្បករមួយចំនួនបានលះបង់វណ្ណៈ បែរងាកទៅរកវណ្ណៈផ្សេងៗទៀត។ ឧទាហរណ៍៖ លោក វិចទ័រ ហ៊ុយហ្គោ លោក បាល់ហ្សាក់ ជាដើម។ អាស្រ័យដោយការតស៊ូវណ្ណៈមានភាពស្មុគស្មាញ វណ្ណៈនីមួយៗបានជះឥទ្ធិពលឱ្យគ្នាទៅវិញទៅមកឥតឈប់ឈរ។ ដូចនេះលក្ខណៈវណ្ណៈនៅក្នុងមនសិការរបស់មនុស្សម្នាក់ៗក៏មានការវិវត្តដែរ។

### ២.៦.៣ លក្ខណៈប្រជាជន

អក្សរសិល្ប៍ដែលគ្មានលក្ខណៈប្រជាជន ជាអក្សរសិល្ប៍ដែលដាច់ចេញពីប្រជាជន និពន្ធដើម្បីបុគ្គល និងវណ្ណៈរបស់គេ។ អក្សរសិល្ប៍បែបនេះបើមាននិយាយដល់ប្រជាជន គឺច្រើនចាត់ទុកប្រជាជនដូចសត្វជាតុមិនស្មើនឹងពួកគេឡើយ។ ស្នាដៃដែលមានលក្ខណៈប្រជាជន គឺជាស្នាដៃដែលយកចិត្តទុកដាក់ខ្លាំងក្លាលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទាំងជីវភាព ភាសា ស្មារតី និងសម្ភារៈ។ នេះមានន័យថាអក្សរសិល្ប៍ដែលមានលក្ខណៈប្រជាជនបាននិយាយយ៉ាងច្រើនពីផ្នត់គំនិត សតិអារម្មណ៍ ព្រលឹង ចំណង់ចំណូលចិត្ត បំណងប្រាថ្នារបស់ប្រជាជន។ បន្ថែមលើនេះទៀតអក្សរសិល្ប៍ដែលមានលក្ខណៈប្រជាជនបានចេញមុខការពារយ៉ាងប្តូរផ្តាច់ នូវផលប្រយោជន៍ប្រជាជនប្រឆាំងនឹងអំពើកេងប្រវ័ញ្ចសព្វបែបយ៉ាងនៃក្រុមជនឱកាសនិយម និងវណ្ណៈជិះជាន់ផ្សេងៗលើញើសឈាមមហាជន។ ម្យ៉ាងទៀតស្នាដៃប្រភេទនេះ ក៏ទាមទារផងដែរនូវការបង្ហាញពីមនោសញ្ចេតនា ឧត្តមគតិ និងសុឆន្ទៈ ព្រមទាំងលើកកម្ពស់នូវបញ្ហាខាងលើនេះ

ដើម្បីបម្រើនូវសេចក្ដីត្រូវការក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ឧទាហរណ៍៖ រឿងធនញ្ជ័យ រឿងអាខ្វាក់អាខ្វិន រឿងអាឡេវ រឿងអន្ទង់វែងឆ្នាំងវែង រឿងបងថ្លៃ និងប្អូនថ្លៃ...។

ចំណែកអក្សរសិល្ប៍ដែលគ្មានលក្ខណៈប្រជាជន គឺជាអក្សរសិល្ប៍ដែលនិពន្ធឡើង ដើម្បីបុគ្គល ដើម្បីក្រុមមនុស្សណាមួយ។ ឧទាហរណ៍៖ រឿងអាជ័យមេរត គឺជារឿងដែលនិពន្ធឡើងដើម្បីបម្រើឱ្យក្រុមមនុស្សដែលមានអំណាច ហើយជិះជាន់អ្នកទន់ខ្សោយ។

សរុបមកស្នាដៃអក្សរសិល្ប៍ដែលមានលក្ខណៈប្រជាជន ជាស្នាដៃដែលអ្នកនិពន្ធបានឆ្លុះបញ្ចាំងនូវបាតុភូតលក្ខណៈនិងចំណោទបញ្ហាសំខាន់ៗ ដែលមានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងជីវិតរបស់មហាជន និងមានអត្ថន័យសង្គមយ៉ាងធំធេងប្រកបដោយលក្ខណៈប្រជាធិបតេយ្យ ក្នុងការសម្ដែងទៀតផង។ ពិសេសទៅទៀត អ្នកនិពន្ធបានប្រើប្រាស់ភាសា ពាក្យពេចន៍ ដែលមហាជនចូលចិត្ត ស្រួលអាន ស្រួលស្ដាប់ងាយយល់ទៀតផង។

### ២.៦.៤ លក្ខណៈប្រវត្តិ

អក្សរសិល្ប៍ដែលមានលក្ខណៈប្រវត្តិ តែងតែទាក់ទងនឹងព្រឹត្តិការណ៍ក្នុងសម័យកាលនៃប្រវត្តិសាស្ត្រ។ បើតាមវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត បានពន្យល់ថា៖ « ប្រវត្តិសាស្ត្រ ឬបវត្តិសាស្ត្រ គឺគម្ពីរ ក្បួន សម្ដែងអំពីពង្សាវតារ ឬអំពីរបាក្សត្រ អំពីសន្តិវង្ស »។ ដូចនេះរាល់ព្រឹត្តិការណ៍ ឬរឿងរ៉ាវសំខាន់ៗ ដែលកើតមានឡើង ក្នុងសង្គមត្រូវបានផ្ទេរកត់ត្រាបញ្ចូលក្នុងគម្ពីរ ( ប្រវត្តិសាស្ត្រ ) ឯអ្នកនិពន្ធ កវីក៏លើកយកព្រឹត្តិការណ៍សំខាន់ៗ ទាំងនោះមករៀបរៀងជាអត្ថបទអក្សរសិល្ប៍។

ឧទាហរណ៍៖ អក្សរសិល្ប៍ខ្មែរដែលមានលក្ខណៈប្រវត្តិមានរឿងព្រះគោព្រះកែវ ( ទាក់ទងនឹងសម័យលង្វែក)រឿងអ្នកតាឃ្លាំងមឿង( ទាក់ទងនឹងសម័យលង្វែក) រឿងភូមិតិរច្ឆាន (ទាក់ទងនឹងសម័យអាណានិគមនិយមបារាំង) កំណាព្យមើលផែនដីខ្មែរសម័យប៉ុលពត អៀងសារី (ទាក់ទងនឹងសម័យកម្ពុជាប្រជាធិបតេយ្យ)។

### ២.៦.៥ លក្ខណៈសង្គម

អក្សរសិល្ប៍ដែលមានលក្ខណៈសង្គម លុះត្រាតែអក្សរសិល្ប៍នោះនិយាយអំពីទំនាក់ទំនងរវាងមនុស្ស និងមនុស្ស រវាងក្រុមមនុស្សនិងក្រុមមនុស្ស រវាងសង្គមមនុស្សនិងសង្គមមនុស្ស។ តួអង្គនីមួយៗដែលមានសកម្មភាព មតិយោបល់ ពាក្យសម្ដី ពុំមែនជាច់ចេញតែឯងទេ គឺជាតំណាងមនុស្សភាគច្រើន (ក្រុមមនុស្ស) ឬតំណាងសង្គមមនុស្សនេះឯង។ ដូចជាក្នុងរឿងទុំទាវ ម្ដាយនាងទាវដែលមានចិត្តលោភលន់ចង់បានកិត្តិយស និងទ្រព្យសម្បត្តិ ជាតំណាងសកម្មភាពនៃអ្នកម្ដាយរបស់មនុស្សមួយក្រុមនៅសម័យលង្វែកជាដើម។ ឯតួអង្គទុំទាវដែលងើបឡើងប្រឆាំងនឹងប្រពៃណី ( ការរៀបចំទុកដាក់កូនចៅ ) គឺជាតំណាងយុវជន យុវនារីមួយក្រុមនាសម័យលង្វែក ដែលទាមទារសិទ្ធិសេរីភាពក្នុងការស្វែងរកគូស្រករ ស្វែងរកសុភមង្គលដោយខ្លួនឯង។

### ២.៦.៦ លក្ខណៈជាតិ

អក្សរសិល្ប៍ដែលមានលក្ខណៈជាតិ គឺបានដល់អក្សរសិល្ប៍ណាដែលបង្ហាញនូវលក្ខណៈជាតិដែលខុសប្លែកពីបរទេសតាំងពីទំនៀមទម្លាប់ ប្រពៃណី អាកប្បកិរិយាជាដើម។ លក្ខណៈជាតិជាផ្នែកមួយសំខាន់ទាក់ទងនឹងសារជាតិសង្គម និងសោភ័ណរបស់អក្សរសិល្ប៍។ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ភាសា វប្បធម៌ ទិដ្ឋភាពធម្មជាតិ សោភ័ណភាពរបស់ប្រទេសជាតិ ជីវភាពរស់នៅរបស់ប្រជាជន គឺជាកម្មវត្ថុក្នុងការឆ្លុះបញ្ចាំង គឺជាប្រធានបទនៃលក្ខណៈជាតិរបស់ចម្រៀង កំណាព្យ សិល្បៈផ្សេងៗ ពោលគឺរបស់អក្សរសិល្ប៍។ ឧទាហរណ៍៖ រឿងទុំទាវ អ្នកនិពន្ធបានបង្ហាញរបៀបរស់នៅរបស់ប្រជាពលរដ្ឋខ្មែរក្នុងសម័យលង្វែក។

លក្ខណៈជាតិពុំមែនមានន័យថា យើងចង្អៀត ឬបដិសេធទាំងស្រុងចំពោះគោលវប្បធម៌ជាតិសាសន៍ដទៃឡើយ។ ក្នុងករណីណាដែលខ្លឹមសារវប្បធម៌មានទស្សនៈជឿនលឿនល្អ សុក្រឹតនោះ យើងរៀនសូត្រវប្បធម៌ទាំងនោះ ដើម្បីបំពេញបន្ថែមលើចំណុចខ្វះខាតរបស់យើងឱ្យបានកាន់តែប្រសើរឡើងមួយកម្រិតបន្ថែមទៀត តែយើងត្រូវរក្សាជាប់ជានិច្ចនូវលក្ខណៈជាតិ។

### ២.៦.៧ លក្ខណៈអន្តរជាតិ

ការតែងនិពន្ធស្នាដៃអក្សរសិល្ប៍ឱ្យមានលក្ខណៈអន្តរជាតិ គឺជាកិច្ចការមួយដ៏ពិបាក ពីព្រោះគេមិនងាយនឹងសម្រេចបាននូវតម្លៃជាសកល ដែលជាផលប្រយោជន៍ទូទៅសម្រាប់មនុស្សជាតិឡើយ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏មានអ្នកនិពន្ធខ្លះប្រកបដោយទេពកោសល្យខ្ពស់អាចរកឃើញនូវចំណុចសំខាន់ៗ មានខ្លឹមសារ ឬតម្លៃជាសកលសម្រាប់មនុស្សជាតិ បានធ្វើឱ្យស្នាដៃរបស់ខ្លួនក្លាយទៅជាអក្សរសិល្ប៍មានលក្ខណៈអន្តរជាតិបាន។ អក្សរសិល្ប៍ដែលមានលក្ខណៈអន្តរជាតិសម្គាល់លក្ខណៈមួយប្រភេទរបស់អក្សរសិល្ប៍ដែលមានលក្ខណៈជាតិរួចហើយ ត្រូវប្រទេសដទៃទៀតទទួលស្គាល់ថាជាអត្ថបទល្អអាចយកទៅសិក្សាបកប្រែជាទូទៅបាន ព្រោះជារឿងមានតម្លៃសកល ទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកទេស សីលធម៌ ដែលជាបំណងមនុស្សជាតិទូទៅ។

**លក្ខណៈវិនិច្ឆ័យនៃលក្ខណៈអន្តរជាតិរបស់អក្សរសិល្ប៍ជារួមមាន៖**

- ស្នាដៃដែលបម្រើនូវឧត្តមគតិ ផលប្រយោជន៍របស់មនុស្សជាតិទូទៅ
- ខ្លឹមសារស្នាដៃបានបម្រើផលប្រយោជន៍នូវសង្គមសមូហភាព ( អន្តរជាតិ )
- ស្នាដៃដែលបានសិក្សាស្រាវជ្រាវស៊ីជម្រៅលើផ្នែកសង្គមសាស្ត្រ
- ស្រាវជ្រាវផ្សព្វផ្សាយពីការរីកចម្រើនបច្ចេកវិទ្យា ដើម្បីធ្វើឱ្យជីវិតមនុស្សទាំងមូលរស់នៅប្រកបដោយសុខមាលភាព សុភមង្គល។
- ស្នាដៃបានបង្កើតនូវតួយ៉ាងខ្លះ ដែលមានឧត្តមគតិ ហើយតាមរយៈឧត្តមគតិនេះ គេបានបញ្ចេញនូវសកម្មភាពដែលដកស្រង់ធ្វើជាមេរៀន ជាគំរូនៃបទពិសោធក្នុងការត្រិះរិះពិចារណា និងយកទៅអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សជាតិទូទៅ។

### ២.៦.៨ លក្ខណៈតថៈ

អក្សរសិល្ប៍ដែលមានលក្ខណៈតថៈ គឺជាអក្សរសិល្ប៍ដែលបានបង្ហាញពីសច្ចភាពសង្គមនាសម័យកាលមួយរួមផ្សំនឹងគំនិតច្នៃប្រឌិតរបស់អ្នកនិពន្ធបង្កើតបានជាស្នាដៃអក្សរសិល្ប៍។ ដូចជាអត្ថបទកាព្យ«មើលផែនដីខ្មែរ» នេះនិយាយអំពីអំពើឃោរឃៅ យង់ឃ្នង់របស់បនប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានធ្វើទុក្ខបុកម្នេញមកលើប្រជាជនខ្មែរស្លូតត្រង់គ្រប់រូប ហើយថែមទាំងបង្ខំឱ្យធ្វើការយ៉ាងធ្ងន់ធ្ងរដូចសត្វធាតុ។

## ២.៧ ប្រភេទអក្សរសិល្ប៍

គេអាចធ្វើបំណែងចែកប្រភេទអក្សរសិល្ប៍បានជាច្រើនបែប ច្រើនយ៉ាងទៅតាមវិធីផ្សេងៗគ្នារបស់អ្នកធ្វើបំណែងចែកដូចជាការកំណត់តាមសម័យកាល តាមលក្ខណៈផ្សាយ វិធីតែងនិពន្ធ ចរន្ត ចលនា គោលនិយម ឬសន្ទស្សន៍ជាដើម។

**ក.តាមសម័យកាល**

- អក្សរសិល្ប៍សម័យបុរាណ
- អក្សរសិល្ប៍សម័យកណ្ដាល
- អក្សរសិល្ប៍សម័យទំនើប

**ខ.តាមលក្ខណៈផ្សាយ**

- អក្សរសិល្ប៍ប្រជាប្រិយ
- អក្សរសិល្ប៍សំណេរ

**គ.តាមវិធីតែងនិពន្ធ**

- អក្សរសិល្ប៍ពាក្យកាព្យ ឬកំណាព្យ
- អក្សរសិល្ប៍ពាក្យរាយ

**ឃ.ចលនាចរន្តគោលនិយម**

- ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម
- ចលនាអក្សរសិល្ប៍ពុទ្ធនិយម
- ចលនាអក្សរសិល្ប៍ខេមរនិយម
- ចលនាអក្សរសិល្ប៍បរទេស

**ង.សន្ទស្សន៍**

- វីណាគីត
- ប្រលោមលោក
- ប្រឌិតកថា ឬនិទានកថា
- នាដ្យកថា ឬរឿងល្ខោន
- ឧបទេសកថា

- លំនឹកកថា និងកំណត់កថា

**ខាងក្រោមនេះជាការបរិយាយខ្លះៗអំពីការបែងចែកអក្សរសិល្ប៍តាមសន្ទស្សន៍៖**

**១.ប្រភេទវីណាគីត ឬវីណកថា ( Le lyrique )៖** ប្រភេទវីណាគីត ឬកំណាព្យវីណាគីត ជាប្រភេទអក្សរសិល្ប៍មួយ ដែលកើតឡើងតាំងពីយូរយារណាស់មកហើយ ក្នុងប្រវត្តិអក្សរសិល្ប៍មនុស្សជាតិមានទម្រង់ជាកំណាព្យ។ អក្សរសិល្ប៍ប្រភេទនេះ បង្ហាញនូវទឹកចិត្តមនុស្ស ដែលទទួលរងនូវការឈឺចាប់ ទុក្ខព្រួយ ការលំបាកក្នុងជីវិតរស់នៅ ជាពិសេសពីសញ្ចេតនា ស្រមើស្រមៃទៅរកសុខៈណាមួយ។ វាបកស្រាយនូវអត្តចរិកផ្ទាល់របស់អ្នកនិពន្ធ។

**១.ក. លក្ខណៈពិសេសរបស់វីណាគីត៖** វាសម្រាប់សម្ដែងពីការពុះកញ្ជ្រោលនូវទឹកចិត្តសញ្ចេតនា មនោរម្មណ៍របស់អ្នកនិពន្ធ។ វាជាសំឡេងសញ្ចេតនាដែលខ្ពង់ខ្ពស់បំផុត។ ប្រធានបទរបស់វីណាគីតគឺជាអត្តផ្ទាល់របស់អ្នកនិពន្ធ ។

**១.ខ. លក្ខណៈពិសេសរបស់តួអង្គវីណាគីត៖** តួអង្គរបស់ប្រភេទវីណាគីត គឺគ្មាននរណា ក្រៅពីអ្នកនិពន្ធនោះទេ។ តួអង្គវីណាគីត គ្មានរូបរាង គ្មានអំពើតែជាតួអង្គ ដែលសម្ដែងឡើងតាមរយៈសញ្ចេតនា តន្ត្រីដែលនាំឱ្យយើងមានចិត្តរំភើប។

**១.គ. លក្ខណៈនិយាមសិល្បៈ៖** ភាគច្រើននៃប្រភេទវីណាគីតត្រូវបានបង្កើតឡើងជាពាក្យកាព្យ។ កំណាព្យវីណាគីតត្រូវបានកំដរដោយសំឡេងពិណ ឬសំឡេងសាដៀវ ពេលស្ដាប់កំណាព្យវីណាគីតយើងហាក់ដូចជាឃើញផ្ទាំងគំនូរមួយ ដែលគួរឱ្យរំភើប ញាប់ញ័រ សោកសង្រេង ឬមានភាពពីរោះ។

**២.ប្រភេទប្រលោម ( Roman )៖** រឿងប្រលោមកើតឡើងតាំងពីយូរយារណាស់មកហើយ គឺតាំងពីសម័យក្រិកបុរាណម្ល៉េះហូតមកដល់សតវត្សទី១៦ វាកើតជាថ្មីម្ដងទៀត នៅប្រទេសបារាំង និងរីកចម្រើនយ៉ាងខ្លាំងនៅសតវត្សទី១៩។ រឿងប្រលោមខ្មែរបុរាណច្រើនសរសេរជាកំណាព្យ ប៉ុន្តែឥឡូវនេះ គេបានសរសេរជាពាក្យរាយច្រើនហើយ។ នៅក្នុងប្រទេសខ្មែរយើង រឿងប្រលោមកើតនៅចុងសតវត្សទី១៨ និងមានច្រើននៅសតវត្សទី១៩។

**២.ក.លក្ខណៈពិសេសនៃរឿងប្រលោម៖** មានលក្ខណៈខុសពីវីណកថា ព្រោះមិនទាមទារឱ្យស្មេរនិពន្ធសរសេរជាកំណាព្យ ហើយតួអង្គក៏ពុំមែនជាវីរជនទាំងអស់នោះទេ។

**២.ខ.តួអង្គ៖** មានតួអង្គចម្រុះ ភាគច្រើនជាតួអង្គអណ្ដែតអណ្ដូង ឬឧត្តមគតិនិយម។ តួអង្គច្រើនមានលក្ខណៈផ្សងព្រេង សម្បូរចិត្តរំភើប ឈឺចាប់ ហើយស្ថិតនៅជុំវិញបញ្ហាស្នេហា។ តួអង្គជាតួអង្គមានទំនាស់វិបត្តិ បុគ្គលនឹងស្ថានភាព បុគ្គលនឹងសង្គម។

**២.គ.និយាមសិល្បៈ៖** នៅក្នុងនិយាមសិល្បៈក្នុងការតាក់តែងរឿង គឺត្រូវបង្កើតដំណើររឿង ឱ្យបានច្រើនយ៉ាងហោចណាស់ពី២០០ទៅ៣០០ទំព័រ។ អ្នកនិពន្ធត្រូវចេះប្រើសន្ទេហវិធីដើម្បីឱ្យអ្នកអានចង់តាមដាន និងត្រូវចេះកាត់រឿងជាភាគតូចៗនៅក្នុងដំណើររឿងទាំងមូល។

ល្បិចនិពន្ធនៅក្នុងរឿងប្រលោមមានលក្ខណៈខុសៗគ្នាទៅតាមអ្នកនិពន្ធបុរាណ និងទំនើប។ នៅក្នុងរឿងប្រលោមគេបែងចែក ដូចជាប្រលោមបែបយុទ្ធសិល្ប៍ មនោសញ្ចេតនា ស៊ើបអង្កេត ទស្សនវិជ្ជា ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រក្នុងក្តីស្រមៃ (ហង្សយន្ត និងរាមកេរ្តិ៍) ផ្សងព្រេងបែបចិត្តសាស្ត្រ នយោបាយ សង្គម សង្គ្រាម អាសអាភាស...។

<u>៣. ប្រឌិតកថា ឬនិទានកថា ( Conte ou Narratif )</u>៖ ប្រឌិតកថា ឬនិទានកថាជាប្រភេទស្នាដៃមានលក្ខណៈសំខាន់ប្រើប្រាស់សម្រាប់ការឆ្លុះបញ្ចាំងបានជាក់ស្តែងនូវតថភាព និងវីរភាពចំពោះអ្នកអាន។ នៅក្នុងស្នាដៃប្រភេទនេះ តួអង្គលេចធ្លោឡើងតាមខ្សែជីវិតរបស់គេរហូតដល់ទីបញ្ចប់ ខុសពីស្នាដៃបែបវីណាគឺតបង្ហាញខ្លឹមសារតាមរយៈអ្នកនិពន្ធ ចំណែកក្នុងប្រភេទនិទាននេះ សំខាន់គឺនៅលើតថភាព។

**៣.ក. លក្ខណៈពិសេសរបស់ប្រភេទនិទាន៖** ស្ថិតនៅលើជីវិតជាក់ស្តែងរបស់មនុស្ស ឬបែបវត្ថុវិស័យឆ្លុះបញ្ចាំងតាមរយៈព្រឹត្តិការណ៍ស្នាដៃនិទានកថាសម្តែងពីកត្តាខាងក្រៅ និងខាងក្នុងរបស់មនុស្សក្នុងស្ថានភាពសង្គមស្មុគស្មាញ គេបានលើកឃ្លាមួយថា « អ្នកនិពន្ធដ៏ល្បីឈ្មោះ គឺជាអ្នកដែលរៀបរាប់ដ៏ស្មោះត្រង់នូវសម័យរបស់គេ »។

**៣.ខ.តួអង្គ៖** មានច្រើន ពុំមានកម្រិតដូចក្នុងស្នាដៃរបស់លោក(បាល់ហ្សាក់) មានតួអង្គជាងពីរពាន់នាក់ រីឯតួអង្គរបស់លោក(តលស្តយ) មានប្រាំរយនាក់តួអង្គទាំងនេះ ត្រូវបានរៀបរាប់ពីស្មារតី និងជីវិតផ្ទាល់ក្នុងស្ថានភាពមួយ។ ចំណងជើងរឿងភាគច្រើនជាបញ្ហារួមផ្តុំបំផុតនៃបញ្ហាអត្ថន័យ ឬជាចំណោទបញ្ហាអ្វីមួយតម្រូវឱ្យអ្នកអានចង់មើល ឬចង់អាន។ ពេលអានចប់ តួអង្គឯកហាក់ដូចជាលេចធ្លោនៅក្នុងអារម្មណ៍ ហើយការរៀបរាប់ពីតួអង្គ គឺមានការរៀបរាប់ពីបញ្ហារាប់រយជំពូក ដែលមាននៅជុំវិញតួអង្គ។

**៣.គ.និយាមសិល្បៈ៖** យើងតែងមានអារម្មណ៍ដូចជាមានមនុស្សម្នាក់កំពុងនិយាយប្រាប់យើងប្រកបដោយចិត្តរំជួល។ អ្នកនិពន្ធហាក់ដូចជាលូកដៃក្នុងការរៀបចំ ជួនកាលតាមរយៈតួអង្គផ្សេងទៀត ជួនកាលប្រើពាក្យថា « ខ្ញុំ នាង គាត់ ...»។ ស្នាដៃនេះ មានលក្ខណៈពិស្តារបំផុតលើពិភពបរានុម័ត។ ការរៀបរាប់មានដំណើរយឺត ពុំជំរុញឱ្យឈានដល់វិបត្តិទំនាស់អ្វីឡើយ។ ដំណើររឿងបែបខ្លីទៅតាមទេពកោសល្យរបស់កវីនិពន្ធក្នុងនិទានកថាមានលក្ខណៈចម្រុះដូចជាហាសវិធី សន្ទេហវិធី...។

**៣.ឃ ការបែងចែកប្រភេទនិទាន៖**

**៣.ឃ.១ វីរកថា៖** ឆ្លុះបញ្ចាំងពីវីរភាពតួអង្គ ដើម្បីជាតំណាងឱ្យសម័យកាល ទំនាស់វិបត្តិ ចម្បាំងសាសនា... ដែលមានលក្ខណៈពិសេស ដោយឆ្លុះបញ្ចាំងពីសកម្មភាពនៃការស្វែងរក និងការពារអត្ថប្រយោជន៍របស់សង្គម ប្រទេសជាតិ មនុស្សជាតិ។ ចំពោះតួអង្គវីរកថា ច្រើនជាវីរជនដែលហ៊ានលះបង់ ដើម្បីមនុស្សជាតិ និងសង្គមជាតិ។ បញ្ហាកាលអាកាសគឺស្ថិតក្នុងពេលវេលាវែងអន្លាយសឹងមួយជីវិត។ ការសរសេរច្រើនជាកាព្យដែលរៀបរាប់រូបារម្មណ៍របស់តួអង្គឯកយ៉ាងសំខាន់។ ដើមកំណើតវីរកថាចេញពីគំនិត ពីទឹកចិត្តរបស់អ្នកនិពន្ធដែលស្រឡាញ់ទឹកដី ប្រទេសជាតិ ឬសាសនាដ៏មោះមុត ដែលគេប្រកាន់យក។ ឧទាហរណ៍៖ រឿងរាមាយណៈរបស់លោកវាល្មិកិ ដែលអ្នកនិពន្ធជឿខ្លាំងទៅលើសាសនាជាហេតុនាំឱ្យទំហំនៃការសរសេរវែងអន្លាយរាប់ខ្សែ។

**៣.ឃ.២.ប្រលោមលោក៖**

**+ នវកថា៖** ជាស្នាដៃប្រលោមលោកខ្នាតខ្លី តិចជាង ១០០ទំព័រ ច្រើនលើកយកបញ្ហាជីវិតមកបង្ហាញដែរ តែចង្អៀត ខ្លី ឆាប់ចប់។ បញ្ហាដំណើររឿង គឺមានខ្សែរឿងតែមួយ។ វាមានច្រើននៅលើទំព័រ កាសែត ទស្សនាវដ្តី វាខុសគ្នាពីរឿងប្រលោមលោក តែស្រដៀងនឹងរឿងព្រេង។ ចំពោះភាសានិយាមសិល្បៈ គឺមិនច្បាស់លាស់ដូចប្រលោមលោកទេ។

**+ រឿងដំណាលខ្លីៗ៖** យ៉ាងច្រើនមួយទំព័រ ឬកន្លះទំព័រ ដូចជារឿងចំអក រិះគន់ ( មាននៅលើទំព័រកាសែត)។ រឿងព្រេងប្រឌិត ជារឿងដែលប្រឌិត ហើយវាដក់ជ្រៅនៅក្នុងសតិអារម្មណ៍របស់ប្រជាជន។

<u>៤. ប្រភេទរឿងល្ខោន ឬនាដ្យកថា ( Drama )</u>៖ ជាប្រភេទអក្សរសិល្ប៍បែបរឿងល្ខោន ដែលត្រូវបានតាក់តែងឡើងជាពិសេស ដើម្បីយកមកសម្តែងនៅលើឆាកមុខទស្សនិកជនទាំងឡាយ ពោលគឺពុំមែនយកមកអានដូចប្រលោមលោក និងវីណាគីតទេ។ វាជាប្រភេទអក្សរសិល្ប៍មួយដែលមានប្រវត្តិតាំងពីសម័យក្រិកបុរាណ ហើយវានៅតែមានប្រជាប្រិយភាពក្នុងចំណោមមហាជនដដែល និងជាស្នាដៃមួយដែលមានលក្ខណៈសកម្ម។ វាមានអត្តរូបមួយពិសេសដែលមានតែសំវាទវិធី និងឯកវាទវិធី តាក់តែងចែកជាឈុត ឆាកយ៉ាងត្រឹមត្រូវ។

**៤.ក.លក្ខណៈពិសេសរបស់នាដ្យកថា៖** ខ្លឹមសាររបស់វាទាក់ទងទៅនឹងទំនាស់វិបត្តិរវាងតួអង្គពីរក្រុមនៅក្នុងសង្គម។ នៅពេលបើកឆាកឡើង គឺបង្ហាញត្រង់ទំនាស់វិបត្តិពីរ។

ឧទាហរណ៍៖ រឿងរាមកេរ្តិ៍ខ្មែរ កាកនាសូរមានទំនាស់ជាមួយឥសីពិស្វាមិត្រ។

**៤.ខ.តួអង្គ៖** តួអង្គនីមួយៗ ត្រូវសម្តែងលើឆាកដែលមានលក្ខណៈសកម្ម។

**៤.គ.និយាមសិល្បៈ៖** គេបែងចែកជាពិសេសទៅលើផ្នែកអត្តរូប គឺគម្រោងតែងដែលជាប្លង់មួយ ត្រូវបែងចែកជាឈុតឆាកយ៉ាងត្រឹមត្រូវ ដូចជារឿងថៅកែចិត្តចោរ រឿងមរណភាពចម្លែក(គីម ពេជ្រពីនន់)។ ភាសានាដ្យភាពជាភាសាសំវាទ និងឯកវាទ ពោលគឺជាភាសាដែលឱ្យមានទឹកចិត្តរំភើបកាន់តែខ្លាំងឡើងៗ ជាភាសាដែលចម្រាញ់ឡើងយ៉ាងផ្ចិតផ្ចង់ ថ្លៃថ្នូរ តែកន្លែងខ្លះយកគ្រាមភាសាមកប្រើដែរ។ ផ្នែកអត្តរូបមានលក្ខណៈចម្រុះ ( ត្រូវមានភ្លេង របាំ ផ្ទាំងគំនូរ រាប់បញ្ចូលទាំងអ្នកដឹកនាំរឿង និងអ្នកទាញផ្ទាំងរូបភាពព្រមទាំងទស្សនិកជនផងដែរ )។

**៤.ឃ. ការបែងចែកប្រភេទនាដ្យកថា៖**

**៤.ឃ.១ ហាសកថា៖** ជាប្រភេទរឿងល្ខោនមួយ ដែលលើកយកគុណវិបត្តិរបស់បុគ្គល របស់ប្រពៃណីសង្គមមកបង្ហាញដើម្បីរិះគន់។ វាជាប្រភេទរឿង ដែលដំណោះស្រាយមានការសប្បាយតាំងពីដើមហូតដល់ចប់។

**៤.ឃ.២.ទារុណកថា៖** ជាប្រភេទល្ខោនមួយដែលលើកយកទំនាស់វិបត្តិរវាងវណ្ណៈខ្លាំងនិងទន់ខ្សោយ បង្កើតបរិយាកាសតឹងតែងពីដើមហូតដល់ចប់ ស្ថានភាពការឈឺចាប់ មរណភាព បានទាក់ទាញឱ្យទស្សនិកជនមានការរំភើប និងរំជួលចិត្ត។ មរណភាពទាំងឡាយដែលបណ្តាលមកពីសង្គម ទើបអាចចាត់ទុកជាទារុណកថា រីឯមរណភាពទាក់ទងនឹងអត្តឃាត គ្រោះថ្នាក់ គឺជាសោកនាដ្យកម្ម។

**៤.ឃ.៣.ទារុណហាសកថា៖** មានលក្ខណៈចម្រុះរវាងទារុណកថា និងហាសកថា គឺទុក្ខព្រួយពាក់កណ្ដាល សើចពាក់កណ្ដាល ដូចជានៅក្នុងរឿងទុំទាវ ពេលដែលទុំទាវជួបគ្នាដំបូងហាក់សប្បាយរីករាយ ពេលដែលទុំបែកពីទាវទុក្ខក្រៀមក្រំព្រោះបែកពីគូស្នេហ៍។ នៅក្នុងរឿងកិត្តិយស ឬស្នេហា នៅពេលដែលនាងស៊ីម៉ែនទាមទារឱ្យស្ដេចកាត់ទោសរ៉ូឌ្រិក( ក្រៀមក្រំ ) ប៉ុន្តែក្រោយពេលដែលស្ដេចអនុម័តឱ្យរ៉ូឌ្រិកប្រយុទ្ធមួយទល់នឹងមួយ នាងស៊ីម៉ែនបែរជាសុំអង្វររ៉ូឌ្រិកការពារខ្លួនទៅវិញ (សើច)។

**<u>៥.អក្សរសិល្ប៍ឧបទេស ( Literature didatique )</u>៖** ជាប្រភេទអក្សរសិល្បិ៍ដែលត្រូវបានតាក់តែងឡើងដើម្បីអប់រំទូន្មានជនានុជន ជាពិសេសទាក់ទងនឹងចរិយាធម៌ សីលធម៌។ វាមានទម្រង់ជាពាក្យរាយ ពាក្យកាព្យ ការប្រដៅសុទ្ធសាធ ដូចជារឿងនិទាន រឿងល្បើក ច្បាប់ផ្សេងៗ។ អក្សរសិល្ប៍ឧបទេសជាការប្រៀនប្រដៅមួយមានលក្ខណៈជាការលួងលោមធ្វើឱ្យគេពិចារណា និងអនុវត្តទៅតាមគន្លងសីលធម៌ដែលគេបានលើកឡើង ។

**៥.ក.លក្ខណៈពិសេសនៃអក្សរសិល្ប៍ឧបទេស៖** គឺបង្ហាញអំពីឧត្តមគតិរបស់អ្នកនិពន្ធ ដោយបានលើកបញ្ហាចោទទៅលើគុណវិបត្តិ ឬទៅលើគុណសម្បត្តិណាដែលល្អ ដើម្បីឱ្យគេយកតម្រាប់តាម និងជម្រុះចោលនូវគុណវិបត្តិទាំងឡាយ ឬជៀសវាងនូវអ្វីដែលខុសឆ្គង។

**៥.ខ.តួអង្គ៖** គឺជាអ្នកនិពន្ធផ្ទាល់ ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងតួអង្គក្នុងកំណាព្យវីណាគីត។ ទន្ទឹមនឹងនោះដែរ អ្នកនិពន្ធក៏បានបង្កើតភាពផ្សេងៗទៀតជាច្រើនដែរ។

**៥.គ.និយាមសិល្បៈ៖** ត្រូវមានវិធីអប់រំឱ្យបានល្អ ដែលខុសពីការអប់រំរបស់ឪពុកម្ដាយចំពោះបុត្រធីតារបស់ខ្លួន។

**៥.ឃ.ការបែងចែកប្រភេទឧបទេសកថា៖**

**៥.ឃ.១.សុភាសិត និងពាក្យទំនឹមទំនៀម៖** សុភាសិតគឺជាពាក្យដែលល្អពីរោះ មានន័យត្រឹមត្រូវ ហើយមានន័យទូទៅ ដូចជា «ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ»...។ ឯពាក្យទំនឹមទំនៀម គឺជាពាក្យពុំត្រឹមត្រូវទូទៅដូចសុភាសិតទេ តែក្នុងន័យអប់រំដូចសុភាសិតដែរ ដូចជា «ធ្វើស្រែឱ្យមើលស្មៅទុកដាក់កូនចៅឱ្យមើលផៅសន្ដាន» «អន្ទង់វែងឆ្នាំងវែង» «កាត់ទឹកមិនដាច់កាត់សាច់មិនបាន»...។ សុភាសិតកើតចេញពីពាក្យស្លោក និងពាក្យទំនឹមទំនៀម។ និយាយពីសុភាសិតគឺត្រូវនិយាយពីអត្ថន្ទរូប(ន័យត្រង់) និងអត្ថបដិរូប ( ន័យធៀប )។

**៥.ឃ.២.ទូន្មានកថា៖** ជាអត្ថបទផ្សេងៗសរសេរជាពាក្យកាព្យ។ ឧទាហរណ៍៖ ច្បាប់បណ្ដាំបិតា ច្បាប់ស្រី ច្បាប់ប្រុស ច្បាប់ក្រមង៉ុយ ច្បាប់ព្រះរាជសម្ភារ ច្បាប់ផ្សេងៗ...។

**៥.ឃ.៣.រិះគន់កថា៖** ជាអត្ថបទដែលប្រធានរឿងលើកយកគុណវិបត្តិណាមួយរបស់បុគ្គលមកបង្ហាញ ហើយរិះគន់ដើម្បីកែប្រែបុគ្គលនោះឱ្យបានត្រឹមត្រូវ។ ការរិះគន់មានពីរគឺ រិះគន់ដើម្បីស្ថាបនា និងបំផ្លាញ។

**៥.ឃ.៤.ដំនៀលកថា៖** ជាការរិះគន់បែបបំផ្លាញដោយលែងគិតពីសីលធម៌ គឺធ្វើយ៉ាងណាឱ្យម្នាក់ទៀតបាត់បង់សីលធម៌ ជាពិសេសអត្ថបទកាសែត ដែលទំនាស់ជាមួយការដឹកនាំរបស់រដ្ឋាភិបាល។

**៥.ឃ.៥.ឧស្សាហកថា៖** ជាការសាកល្បងរបស់អ្នកនិពន្ធ ដែលអត្ថាធិប្បាយអំពីនយោបាយ សេដ្ឋកិច្ច វប្បធម៌។ វាជាអត្ថបទសាកល្បងអត្ថាធិប្បាយពីបញ្ហាអក្សរសិល្ប៍ សាសនា នយោបាយ មតិរបស់ទស្សនវិទូ អ្នកប្រាជ្ញ កវី បណ្ឌិត។ អ្នកនិពន្ធលើកឡើងនូវដំណោះស្រាយមួយដាក់ជូនសាធារណជនពិចារណាសំដៅរកមាគ៌ាមួយ។ ឧទាហរណ៍៖ ការពន្យល់ថាគំនិតរបស់ខ្លួនយ៉ាងនេះ ឬយ៉ាងនោះ។

**៥.ឃ.៦.សុន្ទរកថា៖** ជាអក្សរសិល្ប៍ដែលអ្នកនិពន្ធ អ្នកដឹកនាំរដ្ឋ ប្រធានអង្គភាព ដែលជាអ្នកថ្លែងមានច្រើនបែប គេថ្លែងក្នុងពិធីសម្ពោធ ពិធីជប់លៀង សន្និបាត ការបញ្ចប់ការងារ... គ្រាន់តែប្លង់វាមិនលើសពីរបាយការណ៍។ វាលើកយកពីគុណសម្បត្តិដើម្បីឱ្យមហាជនយកជាគំរូ ជាការណែនាំដល់មហាជន។ អប់រំក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ នយោបាយ។

**៥.ឃ.៧.ល្បើកកថា៖** ជាប្រភេទអក្សរសិល្ប៍មួយប្រភេទដែលមានលក្ខណៈជារឿងនិទានសម្រាប់អប់រំដល់មនុស្សទាំងឡាយ ហើយមានប្រធានរឿងនិងតួអង្គច្បាស់លាស់។ ដូចជារឿងធ្មានិងចាបស្រុក ល្បើកជុចនិងត្រី( វិសេសដូង ) ល្បើកកុកនិងក្តាម។

<u>៦.ប្រភេទលំនឹកកថា ( Les memories et notes )</u>**៖** ជាប្រភេទស្នាដៃមួយត្រូវបានអ្នកនិពន្ធទុកជាគោលការណ៍លំនឹកស្តីអំពីស្នាដៃទាំងឡាយ ដែលគេបានធ្វើរួចមកហើយ។ ស្នាដៃប្រភេទនេះ មាននៅក្នុងចំណោមអ្នកតស៊ូ អ្នកកត់ត្រាប្រវត្តិសាស្ត្រ អ្នកតស៊ូនយោបាយ អ្នកកាសែតក៏ដូចជាបុគ្គលមួយចង់កត់ត្រាពីប្រវត្តិរបស់ខ្លួនគេផ្ទាល់។ ឧទាហរណ៍៖ អត្ថបទព្រះរាជសម្ភារ ជាលំនឹកកថាបែបវីណាគីត អ្នកតស៊ូនយោបាយ ពោធិកំបោរ ក្រឡាហោមគង់ អាចារ្យហែមចៀវ...។

**លក្ខណៈពិសេសរបស់ប្រភេទលំនឹកកថា៖** វាបានផ្សារភ្ជាប់ជាមួយមនុស្សពិតប្រាកដនៅក្នុងជីវភាពរស់នៅរបស់គេ ស្នាដៃនេះមានលក្ខណៈសច្ចៈបែបប្រវត្តិសាស្ត្រ។ វាមានលក្ខណៈឆ្លុះបញ្ចាំងនូវជីវិតពិតៗដោយគ្មានភូតកុហក។ ប្រធានបទរបស់វា អាស្រ័យទៅតាមជំនាញ បើអត្ថបទនោះទាក់ទងនឹងមុខជំនាញកាសែត គេកត់ត្រាដើម្បីចុះក្នុងកាសែត។ ដោយឡែកលំនឹកកថានៅក្នុងអក្សរសិល្ប៍ខ្មែរសំដៅទៅលើអត្ថបទសិលាចារឹកស្តីពីព្រះរាជអង្គណាមួយ។ ឧទាហរណ៍៖ អត្ថបទសិលាចារឹកកវីជ័យនន្ទ ដែលមានខ្លឹមសារនិយាយអំពីអំពើរបស់បុគ្គលជាមនុស្សពិតប្រាកដក្នុងប្រវត្តិសាស្ត្រ។ អ្នកនិពន្ធបានជ្រើសរើសសម្រាំងមនុស្សណាមួយដែលមានលក្ខណៈលេចធ្លោ នៅក្នុងប្រវត្តិសាស្ត្រយកមកសរសេរ។ បញ្ហាអត្តរូប ជាស្នាដៃមួយដែលរូបារម្មណ៍ទាំងឡាយ ហាក់ដូចជាមានកម្រិតទាប ព្រោះគេជានានូវសច្ចភាព រូបារម្មណ៍តែមួយមាននៅក្នុងស្នាដៃគឺរូបារម្មណ៍ជ្រើសរើសតួអង្គជាតំណាង ដែលមានគុណបំណាច់ចំពោះជាតិមាតុភូមិ។

## ៣. សន្និដ្ឋាន

ជារួមមកក្រោយពីបានបង្ហាញរៀបរាប់ពីទ្រឹស្តីអក្សរសិល្ប៍ យើងអាចធ្វើការសន្និដ្ឋានបានថាការសិក្សាទ្រឹស្តីអក្សរសិល្ប៍ជាភារកិច្ចចម្បងទីមួយ ដែលអ្នកសិក្សាគ្រប់រូប មិនត្រូវមើលរំលង ឬបំភ្លេចចោល ដោយការមិនយកចិត្តទុកដាក់ឡើយ។ យើងគ្រប់គ្នាត្រូវសិក្សាឈ្វេងយល់បានច្បាស់លាស់ មុននឹងអាចធ្វើការសិក្សាស្នាដៃអក្សរសិល្ប៍បានល្អត្រឹមត្រូវ ដោយហេតុថាទ្រឹស្តីអក្សរសិល្ប៍បានក្តោបយករឿងរ៉ាវទាំងឡាយក្នុងអក្សរសិល្ប៍គ្មានកន្លែងខ្វះចន្លោះត្រង់ចំណុចណាមួយឡើយ។

# អក្សរសិល្ប៍ប្រជាប្រិយ

## ១. វត្ថុបំណង

- រៀបរាប់បានពីនិយមន័យ ប្រភេទ ប្រភព លក្ខណៈសម្គាល់ លក្ខណៈពិសេស និង តម្លៃអប់រំរបស់អក្សរសិល្ប៍ប្រជាប្រិយ។
- មានសមត្ថភាពក្នុងការបកស្រាយពីអក្សរសិល្ប៍ប្រជាប្រិយ ប្រភេទ ប្រភព និងលក្ខណៈនានានៃអក្សរសិល្ប៍ប្រជាប្រិយ។
- ទាញតម្លៃអប់រំចេញពីដំណើររឿងដើម្បីយកទៅអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។

## ២. ខ្លឹមសារមេរៀន

### ២.១ ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ប្រជាប្រិយ

អក្សរសិល្ប៍ប្រជាប្រិយ ជាអក្សរសិល្ប៍មួយប្រភេទដែលមានកំណកំណើតតាំងពីយូរលង់ណាស់មក ហើយមុននឹងមាននិម្មិតកម្មស្នាដៃអក្សរសិល្ប៍សំណេរ ឬអក្សរសិល្ប៍ចំណេរមកម្ល៉េះ។ អក្សរសិល្ប៍ប្រជាប្រិយនេះ ត្រូវបានគេចាត់ទុកថាជាអក្សរសិល្ប៍ដែលមានប្រជាប្រិយភាពខ្លាំង និងជាទីរាប់អាននៃប្រជាជនទូទៅ មិនថាចាស់ ក្មេង ប្រុស ស្រី តែងពេញចិត្តស្ដាប់ដោយហេតុថាវាបានបំពេរអារម្មណ៍ប្រជាជនឱ្យមានភាពសប្បាយរីករាយផង បានសម្ដែងនូវសញ្ចេតនានានាចំពោះសង្គមផង និងបានបង្កប់នូវតម្លៃខាងអត្តសញ្ញាណជាតិផងដែរ។ អក្សរសិល្ប៍ប្រជាប្រិយមានកំណើតមកអំពីការនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ពីតំបន់មួយទៅតំបន់មួយ ពីភូមិស្រុកមួយទៅភូមិស្រុកមួយ ឬពីប្រទេសមួយទៅប្រទេសមួយទៀតក៏អាចបាន។ តាមសេចក្ដីនៃការចាប់កំណើតរបស់អក្សរសិល្ប៍ប្រជាប្រិយនេះ យើងពុំអាចដឹងឈ្មោះអ្នកនិពន្ធ ពុំអាចដឹងកាលកំណត់តែងឱ្យបានច្បាស់លាស់ឡើយ តែមិនមែនមានន័យថាគ្មានអ្នកនិពន្ធ និងគ្មានកាលតំណែងនិពន្ធដែរ។

អក្សរសិល្ប៍ប្រជាប្រិយ ជាអក្សរសិល្ប៍របស់មហាជនត្រូវបានបង្កើតឡើងក្នុងតំណរយៈការងារពលកម្ម និងការតស៊ូប្រយុទ្ធប្រឆាំងនឹងរាល់ការលំបាកដើម្បីជីវិតរស់នៅ។ តាំងពីសង្គមគ្មានវណ្ណៈរហូតដល់សង្គមមានវណ្ណៈ អក្សរសិល្ប៍ប្រជាប្រិយត្រូវបានបង្កើតផ្សព្វផ្សាយ រីកចម្រើន និងបម្រើឱ្យផលិតកម្ម ព្រមទាំងការតស៊ូក្នុងជីវិត។ ងាកមកនិយាយពីខ្លឹមសារអក្សរសិល្ប៍ប្រជាប្រិយវិញ យើងសង្កេតឃើញថាវាបានឆ្លុះបញ្ចាំងពីអាថ៌កំបាំងនៃបាតុភូតធម្មជាតិផ្សេងៗ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ ចរិតលក្ខណៈរបស់មនុស្សក្នុងសង្គម ការស្រេកឃ្លានចង់បានយុត្តិធម៌របស់អ្នកតូចតាច ការឈឺចាប់ សីលធម៌ អយុត្តិធម៌ ប្រវត្តិសាស្ត្រ ប្រវត្តិភូមិសាស្ត្រទឹកដី របៀបគ្រប់គ្រងប្រទេស ជាដើម។

### ២.២ បញ្ញត្តិនិងនិយមន័យនៃពាក្យ " អក្សរសិល្ប៍ប្រជាប្រិយ "

នៅមុនឆ្នាំ១៩៧៩ ជុំវិញការផ្ដល់បញ្ញត្តិ ឬការហៅឈ្មោះ និងនិយមន័យអក្សរសិល្ប៍ប្រជាប្រិយនេះ គឺមានច្រើនបែបច្រើនយ៉ាងដោយផ្អែកទៅលើទស្សនៈ គំនិតយោបល់ចំពោះលក្ខណៈពិសេសដោយឡែករបស់វាខុសពីអក្សរសិល្ប៍ប្រភេទផ្សេងទៀត។ តែលុះដល់ក្រោយថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ មកបញ្ញត្តិ

« អក្សរសិល្ប៍ប្រជាប្រិយ » នេះ ត្រូវបានលើកយកមកប្រើប្រាស់ ដោយអ្នកសិក្សាអក្សរសាស្ត្រ-អក្សរសិល្ប៍ ដើម្បីវែកញែកវាងអក្សរសិល្ប៍មួយទៀត ដែលមាននាមអ្នកនិពន្ធ មានកាលតំណែងនិពន្ធច្បាស់លាស់។

**ខាងក្រោមនេះ គឺជាការកំណត់បញ្ញត្តិនិងនិយមន័យរបស់អក្សរសិល្ប៍ប្រជាប្រិយ៖**

- តាមលោក **ខឹម សំឱរ** ក្នុងស្នាដៃ « ប្រវត្តិអក្សរសាស្ត្រខ្មែរ » បានហៅអក្សរសិល្ប៍ប្រជាប្រិយនេះជា**អក្សរសាស្ត្រប្រជាជន** ដោយផ្ដល់និយមន័យថា « អក្សរសាស្ត្រប្រជាជន គឺជារឿងព្រេងដែលប្រជាជនបាននិយាយតៗគ្នារៀងរហូតមកពីមាត់មួយទៅមាត់មួយ »។ រឿងព្រេងច្រើនជារឿងខ្លីៗ មានតែរឿងធ្មេញជ័យ អាឡេវដែលវែងបន្តិច។
- តាមលោក **ឃីង ហុកឌី** ក្នុងស្នាដៃ « ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ » បានហៅអក្សរសិល្ប៍ប្រជាប្រិយនេះថា « រឿងព្រេង » ដោយបានផ្ដល់និយមន័យថា « រឿងព្រេងគឺដំបូងជាអក្សរសាស្ត្រសម្ដីពីមាត់មួយទៅមាត់មួយមានមកជាយូរអង្វែងមកហើយ បានផ្ទេររឿងព្រេងតាមបបូរមាត់ជូនតាមេបាយើង តាមអ្នកចម្រៀង និងសិល្បករនានា »។
- តាមលោក **ហ៊ុន គឹមសៀ** ក្នុងស្នាដៃ « មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ » បានឱ្យបញ្ញត្តិអក្សរសិល្ប៍ប្រជាប្រិយថា៖ គឺជារឿងព្រេង ឬជាអត្ថបទរឿងរ៉ាវពីជំនាន់ដើម ដែលនិយាយរៀបរាប់តែពីទេព្ដា ឥន្ទ្រព្រហ្ម មានអារក្សអ្នកតាជាដើម មានចរិតអស្ចារ្យហួសសម័យ រឿងរ៉ាវជាគំនិតនិយមគ្មានហេតុផល ( គំនិតយល់សប្ដិ ) ហើយពិធីរៀបរាប់ ក៏មិនសូវឃើញមានប្រើពាក្យសម្ដីវោហារឱ្យក្បោះក្បាយផងដែរ។ មានរឿងព្រេងមួយពួកទៀត មានចរិតបែបប្រជាមានិត ដែលគេហៅថារឿងព្រេងប្រជាមានិត រឿងនេះភាគច្រើនជារឿងអនាមិក (រឿងដែលគ្មានឈ្មោះអ្នកនិពន្ធ)។
- ពីដើមមកគេច្រើននិយាយឱ្យស្ដាប់តៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ រឿងទាំងអស់នោះមានគុណភាពជាក់ស្ដែងក្នុងការដឹកនាំមនុស្ស ចលនាមនុស្សឱ្យមនុស្សទៅកាន់សភាពសកម្ម និងរិះគន់ដល់សភាវៈដែលមហាជនតូចតាចក្នុងសម័យនោះយល់ថាវាមិនសមរម្យ។
- តាមលោក **លាង ហាប់អាន** « សិក្សាអត្ថបទភាគ១ » បានឱ្យបញ្ញត្តិអក្សរសិល្ប៍ប្រជាប្រិយនេះ ជាពីរគឺប្រឌិតកថា និងព្រេងកថា ដោយពន្យល់ថា៖ ប្រឌិតកថា គឺជាអត្ថបទរឿងមួយផ្នែកដែលបុព្វបុរស ឬអ្នកប្រាជ្ញចាស់ទុំពីបរមបុរាណតែងឡើង ប្រឌិតឡើងដោយយករឿងវិបត្តិទំនាស់បន្តិចបន្តួច ដូចជារឿងឈ្លោះប្រកែកគ្នារវាងសមាជិកគ្រួសារ រឿងទាស់ទែងច្រណែនប្រចណ្ឌ រឿងផិតក្បត់ប្ដីប្រពន្ធ សាហាយស្មន់ រឿងប្រជែងប្រណាំងប្រមាថកាតទានព្យាបាទឈ្នានីសគ្នា ក្នុងសម័យកាលណាមួយនៃប្រវត្តិសាស្ត្រ មកលើកជាសេចក្ដីសម្រាប់និទានប្រាប់កូនចៅញាតិមិត្តជិតឆ្ងាយ ដើម្បីយកហេតុផលជាគ្រឿងអបរំបចិត្តគំនិតប្រដៅណែនាំអនុជន តាមដំបូន្មានចរិយាសាស្ត្រច្បាប់ទម្លាប់ប្រពៃណីល្អតៗគ្នា ដូចជារឿងសុភាទន្សាយ រឿងអាកំជិលអាំងផេះ។ល។ រឿងបែបនេះពីមុនគ្មានកត់ត្រាជាក្បួនខ្នាត ឬជា

សៀវភៅឡើយ។ គេចាំតៗគ្នា ហើយចេះនិយាយគ្រប់ៗគ្នា ពីស្រុកមួយទៅស្រុកមួយរហូតពាសពេញប្រទេស ដែលក្លាយទៅជាមានប្រជាប្រិយភាពយ៉ាងអស្ចារ្យ។

លុះតៗមកប្រឌិតកថាដែលអ្នកស្រុកចេះចាំស្ទាត់ជំនាញក៏បង្កើតជាជំនឿ ជាការចូលចិត្ត ចាប់ចិត្ត បង្កើតជាពិធី ជាការគោរព ជាប្រពៃណីហូរហែទាំងភូមិ ទាំងស្រុក ទាំងប្រទេស ឧទាហរណ៍៖ ដូចជារឿងធនញ្ជ័យ... កាលណារឿងប្រឌិតកើតទៅជាជំនឿ ជាទំនៀមទម្លាប់ ជាប្រពៃណីជុះជាប់ក្នុងចិត្តអ្នកស្រុកជាប់នឹងឈ្មោះទីកន្លែង ភូមិ ស្រុក ឃុំ ឬប្រវត្តិសាស្ត្រ រឿងទាំងនោះមានឈ្មោះថារឿងព្រេង ឬព្រេងកថា។

តាមលោកបណ្ឌិត **អ៊ីវ ចុង** ក្នុងស្នាដៃ « អក្សរសិល្ប៍ប្រជាប្រិយខ្មែរ » បានហៅស្នាដៃអក្សរសិល្ប៍នេះថាផុលក្លរអក្សរសិល្ប៍ ដោយផ្តល់និយមន័យថា « ជាកំណាព្យនិងចម្រៀងប្រជាប្រិយតាមមាត់ ឬនិយាយឱ្យខ្លីគឺសិល្បៈតាមមាត់ »។

តាមគេហទំព័រ http://en.wikipedia.org/wiki/Folklore បានហៅអក្សរសិល្ប៍ប្រជាប្រិយជាភាសាអង់គ្លេសថា Folklore ដែលត្រូវបានប្រើប្រាស់ក្នុងការហៅជាលើកដំបូងដោយអ្នកបុរាណវិទ្យាជនជាតិអង់គ្លេសម្នាក់ឈ្មោះ William Thoms និងបានដាក់បញ្ញត្តិនៃពាក្យនេះ ថាគឺជាសិល្បៈប្រពៃណី អក្សរសាស្ត្រ ចំណេះដឹង និងការអនុវត្តដែលត្រូវបានចែកចាយទូលំទូលាយ ឆ្លងកាត់ពីមាត់មួយទៅមាត់មួយ និងសកម្មភាពដែលបានធ្វើឡើង។

## ២.៣ ប្រភេទអក្សរសិល្ប៍ប្រជាប្រិយ

តាមការសិក្សាស្នាដៃអក្សរសិល្ប៍ប្រជាប្រិយខ្មែរ ដែលបានរៀបរៀងចងក្រងឡើងដោយលោក អ៊ីវ ចុង ដោយបានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំនៅថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ១៩៨៤ ដើម្បីប្រើប្រាស់នៅតាមសាលាចំណេះទូទៅ បានបែងចែកប្រភេទអក្សរសិល្ប៍ប្រជាប្រិយដូចខាងក្រោម៖

អក្សរសិល្ប៍ប្រជាប្រិយ

- តំណាលកថាប្រជាប្រិយ
  - ទេវកថា
  - ព្រេងកថា
  - និទានកថា
    - និទានកថាអស្ចារ្យ
    - និទានកថាសត្វ
    - និទានកថាសង្គម
    - និទានកថាសំណើច
    - ល្បើកថា
- ពាក្យចូនប្រជាប្រិយ
  - សុភាសិត
  - ពាក្យបណ្តៅ
  - ចម្រៀងប្រជាប្រិយ
    - ចម្រៀងក្នុងពិធីផ្សេងៗ
    - ចម្រៀងពលកម្ម
    - ចម្រៀងសកម្មភាពនិង
    - ចម្រៀងរីណាគីត
- របាំប្រជាប្រិយ

### ២.៣.១ តំណាលកថាប្រជាប្រិយ

តំណាលកថាប្រជាប្រិយភាគច្រើនជារឿងប្រឌិត ដែលអ្នកស្រុកនិយាយឱ្យស្របទៅនឹងភូមិសាស្រ្ត ព្រឹត្តិការណ៍សម័យណាមួយ ឬបង្ហាញពីភាពអច្ឆរិយៈរបស់វីរជនណាមួយដែលលះបង់សេចក្ដីសុខដើម្បីជាតិមាតុភូមិ។ តាមរយៈលោក គ័រ គី បានលើកឡើងថា តំណាលកថាប្រជាប្រិយជាអក្សរសិល្ប៍មួយបែបដែលលើកយកទុក្ខសោកមនុស្សក្នុងជីវភាពរស់នៅ ការរងសម្ពាធពីធម្មជាតិគ្មានវិធីដោះស្រាយ ហើយពួកគាត់ចង់ឱ្យទុក្ខសោករលាយក៏បង្កើតជារឿងផ្សេងៗ ដើម្បីបន្ធូរអារម្មណ៍របស់ពួកគេ។

#### ២.៣.១.១ ទេវកថា

ទេវកថាជាសញ្ញាណដំបូងនៃអក្សរសិល្ប៍ខ្មែរ ដែលបុព្វបុរសរបស់យើងមិនទាន់យល់ពីបាតុភូតធម្មជាតិ ហើយត្រូវធម្មជាតិគំរាមកំហែងមិនឈប់ឈរ ធ្វើឱ្យគេយល់ថាបណ្ដាលមកពីអារក្សអ្នកតាបង្កើតឡើងក៏អង្វរអារក្សអ្នកតាទាំងនោះឱ្យអនុគ្រោះ។ ដូចនេះទេវកថា ជាប្រភេទតំណាលកថាស្ដីពីចម្លើយដំបូងរបស់មនុស្សអំពីបាតុភូតធម្មជាតិ តែចម្លើយនោះខុសមកពីចំណេះដឹងរបស់មនុស្សនៅមានកម្រិតទាប។

រឿងទេវកថារួមមាន រឿងអ្នកតាទឹកអ្នកតាភ្នំ រឿងព្រះចន្ទ រឿងព្រះពាយ រឿងកំណើតរន្ទះ រឿងសង្គ្រាមវាងគីង្គក់និងតាព្រហ្ម...។

#### ២.៣.១.២ ព្រេងកថា

ជាប្រភេទតំណាលកថាប្រជាប្រិយ ដែលនិទានបន្តពីទេវកថាហើយទាក់ទងទៅនឹងប្រវត្តិសាស្រ្ត តួអង្គជាវីរជនដោយមានពណ៌នាពីព្រឹត្តការណ៍ប្រវត្តិសាស្រ្តជាក់ស្ដែង។ មិនតែប៉ុណ្ណោះព្រេងកថាតែងតែលើកឡើងទាក់ទងនឹងប្រពៃណីទំនៀមទម្លាប់ ភូមិសាស្រ្ត ការគោរពបូជា។ ព្រេងកថាតែងលើកយកសកម្មភាពតស៊ូរបស់តួអង្គវីរជន ដែលជាប់ទាក់ទងទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្រ្តមកបង្ហាញ។ អ្នកនិពន្ធតាក់តែងរឿងព្រេងកថាសុទ្ធតែរឿងពិតខ្លះមិនពិតខ្លះ ពេលខ្លះមានភាពអច្ឆរិយៈថែមទៀត។ ម្យ៉ាងទៀតអ្នកនិពន្ធបានបណ្ដុះមនោសញ្ចេតនាស្នេហាជាតិ ស្នេហាជាតិសាសន៍ ស្នេហាទឹកដីដល់កុលបុត្រ ពិសេសឱ្យកូនចៅជំនាន់ក្រោយស្គាល់ពីទំនៀមទម្លាប់ ប្រពៃណី សាសនា ប្រត្តិសាស្រ្តឱ្យកាន់តែច្បាស់ ដែលជាអត្តសញ្ញាណជាតិរបស់ខ្លួន។ ព្រេងកថាមានដូចជា រឿងព្រះថោងនាងនាគ រឿងភ្នំប្រុសភ្នំស្រី រឿងប្រវត្តិក្រុងភ្នំពេញ រឿងអ្នកតាឃ្លាំងមឿងជាដើម។

#### ២.៣.១.៣ និទានកថាប្រជាប្រិយ

**និទានកថា ឬប្រឌិតកថាប្រជាប្រិយ** ជាប្រភេទតំណាលកថាប្រជាប្រិយដែលមានដំណើររឿង និងតួអង្គកើតឡើងពីការស្រមើស្រមៃរបស់ប្រជាជន ទៅតាមលំនាំរឿងពិតដែលកើតឡើងនៅក្នុងសង្គម។ ឧទាហរណ៍៖ រឿងចៅសាញ់ចៅធុង រឿងចៅអាចម៍សេះ រឿងបុរសជីកក្ដាម រឿងចៅតប់ប្រមល់...។

**និទានកថាសង្គម** ជាប្រភេទនិទានកថាដែលលើកយកតួអង្គសត្វ ឬរុក្ខជាតិមកបង្ហាញ ដើម្បីឆ្លុះបញ្ចាំងមនុស្សក្នុងសង្គម។ ចំណែកនិទានកថាសង្គមខ្លះលើកយកតួអង្គមនុស្សមកសម្ដែងតែម្ដងដូចជា រឿងចៅចាក់ស្មុគ រឿងមាយាស្ដ្រី រឿងបុរសនេសាទត្រីជាដើម។

**និទានកថាសត្វ** ជាប្រភេទរឿងរ៉ាវដែលបង្ហាញពីប្រវត្តិនៃសត្វ និងបុគ្គលិកលក្ខណៈនៃសត្វ ដើម្បីជាឧបមារូបារម្មណ៍ទៅនឹងមនុស្សក្នុងសង្គម។ និទានកថាសត្វមានដូចជា រឿងត្រដក់ជាន់កូនក្រួច រឿងត្មាតបោកដំរីស រឿងដើមកោងកាងជាដើម។

**និទានកថាសំណើច** ជារឿងមួយប្រភេទដែលប្រកបទៅដោយការរិះគន់របស់អ្នកនិពន្ធលាយឡំទៅដោយសំណើច ដើម្បីបង្វែអារម្មណ៍កុំឱ្យលើកដាក់ដំណើររឿងមកលើខ្លួនដូចតួអង្គក្នុងសាច់រឿង។ និទានកថាសំណើចមានដូចជា រឿងជាងកាត់សក់ចំណាប់ រឿងម៉ៅស្វិត រឿងធ្វើមិនដូច រឿងគំនិតវៀងវៃជាដើម។

### ២.៣.១.៤ ល្បើកកថា

**ល្បើកកថា** ជាសុភាសិតល្បើកបង្រួម។ ល្បើកកថាជាច្រើននិយាយលើកឡើងទាក់ទងនឹងនិទានកថាសត្វដើម្បីបង្ហាញពីនិមិត្តរូបមនុស្សនៅក្នុងសង្គម ដោយសង្កេតពិនិត្យលើតថភាពនៃសង្គមជាក់ស្តែង ក្នុងគោលបំណងអប់រំទូន្មានប្រៀនប្រដៅជននានុជន ហើយភាគច្រើនសរសេរជាកាព្យ។ ល្បើកកថាមានដូចជា ល្បើកជុចនិងត្រី ល្បើកអក ល្បើកស្រីកណ្ដុរល្ងោច រឿងប្រាជ្ញាមនុស្សជាដើម។ ដូចនេះល្បើកកថា ជាអក្សរសិល្ប៍មួយប្រភេទដែលលើកតួអង្គមនុស្ស សត្វ និងធម្មជាតិមកបង្ហាញប្រកបដោយការរិះគន់លាយឡំនឹងសំណើចទៀតផង។

### ២.៣.២ ពាក្យចួនប្រជាប្រិយ

**ពាក្យចួនប្រជាប្រិយ** ជាប្រភេទពាក្យដែលមានវាក្យសព្ទ និងផ្ទុកទៅដោយចំណាប់ចុងជួនរណ្ដំណែងណងបង្កប់ទៅដោយខ្លឹមសារអប់រំយ៉ាងជ្រាលជ្រៅ។ ពាក្យចួនប្រជាប្រិយពេលខ្លះកើតចេញពីប្រជាកសិករ មន្ត្រីរាជការ ឬស្ដេច ក្នុងបំណងរិះគន់ ស្ថាបនា បណ្ដុះទឹកចិត្តកូនចៅឱ្យតស៊ូព្យាយាមចំពោះការងារក្នុងជីវិតរស់នៅ។ ពេលខ្លះទាក់ទងនឹងការងារកសិករតាមបែបផែនផលិតកម្ម ការតស៊ូប្រយុទ្ធនឹងធម្មជាតិធ្វើសឹកសង្គ្រាម។ ពាក្យចួនប្រជាប្រិយរួមមាន៖

- « ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ »។
- « ធ្វើស្រែទាន់ក្ដៅដី ចង់ស្រីទាន់ក្ដៅចិត្ត »។
- « ឃ្លានឆ្ងាញ់ ស្រឡាញ់ល្អ »។
- « ចេះឱ្យគេកោត ឆោតឱ្យគេអាណិត »។

### ២.៣.២.១ សុភាសិត

**សុភាសិត** ជាកម្រងពាក្យពេចន៍ទាំងឡាយណា ដែលបុព្វបុរសយើងបង្កើតឡើងតាមរយៈបទពិសោធនានាធ្លាប់បានជួបប្រទះ ដើម្បីជាប្រយោជន៍ផ្ដល់ជាគតិសម្រាប់អប់រំទូន្មានដល់មនុស្សជំនាន់ក្រោយ។ សុភាសិតជាគតិបណ្ឌិតប្រជាប្រិយ។ សុភាសិតបកស្រាយពីបាតុភូតរបស់ធម្មជាតិ ផលិតកម្ម ជីវភាពសង្គម សីលធម៌។ លោក គ័រ គី បានចាត់ទុកសុភាសិតថាជា បទពិសោធន៍សង្គមប្រវត្តិរបស់ប្រជាជន។

សុភាសិតខ្មែរត្រូវបានបុព្វបុរសយើងប្រើឧបមានប្រៀបធៀប ដើម្បីជាគតិសម្រាប់ពិចារណា ជាពិសេសសុភាសិតមានជីវិតរស់នៅគ្រប់សម័យកាល។ សុភាសិតមានប្រភពមកពីមជ្ឈដ្ឋានបីគឺ៖

- ជីវភាពរស់នៅរបស់មហាជន

- ប្រភេទផ្សេងៗនៃនិទានកថាប្រជាប្រិយ
- អក្សរសិល្ប៍សំណេរ

សុភាសិតចែកជាពីរ គឺសុភាសិតអត្ថានុរូប (អប់រំដោយត្រង់) និងសុភាសិតអត្ថុបដិរូប(អប់រំតាមន័យធៀប)។ ឧទាហរណ៍៖ «ចេះពីរៀនមានពីរក» (ន័យត្រង់) «ដើមស្លកឱនដាក់គ្រាប់» (ន័យធៀប)។

**២.៣.២.២ ពាក្យបណ្ដៅ**

**ពាក្យបណ្ដៅ** ជាកម្រងពាក្យពេចន៍ដែលបុព្វបុរសយើងបង្កើតឡើងសម្រាប់ឱ្យកូនចៅត្រិះរិះពិចារណារកចម្លើយ ហើយចុងបញ្ចប់នៃពាក្យបណ្ដៅ គឺមានពាក្យចោទសួរនៅខាងចុង។

បើតាមការសង្កេតពាក្យបណ្ដៅមួយភាគធំមានលក្ខណៈកំប្លុកកំប្លែង និងខ្លះទៀតមានលក្ខណៈអាសអាភាស ប៉ុន្តែពាក្យពេចន៍មានន័យអប់រំយ៉ាងជ្រាលជ្រៅ។

ឧទាហរណ៍៖ - ទឹកមួយផ្តុកកំពឹសពងពេញ តើជាអ្វី? ( ផ្លែក្រូច )
- ដើមនៅឯស្រែផ្លែនៅឯផ្ទះ តើជាអ្វី? ( ដើមកន្ត្រៃយ )
- នាងដើរដំណើរប្អូនស្រីយកដៃបោសដីបោសផ្កាសុភី តើជាអ្វី? ( ដំរី )
- ស្ដេចក៏ប្រើបាន រាស្ត្រក៏ប្រើបាន តើជាអ្វី? ( លុយ )

**២.៣.២.៣.ចម្រៀងប្រជាប្រិយ**

**ចម្រៀងប្រជាប្រិយ** ជាការសម្ដែងពីមនោសញ្ចេតនាខាងក្នុងរបស់ប្រជាកសិករ ដែលពួកគាត់និយមច្រៀងនៅតាមវាលស្រែចម្ការ ឬនៅក្នុងពិធីបុណ្យផ្សេងៗ។ ក្នុងទំនុកច្រៀងមានរៀបរាប់ពីភាពសប្បាយរីករាយទុក្ខសោក ការងារស្រែចម្ការ និងទំនៀមទម្លាប់ប្រពៃណីជាដើម។ ចម្រៀងប្រជាប្រិយមានភាពរស់រវើកកំប្លុកកំប្លែងលាយឡំនឹងការឈឺចាប់ និងបកស្រាយពីបញ្ហាវណ្ណៈនៅក្នុងសង្គម។ លោក គ័រ គី ចាត់ទុកចម្រៀងប្រជាប្រិយ ប្រវត្តិសាស្ត្រសង្គម ប្រជាជន ជាជីវិតរួមរបស់ប្រជាជន។ ចម្រៀងប្រជាប្រិយដែលមហាជនចាប់អារម្មណ៍នោះ គឺកំណាព្យ ទំនុកច្រៀងនិងតន្ត្រី។ ពេលច្រៀងម្ដងៗ គេតែងរៀបរាប់ពីមនោសញ្ចេតនាផ្ទាល់ខ្លួន និងបំណងប្រាថ្នារបស់មហាជនដែលចង់បានសេចក្តីសុខ ភាពរីកចម្រើន និងគំនិតស្នេហាជាតិមាតុភូមិជាដើម។

ចម្រៀងប្រជាប្រិយមាន៖

- ចម្រៀងក្នុងពិធីមង្គលការមាន៖ បទនគររាជ (ពេលកាត់ខាន់ស្លា ) បទដាវឯក ( ច្រៀងពេលផ្ទឹមកូនប្រុសស្រី)
- ចម្រៀងក្នុងពិធីបញ្ចូលម្លប់កូនស្រី៖ បទសូរសេះ (សូរសេះដំរី មកបញ្ជាន់ទីជាន់ជើងស្តាំឆ្វេងជាន់វក់ជាន់រឹមកបញ្ជាន់ទីឱ្យជ្រះចង្រៃ)
- ចម្រៀងពលកម្ម៖ បទបេះស្លឹកមន (ចម្រៀងទាក់ទងនឹងតម្បាញ ) បទនាងបុកស្រូវ...។
- ចម្រៀងទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ៖ ចម្រៀងរិះគន់នៅសម័យបារាំង ចម្រៀងរិះគន់សាសនា...។

- ចម្រៀងវីណាគីតៈ ចម្រៀងបង្ហាញពីមនោសញ្ចេតនា ចម្រៀងបង្ហាញពីទឹកចិត្តប្រជាជន ចម្រៀងបង្ហាញការខកបំណង...។

### ២.៣.៣ របាំប្រជាប្រិយ

**របាំ** មកពីពាក្យរាំ។ រាំជាការបញ្ចេញកាយវិការវាសដៃវាសជើង ពត់ពែន លោត ហក់ ចាក់ក្បាច់ទៅតាមចម្រៀង និងតន្ត្រី។ ដូចនេះរបាំមានធាតុសំខាន់បីគឺ កាយវិការ ចម្រៀង និងតន្ត្រី។ របាំកើតមាននៅតាមតំបន់នីមួយៗ ដែលបងប្អូនប្រជាកសិករប្រារព្ធតាមទំនៀមទម្លាប់ប្រពៃណី ខ្លះទៀតទាក់ទងនឹងពលកម្មកសិកម្ម ការអង្វរករសុំទឹកភ្លៀង គ្រោះធម្មជាតិកើតឡើងតាមតំបន់នីមួយៗ។ ចំណែករបាំខ្លះទាក់ទងនឹងការងារនេសាទ បេះផល្លានុផលក្នុងជីវភាពរស់នៅប្រចាំថ្ងៃដែលគេជួបប្រទះ។

របាំចែកជាបីគឺ របាំក្បាច់បុរាណ របាំប្រពៃណី និងរបាំប្រជាប្រិយ។

# អក្សរសិល្ប៍ខ្មែរសម័យមុនអង្គរ
# ( សតវត្សទី១ ដល់សតវត្សទី៩ )

## ១. វត្ថុបំណង

- ប្រាប់ពីទិដ្ឋភាពទូទៅនៃសម័យនគរភ្នំ និងសម័យចេនឡាបានត្រឹមត្រូវតាមរយៈសំណួរបំផុសរបស់គ្រូ និងការយល់ដឹងរបស់ខ្លួន ព្រមទាំងការងារក្រុម។
- បកស្រាយបានពីអក្សរសិល្ប៍ខ្មែរសម័យមុនអង្គរបានត្រឹមត្រូវ តាមរយៈសំណួរបំផុសរបស់គ្រូ និងការយល់ដឹងរបស់ខ្លួន ព្រមទាំងការងារក្រុម។
- បណ្ដុះស្មារតីគរុសិស្សឱ្យខិតខំសិក្សាស្រាវជ្រាវស្វែងយល់បន្ថែមទៀតពីសម័យនគរភ្នំ និងបណ្ដុះស្មារតីគរុសិស្សឱ្យមានជំនក់ចិត្តចាប់អារម្មណ៍លើសម័យចេនឡា។

## ២. ខ្លឹមសារមេរៀន

### ២.១ សម័យនគរភ្នំ ( ស.វ.ទី ១ ដល់ គ.ស. ៥៥០ )

#### ២.១.១ សង្គមប្រវត្តិ

- **បញ្ហាឈ្មោះ** ខាងដើមគ្រិស្តសករាជ ប្រទេសកម្ពុជាយើងមានឈ្មោះថា « នគរភ្នំ»។ «នគរភ្នំ» នេះចិនហៅថា ហ្វូណន (Funan ) ឬ ( Founan ) អក្សរនេះ ចិនបុរាណក្នុងរាជវង្ស « តាំង» អានថា ប៊ីវ-ណាំ (B'iu-nâm ) ត្រូវគ្នានឹងសិលាចារឹកជាភាសាខ្មែរថា «កុរុងព្នំ ឬវ្រះវ្នំ» ជាសំស្ក្រឹតថា « បវ៌តភូបាល ឬសៃលរាជ » ប្រែថា « ស្ដេចភ្នំ » រាជធានីថា « វ្យាធបុរៈ = បុរីអ្នកបរបាញ់ » ទីក្រុងតាំងនៅនឹងតំបន់បាភ្នំ (ទំនងជានៅភ្នំខ្សាច់បច្ចុប្បន្ននេះឯង) ទីស្ថាននេះមានបុរាណដ្ឋាន និងបុរាណទេវរូបសម័យនគរភ្នំច្រើន។ ឯលោក G. Coedès ក៏យល់ថាពាក្យហ្វូណននេះត្រូវនឹងពាក្យខ្មែរបុរាណ(វ្នំ) ដែលសព្វថ្ងៃក្លាយជា(ភ្នំ)។ លោកបានបញ្ជាក់ថា ស្ដេចនាសម័យនោះមាន ឋានន្តរនាមថា ស្ដេចភ្នំ ពាក្យខ្មែរបុរាណ(កុរុងភ្នំ)ត្រូវនឹងពាក្យសំស្ក្រឹតថា(សៃលរាជ)។ ឯជនជាតិចិនបានយកឋានន្តរនាមនេះ ប្រើសម្រាប់ហៅប្រទេសដែលស្ដេចទាំងនោះគ្រប់គ្រង។

- **ទីតាំង** អាណាចក្រហ្វូណន តាំងនៅនឹងឈូងសមុទ្រមួយធំ ខាងកើតទល់នឹងប្រទេសលិនយី(ប្រទេសចម្ប៉ា) ចម្ងាយពីប្រទេស លិន យី ចំនួន ១០០លី(១លី=៥៧៦ម៉ែត្រ) ខាងលិចទល់នឹងសមុទ្រប្រទេសឥណ្ឌា និងអាណាចក្រ គិន លិន( ព្រំដែនមាស) ទំហំប្រទេសចំនួន ៣០០០លី។ បើតាមឯកសាររបស់លោកស្រី ត្រឹង ងា បង្ហាញថា៖

- ហ្វូណនមានចម្ងាយ ៣០០០លី ខាងលិចប្រទេស លិន-យី
- ហ្វូណនមានចម្ងាយ ៧០០០លី ពី Jenan ( តុង កឹង )
- ហ្វូណនមានទំហំ ៣០០០លី ក្រោយពង្រីកធំដល់ ៥០០០លី ឬ ៦០០០លី
- ហ្វូណនស្ថិតនៅក្នុងឈូងសមុទ្រធំមួយ

- មានទន្លេធំមួយហូរពីខាងលិច ( តាមឯកសារខ្លះ ) ហើយចាក់ទៅសមុទ្រ។លោក Louis Malleret អ្នកប្រាជ្ញបារាំង បានធ្វើកំណាយផ្សេងៗក្នុងដែនដីសណ្ដទន្លេមេគង្គ ហើយបានរកឃើញរមណីយដ្ឋានអូរកែវ ដែលលោកចាត់ទុកថា ជាកំពង់ផែធំរបស់ហ្វូណន (ស្ថិតក្នុងខេត្តក្រមួនស )។ មតិខ្លះទៀតថា អូរកែវនេះជារាជធានីដើមបង្អស់របស់ហ្វូណន។

### ២.១.២ អរិយធម៌នាសម័យនគរភ្នំ

តាមដំណើរនៃប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញថា អាណាចក្រភ្នំបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌា ដូចជា ប្រជាជនគោរពសាសនាព្រាហ្មណ៍ ( គោរពព្រះមហេស្វរៈ " សិវៈ " ) គោរពពុទ្ធសាសនា ( តាមគម្ពីរបឋមសមន្តប្បាសាទិកា ឬគម្ពីរ មហាវង្ស ប្រភពមកពីកោះលង្កាជាសក្ខីភាពបញ្ជាក់ថា ព្រះពុទ្ធសាសនាបានចូលមកប្រទេសកម្ពុជាតាំងពីពុទ្ធសតវត្សទី៣។ បើតាមពាណិជ្ជករឥណ្ឌាម្នាក់ឈ្មោះ កៀ ស៊ាង លី (Kia. SeangLi) បានមកលក់ដូរដល់នគរភ្នំ ប្រហែលជាក្នុងពាក់កណ្ដាលគ្រិស្តសតវត្សទី២និយាយថា សម័យនគរភ្នំនេះចម្រើនរុងរឿងណាស់។

មនុស្សនៅអាណាចក្រភ្នំមានសម្បុរខ្មៅ សក់រួញ ប្រជុំភូមិមួយមានអណ្ដូងទឹកមួយរកស៊ីធ្វើស្រែចម្ការ ចេះត្បាញវវៃអំបោះសូត្រ ចេះសិល្បៈឆ្លាក់ក្បាច់រចនា ធ្វើចិញ្ចៀន កងដៃ កងជើង ខ្សែដៃ មានចានប្រាក់ ប្រើប្រាស់ គុជ គ្រឿងក្រអូប បង់ពន្ធដារ មានក្បួនតម្រា និងមន្ទីរឯកសារ។ ទំនៀមការកូនចៅ ឬបុណ្យខ្មោច ដូចនៅប្រទេស លិន យី ( ប្រទេសចម្ប៉ា)។ ទំនៀមកប់ខ្មោចមានបួនយ៉ាង គឺកប់ក្នុងដី ចោលក្នុងព្រៃស្មសាន ឱ្យសត្វស៊ី ទម្លាក់ចោលក្នុងទឹក និងបូជា។

សង្គម « មេនិយម » គឺគេចាត់ទុកនារីជាធំក្នុងគ្រួសារផង ក្នុងសង្គមផង ដូចជាព្រះនាង លីវ យី បានលើកកងទ័ពទៅតទល់នឹងសត្រូវ ( ព្រះបាទ ហ៊ុន ទៀន ) នេះជាភស្តុតាងមួយយ៉ាងជាក់ស្តែង។ មនុស្សនាសម័យនោះមានគំនិតទៀងត្រង់ណាស់ ហើយប៉ិនប្រសប់នៅពេលទំនេរពីការងារគេចូលចិត្តលេងល្បែងប្រជល់មាន់ ជ្រូក។

ក្នុងវិស័យស្ថាបត្យកម្ម ប្រាសាទបុរាណទាំងឡាយ សុទ្ធសឹងកសាងពីឥដ្ឋ។ ហេតុនេះទើបពុំមានប្រាសាទបុរាណនាសម័យនោះណាមួយ អាចនៅស្ថិតស្ថេរហូតដល់សព្វថ្ងៃនេះក្រៅពីប្រាសាទ ដែលគេកសាងនឹងជញ្ជាំងភ្នំតែម្តង។ សិល្បៈបដិមា គេបានរកឃើញទេវរូប និងពុទ្ធរូបជាច្រើននៅតំបន់ភ្នំដា ស្រុកព្រៃកប្បាសខេត្តតាកែវ។ សរុបមកសម័យនគរភ្នំបានកសាងអរិយធម៌មួយដ៏ត្រចះត្រចង់ ហើយមានលក្ខណៈខ្ពង់ខ្ពស់ជាងអរិយធម៌ជនជាតិប្រទេសជិតខាងក្នុងសម័យជាមួយគ្នា។ អរិយធម៌សម័យនគរភ្នំ គឺជាមរតកយ៉ាងសំខាន់សម្រាប់កូនចៅជំនាន់ក្រោយៗ ដែលមានគំនិតយកទៅកែច្នៃ ដើម្បីបង្កើតជាអរិយធម៌មួយរុងរឿងដូចសម័យអង្គរជាដើម។

### ២.១.៣ ព្រះមហាក្សត្រនាសម័យនគរភ្នំ

តាមរាជទូតចិនពីររូប គឺលោក កាំង ថៃ ( Kang Thai ) និងលោក ជូ យីង ( Tchou Ying ) បានឱ្យដឹងថានៅប្រទេសនគរភ្នំមានទំនៀមព្រះរាជិនីជាស្ដេចសោយរាជ្យមួយអង្គគឺព្រះនាម លីវ យី មានព្រះរូបឆោមលោមពណ៌ល្អល្អះដូចព្រះរាជកុមារ ហើយមានព្រាហ្មណ៍ម្នាក់ឈ្មោះ ហ៊ុន ទៀន បានផ្ទួសរមួយ ដែល

ទេវតាប្រទានក៏ចុះសំពៅមកកាន់ប្រទេសនគរភ្នំ។ ព្រះនាង លីវ យី លើករបេហ៍ពលទៅច្បាំងតតាំងនឹងព្រាហ្មណ៍ ហ៊ុន ទៀននោះ តែខ្លបខ្លាចចេស្តាក៏ទទួលយកជាស្វាមី។ រឿងព្រះបាទ ហ៊ុន ទៀន និងព្រះនាង លីវ យី នេះ ជាបឋមក្សត្រខ្មែរខាងសោមវង្ស។ ព្រះបាទ ហ៊ុន ទៀន និងព្រះនាង លីវ យី តាមឯកសារចិននេះ ឆ្លើយត្រូវគ្នានឹងសិលាចារឹកនៅមីសឺង ( Myson ) ក្នុងគ្រិស្តសករាជ ៦៥៨ និយាយថា ព្រះបាទ កៅណ្ឌិន្យ បានប្រតិស្ឋានលំពែង ដែលទ្រង់បានពីអស្វត្ថាម័ន ជាបុត្រទ្រោណៈ មកតម្កល់ទុកនៅក្រុងភវបុរៈ បានព្រះនាង នាគីសោមា ជាអគ្គមហេសី ហើយតាំងនៅជារាជវង្សនៃប្រទេសនេះឡើង។ សិលាចារឹកនៅប្រាសាទបក្សីចាំក្រុងគ្រិស្តសករាជ ៩៤៨ ចែងថា៖ ព្រះបាទរុទ្រវរ្ម័ន ដែលជាព្រះរាជាចុងក្រោយ នៃសម័យនគរភ្នំ នោះជាព្រះរាជាតពីសន្តតិវង្សព្រះបាទ កៅណ្ឌិន្យ និងព្រះនាង នាគីសោមា។ ឯកសារចិនបានបញ្ជាក់ទៀតថា ព្រះបាទ ហ៊ុន ទៀន និងព្រះនាង លីវ យី មានព្រះរាជបុត្រមួយព្រះអង្គ ហើយតែងតាំងឱ្យត្រួតត្រាប្រទេសសមន្តរាជ ។

ចំណោរតមកមានព្រះរាជាតំណវង្សមួយព្រះអង្គព្រះនាម ហួន-ហ្វាន់-ហ្វាង(Houen-Phan-Houang) សោយរាជ្យបន្ត ហើយព្រះអង្គសោយទិវង្គតក្នុងព្រះជន្មាយុ៩០ព្រះវស្សា ហើយព្រះរាជបុត្រព្រះអង្គព្រះនាម ហ្វាន់-ហ្វាន់(Phan-Phan)ឡើងសោយរាជ្យ ហើយទ្រង់តែងតាំងឧត្តមសេនីយ៍ម្នាក់ឈ្មោះ ហ្វាន់ ចេម៉ាន់ ឬហ្វាន់ ម៉ុន ឱ្យសម្រេចកិច្ចការព្រះរាជភារៈថ្វាយ។ បីឆ្នាំក្រោយព្រះបាទ ហ្វាន់ ហ្វាន់ ទ្រង់សោយទិវង្គត ទើបអ្នកនគរលើកឧត្តមសេនីយ៍ ហ្វាន់ម៉ុន ឬហ្វាន់ ចេម៉ាន់ ( ស្រីមារៈ) ឡើងសោយរាជ្យ។ ព្រះបាទ ហ្វាន់ចេម៉ាន់ ទ្រង់បានឋានៈជាមហារាជាធិរាជនៃប្រទេសនគរភ្នំ ហើយវាយយកប្រទេសជិតខាងឱ្យចុះចូលព្រះអង្គទាំងអស់មកជាចំណុះ។ ទ្រង់មានព្រះរាជបំណងនឹងលើករបេហ៍ពលទៅច្បាំងយករាជអាណាចក្រ គិន លិន(Kin Lin) «ព្រំដែនមាស » ទៀតតែអនិច្ចាទ្រង់ព្រះឈួន ហើយទ្រង់ទិវង្គតក្នុងឱកាសនោះទៅ (សិលាចារឹកវ៉ូកាញ់នៅខេត្តញ៉ាត្រាងនេះមានចែងពីព្រះរាជវង្ស គ្រីមារៈ ឬស្រីមារៈ។ សម័យដ៏រុងរឿងបំផុតនៃប្រវត្តិអាណាចក្រភ្នំ ឬអាណាចក្រហ្វូណន (The Kingdom of Funan) គឺស្ថិតក្នុងរជ្ជកាលព្រះបាទកៅណ្ឌិន្យវរ្ម័ន (៤៧៨ – ៥១៤ នៃគ.ស. ) (សិលាចារឹកប្រាសាទប្រាំងល្វែង នៅស្រុកទឹកខ្មៅ និងសិលាចារឹកអ្នកតាដំបងដែកក្នុងខេត្តតាកែវ សុទ្ធតែបានថ្លែងពីព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន)។ ព្រះបាទ រុទ្រវរ្ម័ន ទ្រង់សោយរាជ្យនៅ គ.ស.៥១៤ គឺឆ្នាំដែលព្រះវរបិតាទ្រង់ទិវង្គត។ ក្នុងរជ្ជកាលព្រះអង្គព្រះពុទ្ធសាសនារីកចម្រើន។ ព្រះបាទ រុទ្រវរ្ម័ន ប្រហែលជាទ្រង់ទិវង្គតរវាងគ.ស.៥៤០។

### ២.១.៤.អក្សរសិល្ប៍នាសម័យនគរភ្នំ

មុននឹងសិក្សាអក្សរសិល្ប៍ គប្បីដឹងនិងស្គាល់នូវលក្ខណៈវិវត្តន៍នៃអក្សរខ្មែរយើងតាំងពីបុរាណរហូតមកដល់បច្ចុប្បន្ន។ តាមការសិក្សារបស់លោក Georges Maspéro ក្នុងសៀវភៅលោកឈ្មោះ « Grammaire de Langue Khmère » Paris 1915 អក្សរខ្មែរតាំងពីកកើតមកទល់បច្ចុប្បន្នកាលនេះ មានការផ្លាស់ប្តូរលក្ខណៈរូបចំនួន១០លើក ហើយក្នុងមួយលើកៗមានលក្ខណៈរូប ឈ្មោះ ជំនាន់ និង ឆ្នាំដូចខាងក្រោម ៖

- លក្ខណៈទី១៖ អក្សរបែបសិលាចារឹក ហាន់ជ័យ ( ប្រមាណ ស.វទី៦ នៃគ.ស)
- លក្ខណៈទី២៖ អក្សរបែបសិលាចារឹក វាលកន្តែល(ប្រមាណចុងស.វទី៦ ឬដើមស.វទី៧ នៃគ.ស)
- លក្ខណៈទី៣៖ អក្សរបែបសិលាចារឹក អង្គជំនីក (ក្តីអង្គរ) ក្នុងឆ្នាំគ.ស៦៦៧

- លក្ខណៈទី៤៖ អក្សរបែបសិលាចារឹក ព្រះឥន្ទកោសីយ ក្នុងគ.ស៩៧០
- លក្ខណៈទី៥៖ អក្សរបែបសិលាចារឹក ព្រះកែវ ឬតាកែវ  ក្នុងគ.ស១០០២
- លក្ខណៈទី៦៖ អក្សរបែបសិលាចារឹក ព្រះនក ក្នុងគ.ស១០៦៦
- លក្ខណៈទី៧៖ អក្សរបែបសិលាចារឹក បន្ទាយឆ្មា ក្នុងស.វទី១២ ឬដើមស.វទី១៣ នៃគ.ស
- លក្ខណៈទី៨៖ អក្សរបែបសិលាចារឹក អង្គរវត្ត ក្នុងស.វទី១៣ នៃគ.ស
- លក្ខណៈទី៩៖ អក្សរបែបមហាសិលាចារឹកអង្គរ ក្នុងឆ្នាំ១៧០២ នៃគ.ស
- លក្ខណៈទី១០៖ អក្សរបែបបច្ចុប្បន្ន។



( Extrait de la Grammaire Cambodgienne de G. MASPERO, Paris 1.915 )

តាមការសង្កេតទូទៅ កាលពីសម័យដើម បុព្វបុរសយើងបានសរសេរឯកសារទាំងឡាយលើស្បែកសត្វ ដោយប្រើជីសបំពង តែឯកសារទាំងនោះ មិនអាចទ្រាំទ្រនឹងអាកាសធាតុ ឬក៏ត្រូវបំផ្លាញដោយសត្វល្អិតមានកណ្តៀរជាដើម។ ហេតុនេះហើយបានជាបុព្វបុរសយើងមានគំនិតច្នៃប្រឌិតគួបផ្សំនឹង ទេពកោសល្យបានប្រើមធ្យោបាយថ្មីមួយទៀតគឺសរសេរ ឬចារលើផ្ទាំងថ្មដែលគេហៅថា **សិលាចារឹក ឬអក្សរថ្ម**។ សិលាចារឹកនេះបានបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះ ជាកេរមរតកសម្រាប់ខេមរជនជំនាន់ក្រោយៗបានស្គាល់ពីអ្វីដែលជាអតីតកាល។ អ្នកប្រាជ្ញបស្ចឹមប្រទេសមានលោក Barth លោក Bergaigne លោក Louis Finot លោក Geores Coedés បានកត់សម្គាល់នូវសិលាចារឹកបួនកន្លែង ដែលទុកជាគោលនៃអក្សរថ្មគឺ៖

- សិលាចារឹកវ៉ូកាញ់ ខេត្តញ៉ាត្រាង ( វៀតណាមបច្ចុប្បន្ន )
- សិលាចារឹកអ្នកតាដំបងដែក ខេត្តតាកែវ
- សិលាចារឹកប្រាសាទប្រាំល្វែង ក្នុងស្រុកទឹកខ្មៅ ខេត្តព្រៃកប្បស្សី(កម្ពុជាក្រោម)
- សិលាចារឹកទន្លេបាទី ឬប្រាសាទតាព្រហ្ម ខេត្តតាកែវ

**ឧទាហរណ៍៖** សិលាចារឹកវ៉ូកាញ់ ជាសិលាចារឹកចាស់បរមបុរាណជាងគេបង្អស់នៅដែនដីអាស៊ីអាគ្នេយ៍នេះ។ អក្សរនៃសិលាចារឹកនេះ គេអាចប្រដូចទៅនឹងសិលាចារឹក រុទ្រាម៉ន នៅគីរមរ (Gimar) ឬសាតករ

ណិវាសិស្ឋីបុត្រ: ( Satakarni Vasisthiputra ) នៅកាន់ហេរី ( Kanheri ) ដែលនៅក្បែរទន្លេគោទាវរី និងទន្លេក្រឹស្នានៃប្រទេសឥណ្ឌា ទក្ខិណទិស។ សិលាចារឹកនេះ ថ្លែងពីព្រះបាទ ស្រីមារ:(ហ្វាន់ ចេម៉ាន់) ថាទ្រង់មានព្រះទ័យជ្រះថ្លាចំពោះពុទ្ធសាសនា។ សេចក្ដីជ្រះថ្លានេះ ប្រាកដដូចជាសេចក្ដីជ្រះថ្លានៅក្នុងសិលាចារឹកជាព្រះរាជប្រកាសព្រះបាទធម្មាសោកមហារាជប្រទេសឥណ្ឌាដែរ ហើយគេបានរកឃើញនៅស្រុកវ៉ូ កាញ់ (Vo Canh) ខេត្តញ៉ាត្រាង ។

តាមទស្សនៈលោក Barth និងលោក Bergaigue បានសន្មតថា អក្សរសិលាចារឹកវ៉ូកាញ់ នេះទំនងជាក្នុងគ្រិស្តសតវត្សទី៣ ឬទី២ ទៀតផង។

**អត្ថបទដើម**

….. ប្រជានំ ….. ប្រថមវិជយ ……. ណ្ឋិមស្យាម ។ អាជ្ញាបិតំ សទសិ រាជវរេណ ….. រាជគណ ….. វាគម្ឋតំបិពន្ទ ក្រីមារ ……. រាជកុល ….. ដ ….. ន ក្រីមារ ….. លោ ….. ន កុលនន្ទនេន | អាជ្ញាបិតំ ស្វជន ….. ស ….. មទ្បៀ វាក្យំ ប្រជាហិតករំ ករិណោរ្វិរេណ |លោកស្យាស្យ គតាគតិ វិ ….. ន សិង្ហាសនាទ្បាសីនេន បុត្រេក្រាតរិ នាន្តកេ ស្វសមីករណធន្ទេន តូប្តេមុ យតិកិញ្ចិទ្រជតំ សុវណ្ណិមបិ រ៉ាសស្ថាវរញ្ជង្គមំ កោដ្ឋាគារិក ….. នំ ប្រិយហិតេ សរ្វំ វិស្ឋម្ពំ មយា តទេវំ មយានុជ្ញាតំ ភវិស្សេរបិ រាជភិរនុមន្តវ្យំ វិទិតមស្តុច មេ ភូត្យស្យ វិរស្យ……។

**សេចក្ដីប្រែ**

"….. សេចក្ដីករុណាចំពោះសព្វសត្វទាំងឡាយ ……. ប្រថមជ័យ ……… ថ្ងៃពេញបុណ្ណមី ( ? ) ព្រះវររាជាទ្រង់បានប្រកាសក្នុងរាជសភាថា ចូរប្រជាជនក្រេបផឹកនូវទឹកអម្រឹត ពោលគឺព្រះរាជបន្ទូល ព្រះបាទ ……… ជាវង្សនៃព្រះបាទ ស្រីមារ: ទ្រង់បានជាកិត្តិយសនៃរាជវង្សស្រីមារ: ទ្រង់បានប្រកាសក្នុងកណ្ដាលជំនុំជន នូវព្រះរាជបន្ទូលសូរសីហនាទ ជាប្រយោជន៍ដល់ប្រជាជនទាំងឡាយ ទ្រង់ជាករិណទាំងពីរដ៏ប្រសើរ ទ្រង់ប្រថាប់លើសិង្ហាសនៈ ( ព្រះរាជបល្លង្កស្វេតឆ័ត្រ ? ) ហើយទ្រង់ឈ្វេងយល់នូវគតាគតិគឺ ការអន្ទោលស្លាប់កើតនៃមនុស្សលោក ទើបត្រាស់ថាកាលបើកូនខ្ញុំក្ដី បងប្អូនខ្ញុំក្ដី មិនមែនអ្នកកន្សៀតទេ បានសម្រេចបំណងខ្លួនហើយ (បានសោយរាជ្យតទៅ?) ( ខ្ញុំសូមឱ្យយក ) សម្បត្តិខ្ញុំទាំងអស់ប្រាក់មាសសង្ហារិមក្ដី អសង្ហារិមក្ដី ទៅប្រើជាវត្ថុសម្រាប់ជាទីរីករាយ និងជាប្រយោជន៍ដល់សត្វលោកទាំងឡាយ។ នេះជាសេចក្ដីបញ្ជារបស់ខ្ញុំ។

សូមព្រះរាជាទាំងឡាយនៅក្នុងអនាគតប្រតិបត្តិតាមបញ្ជាខ្ញុំនេះកុំបីខាន។ ហើយចូរប្រឹក្សាជាមួយសេវតាមាត្យឈ្មោះវិរ ………… របស់ខ្ញុំ។ "

* សិលាចារឹកនេះ ទុកជាសក្ខីភាពគឺជាឯកសារផ្ទៀងផ្ទាត់បញ្ជាក់ថា ប្រទេសនគរភ្នំកាន់ពុទ្ធសាសនាពិសេសក្នុងរជ្ជកាលព្រះបាទស្រីមារ: ។

**អត្ថន័យនៃអត្ថបទសិលាចារឹក៖**

**អត្ថបទសិលាចារឹកវ៉ូកាញ់** បំណងរបស់អ្នកកត់ត្រា គឺបង្ហាញពីព្រះមហាក្សត្រនៃសម័យកាលដែលទ្រង់សព្វព្រះរាជហឫទ័យ ចំពោះជំនឿក្នុងព្រះពុទ្ធសាសនា ដូចព្រះរាជប្រកាសរបស់ព្រះបាទ ស្រីមារ: ដែលចែងអំពីការអន្ទោលកើតស្លាប់នៃមនុស្សលោក។

អត្ថបទសិលាចារឹកនៅអ្នកតាដំបងដែក បានបញ្ជាក់អំពីទឹកព្រះទ័យរបស់ព្រះមហាក្សត្រ ជឿជាក់ចំពោះគុណធម៌នៃព្រហ្មញ្ញសាសនា។ សិលាចារឹកនេះបញ្ជាក់ថាព្រះអគ្គមហេសី ព្រះបាទកៅណ្ឌិន្យ ជ័យវរ្ម័ននាមព្រះ នាង កុលប្រភាវតី ដែលពេញព្រះទ័យចេញចាកលោក ទ្រង់ក៏បានសាង ទេវាល័យ តម្កល់បដិមាករព្រះវិស្ណុធ្វើអំពីមាសសុទ្ធ ហើយព្រះនាងចាត់ឱ្យសាងលំនៅសម្រាប់ព្រាហ្មណ៍ព្រមទាំង ជីកស្រះជាគុណប្រយោជន៍ចំពោះប្រជារាស្ត្រ។ ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន សោយទិវង្គតនៅគ.ស.៥១៤។

**អត្ថបទសិលាចារឹកប្រាសាទប្រាំល្វែង** បានបញ្ជាក់អំពីព្រះរាជបុត្រព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន និងព្រះនាងកុលប្រភាវតី ព្រះនាមព្រះរាជកុមារគុណវរ្ម័ន ដែលត្រូវបានព្រះរាជបិតាតែងតាំងទ្រង់ឱ្យត្រួតត្រាស្រុកទឹកខ្មៅ ខេត្តព្រៃកប្បស្សី ហៅ ( ទីទឹកភក់ ) ក្នុងទឹកដីកម្ពុជាក្រោម។

**អត្ថបទសិលាចារឹកនៅប្រាសាទតាព្រហ្ម** ទន្លេបាទី ក្នុងខេត្តតាកែវ បានបញ្ជាក់ថាព្រះបាទរុទ្រវរ្ម័នជាព្រះរាជបុត្រព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន ( ព្រះបាទរុទ្រវរ្ម័ន ទ្រង់ឡើងសោយរាជ្យ តពីសន្តតិវង្សព្រះបាទកៅណ្ឌិន្យ ជ័យវរ្ម័នជាព្រះរាជបិតាមក។ ទ្រង់ឡើងសោយរាជ្យក្នុងគ.ស.៥១៤ គឺឆ្នាំដែលព្រះរាជបិតាទ្រង់សោយទិវង្គត។) ព្រះរាជាអង្គនេះគោរពបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ។ ក្នុងរជ្ជកាលព្រះបាទ កៅណ្ឌិន្យជ័យវរ្ម័ន និងព្រះបាទរុទ្រវរ្ម័ន កើតមានពុទ្ធរូបច្រើនអង្គធ្វើពីថ្មសំរិទ្ធ ឬពីឈើ ជាការរចនាខ្មែរបែបអមរាវតី គុប្តៈគន្ធារៈ មថុរា ឬអជន្តា។ ព្រះពុទ្ធរូបដែលជាការរចនាបែបភ្នំដានេះ ឃើញមាននៅពីរមណ្ឌល មួយនៅអង្គរបុរីនិងនៅទីជិតខាង ទីនោះមានព្រះពុទ្ធរូបធ្វើពីថ្មចាស់ជាងគេបំផុតនៅអាស៊ីភាគអាគ្នេយ៍ និងពីរនៅត្រពាំងវែងខាងត្បូងខេត្តព្រះត្រពាំង មានព្រះពុទ្ធរូបបុរាណ។

នៅបុរាណដ្ឋាន អុក កែវ សម័យនគរភ្នំ លោក ល ម៉ាល្លឺរេត៍ (L. Malleret) បានរកឃើញព្រះពុទ្ធរូបបុរាណធ្វើពីសំរិទ្ធច្រើនព្រះអង្គ ការរចនាបែបគន្ធារៈ និងអមរាវតី។

**អំពីអត្ថរសនៃអត្ថបទសិលាចារឹក**

តម្លៃជាមូលដ្ឋាននៃអត្ថបទសិលាចារឹក គឺស្ថិតនៅលើសង្គមរស ព្រោះអត្ថបទបានបង្ហាញឱ្យឃើញនូវការរស់នៅ ឬវិបត្តិនានាដែលមនុស្សជាតិក្នុងសម័យកាលនោះបានជួបប្រទះ។ ម្យ៉ាងទៀត អ្នកសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រអាចយកសិលាចារឹកមកធ្វើជាសេចក្ដីសិក្សាស្រាវជ្រាវ ពិនិត្យអំពីជីវភាពការរស់នៅរបស់ខ្មែរកាលនោះ។

**យោបល់៖** សិលាចារឹកសម័យនគរភ្នំ ឬសម័យហ្វូណាន ជាអត្ថបទអក្សរសាស្ត្រដ៏ចំណាស់មួយ ហើយមានប្រយោជន៍សំខាន់ ដែលធ្វើឱ្យខេមរជនប្រុសស្រីជំនាន់ក្រោយបានយល់ បានដឹងនូវវប្បធម៌ អរិយធម៌ខ្មែរដែលប្រជាជនខ្មែរបានរក្សា ទ្រទ្រង់ ពង្រីក តាំងពីបុរាណកាលមកម្ល៉េះ។ ម្យ៉ាងទៀត ទោះបីមានឯកសារតិចតួចក៏ដោយ ក៏វាជាទុនមួយសំខាន់សម្រាប់ឱ្យអ្នកសិក្សាជំនាន់ក្រោយបានស្គាល់ពីវិវត្តន៍ខាងសង្គមកិច្ចនៃសង្គមខ្មែរពីបុរាណ។

## ២.២ អក្សរសិល្ប៍សម័យចេនឡា ( គ.ស.៥៥០ ដល់គ.ស.៨០២ )

### ២.២.១ សង្គមប្រវត្តិ

តើពាក្យថា ចេនឡា មានន័យថាដូចម្តេច?

ចេនឡា ជាឈ្មោះប្រទេសកម្ពុជាយើង ដែលប្រវត្តិវិទូតែងតែហៅជាផ្លូវការចាប់ពីគ្រិស្តសតវត្សទី៦ រហូតមកដល់ដើមសតវត្សទី៩ បន្ទាប់ពីនគរភ្នំ ឬហ្វូណន។

ចំពោះបញ្ហាឈ្មោះចេនឡានេះអ្នកសិក្សាជាច្រើនបានឱ្យយោបល់ផ្សេងៗពីគ្នាដូចខាងក្រោមនេះ៖

- ទស្សនៈលោក Paul Pelliot អ្នកប្រាជ្ញរូបនេះយល់ថា ពាក្យចេនឡា ទំនងជាបានកើតឡើងដោយការផ្សំពាក្យ«ចិន» និងពាក្យ «រាប»**= ចិន + រាប =ចិនរាប** អ្នកដែលគាំទ្រសម្មតិកម្មនេះបានពន្យល់ថា ពួកខ្មែរចេនឡា ដែលមានព្រំប្រទល់នៅជាប់នឹងអាណាខេត្តចិន នៅតំបន់ឥណ្ឌូចិនខាងជើង ប្រហែលជាធ្លាប់មានជម្លោះនឹងចិនហើយធ្លាប់បានទទួលជោគជ័យលើជនជាតិចិននេះឯង ក៏បានដាក់ឈ្មោះកន្លែងនោះថា(ចិនរាបៗទៅ) ហើយដែលចិនថាគ្រាប់តាមខ្មែរមិនច្បាស់ក្លាយជាចេនឡាវិញ។
- **ទស្សនៈលោក កេង វ៉ាន់សាក់** មានគំនិតប្រហាក់ប្រហែលនឹងគំនិតខាងលើ តែលោកយល់ថាពាក្យចេនឡា ក្លាយមកពីពាក្យ (ចិន និងលា)ទៅវិញ ចិន+លា = ចិនឡា។ ក្នុងសម័យប្រជុំពេញអង្គ ក្រុមប្រឹក្សារាជាណាចក្រ( ព្រឹទ្ធសភា) ស្តីពីការបង្កើតវិទ្យាស្ថានខ្មែរ មន-កាលពីថ្ងៃទី១៦០២-១៩៧០ លោក កេង- វ៉ាន់សាក់ បានថ្លែងបំភ្លឺអង្គប្រជុំថាដោយហេតុតែជនជាតិចិនមិនអាចទៅត្រួតត្រាកន្លែងនោះបាន ក៏ដកថយទៅវិញ ឬ(លា) ទៅវិញទើបមានឈ្មោះថា(ចិនលា)ដូច្នេះ។
- **ទស្សនៈលោក លី ធាមតេង** ក្នុងសៀវភៅ( កំណត់ហេតុរបស់ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុក ចេនឡា) បោះពុម្ពផ្សាយនៅភ្នំពេញឆ្នាំ១៩៧២ ទំព័រ៧៤-៧៩ លោក លី ធាមតេង បានសរសេរថា៖ "កាល ខ្ញុំទៅស្រុកចិនជួបនឹងអ្នកស្រាវជ្រាវចិនម្នាក់ឈ្មោះ ស៊ីវ ម៉េង គាត់បានប្រាប់ខ្ញុំថាគាត់ឃើញឯកសារមួយនិយាយពីឈ្មោះ ចេនឡា នេះ។ ពីដើមឡើយ ហៅប្រទេសមួយ ដែលស្ថិតនៅខាងលើប្រទេសហ្វូណន។ ប្រទេសនេះ មានព្រៃក្រាស់ណាស់ហើយសំបូរឃ្មុំយកក្រមួនធ្វើទៀន។ ពួកចិនតែងធ្វើដំណើរតាមសំពៅមកទិញដូរយកក្រមួនសុទ្ធ គឺក្រមួនពីឃ្មុំដើម្បីយកទៅលក់ឯស្រុកគេសម្រាប់ធ្វើទៀន ហើយគេនាំគ្នាសន្មតហៅស្រុកនេះថាក្រមួនសុទ្ធៗ គឺថា ចេន ឬចេង ប្រែថាសុទ្ធ ឯពាក្យ ឡា ឬឡាក់ ប្រែថា ក្រមួន ឬឃ្មុំ ឬទៀន ភាសាចិនគេយកគុណនាមមុខនាម បូករួមមកបានន័យថា ស្រុកក្រមួនសុទ្ធ"។
- **ទស្សនៈលោក ពៅឈិន**ក្នុងសៀវភៅ(អរិយធម៌ខ្មែរមន)ទំព័រ ៣២-៣៣ លោកបានសរសេរថា កាលនោះពុំទាន់មានស្តេចទេ គឺមានតែជាកុលសម្ពន្ធធំៗគឺមនមួយ និងខមមួយប៉ុណ្ណោះឯង។ ជាតិកុលសម្ព័ន្ធមននៅមាត់ទន្លេមេណាម ក្នុងស្រុកសៀមរហូតទៅដល់ខាងត្បូងប្រទេសភូមា ឯកុលសម្ព័ន្ធខម នៅចាប់តាំងពីស្រុកបាភ្នំ។ ស្រីអាយុធ្យា និងនៅលើដីកោះគោកធ្លក តាមជួរភ្នំដងរែករហូតដល់ប្រទេសចិន ទើបមានឈ្មោះថា ចិនឡា។
- **តាមទស្សនៈលោក អ៊ូរ ប៊ុន ( OU PON )** បានលើកហេតុមកបង្ហាញថាពាក្យខ្មែរដែលមានអក្ខរាវិរុទ្ធ និងសូរសព្ទស្រដៀង ឬដូចគ្នានឹងពាក្យ ជលសា៖

- ជលសា ឬជន្លា ជាភាសានិយាយនៃពាក្យ ទន្លា នៃអ្នកស្រុកព្រៃកប្បាស ខេត្តតាកែវ។ ទន្លា ជាឈើមួយប្រភេទ ក្នុងពពួកថ្វាន់ច្រើនដុះនៅក្នុងព្រៃរនាម មាត់បឹង មាត់ស្ទឹង ។ល។
- ជលា ឬជល ដែលក្លាយមកពីភាសាបាលីថា( ជះ) និងពីសំស្រ្កឹតថា ( ជះលះទះ ឬជះលះ ជះ) មានន័យថាទឹក។ គេអាចយក ជល ឬជលា ទៅផ្សំជាមួយពាក្យដទៃទៀតដូចជា+ អស្សុជល ឬជលនេត្រ = ទឹកភ្នែក

  + ជលដ្ឋាន = ទីដែលមានទឹក ដូចជាអណ្តូង ស្រះ ត្រពាំង

  + ជលសា ឬជលសាគរ = សមុទ្រ

  + រដ្ឋជលា ប្រទេសជលា ជលរដ្ឋ = រដ្ឋទឹក ប្រទេសទឹក ប្រទេសសម្បូរដោយទឹក។ ក្នុងចំណោមពាក្យខ្មែរទាំងពីរម៉ាត់ (ជលា ឬជន្លា) ដែលជាឈ្មោះដើមឈើ និង (ជល ឬជលា) ដែលមានន័យថាទឹកនោះ ពាក្យទី២ មានភាពសក្តិសមល្មមរើសយកទៅធ្វើជាឈ្មោះប្រទេសខ្មែរបានគឺជលា។ តែបើតាមសិលាចារឹកខ្មែរនាសម័យបុរាណខ្មែរក៏ធ្លាប់បានប្រើពាក្យ(ជល ឬជលា) នេះដែរ។ ដូចមានពាក្យថា (ជលបុរៈ ឬជលបុរី) ដែលមានន័យថាបូរីទឹក ឬទីក្រុងទឹក។

### ២.២.២ ប្រវត្តិចេនឡា

ដើម្បីជាការងាយស្រួលក្នុងការយល់ចងចាំ គេបាននាំគ្នាសន្មតយកឈ្មោះចេនឡា ( ជាឈ្មោះចិនធ្លាប់ហៅទឹកដីខ្មែរផ្នែកខាងជើងជួរភ្នំដងរែក )។ នគរខ្មែរខាងជើង គឺចេនឡាដីគោក ឯនគរខ្មែរខាងត្បូងគឺចេនឡាទឹកលិច។

- **ចេនឡាដីគោក៖** ដោយគ្មានឯកសារប្រវត្តិសាស្រ្តប្រាកដ ដើម្បីបញ្ជាក់ដែនដីគោកគឺ ស្ថិតក្នុងភាពងងឹតអាថ៌កំបាំង។ អ្នកប្រវត្តិវិទូបានសន្មតថាទឹកដីចេនឡាដីគោកមានប្រវត្តិជាប់ជំពាក់ជាមួយនឹងប្រវត្តិសាស្រ្ត និងព្រឹត្តិការណ៍តូចធំនៃប្រទេសឡាវបច្ចុប្បន្ន។ ម្យ៉ាងទៀតនាសម័យនោះ គេពុំបានឃើញ មានកំណត់អ្វីជាច្បាស់លាស់អំពីសំណាក់អ្នកដំណើរចិន ដែលបានទៅដល់ស្រុកខ្មែរឡើយ។ គេគ្រាន់តែដឹងថាព្រះមហាក្សត្រខ្មែរនៅតែរក្សាទំនាក់ទំនងផ្លូវទូតជាមួយនឹងប្រទេសចិន។
- **ចេនឡាទឹកលិច៖** រីឯចេនឡាទឹកលិចវិញ ត្រូវចែកចេញជានគរពីរដោយមានព្រះរាជធានីពីរ អនិន្ទិតបុរៈ(ពុំស្គាល់ទីកន្លែងពិតប្រាកដ) និងសម្ភុបុរៈ ដែលនៅសំបូណ៌ លើត្រើយទន្លេមេគង្គ ក្នុងខេត្តក្រចេះ។ ព្រះរាជវង្សដែលគ្រប់គ្រងទីក្រុងអនិន្ទិតបុរៈ ប្រកាសបញ្ជាក់ថាខ្លួនជាពូជខ្សែស្រឡាយចុះពីព្រះបាទកៅណ្ឌិន និងព្រះនាង សោមា មកដល់ព្រះបាទ ***ភវវរ្ម័ន*** ដែលជាព្រះចៅ **ព្រះបាទរុទ្រវរ្ម័ន** ព្រះមាហាក្សត្រនគរហ្វូណន។ ចំណែកក្រុមព្រះមហាក្សត្រ ដែលគ្រប់គ្រងរស់នៅ**ទីក្រុងសម្ភុបុរះ** ប្រកាសថាជាប់ព្រះញាតិវង្សចុះមកពីព្រះមហាក្សត្រីយានីព្រះនាងជ័យទេវី។

**សង្កេត៖** តាមឯកសារចិនបានឱ្យដឹងថាអាណាចក្រចេនឡាស្ថិតនៅនិរតីប្រទេស លិន យី ហើយពីដើមជាសាមន្តរដ្ឋមួយរបស់អាណាចក្រភ្នំ ( មជ្ឈមណ្ឌលរបស់ចេនឡាសព្វថ្ងៃ )។ ឯសិលាចារឹកបក្សី

ចាំក្រុងសតវត្សទី១០ ក៏បានបញ្ជាក់ពីទីតាំងចេនឡានៅត្រង់បាសាក់ ហើយនិងបានបញ្ជាក់ថាកូនចៅឥសីកម្ពុ បានភ្ជាប់សូរ្យវង្ស ខាងចេនឡា ទៅនឹងសោមវង្ស ខាងអាណាចក្រភ្នំ។

ការបែងចែកប្រទេសចេនឡាជាពីរ នៅពេលដែលព្រះបាទជ័យវរ្ម័នទី១ សោយទិវង្គតដោយព្រះអង្គពុំមានបុត្រាទេ ទើបបុត្រីរបស់ព្រះអង្គនាម ជ័យទេវី ឡើងសោយរាជ្យស្នងបន្ត (គ.ស.៦៨១?)។ ព្រះនាងនៅគ្រប់គ្រងរដ្ឋរហូតដល់ឆ្នាំ៧១៣ តែអំណាចរបស់ព្រះនាងពុំមានមូលដ្ឋានមាំទាំឡើយ ព្រោះក្នុងអត្ថបទ សិលាចារឹកមួយនៅបារាយណ៍ទឹកថ្លា ព្រះនាងទ្រង់បានត្អូញត្អែរពី (ភាពច្របូកច្របល់ក្នុងចិត្តគំនិត និងពីទុក្ខវេទនាក្នុងគ្រាកើតកលិយុគ។ ភាពកំសោយនៃអំណាចកណ្តាលដែលស្ថិតនៅក្នុងកណ្តាប់ដៃស្ត្រីនេះហើយដែលជាបុព្វហេតុនៃការបែងចែកចេនឡា ( តាមឯកសារចិនចេនឡាចែកជាពីរនៅគ.ស.៧០៦ ? )។

នាសតវត្សទី៨ ជាសម័យមួយដែលគ្មានស្ថេរភាពខាងនយោបាយ ដោយមានការបែកបាក់សាមគ្គីផ្ទៃក្នុង( នាឆ្នាំ៧៧៤ និង៧៨៧ នៃគ.ស.ពួកជ្វាបានមករាតត្បាត និងត្រួតត្រាចេនឡាទឹកលិច។ (សូមអានបន្ថែមចំបាំងចេនឡា អាណាចក្រភ្នំក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់លោកស្រី ត្រឹង ងាទំព័រ១១២ ដល់១២៤)។

### ២.២.៣ អរិយធម៌ខ្មែរសម័យចេនឡា

ចំពោះសម័យចេនឡាក៏ដូចជាសម័យអាណាចក្រភ្នំដែរ ព័ត៌មានទាក់ទងនឹងវប្បធម៌អរិយធម៌ សុទ្ធតែបានមកពីប្រភពចិនស្ទើរតែទាំងអស់។ យើងបានពឹងផ្អែកទៅលើរាជពង្សាវតា ស៊ួ ( Souei ) ដែលបានកត់ត្រារឿងរ៉ាវទាក់ទងនឹងរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ ហើយដែលលោក មាំតួន លិន បានចម្លងដាក់ទាំងស្រុងក្នុងសៀវភៅ «ការសិក្សាពីប្រជារាស្ត្រក្រៅប្រទេសចិន» របស់លោកនាសតវត្សទី១៣។ ជីវភាពសង្គមនាសម័យចេនឡាមានដូចខាងក្រោម៖

- មនុស្សនាសម័យចេនឡាមានមាឌតូច ហើយសម្បុរខ្មៅ ដូចមនុស្សនាសម័យអាណាចក្រភ្នំ ប៉ុន្តែស្រីៗភាគច្រើនមានសម្បុរស។ មនុស្សទាំងប្រុសទាំងស្រី សុទ្ធតែបួងសក់ ហើយពាក់ការ ឬពាក់រយ៉ាថែមទៀត។ មនុស្សនាសម័យនោះ គេនិយមសង់ផ្ទះបែរមុខទៅទិសខាងកើតហើយចាត់ទុកថាដៃស្តាំមានភាពបរិសុទ្ធជាងដៃឆ្វេង ហើយនិយមងូតទឹកជម្រះកាយញឹកញាប់ណាស់ពិសេសរក្សាការពារធ្មេញដោយឧស្សាហ៍សម្អាត ( សុខភាពធ្មេញ )។
- មុនពេលបរិភោគអាហារម្តងៗ គេត្រូវអានគម្ពី រួចសូត្រធម៌ ហើយសម្អាតធ្មេញឱ្យស្អាតជានិច្ច។ ពេលបាយរួច គេសម្អាតធ្មេញ ហើយសូត្រធម៌( ពិធីនេះ គឺធ្វើតាមលទ្ធិព្រហ្មណ៍ )ទំនៀមទម្លាប់នេះ ច្រើនតែធ្វើចំពោះមនុស្សក្នុងវណ្ណៈខ្ពង់ខ្ពស់តែប៉ុណ្ណោះ ឯរាស្ត្រធម្មតានៅស្រែចំការ គឺពុំបានអនុវត្តន៍នូវទម្លាប់ខាងលើនេះឡើយ។
- ចំពោះទំនៀមភ្ជាប់គូវាសនា កូនកំលោះមិនចាំបាច់នាំបណ្ណាការអ្វីទៅឱ្យកូនក្រមុំទេ ក្រៅតែអំពីសំពត់អាវមួយហ៊ូ។ ក្នុងពិធីអាពាហ៍ពិពាហ៍អ្នកមហាមានភារៈជាអ្នកដឹកនាំកូនក្រមុំ។ គេរៀបពិធី៨ថ្ងៃ ដោយគ្រួសារទាំងពីរខាងលើស្ថិតនៅក្នុងផ្ទះដោយមិនចេញទៅណាឡើយ។ គេរៀបពិធីដោយរបៀបបង្វិលពពិលជុំវិញកូនប្រុសស្រី។ ពេលរៀបពិធីមង្គលរួច កូនកំលោះត្រូវទៅ

តាមកូនក្រមុំដើម្បីរួមរស់នៅក្នុងគេហដ្ឋានសង់ថ្មីផ្ទាល់ខ្លួន(គ្រួសារថ្មីនេះនាំយកអំណោយ និង ចំណងដៃផ្សេងៗ ដែលមាតាបិតាញាតិមិត្តឱ្យទៅទុកជាសម្បត្តិផ្ទាល់ខ្លួន)។ គេនិយមរាប់ញាតិ ដោយយកខ្សែតាមម្តាយ។

- នាសម័យចេនឡា កាលណាសមាជិកក្នុងគ្រួសារធ្វើមរណកាលទៅ គេមិនកោរសក់ទេ (គេទុកសក់ឱ្យវែង) កូនចៅត្រូវនាំគ្នាស្រែកយំទួញឱ្យឮៗ។ ក្រុមគ្រួសារសពដោយរួមនឹងភិក្ខុ ភិក្ខុនី បានធ្វើក្បួនដង្ហែដោយមានច្រៀងនិងលេងភ្លេងផង (ក្នុងពិធីបុណ្យសពកូនទាំងឡាយ របស់សពត្រូវអត់បាយរយៈពេល៧ថ្ងៃ)។ សាកសពយកទៅបូជា ហើយមានខ្លះទៀត គេយក សពទៅដាក់ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី។
- របៀបទទួលភ្ញៀវនាសម័យនោះ គឺទទួលភ្ញៀវដោយដាក់ម្លូ ស្លា ទឹកអប់ផ្សេងៗ ( គេមិនដែល ដាក់ស្រាទទួលភ្ញៀវទេ ពីព្រោះស្រាសម្រាប់តែផឹករួមក្នុងគ្រួសារតែប៉ុណ្ណោះ)។
- ទំនៀមក្នុងការសម្តែងគារវភាពចំពោះឥស្សរជនគឺគេត្រូវបែរខ្នង ក្នុងករណីដែលបានជួបប្រទះ (គេធ្វើយ៉ាងនេះគឺចៀសវាងកុំឱ្យអ្នកធំពិបាក ដោយសារឃើញអ្នកតូចតាច) ។ ម្យ៉ាងទៀត ទម្លាប់របស់អ្នកស្រុក ពេលទៅណាមកណាមានពាក់អាវក្រោះ និងកាន់អាវុធ ហើយបើកាល ណាមានរឿងបន្តិចបន្តួចគេក៏ប្រយុទ្ធបង្ហូរឈាមគ្នាភ្លាម។
- នៅចំពោះព្រះភក្ត្រព្រះរាជាពួកមន្ត្រីត្រូវធ្វើគារវកិច្ចដោយអោនក្បាលដល់ដីបីដង។ បើព្រះអង្គ ទ្រង់មានបន្ទូលហៅ ឬប្រើពួកមន្ត្រីត្រូវលត់ជង្គង់ លុះចប់កិច្ចហើយគេត្រូវលត់ជង្គង់សំពះសា ជាថ្មីមុននឹងត្រឡប់ទៅវិញ។ គេឃើញមានពលរេហ៍រាប់ពាន់អ្នកពាក់អាវក្រោះ កាន់លំពែងឈរ យាមគ្រប់ទីកន្លែងតាំងពីជុំវិញបល្លង្កហូតដល់ទ្វារទាំងឡាយ។ ឯសកម្មភាពសេដ្ឋកិច្ចគេឃើញ មាននយោបាយទឹកមានសភាពរីតតែប្រសើរឡើងថែមទៀត ជាហេតុធ្វើឱ្យវិស័យកសិកម្មរីក ចម្រើន ( ដំណាំស្រូវ) ។

## ៣.សន្និដ្ឋាន

បើទោះណាជាសម័យចេនឡាមានវិបត្តិផ្ទៃក្នុងជួររាជវង្សខ្លះៗយ៉ាងណាក៏ដោយ ក៏គេសង្កេតឃើញ ថាសម័យនេះ មានការរីកចម្រើនច្រើនឡើង ហើយជាពិសេសគេសង្កេតឃើញសិលាចារឹកដែលមានវ័យចំណាស់ ជាងគេនៅក្នុងសម័យកាលនោះគឺសិលាចារឹកអង្គរបុរី ដែលមានកាលបរិច្ឆេទ៦១១នៃគ.ស.។ សិលាចារឹក នេះបានសរសេរជាអក្សរខ្មែរបុរាណ ហើយកត់សូរជាភាសាខ្មែរដែលខុសពីសម័យមុន គឺសិលាចារឹកសរសេរ ជាអក្សរខ្មែរបុរាណតែកត់សូរជាភាសាសំស្ក្រឹត។ នេះជាការឆ្លុះបញ្ចាំងឱ្យឃើញការយកព្រះទ័យទុកដាក់របស់ ព្រះមហាក្សត្រខ្មែរពីជំនាន់មួយទៅជំនាន់មួយ ដែលបានខ្វល់ខ្វាយនិងគិតគូរដល់ប្រទេសជាតិខិតខំរើបម្រាស់ ដោយបង្កើតឱ្យមានតួអក្សររបស់ខ្លួន និងកត់សូរអានជាភាសាខ្លួនទៀតផង ដើម្បីយកមកប្រើប្រាស់នៅក្នុង សង្គមជាតិ។ តែទោះជាយ៉ាងណាភាសាសំស្ក្រឹតនៅក្នុងសម័យកាលនេះក៏នៅតែមានវត្តមាននៅឡើយទេ គ្រាន់តែខ្មែរយើងបានបង្កើតអត្តសញ្ញាណជាតិថ្មីមួយទៀតតែប៉ុណ្ណោះ។ នេះជាមោទនភាពមួយដែលមិនអាច

កាត់ថ្លៃបាន ហើយក៏ជាមរតកដ៏មានតម្លៃសម្រាប់កូនខ្មែរជំនាន់ក្រោយៗត្រូវតែចូលរួមថែរក្សា ការពារវប្បធម៌អក្សរសាស្ត្រខ្មែរឱ្យបានស្ថិតស្ថេរគង់វង្ស។

# អក្សរសិល្ប៍សម័យអង្គរ
# ( សតវត្សទី៩ ដល់សតវត្សទី១៥ )

## ១. វត្ថុបំណងមេរៀន

- បង្ហាញទិដ្ឋភាពទូទៅសម័យអង្គរបានត្រឹមត្រូវ តាមរយៈសំណួរបំផុស និងការយល់ដឹងរបស់ខ្លួន។
- ពន្យល់បកស្រាយផ្នែកនីមួយៗបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- បណ្ដុះស្មារតីឱ្យខិតខំសិក្សាស្រាវជ្រាវឈ្វេងយល់បន្ថែមទៀតពីសម័យអង្គរ។

## ២. ខ្លឹមសារមេរៀន

សម័យនោះអត្ថបទអក្សរសិល្ប៍នៅកត់ត្រាលើផ្ទាំងថ្មដដែល ដែលមានឈ្មោះថាសិលាចារឹក។ មានអត្ថបទខ្លះវែង ខ្លះខ្លីត្រឹមមួយបន្ទាត់ ឬពីរបន្ទាត់កត់ត្រានៅនឹងមេទ្វារ កម្រាលថ្ម ឬវត្ថុប្រើប្រាស់ផ្សេងៗទៀត។

គេបែងចែកអក្សរសិល្ប៍នាសម័យអង្គរជាបីផ្នែកដូចខាងក្រោម៖

- **ផ្នែកទី១ ( សតវត្សទី៩ ដល់១០ )៖** អត្ថបទភាគច្រើនជាភាសាសំស្ក្រឹតដែលបានសរសើរពីតេជៈបារមីនៃព្រះអាទិទេព និងពាក្យស្រុតិសុំពរជ័យពីព្រះអាទិត្យ។ ឯភាសាខ្មែរបុរាណវិញគេគ្រាន់តែកត់ត្រាក្នុងបញ្ជីឈ្មោះបន្តិចបន្តួចប៉ុណ្ណោះ។
- **ផ្នែកទី២ (សតវត្សទី១០ ដល់ទី១២)៖** ក្នុងរយៈកាលនេះ អក្សរសិល្ប៍រីកដុះដាលយ៉ាងខ្លាំង ដោយមហិទ្ធិឫទ្ធិរបស់ខ្មែរបានលាតសន្ធឹង ព្រំដែនរបស់ខ្លួនយ៉ាងទូលំទូលាយ។ អត្ថបទភាគច្រើនសរសេរនៅលើស្បែកសត្វលាបពណ៌ខ្មៅ ហើយឆ្លងពីក្រាំងស្បែកនេះទៅ គឺផ្ទាំងចម្លាក់រូបភាព។ អ្នកនិពន្ធភាគច្រើននិទានរឿងដែលទាក់ទងនឹងលទ្ធិសាសនាព្រាហ្មណ៍។
- **ផ្នែកទី៣ ( សតវត្សទី១៣ ដល់១៤ )៖** អក្សរសិល្ប៍បានថយចុះឥទ្ធិពលបន្តិច មូលហេតុមកពីសង្គ្រាមជាមួយប្រទេសជិតខាង ហើយពេលខ្លះសត្រូវលុកលុយដល់រាជធានីទៀតផង។

### ២.១ លក្ខណៈអក្សរសិល្ប៍

- **សិលាចារឹក៖** អក្សរដែលគេសរសេរនៅពេលនោះ គឺអក្សរសំស្ក្រឹតភាគច្រើន ឯអក្សរខ្មែរមានខ្លះដែរ។
- **អត្ថបទ៖** ច្រើនសរសេរនៅលើស្បែកសត្វស្ងួតលាបពណ៌ខ្មៅ ហើយក្រោយមកទៀតឃើញមានឆ្លាក់ជាផ្ទាំងរូបភាពនូវរឿងរ៉ាវផ្សេងៗ ដែលទាក់ទងនឹងអត្ថបទអក្សរសិល្ប៍។

### ២.២ គោលបញ្ញានៃអក្សរសិល្ប៍

មានលក្ខណៈជឿនលឿនងាកមករកមនុស្សនិយម ឯអត្ថន័យសំខាន់ៗគេឃើញមាន៖

- បង្ហាញនូវសេចក្ដីអង់អាចក្លាហានក្នុងសឹកសង្គ្រាម
- កិត្តិនាមរបស់វីរជនជាមេទ័ព

- បង្ហាញនូវសេចក្ដីរំភើបក្នុងជ័យជម្នះ
- ការរៀបចំជីវភាពក្នុងសង្គម នយោបាយ ទំនៀមទម្លាប់ប្រពៃណី
- ការរៀបចំកសាងប្រាសាទថ្មី និងទីក្រុងថ្មីៗបន្តទៀត។

## ២.៣ អត្ថរូបនៃអក្សរសិល្ប៍

- **សេចក្ដីផ្ដើម៖** បញ្ជាក់នាមអ្នកនិពន្ធកត់ត្រាសករាជ សរសើរគុណព្រះវិស្ណុ ព្រះឥសូរ ព្រះព្រហ្ម និងទេវរាជជាដើម។
- **តួសេចក្ដី៖** បង្ហាញពីបញ្ហាសំខាន់ៗ មានការគ្រប់គ្រងប្រទេស ជំនឿពិធីផ្សេងៗក្នុងសាសនាជាដើម។
- **បញ្ចប់សេចក្ដី៖** ភាគច្រើនបញ្ចប់ដោយឧទ្ទិសសុំមគ្គផលកុសលផលបុណ្យ ដែលបានមកពីការធ្វើកុសលនានា ឬគេដាក់បណ្ដាសាចំពោះអ្នកណាដែលបំផ្លាញទេវបូជា ឬអារាមដ្ឋានជាដើម។

## ២.៤ អ្នកនិពន្ធល្បីៗ និងស្នាដៃ

- **បណ្ឌិតសិវសោម៖** ជាអ្នកប្រាជ្ញមួយរូបក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី១។ បណ្ឌិតរូបនេះមានចំណេះដឹងខាងក្បួនច្បាប់ផ្សេងៗក្នុងអក្សរសាស្ត្រ និងមន្តវិជ្ជាគាថាខាងសាសនាព្រាហ្មណ៍។ លោកបាន និពន្ធរឿងមហាភារតយុទ្ធ និងក្បួនវេយ្យាករណ៍ ព្រមទាំងសិលាចារឹកនៅប្រាសាទកណ្ដោលដើម សិលាចារឹកពងកេងកងនៅគូលែន។
- **បណ្ឌិតយតិអមរភាវះ** ជាអ្នកប្រាជ្ញសំខាន់មួយរូបក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន។ ព្រះរាជាទ្រង់សព្វព្រះទ័យ តាំងបណ្ឌិតនេះជាអធិបតីនៃបណ្ឌិតទាំងឡាយ ហើយលើកឱ្យមានឋានន្តរសក្ដិជាសង្ឃរាជលើវត្តឥន្ទ្រាស្រម។ បណ្ឌិតនេះនិពន្ធសិលាចារឹកនៅភ្នំបាយ័ង្គ។
- **បណ្ឌិតទិវាករះ** ជាអ្នកប្រាជ្ញឯកក្នុងរជ្ជកាលព្រះបាទជិន្ទ្រវរ្ម័នទី១ បណ្ឌិតរូបនេះចេះចប់ត្រៃវេទស្ទាត់ ហើយត្រូវបានព្រះរាជាប្រទានព្រះរាជបុត្រីព្រះនាមឥន្ទ្រលក្ស្មីជាភរិយា។ គាត់បាននិពន្ធសិលាចារឹកនៅប្រាសាទកំភឹស ដែលសរសើរពីព្រះបារមីនៃព្រះបាទជយវរ្ម័នទី៥។
- **បណ្ឌិតកវិន្ទ្រះ** ជាអ្នកប្រាជ្ញយ៉ាងធំក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១។ បណ្ឌិតរូបនេះចេះចាំស្ទាត់នូវគម្ពីរក្បួនខ្នាតផ្សេងៗ ដោយមានឋានៈជាទីប្រឹក្សានៃព្រះមហាក្សត្រផ្ទាល់។ លោកបាននិពន្ធសិលាចារឹកនៅប្រាសាទខ្នារ សម្រាប់សរសើរនូវតេជៈបារមីរបស់ព្រះបាទសូរ្យវរ្ម័នជាក្សត្រសឹកដ៏ក្លាហានមោះមុតក្នុងចម្បាំង។
- **បណ្ឌិតភូបេន្ទ្រះ** ជាអ្នកប្រាជ្ញល្បីល្បាញក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី៧។ បណ្ឌិតរូបនេះត្រូវបានព្រះមហាក្សត្រតាំងជាអធិបតីលើគណៈអ្នកប្រាជ្ញ និងមាននាទីជាចៅក្រមល្បីល្បាញខាងចំណេះនីតិសាស្ត្រ។ លោកបាននិពន្ធសិលាចារឹកនៅប្រាសាទទរ សម្រាប់សរសើរព្រះកិត្តិគុណរបស់ព្រះបាទជយវរ្ម័នទី៧ ព្រមទាំងសមិទ្ធិផលធំៗជាស្នាព្រះហស្តនៃមហាវីរក្សត្រអង្គនេះ។

- **ព្រះនាងឥន្ទ្រទេវីៈ** ជាព្រះអគ្គមហេសីទី២នៃព្រះបាទជយវរ្ម័នទី៧ ជាអគ្គសាសនូបត្ថម្ភខាងព្រះពុទ្ធសាសនា ហើយបានកសាងវប្បធម៌អក្សរសាស្ត្រជាតិឱ្យរីកចម្រើនលូតលាស់ក្នុងសតវត្សទី១២ និងទី១៣ ដោយបានបង្កើតឱ្យមានសាលាបាលីជាន់ខ្ពស់ និងវង់ល្ខោនជាដើម។ ព្រះនាងបាននិពន្ធសិលាចារឹកនៅប្រាសាទភិមានអាកាស សរសើរអំពីព្រះទ័យបរិសុទ្ធមានកក្តីភាពរបស់ព្រះនាងជ័យរាជទេវី ជាព្រះរាជកនិដ្ឋា និងជាព្រះរាជអគ្គមហេសីទី១របស់ព្រះបាទជយវរ្ម័នទី៧ មុនព្រះនាងចូលទិវង្គត។
- **បណ្ឌិតយោគីស្វរៈ** ជាគ្រូរបស់ព្រះបាទសូរ្យវរ្ម័នទី១។ លោកបាននិពន្ធសិលាចារឹកនៅប្រាសាទតាកែវ ( សៀមរាប )។
- **បណ្ឌិតសិវាចារ្យៈ** អាអធិការត្រួតត្រាខាងសីលធម៌ក្នុងរជ្ជកាលជយវរ្ម័នទី៥ និងព្រះបាទសូរ្យវរ្ម័ន ទី១។ លោកបានតាក់តែងសិលាចារឹកជាភាសាសំស្ក្រឹតនៅប្រាសាទតាកែវផងដែរ ក្រៅពីនេះគេឃើញមានអត្ថបទរឿងរាមកេរ្តិ៍យកលំនាំតាមរឿងរាមាយណៈ សរសេរជាភាសាខ្មែរចម្រុះ ភាសាសំស្ក្រឹត ហើយនៅមានរឿងមួយទៀតដែលពុំសូវល្បីល្បាញ តែមានន័យទូលំទូលាយនោះ គឺសាស្ត្រាត្រៃភូមិដែលបាននិយាយពីគំនិតមនុស្សក្នុងសម័យដើម ( ការកកើតទឹកដី មនុស្ស សត្វ និងភពទាំងបី សួគ៌ នរក មនុស្ស )។

តាមការស្រាវជ្រាវ ខ្មែរមានប្រាសាទសង់អំពីថ្មចំនួន១០៨០ ហើយមានរូបចម្លាក់ទូទាំងប្រទេសចំនួន ២០៤០០។ ម្យ៉ាងទៀត នាសតវត្សទី១២ ខ្មែរមានមហាវិទ្យាល័យពីរគឺមហាវិទ្យាល័យបន្ទាយក្តី (តាព្រហ្ម?) និងព្រះខ័ន ហើយមានសាស្ត្រាចារ្យបណ្ឌិត ១៨រូប។

## ៣. សន្និដ្ឋាន

ដូចនេះ ដើម្បីស្គាល់អក្សរសិល្ប៍ខ្មែរនៅសម័យអង្គរបានយើងត្រូវរៀនឱ្យស្គាល់អក្សរសិល្ប៍ខ្មែរ នៅសម័យអង្គរឱ្យបានជ្រៅជ្រះឱ្យយល់អក្សរចារឹកថ្មទាំងអស់។ ថ្មមួយដុំៗនៅអង្គរមានពាក្យនិយាយប្រាប់យើងច្រើនណាស់ ខាងរបៀបតិចនិក ខាងរបៀបសិល្បៈ ខាងអក្សរសាស្ត្រ និងបានបញ្ជាក់ឱ្យយើងឃើញថា "វរ្ម័ន" ដែលជាជីដូនជីតាយើង ខំតស៊ូស្វិតស្វាញយ៉ាងអស្ចារ្យ។ យើងត្រូវប្តេជ្ញាការពារសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ ដើម្បីលម្អការរស់នៅរបស់យើងឱ្យមានសិល្បៈ អក្សរសាស្ត្រ យុត្តិធម៌ពិតប្រាកដ។

# អក្សរសិល្ប៍សម័យកណ្ដាល
# ( សតវត្សទី១៦ - សតវត្សទី១៩ )

## ១. វត្ថុបំណង

- រៀបរាប់បានពីអក្សរសិល្ប៍សម័យកណ្ដាលតាមរយៈសិលាចារឹក សង្គមប្រវត្តិ សេដ្ឋកិច្ច នយោបាយ។
- ប្រាប់បានពីភាពទូទៅ នៃអក្សរសិល្ប៍ អ្នកនិពន្ធនិងស្នាដៃអត្ថន័យនៃសិលាចារិកបានច្បាស់លាស់។
- បកស្រាយពីអត្ថន័យសិលាចារឹក ប្រវត្តិសាស្ត្រសង្គម សេដ្ឋកិច្ច នយោបាយ។
- មានស្មារតីស្រឡាញ់ ថែរក្សា អក្សរសិល្ប៍ជាតិ។

## ២. ខ្លឹមសារមេរៀន

អក្សរសិល្ប៍សម័យកណ្ដាលគិតចាប់ពីឆ្នាំ១៤៣១ ពេលដែលរាជាណាចក្រខ្មែរបោះបង់ចោលក្រុងអង្គររួចលើករាជធានីមកតាំងនៅភាគខាងត្បូងប្រទេសរហូតដល់សតវត្សទី១៨។ តាមប្រវត្តិសាស្ត្រស្ថានភាពប្រទេសខ្មែរពេលនោះមានភាពអាប់អួរយ៉ាងខ្លាំងបន្ទាប់ពីភាពរុងរឿងនាសម័យអង្គរ។

នៅចុងសម័យអង្គរពេលដែលប្រទេសខ្មែរកំពុងមានភាពរីកចម្រើន បណ្ដារដ្ឋតូចៗនៅប្រទេសថៃបានរួបរួមគ្នាជារដ្ឋដ៏ខ្លាំងមួយហើយវាយមកលើទឹកដីអង្គរ។ ការសាកល្បងរបស់ប្រទេសថៃត្រូវបរាជ័យក្រោយមកថៃវាយប្រហារជាថ្មីដោយឡោមព័ទ្ធរយៈពេល១ឆ្នាំ ហើយវាយយកអង្គរបាននាឆ្នាំ១៣៥៣ ដល់ឆ្នាំ១៣៥៤ ទើបខ្មែររំដោះបានវិញ។ ក្រោយមកដោយខ្លាចថៃវាយទៀត ព្រះមហាក្សត្រក៏លើករាជធានីមកភាគខាងត្បូងប្រទេសវិញ។

### ២.១ អក្សរសិល្ប៍សម័យលង្វែក ( ពីស.វ.ទី១៥ - ស.វ.ទី១៧ )

#### ២.១.១ អ្នកនិពន្ធ

**បណ្ឌិតជ័យនន្ទះ** ជាអ្នកនិពន្ធដ៏ល្បីនារជ្ជកាលព្រះបាទធម្មរាជាទី១ លោកបានកត់ត្រារៀបរៀងនូវសិលាចារឹកជាច្រើនតាមថៃវប្រសាទអង្គរវត្តដែលជាអត្ថបទបួងសួងសុំសេចក្ដីសុខ និងសម្រេចមគ្គផលក្នុងការធ្វើកុសលផ្សេងៗ។

### ២.២ អក្សរសិល្ប៍សម័យឧដុង្គ (សតវត្សទី១៧ ដល់ទី១៩)

#### ២.២.១ អត្ថន័យអត្ថបទ

មានលក្ខណៈជារឿងប្រឌិត ចងក្រងបែបមនោសញ្ចេតនាយករឿងក្នុងជាតកបែបបាលីមកច្នៃតាមគំនិតអ្នកនិពន្ធគេឃើញមានរឿងផ្សងព្រេង ដោយមានអច្ឆរិយភាពហួសហេតុ។ មនុស្សរស់សង្ឃឹមក្នុងជីវិតហើយប្រើមនោគតិជឿលើហេតុភេទអស្ចារ្យ ដែលខ្លួនយល់ថាពូកែអាចជួយដោះទុក្ខលំបាកទាំងឡាយបាន។

### ២.២.២ អត្ថរូបអត្ថបទ

ប្រើពាក្យកាព្យជាមធ្យោបាយ មានបទកាកគតិ បទពំនោល និងបទព្រហ្មគីតិជាដើម។ ឯកសារកត់ត្រាមានបីយ៉ាងគឺ៖

- នៅលើក្រាំងដែលមានសន្លឹកបើកបានទាំងសងខាង ចារដោយស្លាបប៉ាកាឫស្លាបសត្វ។
- កត់ត្រានៅលើក្រាំងដែលមានសន្លឹកពណ៌ខ្មៅសរសេរដោយដីសថ្ម។
- កត់ត្រាលើស្លឹករឹតដែលមានចងទម្លុះខ្សែតាមរៀងទំព័រហៅថាសាស្ត្រា។

### ២.២.៣ អ្នកនិពន្ធ និងស្នាដៃ

- ព្រះរាជសម្ភារ (១៦២៩ - ១៦៣៤) ៖ ច្បាប់រាជនីតិ ច្បាប់ព្រះរាជសម្ភារ លិខិតផ្ញើទៅព្រះម៉ែយួរតី ពាក្យកាព្យចារឭដ៏កំពូលត្នោត។
- បណ្ឌិតកោះ សាស្ត្រាជ័យទត្ត
- បណ្ឌិតស្អាតឬសម្អាត៖ សាស្ត្រាមុច្ចលិន ឬព្រះចន្ទគោរព
- ព្រះអរិយគោមុនីហ៊ីង៖ សាស្ត្រាជិនវង្ស
- ចៅពញ្ញារាជាភក្ដី៖ សាស្ត្រាចន្ទឃាត
- ភិក្ខុធម្មបញ្ញាម៉ែន៖សាស្ត្រាពេជ្ជតា
- អ្នកឧកញ៉ាប្រាជ្ញាធិបតីកែវ៖ សាស្ត្រាសមុទ្ទឃោសៈ
- អ្នកឧកញ៉ាព្រះឃ្លាំងនង៖ ច្បាប់សុភាសិត ភោគកុលកុមារ ពង្សាវតា
- ព្រះបាទសម្ដេចព្រះអង្គឌួង៖រឿងចម្ប៉ាថោង កាកី ច្បាប់ស្រី
- ឧកញ៉ាកោសាធិបតីកៅ៖ក្រុងសុភមិត្រ។

# អក្សរសិល្ប៍សម័យបុរាណ

## ១. វត្ថុបំណងមេរៀន

- ផ្ដល់នូវខ្លឹមសារមេរៀនអំពីភាពទូទៅរបស់អក្សរសិល្ប៍សម័យបុរាណ (ព្រាហ្មណ៍និយម ពុទ្ធនិយម)
- ដឹកនាំសាកល្បងសិក្សាអត្ថបទរឿងនៅក្នុងអក្សរសម័យសិល្ប៍បុរាណ ជាក្រុម
- បណ្ដុះស្មារតីឱ្យស្រឡាញ់ ថែរក្សា ការពារអក្សរសិល្ប៍បុរាណស្ថិតស្ថេរគង់វង្ស។

## ២. ខ្លឹមសារមេរៀន

តាំងពីបុរាណ ខ្មែរបានទទួលឥទ្ធិពលសាសនាពីឥណ្ឌាគឺព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា មហាយាន។ នៅសម័យបុរាណសាសនានីមួយៗមានតួនាទី និងឥទ្ធិពលយ៉ាងសំខាន់ក្នុងការកំណត់មនសិការសង្គម។ សាសនាបានជ្រាបចូលនៅក្នុងប្រពៃណី ទំនៀមទម្លាប់ ភាសា អក្សរសិល្ប៍ សិល្បៈ ស្ថាបត្យកម្មទៀតផង។ ព្រហ្មញ្ញសាសនាប្រហែលជាចូលមកក្នុងប្រទេសកម្ពុជាក្នុងកំឡុងសតវត្សទី១ នៃ គ.ស.។ រីឯព្រះពុទ្ធសាសនាចូលមកក្នុងប្រទេសកម្ពុជា រវាងសតវត្សទី២ ឬទី៣នៃគ.ស.មកម្ល៉េះ។

អក្សរសិល្ប៍សម័យបុរាណបានផ្ដោតទៅលើសាសនា ដោយសារសាសនាមានតួនាទីសំខាន់នៅក្នុងសង្គម។ ឥទ្ធិពលសាសនាបានជំរុញឱ្យមានការកសាងប្រាសាទ បារាយណ៍ទឹក នយោបាយក្នុងការដឹកនាំ និងការពារប្រទេស បណ្ដុះនូវភាពអង់អាចក្លាហាន ការបង្រួបបង្រួមជាតិ និងសីលធម៌គុណធម៌នៅក្នុងសង្គម។ លើសពីនេះសាសនាក៏បានផ្ដល់នូវពុទ្ធិច្រើនដល់អ្នកនិពន្ធដើម្បីឈ្វេងយល់ពីលទ្ធិ ព្រាហ្មណ៍និយម និងពុទ្ធនិយមដែលមានចារក្នុងគម្ពីរ ដើម្បីយកមកបង្កើតបានជាស្នាដៃរបស់ខ្លួនឡើង។ ដូច្នេះ គម្ពីរសាសនាគឺជាប្រភពនៃដំណើររឿងសម្រាប់និមិត្តកម្មអក្សរសិល្ប៍។ អក្សរសិល្ប៍សម័យបុរាណមានពីរគឺអក្សរសិល្ប៍ព្រាហ្មណ៍និយម និងអក្សរសិល្ប៍ពុទ្ធនិយម។

### ២.១ អក្សរសិល្ប៍ព្រាហ្មណ៍និយម

អក្សរសិល្ប៍ប្រភេទនេះច្រើននិយាយពីវណ្ណៈថ្នាក់ខ្ពស់ ឬវង្សក្សត្រជាដើម ហើយតួអង្គនីមួយៗភាគច្រើនជាតំណាងអាទិទេពធំៗទាំងបី ( ព្រហ្ម សិវៈ និងព្រះវិស្ណុ ) ដូចជាព្រះរាមក្ដី ព្រះក្រិស្ណក្ដី សុទ្ធសឹងជាអវតាព្រះវិស្ណុ។ ឯការដោះស្រាយវិបត្តិនៃរឿងដោយការប្រើហិង្សា។ អក្សរសិល្ប៍ប្រភេទនេះអប់រំមនុស្សឱ្យជឿលើអាទិទេព វត្ថុសក្តិសិទ្ធ និងកម្លាំងក្រៅខ្លួន។

អក្សរសិល្ប៍ព្រាហ្មណ៍និយមដូចជារឿងរាមកេរ្តិ៍ មហាភារតយុទ្ធ។

### ២.២ អក្សរសិល្ប៍ពុទ្ធនិយម

អក្សរសិល្ប៍ប្រភេទនេះច្រើននិយាយពីវណ្ណៈថ្នាក់ខ្ពស់ ឬវង្សក្សត្រជាដើមដូចអក្សរសិល្ប៍ព្រាហ្មណ៍និយមដែរ។ តួអង្គនីមួយៗ តួអង្គឯកប្រុសតំណាងឱ្យព្រះពោធិសត្វ ឯតួអង្គឯកស្រីតំណាងឱ្យកន្សែងសារពេជ្រ ដូចជាតួអង្គព្រះវេស្សន្តរ និងនាងមទ្រីជាដើម។ ឯការដោះស្រាយវិបត្តិនៃរឿងដោយការប្រើអហិង្សា។ អក្សរសិល្ប៍ប្រភេទនេះអប់រំមនុស្សឱ្យរស់នៅស្ថិតក្នុងភាពស្ងប់ស្ងាត់ និងជឿទៅលើកម្មផល ។

**អក្សរសិល្ប៍ពុទ្ធនិយមចែកជាៈ**

### ២.១.១ អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ៖

សម្គាល់លើស្នាដៃអក្សរសិល្ប៍ក្នុងរឿងទសជាតកជាគម្ពីរដ៏សំខាន់របស់ព្រះពុទ្ធសាសនា។ រឿងទាំង ១០លើកឡើងពីការតស៊ូរបស់ព្រះសម្មាសម្ពុទ្ធ ក្នុងពេលព្រះអង្គយោនយកកំណើតជាតួអង្គពោធិសត្វក្នុងជាតិផ្សេងៗ ក្នុងការកសាងបារមីដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ។

**ទសជាតកមាន១០រឿងគឺ៖**

| | | |
|---|---|---|
| ក- រឿងតេមិយជាតក | ខ- រឿងមហាជនកជាតក | គ- រឿងសុវណ្ណសាមជាតក |
| ឃ- រឿងនេមិរាជជាតក | ង- រឿងមហោសថ | ច- រឿងភូរិទត្តជាតក |
| ឆ- រឿងចន្ទកុមារជាតក | ជ- រឿងនារទជាតក | ឈ- រឿងវិធូបណ្ឌិតជាតក |
| | ញ- រឿងមហាវេស្សន្តរជាតក | |

### ២.១.២ អក្សរសិល្ប៍ពុទ្ធនិយមក្លាយ

ត្រូវបានស្តែងចេញតាមរយៈស្នាដៃអក្សរសិល្ប៍បញ្ញាសជាតក។ អ្នកនិពន្ធខិតខំបង្កើតស្នាដៃឡើងដោយពឹងផ្អែកទៅលើគោលទស្សនៈទ្រឹស្តីនៃលទ្ធិពុទ្ធសាសនាផង និងបញ្ចូលបន្ថែមគោលនិយមនៃព្រាហ្មណ៍សាសនាខ្លះផង។

### ២.១.៣ អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ

ជាអក្សរសិល្ប៍ពុទ្ធនិយមមួយបែបដែលពុំមែនជា ទសជាតក ឬបញ្ញាសជាតក ជាស្នាដៃអក្សរសិល្ប៍ខ្មែរ កើតនៅសម័យកណ្តាលដែលទទួលឥទ្ធិពលតិច ឬច្រើនពីឥទ្ធិពលពុទ្ធសាសនាដែរ។ អ្នកនិពន្ធច្រើនលើកយកទស្សនៈកម្មផលមកផ្សារភ្ជាប់ជាមួយជីវិតលោកិយសច្ចៈគួបផ្សំសកម្មភាពអច្ឆរិយៈ ការហោះហើរ មន្តអាគមនៃលទ្ធិព្រាហ្មណ៍។ អក្សរសិល្ប៍ប្រភេទនេះច្រើនជាសាស្ត្រាល្បែង កើតឡើងនៅសតវត្សទី១៨ ឬទី១៩ ដែលមានឈ្មោះអ្នកនិពន្ធច្បាស់លាស់។

រឿងប្រភេទនេះមានដូចជា៖

-រឿងក្រុងសុភមិត្រ(កោសាធិបតីកៅ ១៧៩៨) -រឿងភោគកុលកុមារ(ឧកញ៉ាព្រះឃ្លាំងនង១៨០៤)
-រឿងកាកី(ព្រះអង្គឌួង ១៩១០) -រឿងមរណៈមាតា(ឥន្ទបញ្ញាអ៊ុក ១៨៧៧)។

**សិក្សាអត្ថបទ**

ព្រាហ្មណ៍និយម ( រាមកេរ្តិ៍ )

ពុទ្ធនិយម ( ព្រះវេសន្ដរ )

( គ្រូឧទ្ទេសដឹកនាំគរុសិស្សសិក្សាអត្ថបទ ដែលមាននៅក្នុងកម្មវិធីសិក្សាឆមាសនេះជាក្រុម )

# អក្សរសិល្ប៍សម័យទំនើប

## ១. វត្ថុបំណងមេរៀន

- រៀបរាប់បានពីទិដ្ឋភាពប្រវត្តិនៃអក្សរសិល្ប៍ទំនើប ប្រវត្តិអ្នកនិពន្ធនិងស្នាដៃបានច្បាស់លាស់។
- បកស្រាយបានពីលក្ខណៈសម្គាល់និងស្នាដៃអត្ថបទអក្សរសិល្ប៍ទំនើប។
- មានបំណិនប្រសប់ក្នុងការបង្ហាញពីទិដ្ឋភាពទូទៅ ពីលក្ខណៈពិសេស និងស្នាដៃទាំងឡាយនៃ អក្សរសិល្ប៍សម័យទំនើប។

## ២ ខ្លឹមសារមេរៀន

### ២.១ ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍សម័យទំនើប

មកដល់សតវត្សទី២០ ពុទ្ធសាសនា និងព្រាហ្មណ៍សាសនា បានបាត់បង់ឥទ្ធិពលរបស់ខ្លួនទាំងស្រុងទៅលើនិម្មិតកម្មអក្សរសិល្ប៍ទោះបីស្នាដៃចាស់ៗ បែបពុទ្ធនិយមនិងព្រាហ្មណ៍និយមដែលជាទីពេញនិយមរបស់ប្រជាជនខ្មែរក៏ដោយ។ ពេលនោះស្នាដៃថ្មីៗបានកើតឡើងដោយងាកចេញពីនិន្នាការបែបសាសនា ពោលគឺឈប់បង្ហាញពីអច្ឆរិយភាពរបស់អាទិទេពនៃលទ្ធិព្រាហ្មណ៍ ឬពីជីវភាពបែបរឿងនិទានក្នុងសម័យបែបពុទ្ធសាសនា ហើយចាប់ផ្តើមឆ្លុះបញ្ចាំងពីលក្ខណៈជីវិតក្នុងមជ្ឈដ្ឋាន និងសម័យកាលដែលគេរស់នៅ។ យើងកំណត់ថានោះជាការចាប់ផ្តើមនៃសម័យកាលថ្មី ដែលមានឈ្មោះថាសម័យកាលជីវិតនិយមក្នុងការវិវត្តអក្សរសិល្ប៍ខ្មែរ។

យើងយល់ថានិន្នាការអក្សរសិល្ប៍ថ្មី ដែលលុបចោលលក្ខណៈសាសនាមិនអាចបង្កើតលក្ខណៈប្រជាជនបានភ្លាមៗទេ ព្រោះក្នុងសង្គមខ្មែរមកដល់ទសវត្សទី៥៦នៃសតវត្សទី២០ ប្រជាជននៅតែមានជំនឿយ៉ាងខ្លាំងក្លាលើព្រះពុទ្ធសាសនានៅឡើយ។ ដូចនេះគោលនិយមថ្មីនេះមិនមែនជាសំណូមពររបស់ប្រជាជននោះទេ តែជាលទ្ធផលនៃការវិវត្តមនសិការរបស់អ្នកនិពន្ធ ដែលតែងតែឈានមុនមនសិការរបស់ប្រជាជនជានិច្ច។

ការឈានផុតពីឥទ្ធិពលនៃសាសនានេះ បានបើកទូលាយសមត្ថភាពអ្នកនិពន្ធឱ្យរកឃើញពីវិធីសាស្ត្រថ្មីៗ ប្លែកខុសពីអក្សរសិល្ប៍សម័យបុរាណ និងសម័យកណ្តាល។ ម្យ៉ាងទៀតបានបើកផ្លូវអ្នកនិពន្ធឱ្យឈានទៅរកនិន្នាការផ្សេងៗ តាមការផ្លាស់ប្តូរសង្គម។ យើងសង្កេតឃើញថាក្នុងស្នាដៃថ្មីៗដែលលាតត្រដាងអំពីជីវភាពសាមញ្ញរបស់មនុស្សក្នុងសង្គមអ្នកនិពន្ធ បានប្រើប្រាស់ភាសាសាមញ្ញ ងាយយល់ងាយស្តាប់ជាទីបំផុត។

ពិនិត្យស្នាដៃទាំងឡាយនៅដើមសតវត្សទី២០ យើងឃើញថានិន្នាការរបស់អ្នកនិពន្ធដែលងាកចេញពីសាសនានោះ គឺការនិយមបង្ហាញពីលក្ខណៈខ្មែរសុទ្ធសាធក្នុងអក្សរសិល្ប៍។ និន្នាការនោះគឺជាចលនាសំខាន់បំផុតក្នុងអក្សរសិល្ប៍ខ្មែរ ព្រោះវាបានបញ្ចប់តួនាទីសាសនាដែលមានឥទ្ធិពលលើអក្សរសិល្ប៍តាំងពីសម័យបុរាណមក។ យោងទៅលើការបង្ហាញលក្ខណៈខ្មែរនោះអ្នកសិក្សាកំណត់ឈ្មោះចលនានោះថាខេមរនិយម។

ខេមរនិយមជាស្នាដៃដែលមានលក្ខណៈជាតិខ្មែរយ៉ាងជ្រាលជ្រៅ និងមានលក្ខណតថៈ ព្រោះវាបានឆ្លុះបញ្ចាំងពីតថភាពក្នុងសង្គមខ្មែរដូចជា៖

- បង្ហាញពីជីវភាពរស់នៅ របបគ្រប់គ្រង ប្រពៃណីទំនៀមទម្លាប់ និងបញ្ហាសំខាន់ក្នុងសង្គមខ្មែរ។
- ការបង្ហាញពីតួអង្គដែលមានឈ្មោះ មានចរិត ឬផ្នត់គំនិតជាខ្មែរ។
- ការបង្ហាញពីទីកន្លែងរឿងដែលជាភូមិសាស្ត្រនៃប្រទេសខ្មែរ។

យោងតាមលក្ខណៈពិសេសនេះ យើងឃើញថាចលនានេះមានទំនាក់ទំនងនឹងនិន្នាការរឿងកាកីរបស់ព្រះបាទអង្គឌួង ដែលជាស្នាដៃពុទ្ធនិយមក្លាយ និងលក្ខណៈខ្មែរដែលតែងពីឆ្នាំ១៨១៥។ បានន័យថាអក្សរសិល្ប៍ខេមរនិយមបានចាប់កំណើតតាំងពីចុងសម័យកាល គឺចាប់កំណើតពីស្នាដៃពុទ្ធនិយមនាសតវត្សទី១៩។

តាមប្រវត្តិអក្សរសិល្ប៍ឃើញថាក្នុងជំហានដំបូង ដែលអ្នកនិពន្ធចាប់ផ្ដើមតាក់តែងស្នាដៃនិន្នាការថ្មី ( ខេមរនិយម ) នេះ គេតែងនិយមតែងជាប្រលោមលោកពាក្យកាព្យនៅឡើយ គ្រាន់តែប្រើកាព្យមាត្រថ្មីប៉ុណ្ណោះ។ ស្នាដៃសំខាន់ជាភស្តុតាងគឺរឿងទុំទាវ និពន្ធដោយភិក្ខុសោមឆ្នាំ១៩១៥។ រហូតមកដល់ទសវត្សទី៣ទើបយើងឃើញមានស្នាដៃពាក្យរាយចាប់កំណើតឡើងដូចជារឿងកុលាបប៉ៃលិន និពន្ធដោយលោកញ៉ុកថែម ឆ្នាំ១៩៣៦ រឿងសុផាត និពន្ធដោយលោក រីម គីន ឆ្នាំ១៩៣៨។

ដូចនេះក្នុងការឈានចូលសម័យកាលទំនើបអក្សរសិល្ប៍ខ្មែរ បានឆ្លងកាត់ការវិវត្តសំខាន់ពីរគឺ វិវត្តគោលនិយមក្នុងស្នាដៃតាមរយៈរឿងទុំទាវ និងវិវត្តពីប្រភេទស្នាដៃជាពាក្យកាព្យមកជាពាក្យរាយតាមរយៈរឿងកុលាបប៉ៃលិន។

ចលនាខេមរនិយមបានរក្សាភាពបរិសុទ្ធរបស់ខ្លួន តែក្នុងកំឡុងពេលចាប់កំណើតពាក្យរាយដំបូងនាសតវត្សទី៣ និងទី៤តែប៉ុណ្ណោះ។ ជាពិសេសស្នាដៃទាំងនោះត្រូវបានគេទទួលស្គាល់ និងលើកយកមកសិក្សារហូតមកដល់សព្វថ្ងៃ។ ចាប់តាំងពីទសវត្សទី៥ ពិសេសក្រោយពេលបានឯករាជ្យពីបារាំងមក អក្សរសិល្ប៍ខ្មែរបានបាត់បង់ទាំងឯកភាព ទាំងវិធីសាស្ត្រ ទាំងគោលនិយមស្នាដៃ ដោយសារតែជំនួបនឹងវប្បធម៌បស្ចឹមប្រទេសព្រមទាំងទស្សនវិជ្ជា និងមនោគមវិជ្ជានៃលទ្ធិផ្សេងៗ។ ទើបយើងឃើញមានស្នាដៃគ្រប់ប្រភេទ និងគ្រប់និន្នាការកើតឡើង។ ក្រៅពីនោះ មនោគមវិជ្ជាសង្គមនិយមបានជ្រៀតចូលមកប្រទេសកម្ពុជានាំឱ្យមានអ្នកនិពន្ធបដិវត្តមួយចំនួនសរសេរស្នាដៃ បម្រើស្នាដៃបដិវត្តប្រឆាំងអាណានិគមចាស់ថ្មី និងរបបគ្រប់គ្រងបែបមូលធនដូចជាឌឹក គាម និងឌឹក អំ សរសេររឿងភូមិតិរច្ឆាន អ៊ឹម ថុក សរសេររឿងគូលីកំណែន និងគ្រូបង្រៀនស្រុកស្រែ។

និយាយរួមក្នុងការវិវត្តដ៏យូរលង់ អក្សរសិល្ប៍ខ្មែរបានទុកដានឱ្យយើងល្មមនឹងអាចយល់បានពី ការវិវត្តស្នាដៃទាំងវិធីសាស្ត្រទាំងនិន្នាការអ្នកនិពន្ធ ទោះបីប្រទេសខ្មែរបានឆ្លងកាត់ប្រវត្តិសាស្ត្រស្មុគស្មាញ និងមាននិន្នាការផ្សេងគ្នាក៏ដោយ ក៏វានៅរក្សាបាននូវអត្តិភាពរបស់វាក្នុងសង្គមខ្មែរ ព្រោះនិន្នាការទាំងនោះ វាជានិន្នាការសង្គមខ្មែរទាំងមូល ដែលនៅលាយឡំក្នុងព្រលឹងខ្មែររហូតដល់សព្វថ្ងៃ។

សព្វថ្ងៃប្រជាជនខ្មែរក៏ដូចជាអ្នកសិក្សាអក្សរសិល្ប៍ខ្មែរ បានខិតខំថែរក្សាកេរដំណែលអក្សរសិល្ប៍សំខាន់ៗនៃសម័យកាលនីមួយៗជាមរតកសម្បត្តិវប្បធម៌ជាតិ។

## ២.២ អក្សរសិល្ប៍សម័យអាណានិគមបារាំង ( គ.ស.១៨៦៣ - ១៩៥៣ )

បារាំងបានបង្ខំកូនខ្មែរឱ្យរៀនអក្សរបារាំង ហើយបារាំងបង្ខំកវីខ្មែរសរសេរលើកតម្កើងជាតិបារាំង បង្អាប់ខ្មែរកាឡៃរឿងពិត ហើយបញ្ចូលវប្បធម៌បារាំង។ មានស្នាដៃមួយចំនួនបង្កប់នូវកំហឹងឈឺចាប់ ខ្លះទៀតបង្ហាញនូវការសោកស្តាយចំពោះប្រទេសជាតិដែលត្រូវធ្លាក់ក្នុងមហន្តរាយ។

អ្នកនិពន្ធនិងស្នាដៃមានដូចជា៖

- ឧកញ៉ាសុត្តន្តប្រីជាឥន្ទ៖ កំណាព្យនិរាសអង្គរ រឿងអំបែងបែក គតិលោក
- ធម្មបញ្ញាអ៊ុក៖ រឿងមរណមាតា
- យុនសន្ធាពិនិត្យ៖ រឿងចៅមាស
- ឧកញ៉ាវង្សាធិបតីអ៊ុក៖ រឿងសង្ខសិល្ប៍ជ័យ
- វិបុលរាជ នូ កន៖ រឿងទាវឯក
- គីម ហាក់៖ រឿងទឹកទន្លេសាប សេកសោមបណ្ឌិត
- នូ ហាច៖ រឿងផ្កាស្រពោន រឿងមាលាដួងចិត្ត
- ភិរម្យភាសាអ៊ូហៅង៉ុយ៖ ច្បាប់ល្បើកថ្មី ច្បាប់កេរកាលថ្មី ច្បាប់ក្រមង៉ុយ
- ព្រហ្មបរកេត្តិ៍៖ រឿងពោធិវង្ស
- ហ៊្មឹនកត្តីអក្សរតន់៖ រឿងសព្វសិទ្ធ
- អ្នកស្រីសិទ្ធ៖ រឿងពិម្ពាពិលាប
- ញ៉ុក ថែម៖ រឿងកុលាបប៉ៃលិន រឿងបិសាចស្នេហា
- រីម គីម៖រឿងឈាមរត់រកឈាម រឿងសុផាត

## ២.៣ អក្សរសិល្ប៍សម័យសង្គមរាស្ត្រនិយម ( គ.ស.១៩៥៣ - ១៩៧០ )

គេហៅបានថាអក្សរសិល្ប៍សម័យសម្តេចព្រះ នរោត្តម សីហនុ។ បន្ទាប់ពីបានឯករាជ្យពីប្រទេសបារាំងថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ សង្គមខ្មែរមានការវិវឌ្ឍគ្រប់វិស័យក្រោមការដឹកនាំរបស់សម្តេចសីហនុ។ វិស័យអក្សរសាស្ត្រអក្សរសិល្ប៍រីកចម្រើនគ្រប់វិស័យ ឯវិស័យសិល្បៈក៏ដូច្នេះដែរ។

នៅសម័យឯករាជ្យ យើងសង្កេតឃើញមានការកើនឡើងនូវអ្នកនិពន្ធ និងស្នាដៃអក្សរសិល្ប៍។ ការរីកចម្រើនវិស័យសំខាន់នោះគឺ៖

- វិស័យពោងពុម្ព
- កាសែតនិងទស្សនាវដ្តី
- សមាគមអ្នកនិពន្ធខ្មែរ
- មានការបង្កើតនូវរង្វាន់លើកទឹកចិត្តដល់ស្នាដៃនិពន្ធ

- សៀវភៅប្រលោមលោក ភាពយន្តមានសម្បូរបែប
- បង្កើតសកលវិទ្យាល័យនិងមហាវិទ្យាល័យជាច្រើន

### ២.៤ អក្សរសិល្ប៍សម័យសាធារណរដ្ឋ ( គ.ស.១៩៧០ - ១៩៧៥ )

សង្គ្រាមឆាបឆេះពាសពេញផ្ទៃប្រទេសរយៈពេល៥ឆ្នាំ ១ខែ ក្នុងរបបសាធារណរដ្ឋរហូតដល់ខ្មែរក្រហមឈ្នះសង្គ្រាមនាថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ អក្សរសិល្ប៍នាសម័យនោះ បានបន្តវេនពីសម័យមុនៗទាំងរចនាបថ និងវិធីសាស្ត្រ។ អ្នកនិពន្ធជំនាន់ក្រោយលេចចេញមកជាមួយនូវស្នាដៃអក្សរសិល្ប៍។ អ្នកនិពន្ធសម័យនោះ កាន់តែមានសេរីភាពជាងសម័យមុនៗ បានពង្រីកបន្ថែមនូវស្មារតីទាមទារសិទ្ធិសេរីភាព ប្រជាធិបតេយ្យក្នុងអក្សរសិល្ប៍យ៉ាងផុសផុល។

ស្នាដៃនិពន្ធពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មានច្រើន តែបាត់បង់អស់នៅសម័យប៉ុលពត។ យើងឃើញមានស្នាដៃមួយចំនួនត្រូវបានបោះពុម្ពផ្សាយឡើងវិញដូចជារឿងជ្រោះភ្នំគូលែន រឿងលំនៅចុងក្រោយ រឿងទំនួញក្មេងកំព្រា ប្រវត្តិអាចារ្យស្វា រឿងបាត់ដំបងសម័យលោកម្ចាស់...។

### ២.៥ អក្សរសិល្ប៍សម័យកម្ពុជាប្រជាធិបតេយ្យ ( គ.ស.១៩៧៥ - ១៩៧៩ )

សម័យកម្ពុជាប្រជាធិបតេយ្យ យើងសង្កេតឃើញមានអក្សរសិល្ប៍សំណេរមួយចំនួនដូចជារឿងបដិវត្តស្នាដៃកំណាព្យ ចម្រៀង ពាក្យស្លោក...។

សម័យកម្ពុជាប្រជាធិបតេយ្យមានលេចចេញនូវចរន្តអក្សរសិល្ប៍ពីរគឺៈ

- អក្សរសិល្ប៍ប្រជាប្រិយ

ឧទាហរណ៍ៈ ជយោ!អង្គការដ៏រុងរឿង រុះរើផ្ទះក្បឿងទៅនៅផ្ទះស្បូវ
ជយោ!អង្គការដ៏ត្រឹមត្រូវ រុះរើផ្ទះស្បូវទៅនៅក្នុងព្រៃ។

- អក្សរសិល្ប៍សំណេរៈ បានប្រើប្រាស់អក្សរសិល្ប៍ធ្វើជារណសិរ្សឃោសនា អប់រំសតិអារម្មណ៍ បោកបញ្ឆោតប្រជាជនដើម្បីបម្រើគោលមាគ៌ារបស់គេ។

អក្សរសិល្ប៍សម័យនោះផ្ទុកទៅដោយស្មារតីឈឺចាប់ សងសឹក បំផុសកំហឹងវណ្ណៈ សម្រុកបង្កបង្កើនផល ពិសេសឱ្យដើរតាមមាគ៌ាបដិវត្តឥតងាករេ។

### ២.៦ អក្សរសិល្ប៍សម័យក្រោយថ្ងៃ៧មករា ឆ្នាំ១៩៧៩ រហូតដល់បច្ចុប្បន្ន

អក្សរសិល្ប៍សម័យនេះជាបច្ចុប្បន្នភាពនៃអក្សរសិល្ប៍ដែលមានរបត់វិវត្ត និងបន្តអត្ថិភាពរហូតដល់បច្ចុប្បន្ន។ យើងសង្កេតឃើញមានរបត់វិវត្តជាបីដំណាក់កាលៈ

- **ដំណាក់កាលទី១ៈ** អ្នកនិពន្ធត្រូវគោរពតាមគោលការណ៍នៃនិម្មិតកម្មអក្សរសិល្ប៍ គឺអក្សរសិល្ប៍បដិវត្តបម្រើឱ្យប្រជាជននិងបក្សកាន់អំណាច ពោលគឺសេរីភាពអ្នកនិពន្ធស្ថិតក្នុងព្រំដែនរបស់បក្ស។ យើងឃើញមានស្នាដៃមួយចំនួនដូចជាៈ
  - រឹតចំណងសាមគ្គីចំណងអធន ពិសេសសាមគ្គីជាមួយវៀតណាម
  - បំផុសអូសទាញជនវង្វេងផ្លូវ បង្កបង្កើនផលគឺស្នេហាជាតិ

- ស្មារតីតស៊ូបដិវត្ត កសាងកម្លាំងពិតបដិវត្ត
- បំផុសកំហឹងឈឺចាប់នឹងប៉ុលពត

- ដំណាក់កាលទី២៖ ឃើញលេចចេញនូវស្នាដៃក្រញាំមូលធន របស់អ្នកនិពន្ធ ហ៊ី សុខហៃ ដែលផ្សាយដំបូងជាល្ខោននិយាយតាមវិទ្យុជាតិនាឆ្នាំ១៩៨៥។ ស្នាដៃនេះមានលក្ខណៈជាប្រធានបទថ្មីប្លែកពីប្រធានបទបដិវត្តកំណត់មុនៗ ដែលធ្វើឱ្យមានការចាប់អារម្មណ៍ពីអ្នកស្តាប់មួយចំនួន។
- ដំណាក់កាលទី៣៖ យើងសង្កេតឃើញមានលេចចេញនូវស្នាដៃប្រលោមលោកខ្លីៗចុះតាមទំព័រសារព័ត៌មានដែលសរសេរពីមនោសញ្ចេតនាសុទ្ធសាធ មិនទាក់ទងនឹងមាគ៌ាបដិវត្តបរិយាយ និងឆ្លុះបញ្ចាំងជ្រុងនៃជីវិតក្នុងសង្គមបន្តបន្ទាប់។ ឧទាហរណ៍៖ លោក ប៉ុក ប៊ុណ្ណសាមាជ សរសេររឿង «យប់កណ្តាលថ្ងៃ» ដែលពណ៌នាពីមនោសញ្ចេតនាពិតៗក្នុងគ្រួសារតូចមួយដែលតថភាពសង្គមបានរុញច្រានទៅដល់ភាពជូរចត់ក្នុងគ្រួសារ។ ក្រោយបោះឆ្នោតដែលរៀបចំដោយ អ៊ុន តាក់ អក្សរសិល្ប៍បានរីកចម្រើនបែបសេរីឡើងវិញ តែត្រូវជួបនឹងប៉ះទង្គិចយ៉ាងខ្លាំងនូវបច្ចេកវិទ្យា វីដេអូ ព្រមទាំងហូរចូលយ៉ាងគំហុកដោយខ្វះការត្រួតពិនិត្យឱ្យបានត្រឹមត្រូវនៃវប្បធម៌ និងខ្សែវីដេអូបរទេសចូលលុកលុយសង្គមកម្ពុជាយើងហើយសង្កត់វិស័យវប្បធម៌ខ្មែរ និងវិស័យអក្សរសិល្ប៍ខ្មែរ ដែលទើបតែងើបពីសង្គ្រាមជាងពីរទសវត្សកន្លងមក។

**សិក្សាអត្ថបទ**

- រឿងកុលាប ប៉ៃលិន
- ថៅកែចិត្តចោរ
- ព្រះអាទិត្យថ្មីរះលើផែនដីចាស់

( គ្រូឧទ្ទេសដឹកនាំគរុសិស្សសិក្សាអត្ថបទ ដែលមាននៅក្នុងកម្មវិធីសិក្សាឆមាសនេះជាក្រុម )

## ៣. សន្និដ្ឋាន

ឆ្លងតាមការបង្ហាញ រៀបរាប់ ឆ្លុះបញ្ចាំងនូវប្រវត្តិអក្សរសិល្ប៍នាសម័យក្រោយអង្គរយើងឃើញថាតាំងពីសម័យក្រោយអង្គរហូតដល់សម័យបច្ចុប្បន្នអក្សរសិល្ប៍ មានការវិវត្តប្រែប្រួលជាច្រើនទៅតាមសម័យកាលនីមួយៗ ជួនរីកចម្រើនជួនធ្លាក់ចុះអាស្រ័យលើបេត់សង្គម។ មិនតែប៉ុណ្ណោះដោយសារតែអក្សរសិល្ប៍ដែលបុព្វបុរសយើង បានបន្សល់ទុកធ្វើឱ្យកូនខ្មែរជំនាន់ក្រោយបានដឹងពីវប្បធម៌ អរិយធម៌ អក្សរសាស្រ្ត អក្សរសិល្ប៍នាសម័យនោះ។ ដូច្នេះយើងត្រូវតែអភិរក្សនូវស្នាដៃទាំងនោះ ហើយខិតខំរិះរក និងបង្កើតនូវអ្វីៗប្លែកៗថ្មីៗល្អៗសម្រាប់បន្សល់ទុកឱ្យអ្នកជំនាន់ក្រោយទៀត។ បន្ថែមពីនេះទៀតយើងឃើញថាអក្សរសិល្ប៍ខ្មែរយើងមានការវិវត្តជាច្រើនសម័យកាល ហើយមានការផ្លាស់ប្តូរទាំងនិន្នាការ ទាំងសិល្បវិធីតែងទៅតាមបេត់សង្គមនីមួយៗ និងទៅតាមចលនាអក្សរសិល្ប៍។ ទោះបីមានការផ្លាស់ប្តូរយ៉ាងណាក៏ដោយ ក៏អក្សរសិល្ប៍ទាំងនោះនៅតែរក្សាអត្តិភាពរបស់ខ្លួន រហូតមកដល់សព្វថ្ងៃ ហើយត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាទៀតផងដូចជា

រឿង ទុំទាវ រឿងផ្កាស្រពោន រឿងកុលាបប៉ៃលិន...។ ដូចនេះយើងជាកូនចៅជំនាន់ក្រោយត្រូវតែថែរក្សានូវស្នាដៃទាំងនោះឱ្យបានគង់វង្ស ស្ថិតស្ថេរយូរអង្វែង។

# សិក្សាអត្ថបទអក្សរសិល្ប៍

## ១. វត្ថុបំណង៖

- ផ្ដល់គម្រោងគំរូសម្រាប់ជាគន្លឹះក្នុងការសិក្សាអត្ថបទអក្សរសិល្ប៍
- ឈ្វេងយល់ពីបញ្ញត្តិផ្សេងៗ ( អត្ថន័យ អត្ថរូប អត្ថរស )
- ជាស្ពានសាកល្បងសិក្សាអត្ថបទស្នាដៃអក្សរសិល្ប៍ផ្សេងទៀត

## ២. ខ្លឹមសារមេរៀន

### គម្រោងសិក្សាអត្ថបទ

**១.ទិដ្ឋភាពប្រវត្តិ / ទិដ្ឋភាពទំនាក់ទំនងរឿង**

១.១.អត្ថបទ

១.១.១.ចំណងជើង

១.១.២.ប្រភព

១.១.៣.ប្រភេទ

១.១.៤.ចលនា

១.២.អ្នកនិពន្ធនិងស្នាដៃ

១.៣.សង្គមបរិយាកាស

១.៣.១.កាលប្រវត្តិ

១.៣.២.ព្រឹត្តិការណ៍សំខាន់ៗក្នុងសង្គម

**២.ទិដ្ឋភាពវិភាគរឿង**

២.១.ស្ថានភាពរឿង

២.១.១.សង្ខេបរឿង

២.១.២.តួអង្គ

២.១.៣.កាលអាកាស

២.១.៤.ព្រឹត្តិការណ៍សំខាន់ៗក្នុងរឿង

២.២.ទិដ្ឋភាពអត្ថន័យ

២.២.១.ប្រធានរឿង

២.២.២.មូលបញ្ហារឿង

២.២.៣.ទំនាស់និងដំណោះស្រាយ

២.២.៤.វិភាគតួអង្គ

២.២.៥.ឧត្ដមគតិរឿង

២.៣.ទិដ្ឋភាពអត្ថរូប

២.៣.១.ការផ្ដើមរឿង

២.៣.២.ដំណើររឿង

- **វចនវិធី៖** អ្នកនិពន្ធចេះប្រើប្រាស់ពាក្យពេចន៍សាមញ្ញ ងាយអាន ងាយយល់ ងាយស្ដាប់ ឬប្រើពាក្យពេចន៍ពិបាកយល់ ពិបាកអានដូចជាពាក្យខ្មែរបុរាណ បាលីសំស្ក្រឹត។
- **រចនាវិធី៖** ជាវិធីដែលអ្នកនិពន្ធប្រើដើម្បីសរសេរតាក់តែងអត្ថបទរឿងរបស់ខ្លួន ទោះជាពាក្យពាយ ពាក្យកាព្យឱ្យមានពាក្យពេចន៍ ឃ្លា ល្បះធម្មតាដែលប្រជាជនទូទៅនិយមប្រើ ធ្លាប់ស្ដាប់ ធ្លាប់ប្រើ មិនពិបាកអាន ពិបាកស្ដាប់ ឬពិបាកយល់ឡើយ។
- **ពណ៌នាវិធី៖** គឺជាវិធីដែលអ្នកនិពន្ធប្រើវិធីរៀបរាប់ធម្មជាតិ តួអង្គ សកម្មភាពប្រកបដោយសិល្បៈរូបារម្មណ៍ខ្ពស់ ធ្វើឱ្យអ្នកមើល អ្នកអាន អ្នកស្ដាប់ ហាក់ដូចជាឃើញរូបពិតក្នុងអារម្មណ៍របស់ខ្លួន។
- **ឯកវាទវិធី៖** ជាវិធីដែលអ្នកនិពន្ធឱ្យតួអង្គនិយាយ ឬ ពោលតែម្នាក់ឯង។
- **សំវាទវិធី៖** ជាវិធីដែលអ្នកនិពន្ធឱ្យតួអង្គនិយាយឆ្លើយឆ្លងគ្នា។
- **ឧបមានវិធី ឬទំហៀបន័យ៖** ជាវិធីដែលអ្នកនិពន្ធធ្វើការប្រៀបធៀបតួអង្គ ឬសកម្មភាពនៅក្នុងដំណើររឿងដើម្បីរំលេចនូវជីវរូបារម្មណ៍ ឬមនោរម្មណ៍។ ការប្រដូចនេះ ប្រើសំនួនប្រដូចដូចជា ហាក់ដូច ហាក់ដូចជា ប្រៀបបាន ប្រៀបដូច រូហាន រូពិនជាដើម។
- **បំរៀបន័យ ឬមេតាផរ៖** ជាវិធីដែលអ្នកនិពន្ធធ្វើការប្រៀបធៀបតួអង្គ ឬសកម្មភាពនៅក្នុងដំណើររឿងទៅនឹងសភាពលក្ខណៈអ្វី ដែលជាទំហៀបដោយគ្មានប្រើសំនួនប្រៀបធៀបទេ។ ឧទាហរណ៍៖ ភ្នំធ្មឹង សមុទ្រឈាមជាដើម។
- **ទារុណវិធី៖** ជាវិធីដែលអ្នកនិពន្ធចេះប្រើប្រាស់ ធ្វើឱ្យអ្នកទស្សនាក្ដុកក្ដួល រំជួលចិត្តទៅតាមសកម្មភាព កម្សត់ព្រាត់ប្រាស លំបាក វេទនា ឈឺចាប់ របស់តួអង្គ។
- **សន្ទេហវិធី៖** ជាវិធីដែលអ្នកនិពន្ធធ្វើឱ្យអ្នកទស្សនាមានការងឿងឆ្ងល់ និង ចង់ទស្សនាបន្តទៀត។
- **វឌ្ឍនាវិធី៖** ជាវិធីដែលអ្នកនិពន្ធធ្វើឱ្យរឿងមានលក្ខណៈតឹងឡើងៗ រហូតដល់តួអង្គអាចស្លាប់ក៏មាន។
- **បដិវិធី៖** ជាវិធីដែលអ្នកនិពន្ធបង្ហាញឱ្យឃើញលក្ខណៈផ្ទុយគ្នានៅក្នុងដំណើររឿង។
- **ប្រលោមវិធី៖** ជាវិធីដែលអ្នកនិពន្ធប្រើសម្រាប់បបោសអង្អែលអារម្មណ៍អ្នកអាននៅក្នុងស្នាដៃ។

២.៣.៣.ការបញ្ចប់រឿង

២.៤.ទិដ្ឋភាពអត្ថរស

២.៤.១.កុសលរស

២.៤.២.សង្គមរស

២.៤.៣.តថរស

២.៤.៤.វីររស

២.៤.៥.អច្ឆរិយរស

២.៤.៦.ហាសរស

២.៤.៧.ទារុណរស

## ៣. សន្និដ្ឋាន

គំរូខាងលើគ្រាន់ជាគំរូមួយ ដែលអ្នកសិក្សាអត្ថបទអក្សរសិល្ប៍តែងយកជាប្លង់ឬគ្រោងឆ្អឹងសិក្សា។ ដោយឡែកខ្លឹមសារឬសាច់ខាងក្នុងដែលត្រូវបំពេញ គឺប្រែប្រួលទៅតាមចំណាងជើងអត្ថបទដែលយក មកសិក្សា។ ជារួមគោលបំណងនេះគឺតម្រូវឱ្យអ្នកសិក្សាតោងយល់ច្បាស់ពី អត្ថន័យ អត្ថរូប អត្ថរស និងជាតុល្អិតៗសំខាន់របស់វា។

# ភាសាវិទ្យា

## ១. វត្ថុបំណង

ក្នុងមេរៀននេះ បានផ្តល់ចំណេះដឹងអំពីភាសាវិទ្យារួមមានបង្ហាញពីៈ

- សញ្ញាណទូទៅនៃភាសា
- ប្រវត្តិភាសាខ្មែរ
- វិវត្តន៍នៃភាសាខ្មែរ
- លក្ខណៈពិសេសនៃភាសាខ្មែរ
- សូរវិទ្យា
- វចនវិទ្យា
- សម្ពន្ធវិទ្យា ដែលសិក្សាតែទៅលើ " ឈ្មោះ " តែប៉ុណ្ណោះ

## ២. ខ្លឹមសារមេរៀន

ភាសាវិទ្យា គឺជាការសិក្សាអំពីភាសាតាមបែបវិទ្យាសាស្ត្រលើភាសា។ យើងមិនគួរច្រឡំភាសាវិទ្យា និងវេយ្យាករណ៍ឡើយ ព្រោះចំពោះភាសាមួយវេយ្យាករណ៍ជាក្បួនខ្នាតមានលក្ខណៈប្រពៃណីជាង ហើយមានប្រធានបទខ្លះគេសិក្សាក្នុងភាសាវិទ្យា តែពុំមានសេចក្តីលម្អិតក្នុងវេយ្យាករណ៍ប្រពៃណីឡើយ។ ភាសាវិទ្យាសិក្សាផ្នែកផ្សេងៗនៃភាសាមានដូចជាការបញ្ចេញសំឡេង ការកត់ត្រាសំឡេង ន័យរបស់ពាក្យ របៀបរៀបលំដាប់ពាក្យឱ្យមានន័យស្តាប់បាន របៀបប្រើប្រាស់ភាសាតាមបរិបទ និងលក្ខណៈជាច្រើនទៀត។ សាខារបស់ភាសាវិទ្យា ចេះតែកើនឡើងជាបន្តបន្ទាប់តាមកាលសម័យ។

### ២.១ សញ្ញាណទូទៅអំពីភាសា

ពាក្យថា ភាសាមានន័យត្រូវគ្នានឹងពាក្យបារាំងថា La Langue ដូចជាកម្រងពាក្យថា ភាសាខ្មែរ ភាសាបារាំង ភាសាអង់គ្លេស ភាសាក្រិក ភាសាបាលី ភាសាសំស្ក្រឹតជាដើម។

តាមវចនានុក្រមខ្មែរភាគមួយទំព័រទី២៧៤ បានឱ្យនិយមន័យភាសាយ៉ាងខ្លីថាជា « សម្តី ឬពាក្យ »។ រីឯតាមសព្វវចនាធិប្បាយធំ Grande Larousses វិញ បានឱ្យនិយមន័យដល់ពាក្យនេះថា « ភាសាជាការសម្តែងនូវសកម្មភាព ដោយនិម្មិតរបស់មនុស្ស ពោលគឺសម្បទារបស់គេក្នុងការសម្តែងចិត្តគំនិត និង ហេតុការណ៍នានា តាមសូរសំឡេង និងកាយវិការ »។ តាមទស្សនៈរបស់វាក្យវិទូ Webster ថា «ភាសា គឺជាការសម្តែងនូវគំនិត សញ្ចេតនា ដោយប្រើសូរសំឡេង និងដោយការផ្តុំសូរសំឡេងនោះជាន័យសេចក្តីមួយ»។ ដូច្នេះសរុបសេចក្តីមក ភាសាគឺជាឧបករណ៍នៃគំនិត ដែលមនុស្សបានបង្កើតឡើងសម្រាប់បណ្តុះទំនាក់ទំនងក្នុងជីវភាពសង្គម។ម្យ៉ាងវិញទៀតចំពោះភាសាដែលមានន័យថាប្រព័ន្ធសញ្ញាពិសេសនោះ គឺជាភាសាសំណុំមួយដែលមានទំនាក់ទំនងគ្នា តាមរយៈសញ្ញាពិសេសដោយឡែកអាចផ្សំគ្នាបាន ហើយមានលក្ខណៈបន្តមានន័យមួយ ឬច្រើន ហើយមានលក្ខណៈយូរអង្វែង។

ភាសាមានការកកើតឡើង មានការរីកចម្រើន ចុះថយ ឬរលត់បាត់បង់ទៅវិញក៏មាន។ ភាសាមានការផ្លាស់ប្តូរទៅតាមដំណាក់កាលនៃប្រវត្តិ និងតាមតម្រូវការរបស់មនុស្សក្នុងសង្គម។ ភាសាកាលពីជំនាន់ដើមខុសគ្នាពីភាសាសព្វថ្ងៃ។ អាស្រ័យហេតុនេះហើយបានជាយើងពិបាកយល់ន័យរបស់ភាសាខ្មែរបុរាណ។ ក្នុងនិយមន័យភាសានេះទៀត យើងក៏គប្បីយល់ដឹងអំពីពាក្យថា ស្រដី និងសម្តី ផងដែរ ដើម្បីងាយស្រួលដល់ការសិក្សាភាសាវិទ្យា។

- ស្រដី៖ តាមវចនានុក្រមបារាំងប្រែថា « ការប្រើពាក្យ ឬសម្តី សម្រាប់ទាក់ទងគ្នា »។ ពាក្យនេះតាមន័យសព្ទវិទ្យាប្រែថាផលដែលបានមកពីស្តី ឬប្រែថាផលដែលបានមកពីភាសា និងសម្តី។
- សម្តី៖ តាមវចនានុក្រមខ្មែរប្រែថា « ការចេះនិយាយ ( ភាសា ) »។

បើប្រៀបធៀបភាសា និងសម្តី ឃើញថា ភាសាមានលក្ខណៈរបស់សង្គម មានលក្ខណៈរួម ភាសាប្រៀបបាននឹងលោហធាតុ។ ចំណែកឯសម្តីមានលក្ខណៈជាបុគ្គលឯកជន សម្តីអាចប្រៀបបាននឹងរ៉ែ។ ទំនាក់ទំនងរវាងភាសានឹងសម្តី យើងអាចប្រៀបធៀបនឹងក្រដាសមួយសន្លឹកដែលមានទំព័រពីរជាប់គ្នា។

តាមលោក F. de Saussure ថា ភាសាគឺរូបរាងទម្រង់ក្រៅ គឺមិនមែនជាសារជាតិទេ។ ចំពោះសម្តីវិញ គាត់បានសរសេរថា សម្តី ឬពាក្យជាឯកតាមួយ ដែលមានឥទ្ធិពលទៅលើគំនិត។

ភាសាវិទូបានសិក្សាស្រាវជ្រាវអំពីភាសាទាំងអស់ក្នុងលោកឃើញថា ភាសាមានចំនួនច្រើនណាស់ បើរាប់ទាំងភាសាតូច ធំ ស្លាប់ រស់ មានចំនួនពីពីរពាន់ប្រាំរយទៅបីពាន់ប្រាំរយភាសា។ ក្នុងចំណោមភាសាទាំងនោះ ភាសាវិទូបានធ្វើប្រភេទវិភាគចែកភាសាជាក្រុម ឬអម្បូរ។ ភាសាដែលអាចស្ថិតនៅក្នុងអម្បូរជាមួយគ្នាបាន លុះត្រាតែមានលក្ខណៈពិសេសប្រហែលៗគ្នា។ អម្បូរភាសាធំៗមានចំនួន២០ដូចជា៖

- អម្បូរឥណ្ឌូ-អឺរ៉ុប គឺជាអម្បូរភាសាមួយ ទូលំទូលាយក្នុងបណ្តាអម្បូរភាសាក្នុងលោកគ្របដណ្តប់លើទ្វីបអឺរ៉ុបជិតតែទាំងអស់ និងលើមួយភាគធំនៃប្រទេសឥណ្ឌា។
- អម្បូរខ្មែ-មន គឺជាអម្បូរធំសំខាន់មួយនៅទ្វីបអាស៊ីអាគ្នេយ៍។
- អម្បូរម៉ាឡាយូ-ប៉ូលីនេស៊ី គឺជាអម្បូរធំគួរសម ស្ថិតនៅតាមកោះ និងនៅទៀបកោះ ក្នុងភាគខ្លះនៃមហាសមុទ្រប៉ាស៊ីហ្វិក និងនៃមហាសមុទ្រឥណ្ឌា។

## ២.២ ប្រវត្តិភាសាខ្មែរ

ភាសាមានកំណើតដំណាលគ្នានឹងកំណើតមនុស្ស។ យ៉ាងណាមិញ ប្រវត្តិសាស្ត្រខ្មែរបានចែងថាជាតិខ្មែរមានយូរយារណាស់មកហើយ ( ប្រមាណ ៣០០០ឆ្នាំមុនគ.ស. ) គឺជាជាតិសាសន៍ដែលធ្លាប់មានអរិយធម៌រុងរឿងក្នុងចំណោមជាតិសាសន៍ដទៃ ក្នុងភូមិភាគអាស៊ីអាគ្នេយ៍។ ដូចនេះភាសាខ្មែរ ដែលមានប្រភពដំណាលគ្នានឹងជាតិកំណើតមនុស្សខ្មែរ ក៏កើតមានតាំងពីយូរណាស់មកហើយដែរ។ ក្រោយដែលបានសិក្សាស្រាវជ្រាវអំពីភាសាខ្មែរអស់ពេលជាយូរមក ភាសាវិទូបរទេសបានបញ្ចូលភាសានេះ ទៅក្នុងអម្បូរភាសាធំមួយក្នុងចំណោមអម្បូរភាសានៅទ្វីបអាស៊ីអាគ្នេយ៍ គឺអម្បូរខ្មែរ-មននេះឯង។ តាមលោក ពីណូវ

H.J.Pinnow អម្បូរភាសាខ្មែរ-មន ជាក្រុមភាសាមួយដែលគួរចាប់អារម្មណ៍ជាងគេក្នុងបណ្តាភាសាអាស៊ីភាគខាងត្បូង( អម្បូរភាសាអូស្ត្រូអាស៊ី : អម្បូរភាសាម៉ាឡាយូ-ប៉ូលីនេស៊ី អម្បូរភាសាថៃ-វៀតណាម អម្បូរភាសាខ្មែរ-មន ) ព្រោះជាភាសាដែលមានប្រវត្តិអក្សរប្លែកពីភាសាដទៃទៀត ដែលទើបតែមានភាសាសរសេរ ហើយខ្លះទៀតនៅតែគ្មានអក្សរសរសេរដដែល។

## ២.៣ វិវត្តន៍នៃភាសាខ្មែរ

ភាសាក៏ដូចជាធាតុឯទៀតនៃអរិយធម៌ខ្មែរ តែងប្រែប្រួលចម្រើនលូតលាស់ ឬអន់ថយស្របតាមការរស់នៅរបស់មនុស្សក្នុងសង្គម។ គេបានកត់សម្គាល់ឃើញថាភាសាសរសេរវិវត្តពុំទាន់ភាសានិយាយទេ។

ចំពោះកំណកំណើតភាសាខ្មែរ ដែលមានជីវិតរហូតមកដល់សម័យបច្ចុប្បន្ននេះ អ្នកប្រាជ្ញខាងភាសាបានសង្កេតឃើញមានវិវត្តបីលើកធំៗគឺៈ

- ភាសាខ្មែរបុរាណ ( តាំងពីកំណកំណើតមដល់សតវត្សទី១៥ )
- ភាសាខ្មែរកណ្តាល ( សតវត្សទី១៦ ដល់សតវត្សទី១៩ )
- ភាសាខ្មែរបច្ចុប្បន្ន ( ចាប់ពីសតវត្សទី២០រហូតមក )

ល្បាយភាសាកើតឡើងនៅពេលដែលខ្មែរមានទំនាក់ទំនងជាមួយនឹងបរទេស ដូចជាទាក់ទងក្នុងកិច្ចការទូត ទេសចរណ៍ ពាណិជ្ជកម្ម សិក្សាអប់រំ ជំនឿ សាសនា។ល។ គេបានកត់សម្គាល់ឃើញថាភាសាមានអាយុវែង កាលណាល្បាយភាសាកំណើតកាន់តែមានច្រើនឡើងៗ សឹងរកភាពសុទ្ធរបស់ខ្លួនពុំឃើញ។ ភាសាបរទេសដែលនៅលាយឡំច្រើនជាងគេក្នុងភាសាខ្មែរយើងសព្វថ្ងៃ គឺភាសាបាលី និង សំស្ក្រឹត។ ភាសាបាលីហូរចូលមកក្នុងភាសាខ្មែរ តាមរយៈពុទ្ធសាសនាហីនយាន ឯភាសាសំស្ក្រឹតហូរចូលតាមរយៈពុទ្ធសាសនាមហាយាន និងព្រហ្មណ៍សាសនា។ ដោយជនជាតិខ្មែរយើងនិយមគោរពសាសនាឥណ្ឌាទាំងនេះហើយបានជាភាសាបាលី-សំស្ក្រឹត ព្រមទាំងក្បួនខ្នាតវេយ្យាករណ៍មានឥទ្ធិពលខ្លាំងក្លាមកលើភាសាខ្មែរ ហើយចាក់ឫសគល់មកដល់សព្វថ្ងៃ ជាហេតុនាំឱ្យអ្នកខ្លះ ដែលមើលលក្ខណៈដើមនៃភាសាខ្មែរពុំឃើញ ហើយក៏តាំងចោទថាភាសាខ្មែរមានប្រភពពីភាសាបាលី-សំស្ក្រឹតនេះឯង។ ការពិតភាសាទាំងពីរនេះ ចូលមកក្រោយពេលដែលខ្មែរមានភាសាផ្ទាល់ខ្លួនរួចស្រេចទៅហើយ។ ដូចនេះភាសាខ្មែរពុំមែនកើតចេញពីភាសាបាលីសំស្ក្រឹត ឬភាសាបាលីសំស្ក្រឹតជាម្តាយនៃភាសាខ្មែរដូចទស្សនៈរបស់លោក J. Taupin នោះទេ។ ខ្មែរប្រើប្រាស់ពាក្យបាលី-សំស្ក្រឹតជាពាក្យកម្ចី ដើម្បីបង្រួប់នូវកង្វះខាតតែប៉ុណ្ណោះ។ រីឯពាក្យបាលី-សំស្ក្រឹតក៏ត្រូវតែកែប្រែទាំងសូរសព្ទ ទាំងរូបសព្ទ ដើម្បីឱ្យស្របមកនឹងសម្តីខ្មែរ ចំណង់ចំណូលចិត្តខ្មែរ។ ខេមរនីយកម្មបែបនេះ ពុំមែនធ្វើចំពោះតែពាក្យបាលី-សំស្ក្រឹតប៉ុណ្ណោះទេ ភាសាបរទេសណាក៏ដោយដែលជ្រាបចូលមកក្នុងភាសាខ្មែរត្រូវទទួលការផ្លាស់ប្តូរឱ្យមានលក្ខណៈជាខ្មែរដែរ។ ម្យ៉ាងទៀតភាសាបាលីសំស្ក្រឹត ស្ថិតជាប់នឹងអម្បូរខ្មែរ-មន ព្រោះមានវិភត្តិដូចភាសានៃជនជាតិអឺរ៉ុបដែរ។ ដូចនេះភាសាបាលីសំស្ក្រឹតនៅក្នុងអម្បូរឥណ្ឌូ-អឺរ៉ុប។

## ២.៤ លក្ខណៈពិសេសនៃភាសាខ្មែរ

ដើម្បីបំផុសឱ្យឃើញលក្ខណៈពិសេសនៃភាសាខ្មែរ និងដើម្បីកុំឱ្យមានការយល់ច្រឡំដូចទស្សនៈខាងលើ យើងសូមធ្វើការប្រៀបធៀបចំណុចសំខាន់ៗខ្លះនៃភាសាខ្មែរ ទៅនឹងភាសាខ្លះទៀត ជាពិសេសភាសាបាលី សំស្ក្រឹត។

**+ អំពីការបន្លឺសំឡេង**

ក្នុងការបន្លឺសំឡេង ពាក្យខ្មែរក្តី មនក្តី ពុំមានសំឡេងឡើងចុះ ឬលើកដាក់ខ្ពស់ទាបទៅតាមសញ្ញាប្រើដាក់លើពាក្យ ដែលនាំឱ្យផ្លាស់ប្តូរន័យរបស់ពាក្យនោះទេ។ នេះជាចំណុចសំខាន់មួយ ដែលបង្ហាញនូវសភាពប្លែកគ្នារវាងភាសាខ្មែរ-មន និងក្រុមភាសាចិន យួន សៀម ឡាវ ដែលជាភាសាភ្ជាប់ន័យទៅនឹងសំឡេងខ្ពស់ទាប ឬចុះឡើង។

**+ អំពីចំនួនព្យាង្គ**

ពាក្យខ្មែរសុទ្ធ ច្រើនតែមានចំនួនព្យាង្គតិច គឺសម្បូរពាក្យមួយព្យាង្គ ប្លែកអំពីពាក្យបាលី-សំស្ក្រឹត ដែលច្រើនតែមានចំនួនព្យាង្គច្រើន។ ក្នុងករណីពាក្យខ្មែរសុទ្ធ២ព្យាង្គ ឬច្រើនព្យាង្គ គេបានសង្កេតឃើញថាការបន្លឺតែងមានទំនោរទៅរកការបង្រួញព្យាង្គច្រើន ឱ្យនៅសល់តិចបំផុត ដោយបន្លឺរស្នូរ ឬបង្រួញស្នូរនៅព្យាង្គមុខ ហើយសង្កត់ស្នូរនៅព្យាង្គក្រោយដូចជា៖

| | | | | |
|---|---|---|---|---|
| ប្រអប់ | > | ប្អប់ | ត្របែក | > | តបែក |
| ក្រមា | > | កមា | សៀវភៅ | > | សភៅ |

ទំនោរបង្រួញព្យញ្ជនៈ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើពាក្យបាលី សំស្ក្រឹត ដែលចូលមកលាយឡំក្នុងភាសាខ្មែរ ហើយដែលមានចំនួនព្យាង្គច្រើនដូចជា៖

ជាតិ ( Jati ) អាន ជាត ២ព្យាង្គនៅសល់ ១ព្យាង្គ

និរន្តរៈ ( Nirantara ) អាន និរាន់ ៤ព្យាង្គនៅសល់ ២ព្យាង្គ

សមាធិ ( Samadhi ) ក្លាយទៅជាស្មាធិ៍ ៣ព្យាង្គនៅសល់ ១ព្យាង្គ។

នៅមានវិធីច្រើនបែបយ៉ាងទៀត ដែលខ្មែរយកមកអនុវត្ត ដើម្បីកែប្រែ ឬបង្រួញព្យាង្គបាលី សំស្ក្រឹតឱ្យមានលក្ខណៈបែបខ្មែរឡើង ( ខេមរនីយកម្មចំនួនព្យាង្គ )។ លក្ខណៈកែប្រែនេះ ឱ្យឃើញថាខ្មែរពុំមែនចេះតែទទួលយកពាក្យបរទេសមកប្រើទាំងស្រុងទេ។

**+ អំពីស្រៈ ព្យញ្ជនៈ ព្យាង្គ**

ក្នុងការធ្វើប្រភេទវិភាគស្រៈ ព្យញ្ជនៈ ព្យាង្គ ឱ្យមានគូគ្នា ភាសាខ្មែរបានសំអាងទៅលើគោលពិសេសមួយគឺខ្យល់ អ-អ៊។ ភាសាមន គេចែកជាខ្យល់ អ-អេ ឯភាសាបាលី-សំស្ក្រឹតមានតែខ្យល់ អៈ ( a ) មួយទេ។ ចំពោះខ្យល់ អ-អ៊ រួចមកហើយ មានអ្នកខ្លះយល់ច្រឡំថាព្យញ្ជនៈណាដែលមានខ្យល់ អ ជាព្យញ្ជនៈអឃោសៈ ឯព្យញ្ជនៈណាដែលមានខ្យល់ អ៊ ជាព្យញ្ជនៈឃោសៈ។ ប៉ុន្តែតាមការពិសោធដោយគ្រឿងម៉ាស៊ីនថតសំឡេង គេបានដឹងថាព្យញ្ជនៈពួកខ្យល់ អ ក្តី ខ្យល់ អ៊ ក្តី ដែលមានសំឡេងមិនខ្ទរខ្ទារ (ថ្លង់) ហៅថាព្យញ្ជនៈ អឃោសៈ។ ចំណែកព្យញ្ជនៈឃោសៈវិញ គឺព្យញ្ជនៈពួកខ្យល់ អ ក្តី ខ្យល់ អ៊ ក្តី ដែលមានសំឡេងខ្ទរខ្ទារ (ឮ )។ ព្យញ្ជនៈ

ខ្យល់ឮមានចំនួនតិចណាស់ដូចជា ប-ប៊ ដ-ឌ ម៉-ម ណ-ន ញ៉-ញ ង៉-ង វ៉-វ ឡ-ល រ៉-រ យ៉-យ។ ដូចនេះខ្យល់ អ ពុំដូចគ្នានឹងខ្យល់ អឃោសៈ ទេ ហើយខ្យល់ អ៊ ក៏ពុំដូចគ្នានឹងខ្យល់ ឃោសៈដែរ។ ក្នុងការចែកមូលសព្ទ ( ស្រៈ ព្យញ្ជនៈ ព្យាង្គ ) ខ្យល់ អ អ៊ បានវែកញែកមូលសព្ទនោះជាគូៗគ្នាដូចជា៖

+ ស្រៈ
- ខ្យល់ អ ៖ ា ិ ី ឹ ឺ... ឧទាហរណ៍៖ តា បី...
- ខ្យល់ អ៊ ៖ ា ិ ី ឹ ឺ... ឧទាហរណ៍៖ ទា ពី...

សេចក្ដីសង្កេត៖ សញ្ញាស្រៈមានតែមួយបែប ប៉ុន្តែសម្គាល់ខ្យល់ អ ផង ខ្យល់ អ៊ ផង។

+ ព្យញ្ជនៈ
- ខ្យល់ អ ៖ ក ខ ច ឆ...
- ខ្យល់ អ៊ ៖ គ ឃ ជ ឈ...

**សេចក្ដីសង្កេត៖** ព្យញ្ជនៈនីមួយៗ ដែលយើងអាចបន្លឺបាន អាស្រ័យដោយមានខ្យល់ អ ឬ អ៊ កប់នៅក្នុងព្យញ្ជនៈនោះ ប៉ុន្តែស្រៈកប់ ឬស្រៈអនុស័យនោះពុំឃើញរូបរាងទេ។ ក្នុងព្យញ្ជនៈ ក មានស្រៈកប់ « អ » ក្នុងព្យញ្ជនៈ ជ មានស្រៈកប់ « អ៊ »។ ដោយសារមានស្រៈកប់នៅក្នុងនោះហើយ បានជាព្យញ្ជនៈមួយតួអាចទៅជាព្យាង្គមួយបានដូចជា ក ( កដៃ - កដប ) គ ( មនុស្សគ ) ត ( តជាប់គ្នា ) ជាដើម។ ប៉ុន្តែគេអាចផ្ដល់ស្រៈកប់ចេញពីតួព្យញ្ជនៈ កាលណាព្យញ្ជនៈនោះ មានមុខងារជាតួប្រកបដូចពាក្យ កាច គិត ( ច និង ត គ្មានស្រៈកប់ មានតែខ្យល់ផ្ទប់ )។

+ ព្យាង្គ
- ខ្យល់ អ ៖ ក - កម - ចុក - ញាំ...
- ខ្យល់ អ៊ ៖ គ - គម - ជុក - ញាំ...

**អំពីវិធីកម្លាយពាក្យ**

ភាសាខ្មែរយើងមានវិធីពិសេសក្នុងកម្លាយពាក្យដើម ឬឫសឱ្យក្លាយជាពាក្យផ្សេងៗ ហើយមានន័យប្លែកៗគ្នា ប៉ុន្តែស្ថិតនៅក្នុងក្រុមញាតិតែមួយដូចឧទាហរណ៍ក្នុងតារាងកម្លាយខាងក្រោមនេះ៖

| ឫស( ដែលជាកិរិយាសព្ទ ) | **កើត** | **ចាំ** | **សិត** | **ចុក** | **ជាន់** |
|---|---|---|---|---|---|
| **កិរិយាបង្ក** **( ធ្វើឱ្យ ឬញុំាងឱ្យ )** | បង្កើត | បញ្ចាំ | ផ្សិត | បញ្ចុក | បញ្ជាន់ |
| **នាម** | ខ្នើត | ច្នាំ | ស្និត | ចំនុក | ឈ្នាន់ |

| ( មនុស្ស ឬអ្នកធ្វើ ) | | | | | |
|---|---|---|---|---|---|
| នាម ( ប្រដាប់ប្រើប្រាស់ ) | ខ្នើត | ផ្នាំ | ស្និត | ផ្នុក | ឈ្នាន់ |
| នាម ( សភាព ឬអំពើ ) | កំណើត | ចំណាំ | សំណិត | ចំណុក | ជំនាន់ |

នេះជាក្បួនកម្លាយពាក្យមួយបែប ដែលមានឫសដើមជាកិរិយាសព្ទ។ ឯឫសដែលជាគុណនាម ក៏អាចកម្លាយទៅជានាមបានដែរដូចជា៖

ធំ > ទំហំ ទាប > ទំនាប ចាស់ > ចំណាស់ ខូច > កំហូច ។ល។

កំណើតពាក្យដែលក្លាយចេញពីឫសដើមបែបនេះ មានទំនាក់ទំនងទៅនឹងវិធីប្រើបទភ្ជាប់ ឬអព្ភាស។ បទភ្ជាប់ប្រើដាក់ពីខាងមុខឫសហៅថា បទមុខ ឬបុព្វបទ ដូចក្នុងពាក្យបង្កើត ( ប ជាបុព្វបទ )។ បទភ្ជាប់ណាដែលប្រើចុះកណ្ដាលឫសហៅថា បទកណ្ដាល ឬបទស្នៀត ឬអន្តរបទ ដូចពាក្យ ផ្ទាំ ផ្នាំ ចំណាំ ( ្ទ ្ន ណ ជាបទកណ្ដាល )។ បទកណ្ដាលខ្មែរប្លែកពីបទកណ្ដាលបាលី-សំស្ក្រឹត ដែលហៅថា អាគម។ អាគមគ្រាន់តែចុះមកសម្រួលការភ្ជាប់សន្ធិឱ្យពីរោះតែប៉ុណ្ណោះ ពុំមែនចុះការបំបែកឫសឱ្យមានន័យប្លែកដូចបទកណ្ដាលខ្មែរឡើយ។

ឧទាហរណ៍៖ អ + អត្ត > អ + ន + អត្ត > អនត្ត ( ន = អាគម )

ចតុ + អង្គ > ចតុ + រ + អង្គ > ចតុរង្គ ( រ = អាគម )។

ចំណែកឯបទភ្ជាប់ខាងចុងឫស ដែលហៅថា បទចុង ឬបច្ឆិមបទ ពុំឃើញមានប្រើក្នុងភាសាខ្មែរទេ។

**អំពីលិង្គ វចនៈ**

លិង្គ ពុំមែនសំដៅលិង្គរបស់មនុស្ស ឬសត្វទេ គឺលិង្គរបស់ពាក្យ។ ពាក្យដែលជានាមនៅក្នុងភាសាឥណ្ឌូ-អឺរ៉ុប សុទ្ធតែមានលិង្គសម្គាល់។ នាមបាលី-សំស្ក្រឹតមានលិង្គបីយ៉ាងគឺបុំលិង្គ(ភេទប្រុស ឬឈ្មោល) ឥត្ថីលិង្គ ( ភេទស្រី ឬញី ) និងនបុំសកលិង្គ ( មិនមែនភេទប្រុស-ស្រី )។ គេសម្គាល់លិង្គទាំងបីប្រភេទដោយសារការន្ត គឺកំណត់ត្រង់ស្រៈដែលនៅខាងចុងនៃពាក្យ។

ឧទាហរណ៍៖ ស្រៈ ា សម្គាល់បុំលិង្គ ( កុមារា ) ស្រៈ ី សម្គាល់ឥត្ថីលិង្គ ( កុមារី ) ស្រៈ អ សម្គាល់ នបុំសកលិង្គ ( អដ្ឋិ )។

វចនៈរបស់នាម ក៏មានគ្រឿងសម្គាល់ជាប់នឹងពាក្យដែរ។

ឧទាហរណ៍៖ មនុស្សោ ( ឯកវចនៈ ) មនុស្សា ( ពហុវចនៈ ) មានមុខងារជាប្រធាន។

មនុស្សំ ( ឯកវចនៈ ) មនុស្សេ ( ពហុវចនៈ ) មានមុខងារជាកម្មបទ។

ក្នុងភាសាបារាំង គេសម្គាល់លិង្គ និងវចនៈ របស់នាមដោយសារមានពាក្យនៅពីខាងមុខ ឬទ្រង់ទ្រាយនៃពាក្យនោះ។

ឧទាហរណ៍៖ la maison ( n. fém. sing. ) ; les cahiers ( n. mas. pliur. )

តើពាក្យខ្មែរមានលិង្គ និងវចនៈដែរឬទេ? សៀវភៅវេយ្យាករណ៍ខ្មែរដែលមានរួចមកហើយ ហើយដែលបានទទួលឥទ្ធិពលវេយ្យាករណ៍បាលី-សំស្ក្រឹតបានអធិប្បាយថាពាក្យខ្មែរមានលិង្គ-វចនៈដែរ ប៉ុន្តែគ្មានគ្រឿងជាប់នឹងពាក្យ ឬទ្រង់ទ្រាយសម្រាប់សម្គាល់ដូចភាសាឥណ្ឌូ-អឺរ៉ុបទេ គឺសម្គាល់តាមន័យនៃពាក្យនោះ ឬក៏បន្ថែមពាក្យពីក្រោយដូចជា៖

ប្ដី ឪពុក មនុស្សប្រុស ឆ្កែឈ្មោល... ( បុំលិង្គ )

ប្រពន្ធ ម្ដាយ មនុស្សស្រី ឆ្កែញី... ( ឥត្ថីលិង្គ )

ក្មេង ឆ្កែ ផ្ទះ បង ប្អូន... ( អលិង្គ )

នៅមានលិង្គម្យ៉ាងទៀតហៅថា នបុំសកលិង្គ គឺពុំមែនប្រុស ពុំមែនស្រី ពុំមែនញី ពុំមែនឈ្មោល គឺខ្ទើយ។

គេបានបញ្ជាក់ទៀតថា តាមបញ្ញត្តិនៃក្បួនហោរានាមរបស់មនុស្សប្រុស និងងាររបស់មន្ត្រី គឺជាបុំលិង្គ ឯនាមរបស់មនុស្សស្រី ឬនាមរបស់ស្រុក ភូមិ ខេត្ត វត្ត នគរ និងឈ្មោះគ្រឿងលេងដូចជាអង្គុញ បាយខុំ ចត្រង្គជាដើម។

ចំពោះវចនៈ គេសម្គាល់ដោយមានពាក្យភ្ជាប់ពីក្រោយ។

ឧទាហរណ៍៖ អាវមួយ ( ឯកវចនៈ ) គោ ៥ក្បាល ( ពហុវចនៈ ) ពពែមួយហ្វូង ( ពហុវចនៈ )។

ការអធិប្បាយបែបនេះ ពុំមានក្បួនខ្នាតច្បាស់លាស់ទេ ហើយការទាញភាសាខ្មែរឱ្យមានលិង្គ មានវចនៈដូចភាសាបាលី-សំស្ក្រឹតក៏ឃើញថាមិនសមហេតុផលដែរ។

បើយើងពិចារណាឱ្យបានហ្មត់ចត់ទៅ យើងនឹងឃើញថាពាក្យខ្មែរគ្មានលិង្គ គ្មានវចនៈទេ។ ប៉ុន្តែមានពាក្យសម្គាល់ភេទរបស់មនុស្សប្រុស ស្រី របស់សត្វញី ឈ្មោល ដែលគេប្រើភ្ជាប់នឹងនាមដូចជាបងប្រុស ក្មេងស្រី មាន់ញី ទាឈ្មោល និងពាក្យម៉ែ ម្ដាយ ឪពុក ជីដូន ជីតា មា មីង ពូ (ពាក្យបែបនេះមានចំនួនតិចណាស់ )។ ពាក្យសម្រាប់សម្គាល់វចនៈដូចពាក្យ មួយ ពីរ ទាំងអស់ ទាំងឡាយ ទាំងពួង ហ្វូង ។ល។ តើមានប្រយោជន៍អ្វីដែលខំធ្វើឱ្យពាក្យខ្មែរមានលិង្គ មានវចនៈ?

**អំពីសម្ពន្ធ**

ប្រសិនបើយើងយល់ថាពាក្យខ្មែរត្រូវតែមានលិង្គ មានវចនៈ ជាការឥតប្រយោជន៍សោះហើយ នាំឱ្យកាន់តែស្មុគស្មាញថែមទៀត ព្រោះក្នុងភាសាខ្មែរ ពាក្យពេចន៍នៅក្នុងឃ្លាប្រយោគពុំមានការប្រែប្រួល ផ្លាស់ប្ដូររូបរាងទៅតាមលិង្គ វចនៈ បុរិសៈ កាល ឡើយ។ ផ្ទុយទៅវិញក្នុងភាសាអម្បូរឥណ្ឌូ-អឺរ៉ុប ពាក្យកិរិយាស័ព្ទ នាមស័ព្ទ គុណនាមស័ព្ទ កាលណាតែមានទំនាក់ទំនងគ្នាក្នុងឃ្លាប្រយោគហើយត្រូវតែមានវិភត្តិជាដរាបបានសេចក្ដីថាត្រូវផ្លាស់ប្ដូររូបរាងឱ្យប្លែកពីធម្មតា។

| ឧទាហរណ៍៖ | **អហំ** | **កាឡំ** | **សុនខំ** | **បស្សាមិ** | **( ឯកវចនៈ )** |
|---|---|---|---|---|---|
| | ( ខ្ញុំ ) | ( ខ្មៅ ) | ( សុនខ ) | ( ឃើញ ) | |
| | **មយំ** | **កាឡេ** | **សុនខេ** | **បស្សាម** | **( ពហុវចនៈ )** |
| | ( យើង ) | ( ខ្មៅ ) | ( សុនខច្រើន ) | ( ឃើញ ) | |

ចំពោះរបៀបពាក្យក្នុងឃ្លាបាលីនេះ ពុំរៀបរយតាមលំដាប់លំដោយសោះ គេនិយមដាក់ច្របូកច្របល់គ្នា ប្លែកពីឃ្លាប្រយោគខ្មែរ ដែលមានលក្ខណៈសមហេតុសមផល មានលំដាប់លំដោយហូរហែគ្នាទៅតាមហេតុការណ៍ដូចជា៖

| ខ្ញុំ | ឃើញ | សុនខ | ខ្មៅ |
|---|---|---|---|
| ( ប្រធាន ) | ( កិរិយា ) | ( កម្មបទ ) | ( លក្ខណៈនៃកម្មបទ ) |

ប្រសិនបើប្រធានមានចំនួនច្រើនទៅវិញ ក៏ពាក្យទាំងនោះ ពុំប្រែប្រួលរូបរាងដែរ ហើយប្រសិនបើចង់ឱ្យឃ្លានេះមានន័យប្លែកពីមុន គេគ្រាន់តែថែមពាក្យខ្លះប៉ុណ្ណោះដូចជា៖ យើងទាំងអស់គ្នាឃើញសុនខជាច្រើន។

អាស្រ័យដោយភាសាខ្មែរគ្មានវិភត្តិបែបនេះហើយ បានជាយើងយល់ថាមិនចាំបាច់មានលិង្គ និងវចនៈសម្រាប់ពាក្យខ្មែរទេ យើងអាចចងក្រងឃ្លាប្រយោគបានយ៉ាងងាយ ព្រមទាំងមានលំដាប់លំដោយល្អផង។ លក្ខណៈពិសេសនេះបង្ហាញឱ្យឃើញថា ភាសាខ្មែរជាភាសាងាយសិក្សា ងាយយល់ជាងពពួកភាសាឥណ្ឌូ-អឺរ៉ុបឆ្ងាយណាស់។

**យោបល់រួមចំពោះភាសាខ្មែរ**

ការលើកយកលក្ខណៈសំខាន់ៗខ្លះនៃភាសាខ្មែរ មកប្រៀបធៀបនឹងភាសាបរទេសមានភាសាបាលី-សំស្ក្រឹតជាដើម ឃើញថាប្លែកគ្នាឆ្ងាយណាស់ ទាំងផ្នែកសូរ ផ្នែកសព្ទ ផ្នែកសម្ពន្ធ។ ភស្តុតាងទាំងនេះបានបញ្ជាក់ថាភាសាខ្មែរមានលក្ខណៈពិសេសរបស់ខ្លួន ពោលគឺពុំមែនកើតចេញអំពីភាសាណាមួយឡើយ។ ទំនាក់ទំនងរវាងខ្មែរនិងបរទេសធ្វើឱ្យមានល្បាយភាសាបរទេសក្នុងភាសាខ្មែរក៏ពិតមែន ប៉ុន្តែការទទួលឥទ្ធិពលភាសាបរទេសនេះ តែងប្រព្រឹត្តទៅដោយការប្រែសម្រួលឱ្យស្របស្រួលទៅនឹងភាសាជាតិ ដូចជាខេមរនីយកម្មចំពោះភាសាបាលី សំស្ក្រឹត។

ប្រសិនបើយើងបានដឹងបានយល់អំពីដើមកំណើត និងក្បួនខ្នាតដ៏ប្រពៃនៃភាសាជាតិរបស់យើងហើយ តើយើងដែលជាខ្មែរត្រូវមានករណីយកិច្ចបែបណាដែរ? ទោះបីយើងមានការលំបាកខ្លះក្នុងការសរសេរ ឬនិយាយដោយសារឥទ្ធិពលបរទេសមកលើភាសាយើងយ៉ាងណាក៏ដោយ ក៏យើងត្រូវមានស្មារតីជាតិជានិច្ចលើកតម្កើងភាសាជាតិ ដោយនាំគ្នានិយមប្រើភាសាជាតិក្នុងករណីណាដែលអាចជៀសវាងភាសាបរទេសបាន ហើយខំការពារភាសាខ្មែរដោយកុំបង្អាប់ កុំខំទាញបញ្ចូលទៅក្នុងក្បួនភាសាបរទេស។ លើសពីនេះទៅទៀត ត្រូវខំពង្រឹង និងពង្រីកឱ្យកាន់តែដុះដាលឡើង។ បើខ្មែរម្នាក់ៗមានស្មារតីជាតិបែបនេះមែន យើងសង្ឃឹមថាភាសាជាតិយើង មុខជាមានការចម្រើនលូតលាស់ ហើយនឹងបានជាគ្រឹះយ៉ាងមាំនៃជាតិខ្មែរជាពុំខាន។

## ២.៥ សូរវិទ្យា

### ២.៥.១ អំពី « ស្រៈ »

#### ២.៥.១.១ សញ្ញាស្រៈ

សញ្ញាស្រៈសម្រាប់កត់សូរមានបីយ៉ាងគឺ៖

- សញ្ញាស្រៈកប់តួ
- សញ្ញាស្រៈភ្ជាប់តួ
- សញ្ញាស្រៈពេញតួ

**សម្គាល់៖** សញ្ញាស្រៈមាន២ពួកគឺសញ្ញាស្រៈនិស្ស័យ និងសញ្ញាស្រៈពេញតួ។

**ក.សញ្ញាស្រៈកប់តួ**

សញ្ញាស្រៈកប់តួ គឺជាសញ្ញាស្រៈដែលមានស្រាប់ក្នុងសញ្ញាព្យញ្ជនៈ។ សញ្ញាស្រៈកប់តួកំណត់ដោយសញ្ញាដែលមានតាមទម្លាប់រួចមកហើយគឺសញ្ញាស្រៈ « ı » សញ្ញាស្រៈកប់តួមាន អ [ ɒː ], អ' [ ɒ ], អ៊ [ ɔː ], អ៊' [ ɔ ] ។

**ខ.សញ្ញាស្រៈនិស្ស័យ ឬសញ្ញាស្រៈភ្ជាប់តួ**

ស្រៈនិស្ស័យ គឺតួអក្សរដែលជាទីពឹងពាក់អាស្រ័យនៃព្យញ្ជនៈ។ បើសរសេរតែរូបវាដាច់តែឯងនោះនឹងពុំមានន័យប្រាកដប្រជាថាយ៉ាងណាៗនោះឡើយ ដូចជាស្រៈ ា ស្រៈ ៅ មានតែរូប និងសំឡេងផ្សំ តែពុំមានស្រៈអ្វីទេ។ សញ្ញាស្រៈភ្ជាប់តួខ្មែរយើងមានតែមួយពួក តែសូរស្រៈមាន ២ពួកគឺពួក « **អ** » និងពួក « **អ៊**» ហេតុដូចនេះ យើងមិនដឹងអានវាដូចម្ដេចទេ កាលណាវានៅម្នាក់ឯង។

ក្នុងការកំណត់តួស្រៈនិស្ស័យនៅក្នុងភាសាខ្មែរ ត្រូវបានអ្នកសិក្សាកំណត់ផ្សេងៗគ្នាផ្អែកទៅតាមអំណះអំណាងផ្សេងៗរបស់ខ្លួន។ តែចំពោះក្រសួងអប់រំ យុវជន និងកីឡា បានកំណត់យកចំនួនស្រៈនិស្ស័យខ្មែរមានចំនួន ២៣តួ ដោយបញ្ចូលក្នុងសៀវភៅសិក្សាគោលភាសាខ្មែរថ្នាក់ទី១គឺ៖



ប៉ុន្តែអស់លោកអ្នកអក្សរសាស្ត្រក្រោយមកសន្មតថាមានតែ២០តួវិញ ព្រោះថាស្រៈ ( អ ) មានតែសំឡេងតែគ្មានរូប មិនគួរនឹងរាប់បញ្ចូលទេ។ ស្រៈ ( អ ) នេះ មានបង្កប់នៅគ្រប់ព្យញ្ជនៈទាំងអស់ ទោះជាឃោសៈក្ដី អឃោសៈក្ដី ប្រសិនបើគេយកទៅផ្សំជាមួយនឹងព្យញ្ជនៈសំឡេងឃោសៈ គេអានតាមសំឡេងព្យញ្ជនៈឃោសៈ គឺសំឡេង ( អ៊ ) ឧទាហរណ៍៖ ងា ងិ ងឺ ញោ ញៅ ទុំ ទាំ ទះ...។ បើផ្សំជាមួយនឹងព្យញ្ជនៈអឃោសៈ វាមានសំឡេង ( អ ) ដូចជាកា កី កោ ចូ ចើ ចេ ចែ ចៃ ចោ...។ ចំពោះស្រៈ ួ ឿ និង ៀ ទោះគេយកទៅផ្សំនឹងព្យញ្ជនៈឃោសៈក្ដី អឃោសៈក្ដី វានៅតែមានសូរសំឡេង (អួ អឿ-អៀ ) ដូចគ្នា នេះវាជាករណីលើកលែងសម្រាប់ស្រៈនិស្ស័យរបស់ខ្មែរយើង។ រីឯស្រៈ៤ទៀតដូចជាស្រៈ ុ ិ េ វិញនោះ កាលពី

មុនលោកមិនយកមករាប់បញ្ចូលក្នុងស្រៈនិស្ស័យទេ។ ប៉ុន្តែនៅពេលក្រោយមក ដោយបានពិនិត្យឃើញថា មានពាក្យជាច្រើន ដែលត្រូវការប្រើស្រៈទាំងនេះ នៅក្នុងពាក្យខ្មែរជាចាំបាច់នោះ ទើបលោកអ្នកប្រាជ្ញជាន់ក្រោយ ក៏បានសម្រេចបញ្ចូលបន្ថែមស្រៈទាំង៤នេះ ហើយស្រៈនិស្ស័យក៏បានកើនដល់ (២១-១)+៤ = ២៤ ហើយបើបន្ថែមស្រៈ ឹះ , ស្រៈ ើះ, ស្រៈ ែះ ពីលើស្រៈនិស្ស័យដែលធ្លាប់ឃើញមាននៅក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ក្តី ក្នុងអត្ថបទនានាក្តីទៀតនោះ ស្រៈនិស្ស័យអាចកើនឡើងដល់ ២៦ ឬ២៧។

| | | | | | | | |
|---|---|---|---|---|---|---|---|
| អា | អិ | អី | អឹ | អឺ | អុ | អូ | អួ |
| អើ | អឿ | អៀ | អេ | អែ | អៃ | អោ | |
| អៅ | អុំ | អំ | អាំ | អះ | អិះ | អុះ | |
| អេះ | អោះ | | | | | | |

### គ.ស្រៈពេញតួ

សញ្ញាស្រៈពេញតួ គឺជាសញ្ញាស្រៈបែបបាលី សំស្រ្កឹត។ សញ្ញាស្រៈបែបនេះ អាចប្រើតែឯកឯងបាន ដោយពុំចាំបាច់ភ្ជាប់នឹងសញ្ញាព្យញ្ជនៈឡើយ។ ចំពោះក្រសួងអប់រំ យុវជន និងកីឡា បានកំណត់យកចំនួនស្រៈពេញតួមានចំនួន ១៥តួ ដោយបញ្ចូលក្នុងសៀវភៅសិក្សាគោលភាសាខ្មែរថ្នាក់ទី១គឺះ

អ អា ឥ ឦ ឧ

ឩ ឪ ឫ ឬ ឭ

ឮ ឯ ឰ ឱ ឳ

### ២.៥.១.២ សូរស្រៈ

សូរស្រៈ គឺជាសូរខ្យល់ដែលបន្លឺចេញមកតាមបំពង់សំឡេងបង្ហូរដោយគ្មានទំនប់ ប្រកបដោយភាពច្បាស់លាស់។ ក្នុងការបន្លឺសូរស្រៈនេះប្រដាប់បន្លឺគ្មានការប្រឹងដើម្បីបញ្ចេញសូរឡើយ។

សូរស្រៈអាចចែកតាមះ

- សូរស្រៈពួក អ អ៊ ( បញ្ចេក អ អ៊ )
- សូរស្រៈវែង ខ្លី ( បញ្ចេក វែង ខ្លី )
- សូរស្រៈទោល ផ្សំ ( បញ្ចេក ទោល ផ្សំ )
- សូរស្រៈប្រកប

**ក.សូរស្រៈពួក អ អ៊**

+សូរស្រៈពួក **អ** មាន១៦តួ លើកលែងតែ អួ អឿ អៀ ចេញ៖ អ [ ɒ: ], អ់ [ ɒ ], អា [ a: ], អា់ [ a ], អិ [ ɛ ], អី [ ɛi ], អឹ [ œ ], អឺ [ œ: ], អុ [ Ọ ], អូ [ o: ], អើ [ aə: ], អេ [ e ], អែ [ aɛ: , æ ], អៃ [ ai , aj ], អោ  [ ao: ], អៅ [ au ] ។

+សូរស្រៈពួក អ៊ មាន១៨តួ លើកលែងតែ អ៊ួ អឿ អៀ ចេញ៖ អ៊ [ ɔ: ], អ៊់ [ ɔ ], អ៊ា [ iə ], អ៊ា់ [ iə ], អ៊ិ [ i ], អ៊ី [ i: ], អ៊ឹ [ ɯ ], អ៊ឺ [ ɯ: ], អ៊ុ [ u ], អ៊ូ [ u: ], អ៊ួ [ u:ə , ua ],  អ៊ើ [ ɤ:], អ៊េ [ e: ], អ៊ែ [ ɛ: ], អ៊ែ់ [ ɛ ], អ៊ៃ  [ ei ], អ៊ោ [ o: ], អ៊ៅ [ ɔu ], អ៊ំ [ oa: ] ។

**សម្គាល់៖** សូរស្រៈ អួ អឿ អៀ អាចជាពួក អ ក៏បាន ពួក អ៊ ក៏បាន

ឧទាហរណ៍៖ កួរ គួរ តឿ ជឿ បៀរ ពៀរ ...

**ខ.សូរស្រៈវែង ខ្លី ( បញ្ចេកវែង ខ្លី )**

+ស្រៈវែង (ខ្យល់បង្ហូរវែង)មាន២១តួ៖ អ [ ɒ: ], អ៊ [ ɔ: ], អា [ a: ], អ៊ា [ iə ], អ៊ី [ i: ], អឺ [ œ: ], អ៊ឺ [ ɯ: ], អូ [ o: ], អ៊ូ [ u: ], អើ [ aə: ], អ៊ើ [ ɤ: ], អេ [ e ], អ៊េ [ e: ], អែ [ aɛ: , æ ], អ៊ែ [ ɛ: ], អោ [ ao: ], អ៊ោ [ o: ], អ៊ំ [ oa: ], អួ [ u:ə ], អឿ [ ɯ: ə], អៀ [ i:ə ]។

+សូរស្រៈខ្លី ( កាត់យ៉ាងរហ័សដោយបំណិទនៃខ្សែសំឡេង ) ជាស្រៈបន្លឺដោយដំណើរខ្យល់បង្ហូរខ្លី មាន ១៦តួ៖ អ' [ ɒ ], អ៊' [ ɔ ], អា' [ a ], អ៊ា' [ iə ], អិ [ ɛ ], អ៊ិ [ i ], អី [ ɛi ], អឹ [ œ ], អ៊ឹ [ ɯ ], អុ [ Ọ ], អ៊ុ [ u ], អ៊ែ' [ ɛ ], អៃ [ ai , aj ], អ៊ៃ [ ei ], អៅ [ au ], អ៊ៅ [ ɔu ]។

**គ.សូរស្រៈទោល ផ្សំ ( បញ្ចេក ទោល ផ្សំ )**

+សូរស្រៈទោល គឺសូរស្រៈកើតឡើងតែម្នាក់ឯង

- ស្រៈពួក អ មាន១០តួ៖ អ [ ɒ: ], អ' [ ɒ ], អា [ a: ], អា' [ a ], អិ [ ɛ ], អឹ [ œ ], អឺ [ œ: ], អុ [ Ọ ], អូ  [ Ọ: ], អេ [ e ]។
- ស្រៈពួក អ៊ មាន ១៤តួ៖ អ៊ [ ɔ: ], អ៊' [ ɔ ], អ៊ិ [ i ], អ៊ី [ i: ], អ៊ឹ [ ɯ ], អ៊ឺ [ ɯ: ], អ៊ុ [ u ], អ៊ូ [ u: ], អ៊ួ [ u:ə , ua ], អ៊ើ [ ɤ: ], អ៊េ [ e: ], អ៊ែ [ ɛ: ], អ៊ែ' [ ɛ ], អ៊ោ [ o: ]។

+សូរស្រៈផ្សំ ជាការកើតឡើងដោយស្រៈទោលពីររលាយចូលគ្នា។

- ស្រៈផ្សំពួក អ ៖ អី [ ɛi ], អើ [ aə: ], អែ [ aɛ: , æ ], អៃ [ ai , aj ], អោ [ ao: ], អៅ [ au ]។
- ស្រៈផ្សំពួក អ៊ ៖ អ៊ា [ iə ], អ៊ា' [ iə ], អ៊ៃ [ ei ], អ៊ៅ [ ɔu ], អ៊ំ [ oa: ]។
- ស្រៈផ្សំពួក អ អ៊ ៖ អួ [ u:ə ], អឿ [ ɯ:ə], អៀ [ i:ə ]។

**ឃ.សូរស្រៈប្រកប គឺជាការបន្សំសូរស្រៈនិងសូរព្យញ្ជនៈនៅខាងចុង៖**

+សូរស្រៈប្រកបពួក អ

- សូរស្រៈប្រកបនឹង ម ៖ អុម [ Ọm ], អ'ម [ ɒm ], អា'ម [ am ]
- សូរស្រៈប្រកបនឹង ហ ៖ អា'ហ [ ah ], អិហ [ ɛh ], អឹហ [ œh ], អេហ [ eh ], អុហ [ Ọh ], អ'ហ [ ɒh ]

+សូរស្រៈប្រកបនឹងពួក អ៊

- សូរស្រៈប្រកបនឹង ម ៖ អ៊ុម [ um ], អ៊'ម [ əm ], អ៊ំម [ oa:m ]
- សូរស្រៈប្រកបនឹង ហ ៖ អ៊ា'ហ [ iəh ], អ៊ិហ [ ih ], អ៊ឹហ [ ɯh ], អ៊េហ [ e:h ], អ៊ុហ [ uh ], អ៊ួហ [ u:əh ]

**កំណត់ចំណាំ៖** ស្រៈសំឡេងស្មើគ្នា

+ អែ=អ័យ អេយ្យ

- កែ ដែ ចែ ហែ ខែ
- គែ លែ មែ រែ វែ ទែ
- ច័យ វិស័យ សម័យ អាយុខ័យ
- ន័យ ជ័យ វ័យ ហទ័យ
- អធិបតេយ្យ=អធិបតៃយ៍ ប្រជាធិបតេយ្យ =ប្រជាធិបតៃយ៍

+ អាំ = អម្ម អ័ម

- កាំ ចាំ ដាំ
- មាំ គាំ លាំ រ;->ម្ម ចម្ម សម្មាទិដ្ឋិ អម្ម កម្ពុជា
- ធម្ម គម្ម

**២.៥.២ អំពី « ព្យញ្ជនៈ »**

ព្យញ្ជនៈខ្មែរទាំងអស់មាន៣៣តួ ត្រូវរាប់តាមលំដាប់ពីដើមដល់ចប់។ ព្យញ្ជនៈប្រៀបបាននឹងមនុស្សដែរ គឺមានសក់ ( ៊ ) មានតួខ្លួន ( ក ) មានជើង ( ្ក )។ រូបនៃជើងព្យញ្ជនៈមានទ្រង់ទ្រាយដូចគ្នានឹងតួព្យញ្ជនៈដែរ ប៉ុន្តែគ្រាន់តែតូចជាងតួ និងពុំមាន « សក់ » ទេ។ ខាងក្រោមនេះ គឺព្យញ្ជនៈ និងជើងព្យញ្ជនៈ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង | | | |
| ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ | | | |
| ដ្ដ | ឋ្ឋ | ឌ្ឌ | ឍ្ឍ | ណ្ណ | | | |
| ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន | | | |
| ប្ប | ផ្ផ | ព្ព | ភ្ភ | ម្ម | | | |
| យ្យ | ប្រ | ល្ល | ្វ | ស្ស | ហ្ហ | ឡ្ឡ | អ្អ |

**ការប្រើប្រាស់ជើងព្យញ្ជនៈ**

ដោយហេតុថាមានករណីដោយឡែកខ្លះ ដែលពាក់ព័ន្ធទៅនឹងជើងអក្សរព្យញ្ជនៈខ្មែរយើងនោះ យើងសូមអនុញ្ញាតជម្រាបថា៖

**<u>+ជើង " ត្ត " និងជើង " ដ្ត "</u>** មានរូបរាងដូចគ្នាអាចច្រឡំ ព្រោះការប្រើប្រាស់កន្លងមកហាក់ដូចជាច្របូកច្របល់បន្តិចដូចជាពាក្យ ស្តុកស្តឹង, ផ្តិល ( ទឹក ), ផ្តាច់ផ្តិល។ ប៉ុន្តែអ្នកប្រាជ្ញបានកំណត់ប្រើជើង ( ត្ត ) ទៅផ្ញើពីក្រោមអក្សរ ( ន ) វាមានសំឡេងជាជើង ( ត្ត ) ទាំងអស់ដូចជា ប៉ុន្តែ, កន្តែរ៉, កន្តាំង, អន្តរាយ, បន្តិចបន្តួច។ល។ លើកលែងតែពាក្យបួនម៉ាត់ចេញដែលជើង « ្ត » យកទៅផ្ញើនឹង « ន » ទៅជាមានសំឡេង « ដ » នោះគឺ សន្តោស, សន្តាន, ចិន្តា, អន្តរជាន។ ប៉ុន្តែបើជើង " ្ត " នៅផ្ញើនៅពីក្រោមតួព្យញ្ជនៈ ( ណ ) វិញនោះ វាមានសំឡេងជា « ដ » វិញ ដូចជាសណ្តែក, សណ្តាន់, កណ្តៀវ, កណ្តុរ, កណ្តាល, អណ្តូង, អណ្តើក ។ល។

**<u>+</u>ចំពោះជើង « ញ »** បើកាលណាត្រូវយកជើង ( ញ ) ទៅផ្ញើនឹងព្យញ្ជនៈ ( ញ ) នោះ អក្សរ ( ញ ) ខាងលើត្រូវកំបុតជើង ( ខ្នែង ្ញ )។ រីឯជើង ( ញ ) ដែលយកទៅផ្ញើនឹងតួ ( ញ ) នោះមានសិទ្ធិអាចរក្សាជើង ( ខ្នែង ញ ) នេះបាន។ ឧទាហរណ៍ បញ្ញើក្អែក, បញ្ញត្តិ, អនុញ្ញាត, កញ្ញា, សញ្ញា ។

**<u>+ជើង « ឡ » មិនដែលប្រើទេ</u>**

**<u>+ជើង « ្ត » និងជើង « ្វ »</u>** អាចប្រើចូលគ្នាបាន ដោយយកជើង « ្វ » ទៅផ្ញើពីក្រោមព្យញ្ជនៈ ( ព ) ដូចជា និព្វាន។

**បញ្ជាក់៖** បុព្វបុរសយើងផ្លាស់ប្តូរ ( ពៈ ) ជា ( វៈ ) គឺប្រើជាមួយគ្នាជំនួសគ្នាបាន ប៉ុន្តែគេមិនអាចយកជើង ( ព ) ទៅផ្ញើនឹងតួ ( វ ) ឡើយ។

**អំពីវគ្គ**

| | | | | | |
|---|---|---|---|---|---|
| ១-វគ្គ ( ក ) | ក | ខ | គ | ឃ | ង |
| ២-វគ្គ ( ច ) | ច | ឆ | ជ | ឈ | ញ |
| ៣-វគ្គ ( ដ ) | ដ | ឋ | ឌ | ឍ | ណ |
| ៤-វគ្គ ( ត ) | ត | ថ | ទ | ធ | ន |
| ៥-វគ្គ ( ប ) | ប | ផ | ព | ភ | ម |

តួអក្សរទាំង៨តួដែលសល់ពីវគ្គទាំង៥ខាងដើមនោះ លោកហៅថា សេសវគ្គ បានដល់៖ យ រ ល វ ស ហ ឡ អ ។

### ២.៥.២.១ សូរព្យញ្ជនៈ

សូរព្យញ្ជនៈ គឺជាសូរសំឡេងដែលកើតមកពីដំណើរខ្យល់ តាមបំពង់សំឡេង បន្លឺឡើងដោយមានទំនប់ប្រកបដោយភាពពុំច្បាស់លាស់។

**ក.ព្យញ្ជនៈទោល** គេចែកសូរព្យញ្ជនៈទោលតាមលក្ខណៈបីយ៉ាងគឺ៖

**ក.១.តាមលក្ខណៈបន្លឺ៖** តាមលក្ខណៈបន្លឺ សូរព្យញ្ជនៈទោលចែកចេញជា៖

- សូរព្យញ្ជនៈបបូរមាត់ កើតត្រង់បបូរមាត់មាន៖ « ប-ប៊ [ b ], ប៉-ព [p], ផ-ភ [ph], ម៉-ម [m] »។
- សូរព្យញ្ជនៈធ្មេញ កើតត្រង់ធ្មេញមុខមាន៖ « វ-វ៉ [ v ] »។
- សូរព្យញ្ជនៈក្រអូមមុខ កើតត្រង់ក្រអូមមុខមាន៖ « រ-រ៉ [ r ] »។
- សូរព្យញ្ជនៈគន្លាក់ក្រអូម កើតត្រង់គន្លាក់ក្រអូមមាន៖ « ដ-ឌ [ d ], ត-ទ [ t ], ឋ-ឍ-ថ-ធ [ th ], ន-ណ [ n ], ល-ឡ [ l ], ស-ស៊ [ s ] » ។
- សូរព្យញ្ជនៈក្រអូមកណ្ដាលកើតត្រង់ក្រអូមកណ្ដាលមាន៖«ច-ជ[c],ឆ-ឈ[ch],ញ៉-ញ[ɲ],យ៉-យ[j]»។
- សូរព្យញ្ជនៈក្រអូមក្រោយ កើតត្រង់ក្រអូមក្រោយមាន៖ « ក-គ [k], ខ-ឃ [kh], ង៉-ង [ ŋ ] » ។
- សូរព្យញ្ជនៈដើមមាត់ កើតត្រង់សន្ទះដើមមាត់មាន៖ « ហ-ហ៊ [ h ] »។
- សូរព្យញ្ជនៈចន្លោះខ្សែសំឡេង កើតត្រង់ចន្លោះខ្សែសំឡេងមាន៖ « អ-អ៊ [ ʔ ] »។

**ក.២.តាមលក្ខណៈខ្យល់៖** តាមលក្ខណៈខ្យល់ សូរព្យញ្ជនៈទោលចែកចេញជា៖

- សូរព្យញ្ជនៈខ្យល់ស្ទះជាសូរព្យញ្ជនៈដែលបន្លឺឡើងដោយមានរបៀបចំ បម្រើង និងបម្លាស់ប្ដូរកន្លែងនៃប្រដាប់សំឡេង។ សូរព្យញ្ជនៈខ្យល់ស្ទះចែកចេញជាពីរគឺ៖
  + សូរព្យញ្ជនៈខ្យល់ស្ទះគ្មានខ្យល់មាន៖ « ក-គ [ k ], ច-ឆ [ c ], ដ-ឌ [ d ], ត-ទ [ t ], ប-ប៊ [ b ], ប៉-ព [ p ], អ-អ៊ [ ʔ ] »។
  + សូរព្យញ្ជនៈខ្យល់ស្ទះមានខ្យល់មាន៖ « ខ-ឃ [ kh ], ជ-ឈ [ ch ], ឋ-ឍ-ថ-ធ [ th ], ផ-ភ [ ph ] » ។
- សូរព្យញ្ជនៈខ្យល់ច្រមុះ៖ ជាសូរព្យញ្ជនៈដែលបន្លឺឡើង ដោយមានភាពរំពងក្នុងច្រមុះមាន៖ « ង៉-ង [ ŋ ], ញ៉-ញ [ ɲ ], ន-ណ [ n ], ម-ម៉ [ m ] »។
- សូរព្យញ្ជនៈខ្យល់បង្ហូរត្រដុស ជាសូរព្យញ្ជនៈដែលបន្លឺឡើង ដោយមានដំណើរខ្យល់ផ្លុំបង្ហូរត្រដុសមាន៖ « យ៉-យ [ j ], រ៉-រ [ r ], ឡ-ល [ l ], វ៉-វ [ v ], ស-ស៊ [ s ], ហ-ហ៊ [ h ] » ។

**ក.៣.តាមលក្ខណៈឮ៖** តាមលក្ខណៈឮ គេចែកចេញជាសូរព្យញ្ជនៈឮ និងសូរព្យញ្ជនៈថ្លង់។

- សូរព្យញ្ជនៈឮ គឺជាសូរព្យញ្ជនៈដែលធ្វើឱ្យខ្សែសំឡេងញាប់ញ័រមាន៖ « [ d ], [ b ], [ ŋ ], [ ɲ ], [ n ], [ m ], [ j ], [ r ], [ l ], [ v ] » ។
- សូរព្យញ្ជនៈថ្លង់ គឺជាសូរព្យញ្ជនៈដែលធ្វើឱ្យខ្សែសំឡេងមិនញាប់ញ័រមាន៖ « [ k ], [ kh ], [ c ], [ ch ], [ t ], [ th ], [ p ], [ ph ], [ s ], [ h ], [ ʔ ] » ។

**សម្គាល់៖** សញ្ញាសូរព្យញ្ជនៈនីមួយៗ មានកំណត់សម្គាល់ ដោយសញ្ញាព្យញ្ជនៈពីរ គឺពួក អ មួយតួ និងពួក អ៊ មួយតួ លើកលែងតែ៖ [ th ], [ n ], [ l ] ។

**ខ.ព្យញ្ជនៈផ្សំ** គឺជាសូររួមនៃព្យញ្ជនៈពីរតួ ឬបីតួផ្សំចូលគ្នា ដែលគ្មានសូរស្រៈនៅចន្លោះ។ វាកើតឡើងដូចជា៖

- បន្សំស្ទះ + ស្ទះ ឧទាហរណ៍៖ ប្ដឹង ផ្ទី
- បន្សំស្ទះ + ប្រមុះ ឧទាហរណ៍៖ ក្ងានគ្នា
- បន្សំស្ទះ + បង្ហូរត្រដុស ឧទាហរណ៍៖ ខ្លា ត្រា
- បន្សំប្រមុះ + ស្ទះ ឧទាហរណ៍៖ ម្នាក់ ម្ខាង
- បន្សំប្រមុះ + ប្រមុះ ឧទាហរណ៍៖ ម្នាក់ ម៉្ង៉ៃ
- បន្សំប្រមុះ + បង្ហូរត្រដុស ឧទាហរណ៍៖ ម្សៅ ម្រាម
- បន្សំបង្ហូរត្រដុស + ស្ទះ ឧទាហរណ៍៖ ស្ដាយ ស្ពាយ
- បន្សំបង្ហូរត្រដុស + ប្រមុះ ឧទាហរណ៍៖ ស្វាប ស្នាម
- បន្សំប្រមុះ + បង្ហូរត្រដុស ឧទាហរណ៍៖ ស្លា ស្វា
- បន្សំបង្ហូរត្រដុស + ស្ទះចន្លោះខ្សែសំឡេង ឧទាហរណ៍៖ ស្អាប់
- បន្សំប្រមុះ + ស្ទះចន្លោះខ្សែសំឡេង ឧទាហរណ៍៖ ម្អម
- បន្សំស្ទះ + ស្ទះចន្លោះខ្សែសំឡេង ឧទាហរណ៍៖ ក្អាត់

**គ.ព្យញ្ជនៈកន្លះ** គឺជាព្យញ្ជនៈដែលមានទំនោរទៅរកស្រៈក្នុងមុខងារប្រកប។ ព្យញ្ជនៈកន្លះមាន៖

- យ៉-យ [ j ] ក្នុងមុខងារប្រកបមានទំនោរទៅរកស្រៈ [ i ] ឧទាហរណ៍៖ កាយ
- វ៉-វ [ v ] ក្នុងមុខងារប្រកបមានទំនោរទៅរកស្រៈ [ u ]ឧទាហរណ៍៖ បាវ

### ២.៥.២.២ សញ្ញាព្យញ្ជនៈ

សញ្ញាព្យញ្ជនៈសម្រាប់កត់សូរព្យញ្ជនៈ។ សញ្ញាព្យញ្ជនៈមាន៖

**ក.សញ្ញាព្យញ្ជនៈទោល**

<u>**ក.១.បញ្ចេកតាមមូលភេទ អ-អ៊**</u> សញ្ញាព្យញ្ជនៈទោលត្រូវបានចែកចេញជាពីរពួកគឺ៖

- សញ្ញាព្យញ្ជនៈទោលពួក « អ » មាន៖ ក ខ ង៉, ច ឆ ញ៉, ដ ឋ ណ, ត ថ, ប ប៉ ផ ម៉, យ៉ រ៉ ស ហ វ៉ ឡ អ។
- សញ្ញាព្យញ្ជនៈទោលពួក « អ៊ » មាន៖ គ ឃ ង, ជ ឈ ញ, ឌ ឍ, ទ ធ ន, ប៊ ព ភ ម, យ រ ល វ ស៊ ហ៊ អ៊ ។

<u>**ក.២.តាមបម្រើបម្រាស់**</u>

- សញ្ញាព្យញ្ជនៈផ្គួប់តួ គឺជាសញ្ញាព្យញ្ជនៈដើមព្យាង្គណាដែលមានស្រៈកប់តួនៅជាមួយ។

ឧទាហរណ៍៖ ក [ kɒː]    ត [ tɒː ]    កករ [ kɒ kɒː ]

- សញ្ញាព្យញ្ជនៈភ្ជាប់តួ គឺជាសញ្ញាព្យញ្ជនៈដើមព្យាង្គណាដែលមានស្រៈភ្ជាប់តួនៅជាមួយ។

ឧទាហរណ៍៖ កាយ [ kaːj ]    កែ [ kaɛː ]    ហើរ [ haəː(r) ]

**ខ.សញ្ញាព្យញ្ជនៈផ្សំ**

សញ្ញាព្យញ្ជនៈផ្សំ គឺសម្រាប់កត់សូរព្យញ្ជនៈផ្សំ។

ខ.១.បញ្ចេកតាមមូលភេទ អ អ៊ សញ្ញាព្យញ្ជនៈផ្សំត្រូវបានគេចែកចេញជាពីរពួកគឺៈ

- សញ្ញាព្យញ្ជនៈផ្សំពួក « អ » មានៈ ក្ង ខ្ន ម្គ ល្ប ស្ល...។

- សញ្ញាព្យញ្ជនៈផ្សំពួក « អ៊ » មានៈ ក្ន ខ្ព ស្គ ស្ន ស្ព...។

ខ.២.តាមបម្រើប្រាស់

- សញ្ញាព្យញ្ជនៈផ្សំផ្គប់តួ គឺជាព្យញ្ជនៈផ្សំដើមព្យាង្គណាដែលមានស្រៈកប់តួនៅជាមួយ។

ឧទាហរណ៍ៈ ស្ករ ល្អ ស្ល ស្ន...។

- សញ្ញាព្យញ្ជនៈផ្សំភ្ជាប់តួ គឺជាសញ្ញាព្យញ្ជនៈផ្សំដើមព្យាង្គណា ដែលមានស្រៈភ្ជាប់តួនៅជាមួយ។

ឧទាហរណ៍ៈ ស្តាយ ស្លែ ស្ទើរ ផ្ញើ...។

**សម្គាល់ៈ** តាមមូលភេទ អ អ៊ តម្រូវឱ្យសញ្ញាព្យញ្ជនៈណាខ្វះគូ ត្រូវបានបង្កើតបន្ថែមដោយប្រើសញ្ញាពិសេសមានសញ្ញា « អ » និងសញ្ញា « អ៊ »។

### ២.៥.៣ អំពី « ព្យាង្គ »

ព្យាង្គ ជាសូរួមនៃសទ្ទ[1] បន្លឺឡើងមួយបន្សាយសំឡេង។ ព្យាង្គនីមួយៗស្ថិតនៅក្នុងទម្រង់ដូចជាៈ

- ពស
- ពសព
- ពពស
- ពពសព។

**២.៥.៣.១ សទ្ទនៅក្នុងព្យាង្គ** នៅក្នុងព្យាង្គនីមួយៗមានៈ

- សទ្ទដើមព្យាង្គ
- សទ្ទកណ្ដាលព្យាង្គ
- សទ្ទចុងព្យាង្គ

ក.សទ្ទដើមព្យាង្គៈ ព្យញ្ជនៈទោល និងព្យញ្ជនៈផ្សំទាំងអស់ អាចប្រើជាសទ្ទដើមព្យាង្គ។

ឧទាហរណ៍ៈ កាច ក ជាសទ្ទដើមព្យាង្គ

ស្ងួង ស ជាសទ្ទដើមព្យាង្គ

ខ.សទ្ទកណ្ដាលព្យាង្គៈ ស្រៈទាំងអស់អាចប្រើជាសទ្ទកណ្ដាលព្យាង្គ។

ឧទាហរណ៍ៈ ស្ងួង ួ ជាសទ្ទកណ្ដាលព្យាង្គ

សាប ា ជាសទ្ទកណ្ដាលព្យាង្គ

គ.សទ្ទចុងព្យាង្គៈ អាចជាស្រៈ ឬព្យញ្ជនៈ។

[1] សទ្ទ គឺជាឯកតាតូចបំផុតនៃភាសា ដែលមិនអាចបំបែកតទៅទៀតបាន ហើយមិនមានន័យដោយខ្លួនឯងឡើយ។

ឧទាហរណ៍៖ លី ី ជាសទ្ទចុងព្យាង្គ

គិត ត ជាសទ្ទចុងព្យាង្គ

**២.៥.៣.២ លក្ខណៈរបស់ព្យាង្គ**

**ក.តាមមូលភេទ អ អ៊ ព្យាង្គចែកចេញជាបីពួកគឺ៖**

- ព្យាង្គពួក « អ » ប្រើសញ្ញាព្យញ្ជនៈទោល ឬព្យញ្ជនៈផ្សំដើមព្យាង្គជាពួក « អ »។

ឧទាហរណ៍៖ កាប ចាប ចឹក តៅ ថ្ងៃ ខ្មាស ត្បោក...។

- ព្យាង្គពួក « អ៊ » ប្រើសញ្ញាព្យញ្ជនៈទោល ឬព្យញ្ជនៈផ្សំដើមព្យាង្គជាពួក « អ៊ »។

ឧទាហរណ៍៖ គក់ ជាយ ទាត់ ទាយ ងាយ ស្គរ ស្នើរ ស្លែ ខ្វិល...។

- ព្យាង្គពួក « អ-អ៊ » ប្រើសញ្ញាស្រៈពួក « អ-អ៊ »។ ឧទាហរណ៍៖ ក្បរ គួរ ជឿ តឿ ចៀ ជៀ...។

**ខ.តាមលក្ខណៈខ្យល់ ព្យាង្គចែកចេញជាបួនពួកគឺ៖**

- ព្យាង្គបើក៖ សរសេរបញ្ចប់ដោយស្រៈនៅខាងចុងក្នុងទម្រង់

[ ពស ] ឧទាហរណ៍៖ កា គូ ទូ...។

[ ពពស ] ឧទាហរណ៍៖ ត្រា ស្វា ស្យា...។

- ព្យាង្គបិទ៖ សរសេរបញ្ចប់ដោយព្យញ្ជនៈនៅខាងចុង ក្នុងទម្រង់

[ ពសព ] ឧទាហរណ៍៖ កាប គូទ ទូក...។

[ ពពសព ] ឧទាហរណ៍៖ ត្រាច ស្វាង ស្យាម...។

- ព្យាង្គវែង៖ ប្រើសូរស្រៈវែង។ ឧទាហរណ៍៖ លា គូថ...។
- ព្យាង្គខ្លី៖ ប្រើសូរស្រៈខ្លី។ ឧទាហរណ៍៖ លាក់ គត់...។

**២.៥.៣.៣ សំណេរតួព្យាង្គ៖** ដោយមានភាពផ្គុំតួនៃស្រៈក្នុងតួព្យញ្ជនៈ តួព្យាង្គក្នុងភាសាខ្មែរមាន៖

- ពាក្យមួយព្យាង្គអាចប្រើព្យញ្ជនៈមួយតួ ដូចជា៖ ក ខ គ ង ច ឆ...។
- ពាក្យមួយព្យាង្គអាចប្រើព្យញ្ជនៈពីរតួ ដូចជា៖ កក កប ខក តប ចក ក្វ ក្រ ល្ហ ល្អ...។
- ពាក្យមួយព្យាង្គអាចប្រើព្យញ្ជនៈបីតួ ដូចជា៖ ខ្វរ ខ្វរ ស្ករ ស្គរ ក្អក...។
- ពាក្យពីរព្យាង្គអាចប្រើព្យញ្ជនៈពីរតួ ដូចជា៖ រហ ( ល្ហ ) រឡ ( ឮសូរយំរឡ )...។
- ពាក្យពីរព្យាង្គអាចប្រើព្យញ្ជនៈបីតួ ដូចជា៖ កករ បបរ របក របរ រហប...។
- ពាក្យពីរព្យាង្គអាចប្រើព្យញ្ជនៈបួនតួ ដូចជា៖ គម្រប ប្រកប សម្រប...។
- ពាក្យពីរព្យាង្គអាចប្រើព្យញ្ជនៈបួនតួ ដូចជា៖ កន្ត្រក កន្ត្រង កន្ត្រប...។
- ពាក្យបីព្យាង្គអាចប្រើព្យញ្ជនៈបួនតួ ដូចជា៖ កន្តរ៉...។

## ២.៦ វចនវិទ្យា

***វចនវិទ្យា*** គឺជាមែកធាងមួយនៃភាសាវិទ្យា ដែលធ្វើការសិក្សាអំពីពាក្យក្នុងភាសា។ ការសិក្សាជាមូលដ្ឋាន គឺផ្តោតលើការសិក្សាពីប្រភពរបស់ពាក្យ ( ជាតុផ្សេងៗរបស់ពាក្យក្នុងភាសា ) ឬម្យ៉ាងទៀត វចនវិទ្យាផ្តោត

ការចាប់អារម្មណ៍ទៅលើពាក្យ និងសំណុំប្រយោគដែលមានមុខងារនៅក្នុងខ្សែសម្ដីមនុស្ស។ វចនវិទ្យាក៏សិក្សាផងដែរពីគ្រប់ប្រភេទទាំងអស់នៃទំនាក់ទំនងន័យ (ន័យដូច ន័យផ្ទុយជាដើម) និងដែននៃន័យ។

តាមជាតិសព្ទ វចនវិទ្យា មានន័យថា៖ ការរៀនសូត្រអំពីពាក្យ។

វចនវិទ្យា មានប្រាំប្រភេទគឺ៖

- **វចនវិទ្យាទូទៅ៖** ជាផ្នែកមួយនៃភាសាវិទ្យាទូទៅ ដែលសិក្សាពីលក្ខណៈទូទៅរបស់ពាក្យក្នុងភាសាមួយជាក់លាក់។ វចនវិទ្យាទូទៅ មានបំណងស្វែងរកនូវលក្ខណៈសកលនៃការវិវត្ត និងគំរូរបស់ពាក្យ។ បាតុភូត និងលក្ខណៈទូទៅនៃភាសា ជាទូទៅត្រូវបានគេហៅថា សកលភាពនៃភាសា។

- **វចនវិទ្យាពិសេស៖** ជាការសិក្សាអំពីពាក្យជាក់លាក់នៃភាសាមួយ ដែលបានកំណត់។

ឧទាហរណ៍៖ ការសិក្សាអំពីពាក្យក្នុងភាសាជាក់លាក់ណាមួយដូចជា ភាសាខ្មែរ ភាសាអង់គ្លេស ភាសាបារាំង ភាសាចិន។ល។

- **វចនវិទ្យាពិពណ៌នា៖** ជាការសិក្សាពីពាក្យក្នុងទិដ្ឋភាពសមកាល។ ជាទូទៅ គឺចាប់អារម្មណ៍តែលើពាក្យ ដែលមានក្នុងទិដ្ឋភាពបច្ចុប្បន្នកាលប៉ុណ្ណោះ។

ឧទាហរណ៍៖ ការសិក្សាអំពីពាក្យកម្ចាយក្នុងភាសាខ្មែរសម័យទំនើប។

- **វចនវិទ្យាប្រវត្តិ ឬវចនវិទ្យាប្រតិកាល៖** ជាការសិក្សាពីពាក្យ និងការប្រែប្រួលរបស់ពាក្យទៅតាមកាល។ ឧទាហរណ៍៖ ក្នុងទិដ្ឋភាពវចនវិទ្យាពិពណ៌នា ពាក្យ « to take » « to adopt » ត្រូវបានគេចាត់ទុកថាជាពាក្យអង់គ្លេស។ ប៉ុន្តែប្រសិនបើយើងគិតពីទិដ្ឋភាពវចនវិទ្យាប្រវត្តិ ពាក្យទាំងពីរនេះ ត្រូវបានគេចាត់ទុកថាជាពាក្យកម្ចី។

- **វចនវិទ្យាប្រៀបធៀប៖** ជាការសិក្សាពីលក្ខណៈនៃពាក្យក្នុងភាសាពីរ ឬច្រើន។ ក្នុងផ្នែកនេះ លក្ខណៈចម្បងរបស់ពាក្យក្នុងភាសាពីរ ឬច្រើន ត្រូវបានគេយកមកធ្វើការប្រៀបធៀប។

ឧទាហរណ៍៖ ការប្រៀបធៀបរវាងពាក្យបាលី សំស្ក្រឹត ជាមួយពាក្យក្នុងភាសាខ្មែរ។

### ២.៦.១ អំពីពាក្យ

#### ២.៦.១.១ ន័យដូច

ន័យដូច គឺជាពាក្យទាំងឡាយណា ដែលមានន័យដូច ឬប្រហាក់ប្រហែលគ្នា តែសំណេរ និងសំណួរមិនដូចគ្នា។ ពាក្យន័យដូចក៏ជាប្រភេទមួយនៃពាក្យ ដែលមានន័យកំណត់ដោយទីសេចក្ដីដែរ មានន័យថា អាចជ្រើសរើសពាក្យន័យដូចណាមួយមកប្រើបាន អាស្រ័យនឹងការកំណត់របស់ទីសេចក្ដី។

ឧទាហរណ៍៖

| **ពាក្យ** | **ន័យដូច** |
|---|---|
| ចម្រើន | លូតលាស់ ដុះដាល |
| ឧបត្ថម្ភ | ជួយ ទំនុកបម្រុង |

| | |
|---|---|
| និពន្ធ | តែង សរសេរ |

### ២.៦.១.២ ន័យផ្ទុយ

**ន័យផ្ទុយ** គឺជាពាក្យទាំងឡាយណា ដែលមានន័យប្រឈមគ្នា ឬផ្ទុយគ្នា។ ពាក្យន័យផ្ទុយក៏ជាប្រភេទមួយទៀតនៃពាក្យ ដែលមានន័យកំណត់ដោយទីសេចក្ដីដែរ។

ឧទាហរណ៍៖

| **ពាក្យ** | **ន័យផ្ទុយ** |
|---|---|
| បុរាណ | ទំនើប |
| ស្រួច | ទាល |
| ស្រស់ | ស្រពោន |

### ២.៦.២ អំពីវិធីបង្កើតពាក្យ

ការបង្កើតពាក្យក្នុងភាសាខ្មែរ គេមានវិធីប្រើប្រាស់ច្រើនយ៉ាង ដែលមានដូចជាវិធីកម្លាយ វិធីកម្ចី វិធីគន្លាស់កាត់ វិធីសូរត្រាប់ធម្មជាតិ វិធីរណ្ដំបរិវារសព្ទ វិធីប្រើសំនួនវោហារសព្ទ និងវិធីបន្សំ។

### ២.៦.២.១ វិធីកម្លាយ

វិធីកម្លាយក្នុងភាសាខ្មែរមានពីរបែប គឺវិធីកម្លាយដោយផ្នត់ដើម និងវិធីកម្លាយដោយផ្នត់ដែក។

**ក.ផ្នត់ដើម៖** ពាក្យកម្លាយដែលបានមកពីការប្រើផ្នត់ដើមមានបួនទម្រង់គឺ៖

ក.១.ផ្នត់ដើមទម្រង់ [ ព- ] មាន៖

[ ក- ], [ គ- ], [ ច- ], [ ជ- ], [ ត- ], [ ទ- ], [ ប- ], [ ព- ], [ ម- ], [ ល- ], [ ស- ]

↓ ↓ ↓ ↓ ↓ ↓ ↓ ↓

[ ខ- ], [ ឃ- ], [ ឆ- ], [ ឈ- ], [ ថ- ], [ ធ- ], [ ផ- ], [ ភ- ]

ឧទាហរណ៍៖ ខ្ចាយ < ចាយ + [ ក- ]

( ធ្វើវិធីសម្រួលរូប ពាក្យឫសនៅសល់ព្យញ្ជនៈ « ខ » តែវាជាផ្នត់ដើម [ ក- ] ) ។

ឃ្លាត < លាត + [ គ- ]

( ធ្វើវិធីសម្រួលរូប ពាក្យឫសនៅសល់ព្យញ្ជនៈ « ឃ » តែវាជាផ្នត់ដើម [ គ- ] ) ។

**សម្គាល់៖** ផ្នត់ដើមទម្រង់ [ ព- ] បង្កើតពាក្យកម្លាយមួយពាក្យមាន១ព្យាង្គ ហើយជាព្យាង្គតម្រួត។

<u>ក.២.ផ្នត់ដើមទម្រង់ [ ពស- ] មាន៖</u> [ ក- ], [ គ- ], [ ច- ], [ ជ- ], [ ត- ], [ ទ- ], [ ប៉- ], [ ព- ], [ ង- ], [ ញ- ],[ ម- ], [ រ- ], [ ស- ], [ ប- ]។

**សម្គាល់៖** ផ្នត់ដើមទម្រង់ [ ពស- ] បង្កើតពាក្យកម្លាយមួយពាក្យមាន២ព្យាង្គ ដែលព្យាង្គដើមជាសញ្ញាផ្នត់ និងព្យាង្គមួយទៀតជាពាក្យឫស។

ឧទាហរណ៍៖ [ ក- ] + កាយ > កកាយ

សញ្ញាផ្នត់ ពាក្យឫស ពាក្យកម្លាយ

ក.៣.ផ្នត់ដើមទម្រង់ [ ពពស- ] មាន៖ [ ក្រ- ], [ គ្រ- ], [ ប្រ- ], [ ជ្រ- ], [ ត្រ- ], [ ទ្រ- ], [ ប្រ- ], [ ព្រ- ], [ ស្រ- ] ។

ក.៤.ផ្នត់ដើមទម្រង់ [ ពសព- ] មាន៖ [ ក'ង- ], [ ច'ង- ], [ ដ'ង- ], [ ប'ង- ], [ ស'ង- ], [ អ'ង- ], [ គ'ង- ], [ ទ'ង- ], [ រ'ង- ], [ ល'ង- ],[ ក'ញ- ], [ ប'ញ- ], [ អ'ញ- ],[ ជ'ញ- ],[ ក'ន- ], [ ច'ន- ], [ ដ'ន- ], [ ប'ន- ], [ ស'ន- ], [ អ'ន- ], [ គ'ន- ], [ ជ'ន- ], [ ទ'ន- ], [ ព'ន- ], [ រ'ន- ], [ ល'ន- ], [ ក'ម- ], [ ច'ម- ], [ ដ'ម- ], [ ប'ម- ], [ ស'ម- ], [ អ'ម- ], [ គ'ម- ], [ ជ'ម- ], [ ទ'ម- ], [ រ'ម- ], [ ល'ម- ]។

ផ្នត់ដើម [ ក- ] ទម្រង់ [ ព- ]

| **ផ្នត់ដើម** | **ទម្រង់** | **ពាក្យឫស** | **ពាក្យកម្លាយ** |
|---|---|---|---|
| [ ក- ] | [ ព- ] | បង់ | ក្បង់ |
| | | បាក់ | ក្បាក់ |
| | | ងក់ | ក្ងក់ |
| « ក » ក្លាយជា « ខ » | | ចាយ | ខ្ចាយ |
| | | ជាប់ | ខ្ជាប់ |
| | | សោះ | ខ្សោះ |

ផ្នត់ដើម [ គ- ] ទម្រង់ [ ព- ]

| **ផ្នត់ដើម** | **ទម្រង់** | **ពាក្យឫស** | **ពាក្យកម្លាយ** |
|---|---|---|---|
| [ គ- ] | [ ព- ] | មាន | គ្មាន |
| | | រង | គ្រង |
| | | រោង | គ្រោង |

| | | | |
|---|---|---|---|
| « គ » ក្លាយជា « ឃ » | | វាង | ឃ្វាង |
| | | លា | ឃ្លា |
| | | លាត | ឃ្លាត |

## ផ្នត់ដើម [ ច- ] ទម្រង់ [ ព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ច- ] | [ ព- ] | បង | ច្បង |
| | | បូត | ច្បូត |
| | | រឹង | ច្រឹង |
| « ច » ក្លាយជា « ឆ » | | កាង | ឆ្កាង |
| | | គង | ឆ្គង |
| | | លាក់ | ឆ្លាក់ |

## ផ្នត់ដើម [ ជ- ] ទម្រង់ [ ព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ជ- ] | [ ព- ] | រុល | ជ្រុល |
| | | រុះ | ជ្រុះ |
| « ជ » ក្លាយជា « ឈ » | | ងប់ | ឈ្ងប់ |
| | | ងោក | ឈ្ងោក |
| | | លប | ឈ្លប |

## ផ្នត់ដើម [ ត- ] ទម្រង់ [ ព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ត- ] | [ ព- ] | បក | ត្បក |
| | | បៀត | ត្បៀត |
| | | រឹម | ត្រឹម |
| « ត » ក្លាយជា « ថ » | | កល់ | ថ្កល់ |
| | | លៃ | ថ្លៃ |
| | | លោះ | ថ្លោះ |

## ផ្នត់ដើម [ ទ- ] ទម្រង់ [ ព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ទ- ] | [ ព- ] | រាប | ទ្រាប |
| | | រឹង | ទ្រឹង |
| | | រេល | ទ្រេល |
| « ទ » ក្លាយជា « ធ » | | លា | ធ្លា |
| | | លោ | ធ្លោ |
| | | លាក់ | ធ្លាក់ |

## ផ្នត់ដើម [ ប- ] ទម្រង់ [ ព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ប- ] | [ ព- ] | ដឹង | ប្ដឹង |
| | | រៀន | ប្រៀន |
| | | អូន | ប្អូន |

| | | | |
|---|---|---|---|
| « ប » ក្លាយជា « ផ » | | ចាញ់ | ផ្ចាញ់ |
| | | ដល់ | ផ្ដល់ |
| | | សះ | ផ្សះ |

## ផ្នត់ដើម [ ព- ] ទម្រង់ [ ព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ព- ] | [ ព- ] | យួរ | ព្យួរ |
| | | រាង | ព្រាង |
| « ព » ក្លាយជា « ភ » | | ញាក់ | ភ្ញាក់ |
| | | ជាប់ | ភ្ជាប់ |

## ផ្នត់ដើម [ ម- ] ទម្រង់ [ ព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ម- ] | [ ព- ] | ជូរ | ម្ជូរ |
| | | ជុល | ម្ជុល |

## ផ្នត់ដើម [ ល- ] ទម្រង់ [ ព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ល- ] | [ ព- ] | គាយ | ល្គាយ |
| | | វែង | ល្វែង |
| | | អៀង | ល្អៀង |

## ផ្នត់ដើម [ ស- ] ទម្រង់ [ ព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ស- ] | [ ព- ] | កក | ស្ទក |
| | | គាល់ | ស្គាល់ |
| | | បង់ | ស្បង់ |

## ផ្នត់ដើម [ ក- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ក- ] | [ ពស- ] | កាយ | កកាយ |
| | | កូរ | កកូរ |
| | | កិត | កកិត |

## ផ្នត់ដើម [ គ- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ គ- ] | [ ពស- ] | គ្រេង | គគ្រេង |
| | | គ្រឹម | គគ្រឹម |
| | | គើម | គគើម |

## ផ្នត់ដើម [ ច- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ច- ] | [ ពស- ] | ចឹក | ចចឹក |
| | | ចាក់ | ចចាក់ |
| | | ចុច | ចចុច |

### ផ្នត់ដើម [ ជ- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ជ- ] | [ ពស- ] | ជីក | ជជីក |
| | | ជ្រើស | ជជ្រើស |
| | | ជ្រុល | ជជ្រុល |
| | | ជុះ | ជជុះ |

### ផ្នត់ដើម [ ទ- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ទ- ] | [ ពស- ] | ទះ | ទទះ |
| | | ទាក់ | ទទាក់ |
| | | ធាក់ | ទធាក់ |

### ផ្នត់ដើម [ ត- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ត- ] | [ ពស- ] | តោង | តតោង |
| | | តាំង | តតាំង |
| | | តែង | តតែង |

### ផ្នត់ដើម [ ប៉- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ប៉- ] | [ ពស- ] | ប៉ប់ | ប៉ប៉ប់ |
| | | ប្រួង | ប៉ប្រួង |

| | | | |
|---|---|---|---|
| | | ប៉ាច់ | ប៉ប៉ាច់ |

## ផ្នត់ដើម [ ព- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ព- ] | [ ពស- ] | ពុះ | ពពុះ |
| | | ពាក់ | ពពាក់ |
| | | ពួក | ពពួក |

## ផ្នត់ដើម [ ង- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ង- ] | [ ពស- ] | ងីស | ងងីស |
| | | ង៉េស | ងង៉េស |
| | | ងុះ | ងងុះ |
| | | ងប់ | ងងប់ |

## ផ្នត់ដើម [ ញ- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ញ- ] | [ ពស- ] | ញ័រ | ញញ័រ |
| | | ញួរ | ញញួរ |
| | | ញាក់ | ញញាក់ |
| | | ញ៉ោះ | ញញ៉ោះ |
| | | ញ៉េះ | ញញ៉េះ |

## ផ្នត់ដើម [ ម- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ម- ] | [ ពស- ] | មិង | មមិង |
| | | ម៉េះ | មម៉េះ |
| | | មាំង | មមាំង |
| | | ម៉ោះ | មម៉ោះ |

## ផ្នត់ដើម [ រ- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ រ- ] | [ ពស- ] | គោង | រគោង |
| | | ងុំ | រងុំ |
| | | ញឹក | រញឹក |
| | | ញៀច | រញៀច |
| | | ខក | រខក |

## ផ្នត់ដើម [ ស- ] ទម្រង់ [ ពស- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ស- ] | [ ពស- ] | សៀរ | សសៀរ |
| | | ស្រាក់ | សស្រាក់ |
| | | ស្លោ | សស្លោ |
| | | ស្លន់ | សស្លន់ |
| | | សិត | សសិត |

## ផ្នត់ដើម [ ក'ង- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ក'ង- ] | [ ពសព- ] | កុញ | កង្កុញ |
| | | កួច | កង្កួច |
| | | វៀច | កង្វៀច |

## ផ្នត់ដើម [ ច'ង- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ច'ង- ] | [ ពសព- ] | គ្រោង | ចង្គ្រោង |
| | | ហួរ | ចង្ហួរ |

## ផ្នត់ដើម [ ដ'ង- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ដ'ង- ] | [ ពសព- ] | ហក់ | ដង្ហក់ |
| | | កាប់ | ដង្កាប់ |
| | | គុំ | ដង្គុំ |

## ផ្នត់ដើម [ ប'ង- ]ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ប'ង- ] | [ ពសព- ] | ក | បង្ក |
| | | កើត | បង្កើត |
| | | ខំ | បង្ខំ |

## ផ្នត់ដើម  [ ស'ង- ]ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ស'ង- ] | [ ពសព- ] | គ្រប់ | សង្គ្រប់ |
| | | កិន | សង្កិន |
| | | រៀន | សង្រៀន |
| | | រួម | សង្រួម |

## ផ្នត់ដើម [ អ'ង- ]ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ អ'ង- ] | [ ពសព- ] | រុត | អង្រុត |
| | | រឹង | អង្រឹង |
| | | គប់ | អង្គប់ |

## ផ្នត់ដើម [ គ'ង-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ គ'ង-] | [ ពសព- ] | គួន | គង្គួន |
| | | គាន | គង្គាន |

## ផ្នត់ដើម [ ទ'ង- ]ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ទ'ង- ] | [ ពសព- ] | គោល | ទង្គោល |

## ផ្នត់ដើម [ ព'ង-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ព'ង-] | [ ពសព- ] | រឹង | ពង្រឹង |
| | | រឹក | ពង្រឹក |
| | | រាប | ពង្រាប |
| | | រត់ | ពង្រត់ |
| | | វាង | ពង្វាង |

## ផ្នត់ដើម [រ'ង - ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [រ'ង - ] | [ ពសព- ] | វាស់ | រង្វាស់ |
| | | វង់ | វង្វង់ |
| | | កៀស | រង្កៀស |

## ផ្នត់ដើម [ ក'ញ-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ក'ញ-] | [ ពសព- ] | ចាស់ | កញ្ចាស់ |
| | | ឆែវ | កញ្ឆែវ |
| | | ចប់ | កញ្ចប់ |

ផ្នត់ដើម [ ប'ញ-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ប'ញ-] | [ ពសព- ] | ចប់ | បញ្ចប់ |
| | | ប្រាស | បញ្ច្រាស |
| | | ឈប់ | បញ្ឈប់ |

ផ្នត់ដើម [ អ'ញ-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ អ'ញ-] | [ ពសព- ] | ចង | អញ្ចង |
| | | ជុល | អញ្ជុល |
| | | ចាច | អញ្ចាច |
| | | ចាញ | អញ្ចាញ |
| | | ចាប | អញ្ចាប |

ផ្នត់ដើម [ ជ'ញ- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ជ'ញ- ] | [ ពសព- ] | ជាត់ | ជញ្ជាត់ |
| | | ជាន់ | ជញ្ជាន់ |
| | | ជាំង | ជញ្ជាំង |

## ផ្នត់ដើម [ ក'ន-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ក'ន-] | [ ពសព- ] | តើយ | កន្តើយ |
| | | ធាត់ | កន្ធាត់ |
| | | លង | កន្លង |

## ផ្នត់ដើម [ ច'ន-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ច'ន-] | [ ពសព- ] | ទល់ | ចន្ទល់ |
| | | លោះ | ចន្លោះ |
| | | លុះ | ចន្លុះ |

## ផ្នត់ដើម [ ដ'ន-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ដ'ន-] | [ ពសព- ] | ដឹង | ដណ្តឹង |
| | | ដាំ | ដណ្តាំ |
| | | ដើម | ដណ្តើម |

## ផ្នត់ដើម [ ប'ន-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ប'ន-] | [ ពសព- ] | តឹង | បន្តឹង |
| | | ទាប | បន្ទាប |
| | | លឺ | បន្លឺ |

### ផ្នត់ដើម [ ស'ន - ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ស'ន - ] | [ ពសព- ] | ដាន | សន្ដាន |
| | | ទូច | សន្ទូច |
| | | ទះ | សន្ទះ |

### ផ្នត់ដើម [ អ'ន- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ អ'ន- ] | [ ពសព- ] | ទាក់ | អន្ទាក់ |
| | | លើ | អន្លើ |
| | | ត្រត | អន្ត្រត |

### ផ្នត់ដើម [ គ'ន- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ គ'ន- ] | [ ពសព- ] | លាក់ | គន្លាក់ |
| | | លង | គន្លង |
| | | លោង | គន្លោង |

### ផ្នត់ដើម [ ជ'ន-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ជ'ន-] | [ ពសព- ] | ដើរ | ជណ្ដើរ |
| | | លង់ | ជន្លង់ |
| | | លួញ | ជន្លួញ |

ផ្នត់ដើម [ ទ'ន- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ទន់- ] | [ ពសព- ] | ទាន់ | ទន្ទាន់ |
| | | ទិញ | ទន្ទិញ |
| | | ទឹម | ទន្ទឹម |
| | | ទ្រាន | ទន្ទ្រាន |

ផ្នត់ដើម [ ព'ន- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ ពន់- ] | [ ពសព- ] | យល់ | ពន្យល់ |
| | | យឺត | ពន្យឺត |
| | | យារ | ពន្យារ |

ផ្នត់ដើម [ រ'ន-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ រ'ន-] | [ ពសព- ] | ដៅ | រណ្ដៅ |
| | | ដាប់ | រណ្ដាប់ |
| | | ដំ | រណ្ដំ |

ផ្នត់ដើម [ ល'ន- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ លន់- ] | [ ពសព- ] | លង់ | លន្លង់ |
| | | លោច | លន្លោច |

ផ្នត់ដើម [ ក'ម-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ក'ម- ] | [ ពសព- ] | ពៀច | កំពៀច |
| | | បាក់ | កំបាក់ |
| | | ផិត | កំផិត |

ផ្នត់ដើម [ ច'ម- ] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ច'ម-] | [ ពសព- ] | កោង | ចំកោង |
| | | បែង | ចំបែង |
| | | បាប់ | ចំបាប់ |
| | | ទែង | ចំទែង |

ផ្នត់ដើម [ ដ'ម-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ដ'ម-] | [ ពសព- ] | បូក | ដំបូក |
| | | លាន់ | ដំលាន់ |
| | | ឡើង | ដំឡើង |

ផ្នត់ដើម [ ប'ម-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ប'ម-] | [ ពសព- ] | ពើង | បំពើង |
| | | ពូក | បំពូក |

## ផ្នត់ដើម [ ស'ម-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ស'ម-] | [ ពសព- ] | ងំ | សំងំ |
| | | នឹក | សំនឹក ( កិ ) |
| | | រុក | សម្រុក |

## ផ្នត់ដើម [អ'ម-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [អ'ម-] | [ ពសព- ] | បុក | អំបុក |
| | | បែង | អំបែង |
| | | ពក | អំពក |

## ផ្នត់ដើម [គ'ម-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [គ'ម-] | [ ពសព- ] | រលេ | គំរលេ |
| | | រើល | គំរើល |
| | | រិះ | គម្រិះ |

## ផ្នត់ដើម [ជ'ម-] ទម្រង់ [ ពសព- ]

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ជ'ម-] | [ ពសព- ] | ទប់ | ជំទប់ |
| | | ពាក់ | ជំពាក់ |
| | | ទាស់ | ជំទាស់ |

| | | | |
|---|---|---|---|
| | | រើស | ជម្រើស |
| | | រត់ | ជំរត់ |

**ផ្នត់ដើម [ រ'ម-] ទម្រង់ [ ពសព- ]**

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [រ'ម-] | [ ពសព- ] | កិល | រំកិល |
| | | យោល | រំយោល |
| | | ហួត | រំហួត |
| | | ងាប់ | រំងាប់ |
| | | ដោះ | រំដោះ |

**ផ្នត់ដើម [ល'ម-  ] ទម្រង់ [ ពសព- ]**

| ផ្នត់ដើម | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ល'ម-] | [ ពសព- ] | នាច | លំនាច |
| | | នឹង | លំនឹង |
| | | នៅ | លំនៅ |
| | | ដាប់ | លំដាប់ |
| | | នាំ | លំនាំ |

**ខ.ផ្នត់ដែក** គឺជាវិធីសាស្ត្រមួយសម្រាប់ធ្វើការពែ្រកព្យាង្គ ឬក៏ព្យញ្ជនៈនៅក្នុងភាសាខ្មែរ ដែលចេញមកពីពាក្យឫសជាច្រើន ហើយគេបានបែងចែកជាប្រាំមួយទម្រង់គឺៈ

**ខ.១.ផ្នត់ដែកទម្រង់ [ -ព- ] មានៈ** [ -ប- ], [ -ង- ], [ -ន- ], [ -ម- ], [ -រ- ], [ -ល- ], [ -វ- ]។

**សម្គាល់ៈ** ផ្នត់ដែកទម្រង់ [ -ព- ] បង្កើតពាក្យកម្លាយមួយពាក្យមាន១ព្យាង្គ ដែលសញ្ញាផ្ទត់នេះ ស្ថិតនៅជាជើងក្នុងពាក្យកម្លាយ។ ឧទាហរណ៍ៈ កើត + [ -ន- ] > ខ្នើត ។

ខ.២.ផ្នត់ជែកទម្រង់ [ -ពស- ] មាន៖ [ -្រ- ] ។

ខ.៣.ផ្នត់ជែកទម្រង់ [-សព-]មាន៖ [-អ៉ង-], [-អ៊ិ'ង-], [-អ៉ញ-], [-អ៊ិ'ញ-], [-អ៉ន-], [-អ៊ិ'ន-], [-អ៉ម-], [-អ៊ិ' ម-] ។

ខ.៤.ផ្នត់ជែកទម្រង់ [ -ស/ព- ] មាន៖ [ -អ៊ិ/ន- ], [ -អ៊ិ/ប- ] ។

ខ.៥.ផ្នត់ជែកទម្រង់ [ -សព/ព- ] មាន៖ [ -អ'ម/ន- ], [ -អ៊ិ'ម/ន- ] ។

ខ.៦.ផ្នត់ជែកទម្រង់ [ -ពស/ព- ] មាន៖ [ -្រ/ម- ], [ -្រ/ន- ] ។

### ផ្នត់ជែក [ -ប- ] ទម្រង់ [ -ព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -ប- ] | [ -ព- ] | លោត | ល្បោត |
| | | លឺ | ល្បឺ |
| | | កៀស | ក្បៀស |

### ផ្នត់ជែក [ -ង- ] ទម្រង់ [ -ព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -ង- ] | [ -ព- ] | សោយ | ស្ងោយ |
| | | កែង | ក្ងែង |

### ផ្នត់ជែក [ -ន- ] ទម្រង់ [ -ព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -ន- ] | [ -ព- ] | ចាំ | ឆ្នាំ |
| | | កើយ | ខ្នើយ |
| | | បួស | ផ្នួស |

### ផ្នត់ជែក [ -ម- ] ទម្រង់ [ -ព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -ម- ] | [ -ព- ] | ចាំ | ឆ្មាំ |
| | | ដើរ | ថ្មើរ |

### ផ្នត់ជែក [ -រ- ] ទម្រង់ [ -ព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -រ- ] | [ -ព- ] | ជែក | ជ្រែក |
| | | បោះ | ប្រោះ |

### ផ្នត់ជែក [ -ល- ] ទម្រង់ [ -ព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -ល- ] | [ -ព- ] | កៀក | ក្លៀក |
| | | ឃាំង | ឃ្លាំង |

### ផ្នត់ជែក [ -វ- ] ទម្រង់ [ -ព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -វ- ] | [ -ព- ] | កាត់ | ខ្វាត់ |
| | | កែង | ខ្វែង |

### ផ្នត់ជែក [ -រ- ] ទម្រង់ [ -ពស- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -រ- ] | [ -ពស- ] | ខ្មៅ | ក្រមៅ |
| | | ខ្សែ | ក្រសែ |
| | | ស្ដី | ស្រដី |

### ផ្នត់ជែក [ -អ'ង- ] ទម្រង់ [ -សព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ'ង- ] | [ -សព- ] | ខ្ទាក់ | កង្ទាក់ |
| | | ផ្អាក | បង្អាក |
| | | ស្ងិត | សង្ងិត |

### ផ្នត់ជែក [ -អ៊'ង- ] ទម្រង់ [ -សព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ៊'ង- ] | [ -សព- ] | ព្រោះ | ពង្រោះ |
| | | ធ្វើ | ទង្វើ |
| | | ព្រាង | ពង្រាង |

### ផ្នត់ជែក [ -អ'ញ- ] ទម្រង់ [ -សព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ'ញ- ] | [ -សព- ] | ផ្ញើ | បញ្ញើ |
| | | ភ្ជាប់ | បញ្ជាប់ |
| | | ខ្ជប់ | កញ្ជប់ |

### ផ្នត់ជែក [ -អ៊'ញ- ] ទម្រង់ [ -សព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ៊'ញ- ] | [ -សព- ] | ភ្ញាក់ | ពញ្ញាក់ |

### ផ្នត់ជែក [ -អ'ន- ] ទម្រង់ [ -សព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ'ន- ] | [ -សព- ] | ក្តាប់ | កណ្តាប់ |
| | | ផ្សះ | បន្សះ |
| | | ប្តឹង | បណ្តឹង |
| | | ផ្សាយ | បន្សាយ |

### ផ្នត់ជែក [ -អ៊'ន- ] ទម្រង់ [ -សព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ៊'ន- ] | [ -សព- ] | ភ្លឺ | ពន្លឺ |
| | | ភ្លឹក | ពន្លឹក |
| | | ធ្លាក់ | ទន្លាក់ |

### ផ្នត់ជែក [ -អ'ម- ] ទម្រង់ [ -សព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ'ម- ] | [ -សព- ] | ខឹង | កំហឹង |
| | | ឆេះ | ចំហេះ |
| | | ក្រង | កម្រង |
| | | ខិត | កំហិត |
| | | ខុស | កំហុស |

## ផ្នត់ជែក [ -អ៊ិ'ម- ] ទម្រង់ [ -សព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ៊ិ'ម- ] | [ -សព- ] | ជ្រើស | ជម្រើស |
| | | ធ្វន់ | ទម្ងន់ |
| | | ធំ | ទំហំ |
| | | ឈាន | ជំហាន |
| | | ធៀប | ទំហៀប |

## ផ្នត់ជែក [ -អ៊ិ/ន- ] ទម្រង់ [ -ស/ព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ៊ិ/ន- ] | [ -ស/ព- ] | រាប | រនាប |
| | | រុក | រនុក |
| | | រាស់ | រនាស់ |

## ផ្នត់ជែក [ -អ៊ិ/ប- ] ទម្រង់ [ -ស/ព- ]

| ផ្នត់ជែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ៊ិ/ប- ] | [ -ស/ព- ] | រង | របង |
| | | រក | របក |
| | | រាំង | របាំង |

**ផ្នត់ដែក [ -អ'ម/ន- ] ទម្រង់ [ -សព/ព- ]**

| ផ្នត់ដែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ'ម/ន- ] | [ -សព/ព- ] | កើត | កំណើត |
| | | ចាស់ | ចំណាស់ |
| | | ដល់ | ដំណល់ |

**ផ្នត់ដែក [ -អ៊'ម/ន- ] ទម្រង់ [ -សព/ព- ]**

| ផ្នត់ដែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -អ៊'ម/ន- ] | [ -សព/ព- ] | គួរ | គំនួរ |
| | | គិត | គំនិត |
| | | ជន់ | ជំនន់ |

**ផ្នត់ដែក [ -រ/ម- ] និង ផ្នត់ដែក [ -រ/ន- ] ទម្រង់ [ -ពស/ព- ]**

| ផ្នត់ដែក | ទម្រង់ | ពាក្យឫស | ពាក្យកម្លាយ |
|---|---|---|---|
| [ -រ/ម- ] | [ -សព/ព- ] | ទាក់ | ទ្រមាក់ |
| | | ផឹក | ប្រមឹក |
| [ -រ/ន- ] | | ទំ | ទ្រនំ |

### ២.៦.២.២ វិធីកម្ចី

វិធីកម្ចី គឺជារបៀបដែលខ្មែរបានខ្ចីពាក្យពីភាសាដទៃមកប្រើ ដើម្បីបំពេញការខ្វះខាតពាក្យក្នុងភាសាខ្មែរ។ ពាក្យដែលបានខ្ចីប្រើច្រើនជាងគេ គឺបាលី សំស្ក្រឹត។

<u>ក.បាលីសំស្ក្រឹត៖</u> ជាភាសាគ្រឹះរបស់ខ្មែរនាសម័យដើម ហើយខ្មែរយកមកសំយោគទៅជាភាសារបស់ជាតិផងដែរ។ ឧទាហរណ៍៖ ទុក្ខ មេត្តា វិចារណ៍ សីល សីមា លង្កា លតា លទ្ធិ។

<u>ខ.បារាំង៖</u> ពាក្យកម្ចីទាំងនោះរួមមានបេតុង កុងស៊្រីយ៍ កុងតាក់ កុងស៊ុល (ក្លាយមកពីពាក្យ កុងស៊ុន) ស៊ីម៉ង់ ស៊ីក្លូ រ៉ឺម៉ក ស៊ីញេ ស៊ីរ៉ូ ស៊ីហ្គេ ឡាវហាវ ការាត់ កាសែត ក្រាម កៅស៊ូ ក្រែប ឡូ អារ៉ូកាចេរ អាស៊ី

អាហ្វ្រិក អូសេអានី អូស្ត្រាលី គីមី គីឡូ គីឡូស៊ីក គីឡូម៉ែត្រ គីឡូវ៉ុល ហ្វ្រង់ ហ្វ្រាំង ហ្វារ ឆែកឆេរ ឆៃកែវ សង់ទីម៉ែត្រ...។

គ.សៀម៖ ភាសាដែលខ្មែរបានយកពីសៀមមកប្រើមានដូចជាដួងចៃ ចោងហោង យាយ យីថោ យីស៊ុន យីហ៊ុប យោក យោក្សត្រ យោនយាន យ៉ យ៉ាក យ៉ាដាំ យ៉ាប់ឆា កាប៉ៅ កាពិ កាពិផៅ កាឡៃ ឡាំ ឡុក ឡូត ឡប់ឡៃ ឡាក ឡាយឡុង ឡិន ឡឺត ឡុងបុត ឡុងសុង ឡេវ ឡេវឡៃ ឡោ ឡោម ឡៅ អង្វរ អាប៉ោង អាប់ចុន អារីអារ៉ប ខៅតាក ខ្វាន់នាគ ខ្វាម អុង ហ្មត់ចត់ ហ្មត់ហ្មង ហ្មប ហ្មាយ ហ្លាក់ ហ្លាក់ហ្លាំង ហ្លួង ហ្វឹក ហ្វួង ហ្លួងជិន ហួងហ្វាយ លវោ អយុធ្យា ពញា ផាប៉ា ផាប់ ផាមួង ផាយោង ផាហ៊ុម ផិត ផូក ផឿក ផែន ផៅ ណាំ ណាំនួន ណៃណាន តាប់ ណាំយ៉ា ស៊ុម ឆាន់ ង៉ាវ ចក ដើមចម សាមសិប សែសិប ហាសិប ហុកសិប ចិតសិប ប៉ែតសិប កៅសិប លយ លយកែវ លយឆាយ ក្រនៀវកែវ ក្រសៃ បៀលៀង បែន បែជីកា បែតង បែមន់ មាក់ប្រេង មាក់ប្រាង មាក់ដោក សក្លាត សងខាង សង៉ា សង់ខ្យា សង្វារ សង្វៀន សជី សណ្ដាន់ សន្លប់ សប សាជៀវ សានណូវ ពិន ពិនតូ ពិផាត ពិភេក សាវ សាវកែ សាំ សាវឡិក សាវដៃ សាំប៉ែសាំម៉ា...។

**ចំណាំ៖** ចំពោះអ្នកនិពន្ធបទចម្រៀងខ្មែរ ការប្រើនូវឃ្លាប្រយោគឃើញមានពាក្យខ្លះមានភាពខុសឆ្គង ដូចជាពាក្យថា « ដួងចៃ » ដោយពាក្យ « ចៃ » គឺជាពាក្យ « ចិត្ត » របស់ថៃ។

ឃ.ចិន៖ ភាសាដែលក្លាយមកពីពាក្យចិន ដូចជាពាក្យកុង កុងស៊ី យីហោ កាវ កៅយក់ កៅឡាក់ កៅឡៅ កៅអី កៅអូរ ឡាំសាំ ឡុងចុង ឡៅតេង អាំងយី អុងប៉ាង អាំឡូ អៀម គុយទាវ ផាវ ផូយ ផួយ ផេង ទឹកស៊ីអ៊ីវ ឆា ឆាឆៅ ឆាប ឆុង ឆៃ ឆៃថាវ ឆៃប៉ូវ ងីវ ចាប់ឆាយ ចិក...។

ង.យួន៖ ជាភាសាដែលក្លាយមកពីភាសាយួន ដូចជាកំពង់ដរ ឡុកឡាក់ ឡាញ់ ឡាំប៉ា ឡូអុង ខ្វៃ ហ្វេ ផឹង ណៃម ណៃវ ងឿក...។

**ចំណាំ៖** ចំពោះការប្រើពាក្យ « ទូកដរ » វាមានលក្ខណៈខុសគ្នាដោយសារតែពាក្យ « ដរ » របស់វៀតណាម ត្រូវនឹងពាក្យ « ចម្លង » របស់ខ្មែរ។ គួរតែប្រើពាក្យថា « កំពង់ចម្លង » វិញ ទើបត្រឹមត្រូវ។

ច.ឡាវ៖ ជាពាក្យដែលក្លាយមកពីពាក្យឡាវ ដូចជាឡាប អាប៉ោង អាប់ចុន អុង ខៅតាក ហ្លាក់ហ្លួង។

### ២.៦.២.៣ វិធីបន្សំ

វិធីបន្សំមាន២យ៉ាងគឺ៖

**ក.វិធីបន្សំបែបទី១ (បែបខ្មែរ)**

ពាក្យទាំងឡាយដែលចូលខ្លួនជាសមាសធាតុផ្សំ ពុំមែនសុទ្ធតែជាពាក្យខ្មែរសុទ្ធនោះទេ វាអាចជាពាក្យខ្ចីមកពីភាសាបាលី សំស្ក្រឹត ឬភាសាផ្សេងទៀតដែរ នៅពេលពាក្យផ្សំចូលគ្នា វានៅតែគោរពតាមរចនាសម្ពន្ធនៃកន្សោមពាក្យបែបខ្មែរ។

នៅក្នុងទម្រង់ផ្សំបែបទី១ គេចែកចេញជា៣ផ្នែក គឺនាមផ្សំ គុណនាមផ្សំ កិរិយាផ្សំ។

## ក.១.នាមផ្សំ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| - ន + ន | : | ដំឡូង | + | ដូង | | | > | ដំឡូងដូង |
| - ន + ន + ន | : | ដំឡូង | + | ដៃ | + | ខ្លា | > | ដំឡូងដៃខ្លា |
| - ន + គុ | : | ទឹក | + | ខ្មៅ | | | > | ទឹកខ្មៅ |
| - ន + គុ + គុ | : | ដី | + | ស | + | ក្រហម | > | ដីសក្រហម |
| - ន + កិ | : | ទឹក | + | កក | + | | > | ទឹកកក |
| - ន + កិ + ន | : | ត្បាល់ | + | បុក | + | ស្រូវ | > | ត្បាល់បុកស្រូវ |
| - គុ + ន | : | ខ្មៅ | + | ដៃ | + | | > | ខ្មៅដៃ |
| - គុ + ន + គុ | : | ខ្មៅ | + | ដៃ | + | ក្រហម | > | ខ្មៅដៃក្រហម |
| - ន + ចំនួន | : | ម៉ោង | + | ដប់ | | | > | ម៉ោងដប់ ( ឈ្មោះផ្កា ) |

## ក.២.គុណនាមផ្សំ

| | | | | | | |
|---|---|---|---|---|---|---|
| - គុ + គុ | : | ធំ | + | ជាត់ | > | ធំជាត់ |
| | | តូច | + | ធំ | > | តូចធំ |
| | | ខ្មៅ | + | ស | > | ខ្មៅស |
| - គុ + ន | : | ខ្មៅ | + | ដៃ | > | ខ្មៅដៃ |
| | | ឆ្គួត | + | ចិត្ត | > | ឆ្គួតចិត្ត |
| | | កំបុត | + | ច្រមុះ | > | កំបុតច្រមុះ |

## ក.៣.កិរិយាផ្សំ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| - កិ + ន | : | បាក់ | + | សាច់ | | | > | បាក់សាច់ |
| | | ដើរ | + | តួ | | | > | ដើរតួ |
| | | លាក់ | + | គំនួច | | | > | លាក់គំនួច |
| - កិ + ន + ន | : | បាក់ | + | ដំរ | + | បាយ | > | បាក់ដំរបាយ |
| | | ចង | + | ស្ពាន | + | មេត្រី | > | ចងស្ពានមេត្រី |
| | | គង | + | អន្ទាក់ | + | ខ្លា | > | គងអន្ទាក់ខ្លា |
| - កិ + កិ | : | ចុះ | + | ចូល | | | > | ចុះចូល |
| | | ដើរ | + | តួ | | | > | ដើរតួ |
| | | រក | + | ស៊ី | | | > | រកស៊ី |

**ខ.វិធីបន្សំបែបទី២ ( ភាសាបាលី-សំស្រ្កឹត )**

**ខ.១.ពាក្យបន្ថែមដើម៖** ជាពាក្យសម្រាប់ដាក់នៅខាងដើមពាក្យឫសដើម្បីបង្កើតពាក្យកម្លាយ។ ពាក្យបន្ថែមដើមមាន៖ « ការ សេចក្តី ភាព អ្នក ជន ជាង... » ។

- **ការៈ** ប្រើនៅខាងដើមកិរិយាសម្គាល់អំពើរបស់នាម។

ឧទាហរណ៍៖ ការរៀន ការធ្វើ ការដេក ការប្រតិបត្តិ ...។

- **សេចក្ដី៖** ប្រើនៅមុខគុណនាម ។

ឧទាហរណ៍៖ សេចក្ដីសុខ សេចក្ដីថ្លៃថ្នូរ សេចក្ដីស្រេកឃ្លាន សេចក្ដីក្រេវក្រោធ...។

- **ភាព៖** ប្រើនៅខាងមុខគុណនាម ដើម្បីសម្គាល់សភាពរបស់នាម ។

ឧទាហរណ៍៖ ភាពសោះអង្គើយ ភាពសមរម្យ ភាពក្រីក្រ ភាពជាត់ ...។

- **អ្នក៖** ប្រើនៅមុខកិរិយា គុណនាម ឬនាមដើម្បីសម្គាល់នាមការក៍។

ឧទាហរណ៍៖ អ្នក + លេង ( កិ ) > អ្នកលេង
អ្នក + ផឹក ( កិ ) > អ្នកផឹក
អ្នក + ក្រ ( គុ ) > អ្នកក្រ
អ្នក + ជនបទ ( ន ) > អ្នកជនបទ

- **ជន៖** ប្រើនៅដើមនាម គុណនាម ឬនាមដើម្បីសម្គាល់នាមការក៍ ។

ឧទាហរណ៍៖ ជន + កំហូច ( ន ) > ជនកំហូច
ជន + កតញ្ញូ ( ន ) > ជនកតញ្ញូ

- **ជាង៖** ប្រើសម្រាប់នៅខាងដើមនាម ដើម្បីសម្គាល់នាមការក៍។

ឧទាហរណ៍៖ ជាង + ឈើ ( ន ) > ជាងឈើ
ជាង + ដែក ( ន ) > ជាងដែក

**ខ.២.ពាក្យបន្ថែមចុង** ជាពាក្យសម្រាប់បន្ថែមចុងពាក្យឫស ដើម្បីបង្កើតពាក្យកម្លាយ។ ពាក្យប្រើសម្រាប់បន្ថែមពីខាងចុងនៃពាក្យ ឬក៏សំនួនពាក្យឱ្យមានន័យកាន់តែច្បាស់លាស់។ ពាក្យទាំងនោះមានដូចជា កម្ម កិច្ច ធម៌ ភាព ករ ការី និយម ជន បុរស នារី បុគ្គល ។ល។

ឧទាហរណ៍៖ កសិកម្ម កាតព្វកិច្ច សប្បុរសធម៌។

- **កម្ម៖** ប្រើជាពាក្យបន្ថែមខាងចុងសម្រាប់សម្ដែងសកម្មភាពរបស់នាមករណ៍ ឬករណនាម។

ឧទាហរណ៍៖ ផលិត + កម្ម > ផលិតកម្ម
ហត្ថ + កម្ម > ហត្ថកម្ម

- **កិច្ច៖** ប្រើសម្គាល់អំពើត្រូវឱ្យអនុវត្ត។

ឧទាហរណ៍៖ ទស្សនៈ + កិច្ច > ទស្សនកិច្ច
ករណី + កិច្ច > ករណីកិច្ច
បដិសណ្ឋារ + កិច្ច > បដិសណ្ឋារកិច្ច

- **ធម៌៖** ប្រើសម្រាប់សម្គាល់នូវសភាព។

ឧទាហរណ៍៖ មនុស្ស + ធម៌ > មនុស្សធម៌

អរិយ + ធម៌ > អរិយធម៌

- **ភាព៖** ប្រើសម្រាប់សម្គាល់នូវសភាពទូទៅ ទោះល្អក្ដី អាក្រក់ក្ដី។

ឧទាហរណ៍៖ មិត្ត + ភាព > មិត្តភាព

ទេវ + ភាព > ទេវភាព

មនុស្ស + ភាព > មនុស្សភាព

- **ករឬ ការី៖** ប្រើសម្រាប់សម្គាល់នូវសភាពទូទៅ ទោះល្អក្ដី អាក្រក់ក្ដី។

ឧទាហរណ៍៖ កសិ + ករ > កសិករ

ផលិត + ករ > ផលិតករ

យន្ត + ការី > យន្តការី

- **ជន បុរស បុគ្គល**... សម្រាប់សម្គាល់នូវនាមការក៍ ដែលស្ថិតក្នុងសភាពលក្ខណៈណាមួយ។

ឧទាហរណ៍៖ បុព្វ + ជន > បុព្វជន

វីរៈ + បុរស > វីរបុរស

អច្ឆរិយ + បុគ្គល > អច្ឆរិយបុគ្គល

- **វិទូ៖** ប្រើសម្រាប់សម្គាល់នូវសភាពជាមនុស្ស ដែលមានចំណេះដឹងជ្រាលជ្រៅមហិមា។

ឧទាហរណ៍៖ គរុ + វិទូ > គរុវិទូ

ទស្សនៈ + វិទូ > ទស្សនវិទូ

ប្រវត្តិ + វិទូ > ប្រវត្តិវិទូ

- **និយម៖** ប្រើសម្រាប់សម្គាល់នូវទស្សនៈណាមួយ។

ឧទាហរណ៍៖ ពុទ្ធ + និយម > ពុទ្ធនិយម

ទេវ + និយម > ទេវនិយម

វិធីផ្សំពាក្យបែបបាលី សំស្ក្រឹត ក្នុងភាសាខ្មែរមាន២វិធី៖

**១. វិធីផ្សំដែលគ្មានសន្ធិ សម្រាប់ភ្ជាប់**

ឧទាហរណ៍៖ នាម + បណ្ណ = នាមបណ្ណ

កាយ + ពល = កាយពល

២.វិធីផ្សំដែលមានប្រើសន្ធិ សម្រាប់ភ្ជាប់

ឧទាហរណ៍៖ ធន + អគារ > ធនាគារ

ព្រះពុទ្ធ + បវត្តិ > ពុទ្ធប្បវត្តិ

រដ្ឋ + អភិបាល > រដ្ឋាភិបាល

សុខ + អភិបាល > សុខាភិបាល

មហា + អាត្មា > មហាត្មា

មហា + អនុភាព > មហាអនុភាព

**២.៦.២.៤ ពាក្យគន្លាស់កាត់**

ពាក្យគន្លាស់កាត់ ជាពាក្យដែលកើតពីការគន្លាស់នៃពាក្យពីរ ដោយគេកាត់ចោលមួយភាគ។ ពាក្យនេះមានលក្ខណៈពីរយ៉ាងខុសពីភាសាឯទៀតៗ។

ឧទាហរណ៍៖ កោស = កាយ + បោស > កោស (បាយ)

បង្កោង = បង្អែក + តោង > បង្កោង (តែក)

**២.៦.២.៥ វិធីត្រាប់សូរធម្មជាតិ**

ពាក្យខ្លះបង្កើតឡើងតាមការស្ដាប់សូរធម្មជាតិ សំឡេងសត្វស្រែក ខ្យល់បក់ ទឹកហូរ ដូចជា៖ វ៉ូៗ តុកៗ ប៉ាំងៗ គូកៗ ជាដើម។

**២.៦.២.៦ វិធីរណ្ដំបរិវារសព្ទ**

បង្កើតពាក្យដោយការផ្លួនស្រៈ ឬព្យញ្ជនៈនៃព្យាង្គរបស់ពាក្យបង្គោលទៅនឹងព្យាង្គបរិវារសព្ទ។

ឧទាហរណ៍៖ ឃ្លេងឃ្លោង ក្រឡិចក្រឡុច មាំមួន ទ្រេតទ្រោត ប្រើប្រាស់ ក្រវេមក្រវាម...។

**២.៦.៣.ថ្នាក់ពាក្យ**

គេចែកពាក្យដែលយើងប្រើសព្វថ្ងៃជា៨ក្រុម ឬជាថ្នាក់ដូចជា៖ នាម សព្វនាម គុណនាម កិរិយាសព្ទ គុណកិរិយា ចំណងធ្នាក់ ចំណងឈ្នាប់ និងឧទានសព្ទ។

**២.៦.៣.១ នាមសព្ទ**

នាមសព្ទ គឺជាពាក្យ ឬកន្សោមពាក្យសម្រាប់ប្រាប់ឈ្មោះមនុស្ស សត្វ រុក្ខជាតិ ទីកន្លែង វត្ថុ ធម្មជាតិ។ ឧទាហរណ៍៖ តុ ទូ កៅអី...។ ប្រភេទរបស់នាមក្នុងភាសាខ្មែរមានដូចជា៖

- **នាមសាធារណ៍ ឬសាធារណនាម៖** ជានាមសម្ដែងប្រាប់ឈ្មោះទូទៅ មិនចំពោះ។
  ឧទាហរណ៍៖ ទន្លេ ផ្ទះ ប្រាសាទ...។
- **នាមអសាធារណ៍ ឬអសាធារណនាម៖** ជានាមសម្ដែងប្រាប់ឈ្មោះចំពោះ មិនទូទៅ។
  ឧទាហរណ៍៖ ទន្លេសាប ផ្ទះលោកហ្លួងរតនសម្បត្តិ ប្រាសាទព្រះវិហារ...។
- **នាមរូបី៖** ជានាមបង្ហាញពីមនុស្ស សត្វ វត្ថុ ឬរុក្ខជាតិ ដែលយើងដឹងបានដោយវិញ្ញាណ។
  ឧទាហរណ៍៖ កសិករ គោ ដើមត្នោត...។
- **នាមអរូបី៖** ជានាមដែលបង្ហាញពីអំពើ គុណភាព ភាព ឬលក្ខណៈរបស់មនុស្ស សត្វ ឬក៏វត្ថុ។
  ឧទាហរណ៍៖ សម្ដីមាស ភាពក្លាហាន មោទកភាព...។
- **នាមជីវចលៈ** ជានាមទាំងឡាយណាដែលបង្ហាញពីភាវៈមានជីវិត និងមានសកម្មភាពក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ឧទាហរណ៍៖ <u>មីងសំ</u>និយាយជាមួយ<u>ពូសុខ</u>។

- **នាមអជីវចលៈ** ជានាមទាំងឡាយណាដែលបង្ហាញពីភាវៈគ្មានជីវិត ឬមានជីវិតដែរ តែពុំមានសកម្មភាពក្នុងជីវិតរស់នៅទេ។ ឧទាហរណ៍៖ មីងសំហូបស្វាយ។
- **នាមករណ៍៖** ជានាមសម្ដែងសភាព ឬសកម្មភាពបែបណាមួយ។
  ឧទាហរណ៍៖ មោទកភាព ការអនុវត្ត សេចក្ដីស្នេហា...។
- **នាមការក៍៖** ជានាមសម្ដែងប្រាប់អ្នកធ្វើអំពើ ឬអ្នកមានសភាពលក្ខណៈបែបណាមួយ។
  ឧទាហរណ៍៖ កសិករ នាយក សិល្បករ អ្នកក្រូ...។
- **នាមនាប់៖** ជានាមដែលសម្គាល់ឯកតាមនុស្ស សត្វ រុក្ខជាតិ រង្វាស់រង្វាល់ដែលគេប្រើរាប់ចំនួន។ នាមនាប់មាន៖ នាក់ ក្រុម ពួក គូ នឹម ហ្វូង ស្និត ផ្លូន ឡូ ឈុត កំផ្លេ គ្រឿង គីឡូ...។
- **ពាក្យផ្សំ៖** ជាពាក្យដែលកើតឡើងដោយពាក្យមួយរួមនឹងពាក្យមួយទៀត។
  ឧទាហរណ៍៖ ទឹកក្រូច ចិត្តក្ដៅ ត្បាល់កិនស្រូវ...។

### ២.៦.៣.២.គុណនាម

គុណនាម គឺជាពាក្យសម្ដីសម្ដែងបញ្ជាក់លក្ខណៈរបស់នាម។

ឧទាហរណ៍៖ **តុល្អ**ធ្វើពីឈើបេង។

ប្រភេទនៃគុណនាមក្នុងភាសាខ្មែរចែកចេញជាពីរប្រភេទ៖

- **គុណនាមប្រក្រតី៖** បំពេញន័យនាមឱ្យច្បាស់លាស់។ គុណនាមប្រក្រតីមានពាក្យ៖ ខ្ពស់ ទាប ល្អ អាក្រក់ មូល ជ្រុង ទាល ស្រួច...។ ឧទាហរណ៍៖ តុល្អធ្វើអំពីឈើបេង។
- **គុណនាមកំណត់៖** កំណត់ន័យឱ្យនាម។ គុណនាមកំណត់ចែកចេញជា៖
  - **គុណនាមចង្អុល៖** កំណត់ចង្អុលបង្ហាញមនុស្ស សត្វ វត្ថុ ទីកន្លែង និងភាវៈផ្សេងៗ ដែលស្ថិតនៅក្នុងស្ថានភាពបែបណាមួយ។ គុណនាមចង្អុលមានពាក្យ៖ នេះ នោះ។
    ឧទាហរណ៍៖ តុនេះស្អាត។
  - **គុណនាមកម្មសិទ្ធ៖** កំណត់បង្ហាញម្ចាស់កម្មសិទ្ធ។ គុណនាមកម្មសិទ្ធមានពាក្យ៖ ខ្ញុំ គាត់ ឯង វា គេ យើង នាង...។
    ឧទាហរណ៍៖ ម្ដាយខ្ញុំទៅផ្សារ។
  - **គុណនាមចំនួន៖** បង្ហាញពីចំនួន បរិមាណ និងលំដាប់។ គុណនាមនេះមានពីរគឺ៖
    - ចំនួនរៀប៖ សម្រាប់រាប់ឱ្យដឹងទី ជាន់ ថ្នាក់ ប៉ុណ្ណេះ ប៉ុណ្ណោះ។
      ឧទាហរណ៍៖ យើងរៀនថ្នាក់ទី១០។
    - ចំនួនរាប់៖ សម្រាប់រាប់ឱ្យដឹងថាមានចំនួនប៉ុណ្ណេះប៉ុណ្ណោះ។
      ឧទាហរណ៍៖ សិស្សប្រាំនាក់កំពុងជជែកគ្នា។
  - **គុណនាមសំណួរ៖** សម្រាប់បង្កើតល្បះសំណួរ ដើម្បីសួររកឯកលក្ខណភាពណាមួយ។
    ឧទាហរណ៍៖ សុខទិញប៊ិកប៉ុន្មាន?

- **គុណនាមមិនច្បាស់៖** ប្រាប់សេចក្ដីមិនច្បាស់ មិនជាក់លាក់។
  ឧទាហរណ៍៖ វាទិញប៊ិកពីរបីដើម។
- **គុណនាមពណ៌** : ប្រាប់ពីពណ៌នៃនាមទាំងឡាយ។
  ឧទាហរណ៍៖ សំពត់ខៀវ អាវស...។

### ២.៦.៣.៣ សព្វនាម

សព្វនាម គឺជាពាក្យប្រើសម្រាប់ជំនួសឱ្យនាម ឬកន្សោមនាម ឬក៏បង្ហាញបុគ្គលកំពុងប្រាស្រ័យទាក់ទងគ្នា។ ឧទាហរណ៍៖ ធីតាជាសិស្សពូកែ។ នាងជាសិស្សថ្នាក់ទី៩។

**ប្រភេទរបស់សព្វនាមនៅក្នុងភាសាខ្មែរមាន៖**

- **សព្វនាមបុរិសៈ៖** ប្រើជំនួសឱ្យនាម ឬកន្សោមនាម និងបង្ហាញពីបុគ្គលដែលរួមប្រាស្រ័យទាក់ទងគ្នា មានពាក្យ **ខ្ញុំ ឯង គាត់ គេ អ្នក វា យើង ពួកគេ**។
  ឧទាហរណ៍៖ ពួកគេប្រឹងរៀនណាស់។
- **សព្វនាមចង្អុល៖** ប្រើសម្រាប់បង្ហាញឱ្យឃើញច្បាស់ពីទីជិត ឬទីឆ្ងាយ មានពាក្យ **នេះ នោះ អានេះ អានោះ**។
  ឧទាហរណ៍៖ **នេះ** ជាសៀវភៅខ្ញុំ។
- **សព្វនាមសំណួរ៖** ប្រើជំនួសកន្សោមនាមដែលជាចម្លើយនៃសំណួរ និងសម្រាប់បង្កើតល្បះសំណួរ។ សព្វនាមនេះមានពាក្យ៖
  - សម្រាប់មនុស្ស៖ អ្នកណា នរណា អ្នកណាមួយ នរណាខ្លះ...។
    ឧទាហរណ៍៖ អ្នកណាដើរ?
  - សម្រាប់សត្វ៖ ស្អី ស្អីខ្លះ...។
    ឧទាហរណ៍៖ ស្អីរត់អម្បាញ់មិញ?
  - សម្រាប់វត្ថុ៖ អី អ្វី អ្វីមួយ អ្វីខ្លះ? ឧទាហរណ៍៖ អ្នកឈ្មោះអ្វី?
- **សព្វនាមមិនច្បាស់៖** ប្រើសម្រាប់ជំនួសឱ្យកន្សោមនាមណាមួយ ដែលគេលាក់ទុកព័ត៌មាន ពុំចង់ប្រាប់។ សព្វនាមនេះមានពាក្យ ម្នាក់ អ្វីមួយ ស្អីមួយ ច្រើនគ្នា គ្មានអ្វីមួយ ទាំងអស់...។
  ឧទាហរណ៍៖ ទាំងអស់គ្នាត្រូវខិតខំរៀន។
- **សព្វនាមឈ្នាប់៖** ប្រើជំនួសកន្សោមនាម និងបង្កើតឃ្លាវណបា។ សព្វនាមនេះមានពាក្យ «ដែល» តែមួយគត់។ ឧទាហរណ៍៖ សំហូបនំអន្សមដែលម្ដាយគាត់វេច។
- **សព្វនាមឆ្លុះ៖** សម្រាប់បញ្ជាក់អំពើរបស់ប្រធាន ដែលត្រូវធ្វើដោយខ្លួនឯងផ្ទាល់។ សព្វនាមនេះមានពាក្យ ខ្លួនខ្ញុំ ខ្លួនឯង ខ្លួនគាត់...។ ឧទាហរណ៍៖ គាត់ធ្វើលំហាត់ពិបាកនេះខ្លួនឯង។

**២.៦.៣.៤ កិរិយាសព្ទ**

កិរិយាសព្ទ គឺជាពាក្យសម្ដែងនូវអំពើរបស់ប្រធាន។ ឧទាហរណ៍៖ ធីតារត់។ ប្រភេទរបស់កិរិយាសព្ទនៅក្នុងភាសាខ្មែរមានដូចជា៖

- **កិរិយាសុទ្ធ៖** ជាកិរិយាសព្ទសម្ដែងនូវអំពើរបស់ប្រធាន ដែលធ្វើដោយខ្លួនឯងផ្ទាល់។ កិរិយាសុទ្ធមានពាក្យ ហូប ផឹក ស៊ី ប្រឆាំង ភ្ជួរ ប្រយុទ្ធ ស្រុះស្រួល យល់ព្រម វិភាគ និយាយ លុប បើក...។ ឧទាហរណ៍៖ កសិករភ្ជួរស្រែ។
- **កិរិយាហេតុ៖** ជាកិរិយាសព្ទសម្ដែងនូវអំពើរបស់ប្រធាន ដែលធ្វើឡើងគ្រាន់តែជាហេតុដើមប៉ុណ្ណោះ។ កិរិយាហេតុមានពាក្យ ពន្យល់ ពន្សឺត ពន្យារ បន្សាប បន្ទាប ផ្ដេក បន្ទុំ ផ្សាយ ផ្សឹក ង្រៀន ពង្រីក បង្ហាត់...។ ឧទាហរណ៍៖ គ្រូបង្រៀនសិស្ស។
- **កិរិយាសកម្ម៖** ជាកិរិយាដែលត្រូវការកម្មបទ។ កិរិយាសកម្មមានពាក្យ រៀន ដេញ បង្ហូរ ផ្ដល...។ កិរិយាចែកជាកិរិយាសកម្មផ្ទាល់ និងកិរិយាសកម្មមិនផ្ទាល់។
  ឧទាហរណ៍៖ ថ្ងៃនេះសិស្ស**រៀន**ភាសាខ្មែរ។ ( រៀន ជាកិរិយាសកម្មផ្ទាល់ )
  ឧទាហរណ៍៖ ថ្ងៃនេះ សិស្ស**រៀន**អំពីភាសាខ្មែរ។ ( រៀន ជាកិរិយាសកម្មមិនផ្ទាល់ )
- **កិរិយាអកម្ម៖** ជាកិរិយាដែលមិនត្រូវការកម្មបទ។ កិរិយាអកម្មមានពាក្យ យំ ព្រុស វងារ រត់ សើច ដើរ ឡូឡា...។ ឧទាហរណ៍៖ ក្មេងៗឡូឡា។
- **កិរិយាចំណង៖** ជាកិរិយាសម្រាប់ចងធាតុនឹងធាតុមួយទៀត មានពាក្យ ជា ទៅជា ក្លាយជា ប្រែជា ហាក់ដូចជា ឡើងជា...។ ឧទាហរណ៍៖ ធីតាក្លាយជាសិស្សគំរូ។
- **កិរិយាជំនួយ(ជំនួយកិរិយា) ៖** ជាកិរិយាសម្រាប់ជួយបង្គ្រប់ន័យសេចក្ដីកិរិយាបង្គោលណា មួយក្នុងល្បះ។ កិរិយាជំនួយមានដូចជា៖
  - កិរិយាបំពេញ(ជំនួយបំពេញ)៖ ជាជំនួយដែលបង្ហាញលទ្ធផល ឬលទ្ធភាពរបស់កិរិយាបង្គោល។ កិរិយានេះឈរនៅខាងស្ដាំកិរិយាបង្គោលជានិច្ច មានពាក្យ ឃើញ បាន កើត ទាន់ លក់ ចេះ ខាន រួច ឮ មុត ចប់ តាម...។ ឧទាហរណ៍៖ គាត់ស្ដាប់ឮ។
  - កិរិយាទិសដៅ(ជំនួយទិសដៅ)៖ ជាជំនួយដែលប្រើសម្រាប់ប្រាប់ទិសដៅរបស់កិរិយាបង្គោល។ កិរិយានេះឈរនៅខាងស្ដាំកិរិយាបង្គោលជានិច្ច មានពាក្យ មក ទៅ ចេញ ជូន ឱ្យ ចុះ ឡើង ចូល កាត់ តាម...។ ឧទាហរណ៍៖ សំដើរកាត់។
  - កិរិយាមុខ ឬកិរិយាខាងដើម(ជំនួយដើមកិរិយា) ជាជំនួយដែលប្រើនៅខាងឆ្វេងកិរិយា មានពាក្យ ចង ចូលចិត្ត ប៉ងប្រាថ្នា អាច បាន មាន ត្រូវ ហ៊ាន ដូចជា ធ្លាប់ ប្រញាប់ ខ្ជិល ឧស្សាហ៍ ប្រសប់ ឆាប់ ចាប់ ឱ្យ ចេះ ក្រ ប្រែក្លាយជា នៅ...។
    ឧទាហរណ៍៖ គាត់ឱ្យរៀបចំផ្ទះ។

- កិរិយានុគ្រោះ សម្រាប់សម្ដែងគុណលក្ខណៈរបស់កិរិយាបង្គោល មានពាក្យ ជិត ក៏ កាន់តែ គ្រាន់តែ គួរតែ ត្រូវតែ ច្រើនតែ ចេះតែ សុទ្ធតែ សឹងតែ មុខតែ ស្ទើរតែ នឹង ជួយ សូម សុំ គួរ កុំ មិនមែន មិន...ទេ ពុំ...ទេ ចូរ... ។
  ឧទាហរណ៍៖ ចូរគេងឱ្យបានច្រើន។
  ឧទាហរណ៍៖ គាត់មិនចូលចិត្តស្វាយទេ។

### ២.៦.៣.៥ គុណកិរិយា ឬកិរិយាវិសេសន៍

គុណកិរិយា ឬកិរិយាវិសេសន៍ គឺជាពាក្យសម្រាប់សម្ដែងនូវលក្ខណៈរបស់កិរិយាសព្ទ គុណនាម ឬ គុណកិរិយាខ្លួនវា។

ឧទាហរណ៍៖ សម្ដែងនូវលក្ខណៈរបស់កិរិយា → ជីតារត់លឿន។
សម្ដែងនូវលក្ខណៈរបស់គុណនាម → ជីតាស្អាតណាស់។
សម្ដែងនូវលក្ខណៈរបស់គុណកិរិយា → ជីតារត់លឿនណាស់។

ប្រភេទរបស់គុណកិរិយាក្នុងភាសាខ្មែរមាន៖

- **គុណកិរិយាបំណែប៖** ជាគុណកិរិយាប្រាប់ពីបែបបទនៃអំពើរបស់កិរិយា មានពាក្យ លឿន យឺត ឆាប់ រហ័ស រឿយៗ រឹចៗ ល្ងើយៗ ខ្លាំងៗ តិចៗ សន្សឹមៗ គើមៗ។
  ឧទាហរណ៍៖ វាដើរយឺត។
- **គុណកិរិយាបរិមាណ៖** ជាគុណកិរិយាបញ្ជាក់បរិមាណឱ្យកិរិយា គុណនាម ឬគុណកិរិយាខ្លួនឯង មានពាក្យ ជាង ណាស់ តិច ច្រើន ពេក ហួស ល្មម...។
  ឧទាហរណ៍៖ សិស្សនេះ ឆ្លាតណាស់។
- **គុណកិរិយាកន្លែង៖** ជាគុណកិរិយាប្រាប់ទីកន្លែងនៃអំពើរបស់កិរិយា មានពាក្យ ខាងលើ ខាងក្រោម ខាងក្នុង ខាងក្រៅ ខាងមុខ ឆ្ងាយ ជិត អាយ ឯនាយ ទីនេះ ទីនោះ...។
  ឧទាហរណ៍៖ សំចេញទៅខាងក្រៅហើយ។
- **គុណកិរិយាកាល៖** ជាគុណកិរិយាប្រាប់ពេលវេលានៃអំពើរបស់កិរិយា មានពាក្យ ស្អែក ម្សិលមិញ ឆ្នាំទៅ ខានស្អែក សព្វថ្ងៃ ពេលនេះ កាលពីមុន...។
  ឧទាហរណ៍៖ ម្សិលមិញ ខ្ញុំសរសេររឿងនិទាន។
- **គុណកិរិយាសំណួរ៖** ជាគុណកិរិយាសម្រាប់សួររកទីកន្លែង កាល បែបបទ បំណងរបស់កិរិយា។ វាមានពាក្យសម្រាប់សួររក៖
  - ទីកន្លែង៖ ណា កន្លែងណា ឯណា ទីណា...។
    ឧទាហរណ៍៖ តើឯងរស់នៅឯណា?
  - កាល៖ ពេលណា កាលណា ពេលណាខ្លះ ពីអង្កាល់ ម៉ោងប៉ុន្មាន...។
    ឧទាហរណ៍៖ តើឯងទៅម៉ោងប៉ុន្មាន?
  - ហេតុ៖ ហេតុអ្វីបានជា មូលហេតុអ្វីបានជា ហេតុដូចម្ដេចបានជា...។

ឧទាហរណ៍៖ ហេតុអ្វីឯងសើច?

- បែបបទ៖ ដូចម្ដេច យ៉ាងដូចម្ដេច ដូចម្ដេចខ្លះ...។

ឧទាហរណ៍៖ តើឯងគិតដូចម្ដេច?

- បំណង៖ ដើម្បីអ្វី? ក្នុងបំណងអ្វី?

ឧទាហរណ៍៖ តើអ្នករៀនដើម្បីអ្វី?

### ២.៦.៣.៦.ធ្នាក់ ឬចំណងធ្នាក់

ធ្នាក់ ឬចំណងធ្នាក់ គឺជាពាក្យ ឬកន្សោមពាក្យដែលប្រើនៅពីមុខនាម ឬសព្វនាម។ ធ្នាក់មានពាក្យ លើ ក្រោម នឹង ក្នុង ក្បែរ ក្រោយ ក្រៅ ចំពោះ ជាមួយ ជិត ដល់ ដើម្បី ដោយ នូវ នៃ របស់ ព្រោះ ពីព្រោះ...។ ធ្នាក់មាននាទីបង្កើតកន្សោមមានធ្នាក់ ( កមធ )។ ឧទាហរណ៍៖ កុមារដើរក្នុងសួន។

ទម្រង់របស់កន្សោមមានធ្នាក់មានដូចជា៖

ធ + ន. → នឹងស្លាបព្រា

ធ + កិ. → ដោយយកចិត្តទុកដាក់

ធ + សព្វ. → ជាមួយគាត់

ធ + គុ. → ព្រោះឧស្សាហ៍

ធ + គុណ. → ជាមួយយ៉ាងសប្បាយរីករាយ

កន្សោមមានធ្នាក់នេះ មានមុខងារ៖

- បើវាជាធាតុសំណង់របស់កន្សោមនាម វាមានមុខងារជាកម្មបំពេញបទ។
- បើវាជាធាតុសំណង់របស់កន្សោមកិរិយា វាមានមុខងារពីរគឺ៖

▪ មុខងារជាកម្មបទមិនផ្ទាល់៖ មេរៀននេះ និយាយអំពីចំណងធ្នាក់។

▪ មុខងារជាកម្មទេសកាលមាន៥គឺ៖

  - កម្មទេសកាលកាល៖ កសិករទៅធ្វើចម្ការ ពីព្រឹក។
  - កម្មទេសកាលកន្លែង៖ កសិករបររទេះ តាមផ្លូវជាតិ។
  - កម្មទេសកាលបំណង៖ កសិករធ្វើចម្ការ ដើម្បីផលដំណាំ។
  - កម្មទេសកាលបំណែប៖ កសិករធ្វើចំការ យ៉ាងប៉ិនប្រសប់។
  - កម្មទេសកាលហេតុ៖ កសិកទំនេរពីចំការ ព្រោះរដូវភ្លៀង។

### ២.៦.៣.៧ ឈ្នាប់ ឬចំណងឈ្នាប់ ( សន្ធានសព្ទ )

ឈ្នាប់ ឬចំណងឈ្នាប់ គឺជាពាក្យចំណងសម្រាប់ចងពាក្យនិងពាក្យ ឃ្លានិងឃ្លា ល្បះនិងល្បះ និងប្រើសម្រាប់បង្កើតឃ្លារណបក្នុងល្បះផងដែរ។

ឧទាហរណ៍៖ គ្រូនិងសិស្សនាំគ្នាធ្វើកសិកម្មសម្អាតទីធ្លាសាលា។

ចំណងឈ្នាប់ចែកចេញជាពីរប្រភេទ គឺឈ្នាប់ចង និងឈ្នាប់ឃ្លា។

**ក. ឈ្នាប់ចង៖** ជាឈ្នាប់សម្រាប់ចងពាក្យ កន្សោមពាក្យ ឬល្បះទោលពីរដែលមានលំនឹងស្មើគ្នា គ្មានមួយណារណបមួយណាឡើយ។ ឈ្នាប់ចងមានច្រើនដូចជា៖

- សម្រាប់សម្គាល់ « ការបូកគ្នា »៖ និង ហើយនិង ព្រមជាមួយ រួមនឹង ព្រមទាំង...។
- សម្រាប់សម្គាល់ « ការបំបែកគ្នា » ៖ ឬ ឬក៏ ពុំនោះ ពុំនោះសោត ឯ រីឯ ផ្ទុយទៅវិញ...។
- សម្រាប់សម្គាល់ « ទំនាស់ » ៖ តែ ប៉ុន្តែ...។

**ខ.ឈ្នាប់ឃ្លា៖** ជាពាក្យចំណងសម្រាប់សម្គាល់ទំនាក់ទំនងគ្នារវាងឃ្លានិងឃ្លា ល្បះនិងល្បះ បង្កើតបានល្បះផ្សំ ដែលមានឃ្លាមួយជាឃ្លាច្បងមួយជាឃ្លារណប។ ឈ្នាប់ឃ្លាចែកជាពីរគឺ៖

- ឈ្នាប់ឃ្លា សម្រាប់ប្រើក្នុងឃ្លារណបមានមុខងារជាកម្មបទ ឬគុណប្រធាន មានពាក្យ ថា ជា។
  ឧទាហរណ៍៖ គាត់ប្រាប់ខ្ញុំ**ថា**ឪពុកគាត់ទៅសមុទ្រ។ ខ្ញុំពុំដឹង**ជា**គាត់ទៅណាទេ។
- ឈ្នាប់ឃ្លា សម្រាប់ប្រើក្នុងឃ្លារណបមានមុខងារជាកម្មទេសកាល មានពាក្យប្រាប់ពី៖
  - ហេតុ៖ ពីព្រោះ ព្រោះ ដោយ ដោយសារ ដោយហេតុ...។
  - បំណង៖ ដើម្បី ដើម្បីនឹង ដើម្បីឱ្យ...។
  - បំណើះ៖ បើ បើសិន ប្រសិនបើ...។
  - កាល៖ លុះ កាលណា លុឹកណា...។
  - ទំនាស់៖ ទោះបី ថ្វីត្បិត ថ្វីបើ...។

### ២.៦.៣.៨ ឧទានសព្ទ

ឧទានសព្ទ គឺជាពាក្យដែលគេនិយាយបន្លឺសូររបស់វាឡើងឮខ្លាំង ខុសប្លែកពីពាក្យធម្មតា ដើម្បីបង្ហាញអារម្មណ៍ ភ្ញាក់ផ្អើល បង្ហាញពីភាពសប្បាយ ភ័យ រំជួលចិត្តរបស់មនុស្ស។ របៀបបញ្ចេញសំឡេងឧទានសព្ទ គឺមានបីបែប ដែលបែបនីមួយៗ គឺមានសំឡេងខុសៗគ្នាផងដែរ។

ឧទានសព្ទបែបត្រាប់សូរបាតុភូតធម្មជាតិរួមមាន៖ ផ្គរលាន់ (គ្រឹមៗ!) ខ្យល់បក់ (វ៉ូៗ!) រន្ទះបាញ់ (ផាំងៗ!) សមុទ្ររលក( គ្រាំៗ!)។ ចំពោះឧទានសព្ទត្រាប់សូរសម្រែកសត្វ៖ ឆ្កែព្រុស (វ៉ូសៗ!) សត្វត្អូម (តុំៗ!) ចង្រិតយំ (ច្រេតៗ!)។ ចំណែកឧទានសព្ទត្រាប់សូរវត្ថុ សូរខ្យល់វាយបង្អួច ឮ(ផាំងៗ!)។

នៅមានឧទានសព្ទដទៃទៀតដូចជា អូ! អ្ហេ! អ្ហ៎ា! អីយ៉ា! នែ! យី! យីអើ! អួយ! ណែណេះ! នុ៎ះ! នោះន៎! ម៉ាច់! អស្ចារ្យហើយ! ចម្លែក! អីយ៉ាស់! អូយយ៉ា! អូយយ៉ះ! ចុំ! ហ៊ឺស! យើស! ណ្ហើយ! អើ! យើ! អីយ៉ាស់!។ល។

ឧទាហរណ៍៖ កាបូបរបស់ឯងពិតជាមានតម្លៃថ្លៃណាស់ណ៎!

ពាក្យទាំងអស់នេះ ជាការបង្ហាញអារម្មណ៍លាយឡំគ្នាមានទាំងសរសើរ រីករាយ ត្រេកអរ ភ័យខ្លាចជាដើម។

## ២.៧ ល្បះ

ល្បះ គឺជាការបន្សំរវាងកន្សោមពាក្យនិងកន្សោមពាក្យ ដែលមានន័យគ្រប់គ្រាន់អាចស្ដាប់បាន ហើយបញ្ចប់ដោយសញ្ញាខណ្ឌ ( ។ ) សញ្ញាសួរ ( ? ) សញ្ញាឧទាន ( ! )។

ឧទាហរណ៍៖ ធីតាជាសិស្សពូកែ។

ឧទាហរណ៍៖ ឯងឃើញភ្នំនោះទេ?

ឧទាហរណ៍៖ យី! ពស់នោះធំណាស់!

### <u>២.៧.១ បែបនៃល្បះ</u> បែបនៃល្បះក្នុងភាសាខ្មែរមាន៤គឺ៖

- **ល្បះបញ្ជាក់៖** ជាល្បះប្រើសម្រាប់និយាយបញ្ជាក់ពីអ្វីមួយ ព្រឹត្តិការណ៍ ហេតុការណ៍អ្វីមួយ។ ល្បះនេះបញ្ចប់ដោយសញ្ញាខណ្ឌ ( ។ ) ។
  ឧទាហរណ៍៖ រថយន្តមួយក្រឡាប់នៅជិតមន្ទីរពេទ្យ។
- **ល្បះសំណួរ៖** ជាល្បះប្រើសម្រាប់សួរចង់ដឹងអ្វីមួយ។ ល្បះនេះបញ្ចប់ដោយសញ្ញា( ? )។
  ឧទាហរណ៍៖ ឯងចង់ទៅណា?
- **ល្បះឧទាន៖** ជាល្បះប្រើសម្រាប់សម្ដែងនូវការភ្ញាក់ ភ័យ រន្ធត់ ភ្លាត់មាត់...។ ល្បះនេះបញ្ចប់ដោយសញ្ញាឧទាន ( ! ) ។
  ឧទាហរណ៍៖ ពុទ្ធោ! ជួយផង!
- **ល្បះបញ្ជា៖** ជាល្បះសម្រាប់ប្រើឱ្យនរណាធ្វើបែបណាមួយ បង្គាប់បញ្ជា ស្នើសុំ ជូនយោបល់ឱ្យដំបូន្មាន។ ល្បះនេះបញ្ចប់ដោយសញ្ញាខណ្ឌ ( ។ )
  ឧទាហរណ៍៖ កុំទៅទីនេះនាំឱ្យមានបញ្ហា។

### <u>២.៧.២.ទម្រង់នៃល្បះ</u> ទម្រង់នៃល្បះក្នុងភាសាខ្មែរគេចែកចេញជា៣គឺ៖

#### ២.៧.២.១ ល្បះទោល

ល្បះទោល គឺជាល្បះតូចបំផុត ដែលកើតឡើងដោយកន្សោមនាម និងកន្សោមកិរិយា។

ទម្រង់មូលដ្ឋានរបស់ល្បះទោលមាន៖

- ល → កន + កកិ ( កិ )។ ឧទាហរណ៍៖ ក្មេងៗដេក។
- ល → កន + កកិ ( កិ + ន )។ ឧទាហរណ៍៖ ពួកគេច្រូតស្រូវ។
- ល → កន + កកិ ( កិ + កមធ )។ ឧទាហរណ៍៖ ចាស់ៗនិយាយពីក្មេងៗ។
- ល → កន + កកិ ( កិ + កន + កមធ )។ ឧទាហរណ៍៖ ស្រីៗជូនផ្លែឈើដល់ចាស់ទុំ។
- ល → កន + កកិ ( កិ.ចំ.(ជា) + ន )។ ឧទាហរណ៍៖ គាត់ជាគ្រូវិស្វករ។
- ល → កន + កកិ ( កិ. + គុណ. )។ ឧទាហរណ៍៖ គោដើរយឺត។
- ល → កន + ø + កន។ ឧទាហរណ៍៖ ជីតាខ្ញុំអាយុចិតសិបឆ្នាំ។

### ២.៧.២.២ ល្បះផ្សំ

ល្បះផ្សំ គឺជាការបន្សំរវាងល្បះនិងល្បះ ភ្ជាប់គ្នាដោយសព្វនាមឈ្នាប់ ឬឈ្នាប់ឃ្លា បង្កើតបានឃ្លាមួយជាឃ្លាច្បង និងឃ្លាមួយជាឃ្លារណប។ ទម្រង់របស់ល្បះផ្សំមានបីគឺៈ

- ល្បះផ្សំដែលកើតពីការប្រើប្រាស់ឈ្នាប់ « ថា ជា »
  ឧទាហរណ៍ៈ ខ្ញុំមិនដឹង **ជា**គាត់អញ្ជើញទៅណាទេ។
- ល្បះផ្សំដែលកើតពីការប្រើប្រាស់សព្វនាមឈ្នាប់ « ដែល »
  ឧទាហរណ៍ៈ សំហូបនំអន្សម **ដែល**ម្តាយគាត់វេច។
- ល្បះផ្សំដែលកើតពីការប្រើប្រាស់ឈ្នាប់ឃ្លា
  ឧទាហរណ៍ៈ គ្រូបង្រៀនខិតខំបង្រៀនសិស្ស **ព្រោះ**គាត់ចង់ឱ្យសិស្សមានអនាគតល្អ។

### ២.៧.២.៣ ល្បះក្រង

ល្បះក្រង គឺជាល្បះដែលដាក់បន្តបន្ទាប់គ្នា ឬភ្ជាប់គ្នាដោយឈ្នាប់ចង។

| | | |
|---|---|---|
| ឧទាហរណ៍ៈ | មនុស្សចេះតែដើរ ឆ្កែចេះតែព្រួស។ | ល្បះដែលដាក់បន្តបន្ទាប់គ្នា។ |
| | ម្តាយទៅផ្សារ ឯឪពុកទៅចំការ។ | ល្បះដែលដាក់បន្តបន្ទាប់គ្នាដោយឈ្នាប់ចង។ |

## ៣. សន្និដ្ឋាន

ចំណេះដឹងមូលដ្ឋានភាសាខ្មែរ នៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបឋមសិក្សា ១២ + ២ តាមប្រព័ន្ធក្រេឌីតបានផ្តល់ជាសំខាន់លើគោលដៅពីរ គឺការពង្រឹងសមត្ថភាពលើចំណេះដឹងមូលដ្ឋានប្រវត្តិអក្សរសាស្ត្រខ្មែរ អក្សរសិល្ប៍ និងភាសាវិទ្យា ដែលជាទុនក្នុងការពង្រឹងសមត្ថភាពលើមុខវិជ្ជាភាសាខ្មែរ។

# វិធីសាស្រ្តបង្រៀន

# សញ្ញាណដំបូងនៃការបង្រៀនភាសាខ្មែរ

វិធីសាស្ត្របង្រៀនលើសមត្ថភាពទាំង៤ (ស្តាប់ និយាយ អាន សរសេរ) ដោយផ្អែកលើគោលវិធីសិស្សមជ្ឈមណ្ឌល។

**ក. សមត្ថភាពស្តាប់៖** សមត្ថភាពស្តាប់ ផ្តោតទៅលើការស្តាប់ចងចាំ និងយល់ន័យនូវស្វរតួអក្សរ ព្យញ្ជនៈ ពាក្យ ល្បះ កថាខណ្ឌ រឿងនិទាន ព័ត៌មាន ការអធិប្បាយ កំណាព្យ និងចម្រៀង...។ សិស្សមានសមត្ថភាពស្តាប់ គឺមានន័យថា សិស្សអាចប្រាប់បានសេចក្តីលម្អិតបង្ហាញត្រង់ និងបង្កប់ទាក់ទងនឹងព័ត៌មាន បទពិសោធ ការវិភាគ ឬវិនិច្ឆ័យរាល់ខ្លឹមសារទាំងអស់ដែលបានស្តាប់។

**ខ. សមត្ថភាពនិយាយ៖** សមត្ថភាពនិយាយសំដៅទៅលើការទំនាក់ទំនងគ្រប់ប្រភេទតាមរយៈការប្រើភាសាផ្ទាល់មាត់។ ចំណុចដែលសំខាន់ គឺផ្តោតទៅលើការនិយាយក្នុងបរិបទ និងការស្តាប់ភាសានិយាយតាមបែបផែនផ្សេងៗប្រកបដោយភាពក្លាហាន និងឈ្លាសវៃក្នុងការសន្ទនា ការបញ្ចេញយោបល់ ការសួរឆ្លើយ មតិគាំទ្រ ឬជំទាស់ ការបង្ហាញហេតុផល ការផ្តល់ព័ត៌មាន ការបកស្រាយ ការពន្យល់ ការប្រៀបធៀប ការបញ្ចុះបញ្ចូល និងឆ្លើយតបការបញ្ចុះបញ្ចូល ការផ្តល់អំណះអំណាងសមហេតុសមផល។

**គ. សមត្ថភាពអាន៖** សមត្ថភាពអានផ្តោតទៅលើការអានអក្សរ ព្យញ្ជនៈ ពាក្យ ការអានពាក្យដោយមិនបាច់ប្រកបក្នុងល្បះ និងអត្ថបទ។ ពិសេសការអានស្ទាត់ទៅតាមបែបបទ និងការអានដើម្បីយល់ន័យដូចជាពាក្យ កន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌ អត្ថបទអធិប្បាយ កំណាព្យ ចម្រៀង រឿងនិទាន និងលិខិតផ្សេងៗបានច្បាស់លាស់។ ការស្វែងយល់អត្ថន័យនៅក្នុងអត្ថបទពិត ឬប្រឌិត រួមមានសៀវភៅសិក្សា រឿងនិទាន រឿងរូបភាព កំណាព្យ និងឯកសារពាក់ព័ន្ធផ្សេងៗ។ ជារួមអត្ថបទបោះពុម្ពទាំងនោះ ជាសំណេរដែលទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ មានជាអាទិ៍ សារលិខិត កាសែត ផ្លាកសញ្ញា ស្លាកសញ្ញា សេចក្តីណែនាំអត្ថបទ ឬព័ត៌មានដែលដកស្រង់ពីអ៊ីនធឺណេត និងបណ្តាញទំនាក់ទំនងសង្គមផ្សេងៗ។ តាមរយៈអំណាននេះ សិស្សពង្រីកការយល់ដឹងពីខ្លួនឯង ក៏ដូចជាពិភពលោកទាំងមូល ព្រមទាំងយល់ពីអត្ថន័យនៃជំនឿវប្បធម៌ និងតម្លៃមនុស្សបន្ថែមទៀត។

**ឃ. សមត្ថភាពសរសេរ៖** សមត្ថភាពសរសេរសំដៅលើការសរសេរអក្សរ ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌ អត្ថបទ កំណាព្យ តែងសេចក្តីបែបពណ៌នា អក្សរផ្ចង់ សរសេរតាមអាន កត់ត្រាចំណុចសំខាន់ៗ លិខិតផ្សេងៗ និងបំពេញទម្រង់ផ្សេងៗ។

**ង. វេយ្យាករណ៍៖** កម្មវិធីសិក្សាលម្អិតចំណេះទូទៅសម្រាប់ថ្នាក់ទី១ដល់ទី៦ ផ្តល់ឱ្យសិស្សសិក្សានូវចំណេះដឹង និងការប្រើប្រាស់ អនុវត្តនូវបញ្ញត្តិនៃថ្នាក់ពាក្យ (នាម គុណនាម កិរិយាសព្ទ សព្វនាម ...) សញ្ញាវណ្ណយុត្ត(មូសិកទន្ត បន្តក់ ស្រៀសព្ទ...) សញ្ញាសម្ព័ន្ធ (សញ្ញាខណ្ឌ សញ្ញាសួរ សញ្ញាឧទាន...) និងល្បះ(ល្បះទោល ល្បះផ្សំ និងល្បះក្រុង)។

**ច. បំណិនវាក្យសព្ទ៖** ការសិក្សាអំពីបំណិនវាក្យសព្ទ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពទាំង៤ក្នុងមុខវិជ្ជាភាសាខ្មែរសម្រាប់កម្រិតបឋមសិក្សា។ បំណិនវាក្យសព្ទផ្តល់ឱ្យសិស្សសិក្សាផ្តោត

លើសមត្ថភាពអាន និងសរសេរ។ ពិសេសការផ្តល់ចំណេះដឹង និងការអនុវត្តជាក់ស្តែងក្នុងសមត្ថភាពអំណាន មានដូចជាការរៀនពាក្យ ពន្យល់ពាក្យ បដិសព្ទ សទិសសព្ទ វេវចនសព្ទ ការប្រើបទានុក្រម និងវចនានុក្រម។ ចំពោះសមត្ថភាពសរសេរ ផ្តល់ចំណេះដឹងលើការអនុវត្តជាក់ស្តែងដូចជា សំណេរពាក្យ បំពេញពាក្យក្នុងល្បះ ភ្ជាប់ពាក្យនឹងរូបភាព តែងល្បះ តែងល្បះតាមរូបភាព តែងកថាខណ្ឌ និងតែងសេចក្តី។

**ឆ. បំណិនអក្សរសិល្ប៍៖** ការសិក្សាពីបំណិនអក្សរសិល្ប៍ ផ្តល់ឱ្យសិស្សនូវខ្លឹមសារអត្ថបទរឿង ដោយផ្តោតទៅលើអត្ថន័យ ឬខ្លឹមសាររឿង តាមរយៈការប្រាប់សេចក្តីលម្អិតគាំទ្រគំនិតសំខាន់ក្នុងអត្ថបទ តួអង្គ អ្នកនិពន្ធ កាលបរិច្ឆេទរឿង កាលអាកាសរឿង ព្រឹត្តិការណ៍រឿង ការវិភាគរឿង រឿងពិត រឿងប្រឌិត ដំណើររឿង និងតម្លៃអប់រំនៃរឿង...។ ក្នុងការបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ៖

- ស្វែងយល់ និងណែនាំសិស្សឱ្យបានច្បាស់ពីគោលបំណង សារៈសំខាន់នៃការសិក្សាពីសមត្ថភាព ស្តាប់ និយាយ អាន សរសេរ និងបំណិនផ្សេងៗ ព្រមទាំងការអភិវឌ្ឍឥរិយាបថរបស់សិស្សក្នុងការសិក្សា
- ណែនាំសម្របសម្រួលពីដំណើរការដឹកនាំសកម្មភាពសិក្សានៅក្នុងថ្នាក់ សាលារៀន និងក្រៅសាលា នូវរបៀបសិក្សាស្រាវជ្រាវ តាមរយៈសកម្មភាពបុគ្គល ដៃគូ ក្រុមតូច និងក្រុមធំ
- ការបង្រៀន និងរៀនត្រូវយកចិត្តទុកដាក់លើខ្លឹមសារមេរៀនឱ្យបានច្បាស់លាស់ ដោយឱ្យសិស្សមានការហ្វឹកហាត់ អនុវត្តដោយផ្ទាល់ និងមានការវាយតម្លៃជាប្រចាំ
- រៀបចំសិស្សឱ្យមានសកម្មភាពច្រើនក្នុងការសិក្សាដូចជា ល្បែងដើរតួ ពិភាក្សា ការសិក្សាស្រាវជ្រាវ ដោយបណ្តុះនូវស្មារតីសហការចូលរួម សាមគ្គីភាព ភាពម្ចាស់ការ ការទទួលខុសត្រូវតាមតួនាទី និងភារកិច្ចក្រុម ក្រោមការសម្របសម្រួលពីគ្រូ
- រៀបចំសកម្មភាពបង្រៀន និងរៀន ដើម្បីបណ្តុះសិស្សឱ្យរៀនតាមបែបស្វ័យសិក្សា ការបង្កើតក្លឹបសិក្សានៅក្នុងសាលារៀន ក្រៅសាលារៀន ឬសហគមន៍ ដើម្បីពង្រឹងចំណេះដឹងបន្ថែម
- សកម្មភាពនីមួយៗត្រូវមានអន្តរកម្ម ឬទំនាក់ទំនងរវាងគ្រូនិងសិស្សនៅក្នុងថ្នាក់រៀន
- យកចិត្តទុកដាក់បង្រៀនសិស្សគ្រប់សមត្ថភាព ដោយមិនត្រូវផ្តោតតែលើសមត្ថភាពណាមួយ
- ជំរុញសិស្សឱ្យមានភាពក្លាហានចូលរួមក្នុងការបញ្ចេញមតិយោបល់គាំទ្រ ឬជំទាស់ ដោយបង្ហាញហេតុផល ហ៊ានសួរ ឆ្លើយ ហ៊ានទទួលខុសត្រូវ ស្ថិតក្នុងក្របខណ្ឌវិន័យ និងច្បាប់
- ជំរុញ និងលើកទឹកចិត្តសិស្សឱ្យចូលចិត្តអាន និងស្រាវជ្រាវ តាក់តែង ឬសរសេរអត្ថបទកំណាព្យ ចម្រៀង...។ ពិសេសគ្រូបង្រៀនមិនត្រូវនិយាយបន្ទះបង្អាប់សិស្ស ហើយត្រូវមានឥរិយាបថទន់ភ្លន់តែម៉ឺងម៉ាត់ និងចេះយោគយល់អធ្យាស្រ័យរាល់កំហុស ដែលសិស្សប្រព្រឹត្តដោយចេតនា ឬអចេតនាក្តី
- រៀបចំសកម្មភាពបង្រៀន និងរៀនស្របទៅតាមកម្មវិធីសាលាកុមារមេត្រី និងក្របខណ្ឌសាលារៀនសុវត្ថិភាព

- បញ្ចូលការអប់រំអំពីបរិស្ថាន ការអប់រំពលរដ្ឋសកល អនាម័យសុខភាព ចំណីអាហារ ជំងឺផ្សេងៗ ច្បាប់ សិទ្ធិមនុស្ស ច្បាប់ចរាចរណ៍ និងវិធីដោះស្រាយបញ្ហាផ្សេងៗក្នុងមេរៀន
- រៀបចំការវាយតម្លៃផ្សេងៗ ដើម្បីវាស់ស្ទង់លទ្ធផលសិក្សារបស់សិស្សនៅក្នុងដំណើរការបង្រៀន និងរៀន ក្រោយពីបញ្ចប់ខ្លឹមសារមេរៀន ជំពូក ដំណាក់កាល ប្រចាំខែ ឆមាស និងប្រចាំឆ្នាំ។

# មេរៀនទី១
# បញ្ញត្តិមួយចំនួនស្តីពីភាសា និងការបង្រៀនភាសាខ្មែរ

ជាទូទៅ ការសិក្សាពីបញ្ញត្តិនៅក្នុងភាសាខ្មែរ គឺជាការសិក្សាអំពីខ្លឹមសារសំខាន់ៗមួយចំនួនដែលមានគ្រប់សមត្ថភាពទាំង៤គឺ ការស្តាប់ ការនិយាយ ការអាន និងការសរសេរ តាំងពីកម្រិតបឋមមក។ ការសិក្សាពីបញ្ញត្តិទាំងអស់នៅក្នុងភាសាខ្មែរវាជួយពង្រឹង និងពង្រីកសមត្ថភាពទាំង៤កាន់តែច្បាស់ ស្របតាមប្រធានបទនៃមេរៀននីមួយៗផងដែរ។

## ១. វត្ថុបំណងមេរៀន

ការបង្រៀនភាសាខ្មែរនៅបឋមសិក្សាមានវត្ថុបំណងដូចខាងក្រោមៈ

- ផ្តល់ដល់គ្រូនូវបច្ចេកទេសបង្រៀនភាសាខ្មែរនៅបឋមសិក្សា សម្រាប់បម្រើឱ្យកម្មវិធីសិក្សា
- បណ្តុះសមត្ថភាពបង្រៀនភាសាខ្មែរដល់គ្រូបឋមសិក្សា ដើម្បីអនុវត្តឱ្យសម្រេចនូវសមត្ថភាពមូលដ្ឋានចំនួន៤គឺសមត្ថភាពស្តាប់ និយាយ អាន និង សរសេរ។
- ផ្សារភ្ជាប់ការបង្រៀនភាសាខ្មែរទៅនឹងមុខវិជ្ជាដទៃទៀតក្នុងកម្មវិធីសិក្សា ពិសេសផ្សារភ្ជាប់ទៅនឹង តម្លៃវប្បធម៌ និងអរិយធម៌ខ្មែរ។
- ប្រាប់បានពីបញ្ញត្តិភាសា មានសារៈសំខាន់ និងទំនាក់ទំនងរវាងសមត្ថភាពទាំង៤របស់ភាសាខ្មែរ គឺសមត្ថភាពស្តាប់ និយាយ អាន និងសរសេរបានត្រឹមត្រូវ
- បំណិនផ្សារភ្ជាប់សមត្ថភាពទាំង៤ក្នុងការបង្រៀនភាសាខ្មែរបានល្អប្រសើរ ទៅតាមបំណិនពាក់ព័ន្ធរបស់វា។

## ២. ខ្លឹមសារមេរៀន

### ២.១ បញ្ញត្តិអំពីភាសា និងការបង្រៀនភាសាខ្មែរ

ក្នុងចំណុចនេះមុនចាប់ផ្តើមបង្រៀន គ្រូគប្បីពន្យល់ណែនាំសិស្សឱ្យបានយល់ច្បាស់ថា តើភាសាខ្មែរជាអ្វី? វាមានសារៈសំខាន់ដូចម្តេចខ្លះ? ហេតុដូចម្តេចបានជាត្រូវរៀនភាសាខ្មែរ?

- ភាសាគឺជាមធ្យោបាយទាក់ទងយ៉ាងសំខាន់មិនអាចខ្វះបាន។ សិស្សខ្សោយភាសាអាចនឹងរៀនខ្សោយគ្រប់មុខវិជ្ជា ហើយបើមិនចេះភាសាគឺមិនអាចរៀនបានគ្រប់មុខវិជ្ជាទេ។
- ក្នុងទំនាក់ទំនងផ្នែកភាសាតែងមានទិដ្ឋភាពពីរៈ គឺការសម្តែងចេញ ការផ្សព្វផ្សាយ ឬការផលិត និងការទទួល ឬយល់ភាសា។ ពោលគឺម្នាក់និយាយម្នាក់ទៀតស្តាប់។ អ្នកសម្តែងចេញ និងអ្នកស្តាប់ត្រូវចេះ និងយល់ភាសាដូចគ្នា។
- ការសម្តែងចេញ ឬការផ្សព្វផ្សាយអាចប្រើមធ្យោបាយពីរយ៉ាងគឺ ការសរសេរ និងការនិយាយ
- ក្នុងចំណោមបំណិនទាំង៤នៃភាសាមានៈ

- បំណិនពីរសម្រាប់សម្តែងចេញគឺ ការនិយាយ និងការសរសេរ។ បំណិនទាំងពីរនេះសម្រាប់ផ្សព្វផ្សាយទៅក្រៅឱ្យអ្នកដទៃបានដឹង។
- បំណិនពីរទៀតសម្រាប់យល់អត្ថន័យអ្វីមួយ គឺការស្តាប់ និងការអាន។ ការស្តាប់ និងការអានសម្រាប់ឱ្យមនុស្សបានយល់ព័ត៌មានដែលអ្នកដទៃបានផ្សព្វផ្សាយ។
  - ការបង្រៀនភាសាខ្មែរគឺ ការធ្វើឱ្យសិស្សអភិវឌ្ឍបានបំណិនមូលដ្ឋានទាំង៤ ដោយប្រើវិធីសាស្ត្រ និងល្បិចបង្រៀនយ៉ាងសមស្រប។
  - ជាទូទៅបំណិនទាំង៤នេះ ត្រូវតែផ្សារភ្ជាប់គ្នា ទើបការសិក្សាភាសាខ្មែរមានប្រសិទ្ធភាពនឹងទទួលបានលទ្ធផលល្អ។

- ភាសានិយាយគឺជាមូលដ្ឋាននៃទំនាក់ទំនង និងជាគ្រឹះនៃការអាន និងការសរសេរ។
- អំណាន និងការអភិវឌ្ឍផ្នែកភាសាកើតមានឡើងនៅក្នុងបរិស្ថានសិក្សាដែលអាចៈ
  - ➢ ផ្តល់នូវបទពិសោធផ្សេងៗក្នុងការរៀនភាសា លើកទឹកចិត្តសិស្សឱ្យចូលរួមយ៉ាងសកម្មក្នុងការស្តាប់ ការនិយាយ ការអាន និងការសរសេរ
  - ➢ ជំរុញទឹកចិត្ត និងផ្តល់ឱកាសឱ្យពួកគេបញ្ចេញបំណិនផ្ទាល់ខ្លួន ដោយចេះប្រើប្រាស់ភាសាបានសមរម្យតាមស្ថានភាពជាក់ស្តែង។

## ២.២ ការអនុវត្តបានត្រឹមត្រូវតាមដំណាក់ផ្សេងៗនៃការបង្រៀនភាសា

ជាធម្មតាការបង្រៀនភាសាខ្មែរ គេនិយមអនុវត្តជាប្រាំដំណាក់គឺៈ

### ២.២.១ ការរៀបចំ

មុននឹងបង្រៀនមេរៀនមួយគ្រូត្រូវរកឱ្យឃើញថា តើក្នុងមេរៀននេះ(ប្រធានបទ) សិស្សបានចេះអ្វីខ្លះហើយ(បុរេពុទ្ធិ) ហើយអ្វីខ្លះដែលសិស្សមិនទាន់ចេះ? តើគួរបង្រៀនអ្វីខ្លះទៀតដល់សិស្ស។ ក្រោយពីរកឃើញចំណុចទាំងនេះហើយ គ្រូត្រូវដកស្រង់ខ្លឹមសារថ្មី បញ្ញត្តិថ្មីយកមករៀបចំ ដើម្បីបង្រៀនសិស្សទៅតាមលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ និងទៅតាមវិសេសភាពសិស្សក្នុងថ្នាក់ផង។

គ្រូបង្រៀនគួរកត់សម្គាល់ថាក្នុងដំណាក់ត្រៀមនេះ គប្បីស្រាវជ្រាវប្រភពឯកសារ និងសម្ភារឧបទេសឱ្យបានសមស្របដើម្បីជានាប្រសិទ្ធភាពនៃការបង្រៀន។ ជាមួយគ្នានេះគ្រូបង្រៀនគប្បីត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានពេញលេញ ដើម្បីងាយស្រួលបង្រៀន និងរៀន(បីខ្វង់ ប្រាំជំហាន)។

### ២.២.២ ការដឹកនាំមេរៀន

ការដឹកនាំមេរៀនក្នុងថ្នាក់ គ្រូគប្បីតាំងខ្លួនជាអ្នកបង្កសកម្មភាព និងជំរុញសិស្សឱ្យធ្វើសកម្មភាពដោយខ្លួនឯងផ្ទាល់។ គ្រូមិនត្រូវតាំងខ្លួនជា **មេនៃថ្នាក់រៀនមួយ** ដោយគិតតែពីនិយាយបង្គាប់បញ្ជា គំរាមកំហែងឱ្យសិស្សស្តាប់បង្គាប់ និងអនុវត្តតាមឡើយ។

ដើម្បីបង្កឱកាសឱ្យសិស្សរៀនបានល្អ គ្រូគួរប្រកាន់ឥរិយាបថមួយចំនួនដូចខាងក្រោមៈ

ក. ឈ្លាសវៃក្នុងការរៀបចំសិស្សឱ្យធ្វើសកម្មភាពទៅតាមលទ្ធភាពផ្ទាល់ខ្លួន ដើម្បីស្វែងយល់ខ្លឹមសារដោយខ្លួនឯង។

ខ. ត្រូវប្រើប្រាស់ភាសាទន់ភ្លន់ ឃ្លាល្បះងាយស្តាប់ និងច្បាស់លាស់មិនប្រើប្រាស់ពាក្យគំរោះគំរើយ គំរាមកំហែង ពេលនិយាយទៅកាន់សិស្ស។

គ. ត្រូវនិយាយ ឬអនុវត្តសកម្មភាពជាជំហានៗ ពីងាយទៅពិបាក ពីរូបីទៅអរូបី។

ឃ. ត្រូវចេះណែនាំសិស្សឱ្យប្រើប្រាស់សម្ភារឧបទេស ប្រកបដោយការថ្នៃប្រឌិតទៅតាមគុណភាពនៃសម្ភារៈដែលត្រូវប្រើប្រាស់( ទំហំ ពណ៌ )។

ង. ត្រូវសរសេរពាក្យថ្មី ពាក្យគន្លឹះ បញ្ញត្តិថ្មីៗ លើក្តារខៀន ឬបង្ហាញលើក្តារខៀនក្នុងករណីចាំបាច់។

ច. ត្រូវលើកទឹកចិត្តរាល់ការប្រឹងប្រែងរបស់សិស្ស ដោយចេះសម្របសម្រួលចម្លើយសិស្ស និងពង្រីក អត្ថន័យបន្ថែមឱ្យបានពេញលេញ។ នៅពេលសិស្សគ្មានលទ្ធភាពឆ្លើយគ្រូត្រូវជួយពន្យល់បន្ថែមកែលម្អប្រែប្រួលសំណួររបស់ខ្លួនឡើងវិញ។

ឆ. ត្រូវចេះប្រើសំណួរឱ្យបានសមស្របតាមកម្រិតយល់ដឹងរបស់សិស្ស។

### ២.២.៣ ការប្រតិបត្តិ

ពេលបង្រៀនមេរៀនចប់ ដើម្បីពង្រីកចំណេះដឹង និងទ្រឹស្តីគ្រូត្រូវរៀបចំសកម្មភាពឱ្យសិស្សអនុវត្តជាក់ស្តែង។ ការប្រតិបត្តិនេះអាចធ្វើជាបុគ្គល ឬជាក្រុមតូច។ ជាការល្អការងារនេះគួរអនុវត្តតាមក្រុមតូច ដើម្បីសិស្សមានលទ្ធភាពពង្រីកស្មារតីសហការជួយគ្នាទៅវិញទៅមក។ ក្នុងពេលអនុវត្តសិស្សមានឱកាសច្រើនដើម្បីប្រើប្រាស់ភាសារបស់គេបានផ្ទាល់ តាមរយៈការឡើងឆ្លើយសំណួរ ឬការពិភាក្សាគ្នាក្នុងក្រុម។

### ២.២.៤ វង្វាយតម្លៃ

វង្វាយតម្លៃគឺជាដំណាក់កាលសំខាន់មួយនៃការបង្រៀន។ អ្វីៗទាំងអស់នឹងរកឃើញនៅពេលវាយតម្លៃ។ ការវាយតម្លៃនៃការបង្រៀនរបស់គ្រូ លទ្ធផលនៃការរៀនរបស់សិស្ស ការសម្រេច ឬមិនសម្រេចវត្ថុបំណងមេរៀននឹងឃើញច្បាស់ក្រោយពីវង្វាយតម្លៃ។ ក្នុងការវាយតម្លៃគ្រូអាចប្រើប្រាស់របៀបវាយតម្លៃប្លែកៗ តាមរយៈការធ្វើតេស្តដោយប្រើប្រាស់៖

- សំណួរពហុជ្រើសរើស
- សំណួរផ្ទៀងផ្ទាត់
- សំណួរបំពេញល្បះ
- សំណួរល្បងប្រាជ្ញា ។ល។

### ២.២.៥ ការពង្រីកការយល់ដឹង

នេះគឺជាការផ្តល់ឱកាសឱ្យសិស្សមានលទ្ធភាពគិត និងប្រើប្រាស់បញ្ញត្តិ ដែលទើបទទួលបាននៅក្នុងជីវភាព ឬយកទៅប្រើប្រាស់ក្នុងមុខវិជ្ជាផ្សេងៗទៀត។ ក្នុងការបង្រៀន ផ្តើមចេញពីបំណិនថ្មីៗនេះ សិស្សក៏អាចពិចារណា ដើម្បីពង្រីកការយល់ដឹងរបស់ខ្លួនឱ្យកាន់តែប្រសើរថែមទៀតផង។

**ក្នុងការអនុវត្តដំណាក់ពង្រីកការយល់ដឹង គ្រូអាចៈ**

- ផ្តល់លំហាត់អនុវត្តដែលមានខ្លឹមសារថ្មី និងទូលាយជាងមេរៀនមុន
- ប្រើប្រាស់សំណួរផ្ទាល់មាត់ដោយមានបញ្ចូលខ្លឹមសារមេរៀនថ្មីខ្លះៗ។

## ៣. សន្និដ្ឋាន

ការស្វែងយល់ពីបញ្ញត្តិទូទៅរបស់ភាសាខ្មែរ ក្នុងគោលបំណងឱ្យអ្នកសិក្សាប្រាប់បាននិយមន័យ និង អត្ថប្រយោជន៍របស់ភាសាខ្មែរ ព្រមទាំងទំនាក់ទំនងសមត្ថភាពទាំង៤ក្នុងការរៀនភាសាដែលស្តែងចេញនូវទិដ្ឋភាពពីរគឺការសម្តែងចេញ ឬការផលិត និងការទទួលយក។ ជាពិសេសមេរៀននេះក៏បានរំលេចផងដែរ អំពីការអនុវត្តការបង្រៀនភាសាខ្មែរ ទៅតាមប្រាំដំណាក់សំខាន់ៗ។ ក្នុងមេរៀនទាំងពីរនេះគឺជាសញ្ញាណដំបូងដែលជួយគ្រូថ្មីចាប់ផ្តើមការរៀបចំមេរៀនភាសាខ្មែរទៅតាមដំណាក់នីមួយៗ។

# មេរៀនទី២
# វិធីសាស្ត្របង្រៀនភាសាខ្មែរថ្នាក់ដំបូង

## ១. វត្ថុបំណងមេរៀន

- ស្វែងយល់កាន់តែស៊ីជម្រៅអំពីការប្រើប្រាស់សៀវភៅណែនាំគ្រូ និងសៀវភៅជំនួយសិស្ស ថ្នាក់ទី១ ទី២ និងសៀវភៅសិក្សាគោលថ្នាក់ទី១ ទី២
- អនុវត្តគន្លឹះសំខាន់ៗក្នុងការបង្រៀនភាសាខ្មែរនៅថ្នាក់ដំបូងប្រកបដោយជោគជ័យ
- បណ្ដុះទំនុកចិត្ត និងភាពច្បាស់លាស់ក្នុងការបង្រៀនវិធីសាស្ត្រភាសាថ្នាក់ដំបូងដល់គរុសិស្ស និងគរុនិស្សិត

## ២.ខ្លឹមសារមេរៀន

### ២.១ ការណែនាំអំពីសៀវភៅណែនាំគ្រូ និងសៀវភៅជំនួយសិស្សថ្នាក់ទី១

#### ២.១.១ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១

ក. ទម្រង់សៀវភៅណែនាំគ្រូ

- សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១ ភាគ១ (ឆមាសទី១)
- សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១ ភាគ២ (ឆមាសទី២)
- បានបែងចែកម៉ោងសិក្សាសរុបពេញមួយឆ្នាំ (តារាងបំណែងចែកពេលវេលា)
- ចែកជា២ផ្នែក គឺផ្នែកសេចក្ដីផ្ដើម និងផ្នែកលំនាំបង្រៀនក្នុងមេរៀននីមួយៗ

ខ. កាលវិភាគសង្ខេបក្នុងមួយឆ្នាំសិក្សា តាមប្រភេទមេរៀន

★ ទិដ្ឋភាពទូទៅមេរៀនឆមាសទី១

| អំឡុងខែ | ប្រភេទមេរៀន | មេរៀន |
|---|---|---|
| ដើមខែវិច្ឆិកា | រៀនគូសបន្ទាត់ | ១ |
| ដើមខែវិច្ឆិកា | ចម្រៀងនិងស្រះ ចម្រៀងព្យញ្ជនៈ | ២ - ៤ |
| ដើមខែវិច្ឆិកា-ចុងខែធ្នូ | ក ខ ច ឆ ផ្សំស្រៈ ២៣តួ | (ស្ពានទី១) |
| ចុងខែធ្នូ-កណ្ដាលខែមករា | ព្យញ្ជនៈពួក "អ"<br>ផ្សំស្រៈទាំង២៣តួ(មេរៀនសាឡើងវិញ) | ៥- ១៥ |
| ខែមករា - ដើមខែកុម្ភៈ | គ ជ ទ ល ផ្សំស្រៈ ២៣តួ | (ស្ពានទី២) |
| ដើមខែកុម្ភៈ - ខែមីនា | ព្យញ្ជនៈពួក "អ៊" ផ្សំស្រៈទាំង២៣តួ<br>(មេរៀនសាឡើងវិញ) | |

★ **ទិដ្ឋភាពទូទៅមេរៀនឆមាសទី២**

| អំឡុងខែ | ប្រភេទមេរៀន | មេរៀន |
|---|---|---|
| ថ្ងៃទី២០ មីនា - ៦ មេសា | មូសិកទន្ត និងត្រីសព្ទ | ៣០-៤០ |
| ខែឧសភា - ១២ មិថុនា | ប្រកប | ៤១-៦៤ |
| ខែមិថុនា | ស្រះពេញតួ | ៦៥-៦៦ |
| ខែមិថុនា | ព្យញ្ជនៈ និងជើងព្យញ្ជនៈ | ៦៧ |
| ខែមិថុនា - ខែសីហា | ព្យញ្ជនៈផ្ញើជើង | ៦៨-៩៤ |
| ខែសីហា | ព្យាង្គតម្រួត | ៩៥-១០២ |

❖ **ផ្នែកទី១ នៃសៀវភៅណែនាំគ្រូ**

- មាតិកា
- សេចក្តីផ្តើម
- កាលវិភាគសង្ខេបក្នុងមួយឆ្នាំសិក្សា
- សម្ភារៈបង្រៀន និងរៀនសម្រាប់ឆមាសទី១ និងទី២

❖ **ផ្នែកទី២ នៃសៀវភៅណែនាំគ្រូ**

- លំនាំបង្រៀនលម្អិតមួយជាគំរូតាមប្រភេទមេរៀននីមួយៗ ដែលមានសកម្មភាពបង្រៀនតាមលំដាប់លំដោយនៃសមាសភាព ឬបំណិនទាំង៥នៃអំណាន ព្រមទាំងការហ្វឹកហាត់សរសេរ
- លំនាំបង្រៀនប្រចាំថ្ងៃគ្រប់មេរៀនថ្នាក់ទី១ ដែលមានជ្រើសរើសខ្លឹមសារជាជំនួយដល់គ្រូក្នុងការអនុវត្តទៅតាមជំហានលំនាំបង្រៀន និងជួយដល់សិស្ស
- លំនាំបង្រៀនលម្អិតមានបញ្ចូលការរៀនបែបអប់រំបរិយាបន្ន
- ជួយគ្រូក្នុងការវាយតម្លៃក្នុងដំណើរការបង្រៀន និងរៀន
- ល្បិចជួយសិស្សទូទៅ សិស្សខ្សោយគំហើញ ជួយសិស្សមានបញ្ហាស្តាប់

### ២.១.២ សៀវភៅជំនួយសិស្ស

#### ក. ទម្រង់ទូទៅសៀវភៅជំនួយសិស្ស

❖ សៀវភៅជំនួយសិស្សភាសាខ្មែរថ្នាក់ទី១ ភាគ១ (ឆមាសទី១)ចែកចេញជា៤ផ្នែក៖

- **ផ្នែកទី១** : ក ខ ច ឆ និង ា ដល់ ោះ (ស្ថានទី១)
- **ផ្នែកទី២** : ព្យញ្ជនៈពួក "អ" ក ដល់ អ
- **ផ្នែកទី៣** : គ ជ ទ ល និង ា ដល់ ោះ (ស្ថានទី២)
- **ផ្នែកទី៤** : ព្យញ្ជនៈពួក "អ៊" គ ដល់ វ

❖ **សៀវភៅជំនួយសិស្សភាសាខ្មែរថ្នាក់ទី១ ភាគ២ (ឆមាសទី២)ចែកចេញជា ៦ផ្នែក៖**

- **ផ្នែកទី១** : សញ្ញាមូសិកទន្ត ឬធ្មេញកណ្តុរ និងសញ្ញាត្រីសព្ទ ឬសញ្ញាសក់ក «៊»

- **ផ្នែកទី២** : ប្រកប
- **ផ្នែកទី៣** : ស្រៈពេញតួ
- **ផ្នែកទី៤** : ព្យញ្ជនៈ និងជើងព្យញ្ជនៈ
- **ផ្នែកទី៥** : ព្យញ្ជនៈផ្ញើជើង
- **ផ្នែកទី៦** : ព្យាង្គតម្រួត

❖ **សៀវភៅជំនួយសិស្សភាសាខ្មែរថ្នាក់ទី១ ភាគ១**

- ផ្នែកទី១ និងផ្នែកទី៣ មិនប្រើប្រាស់សៀវភៅសិក្សាគោលទេ
- ផ្នែកទី២ និងផ្នែកទី៤ ប្រើប្រាស់ជាជំនួយសៀវភៅសិក្សាគោលភាសាខ្មែរ

❖ **សៀវភៅជំនួយសិស្សភាសាខ្មែរថ្នាក់ទី១ ភាគ២ គ្រប់ផ្នែកទាំងអស់ប្រើជាជំនួយសៀវភៅសិក្សាគោលភាសាខ្មែរ។**

★ **កំណត់សម្គាល់៖**

- សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ភាគ១ និងភាគ២ និង សៀវភៅជំនួយសិស្សថ្នាក់ទី២មានទម្រង់ប្រហាក់ប្រហែលនឹងថ្នាក់ទី១ដែរ
- ចំពោះថ្នាក់ទី៣សូមមើលសៀវភៅសិក្សាគោល។

### ២.១.៣ មូលដ្ឋានគ្រឹះនៃការរៀនអំណាន

❖ តើអំណានគឺជាអ្វី?

អំណានគឺការបន្លឺសូរបានត្រឹមត្រូវ និងយល់ន័យ ពាក្យ ពាក្យ ឃ្លា ល្បះ កថាខណ្ឌ ឬអត្ថបទ ដោយចេះលើកដាក់សំឡេង គោរពសញ្ញាសម្គាល់ និងចេះអានតាមមនោសញ្ចេតនារបស់តួអង្គ និងសាច់រឿង។

អំណាន = ការផ្សំប្រកប + ការយល់ន័យ

ការស្គាល់សូរ ការស្គាល់តួអក្សរ អានស្ទាត់ → ការផ្សំប្រកប

ចេះវាក្យសព្ទ អានយល់ន័យ → ការយល់ន័យ

❖ តើអានកម្រិតណាទើបអាចទទួលយកបាន?

- ការអានស្ទាត់នៅថ្នាក់ទី១ គឺ ២០ តួអក្សរ ឬពាក្យ/ ១នាទី
- ការអានស្ទាត់នៅ ថ្នាក់ទី២ គឺ ៤០ តួអក្សរ ឬពាក្យ/ ១នាទី
- ការអានស្ទាត់នៅ ថ្នាក់ទី៣ គឺ ៦០ ពាក្យ/ ១នាទី
- ការអានស្ទាត់នៅ ថ្នាក់ទី៤ គឺ ៨០ ពាក្យ/ ១នាទី
- ការអានស្ទាត់នៅ ថ្នាក់ទី៥ គឺ ១០០ ពាក្យ/ ១នាទី
- ការអានស្ទាត់នៅ ថ្នាក់ទី៦ គឺ ១២៥ ពាក្យ/ ១នាទី
- ការអានស្ទាត់នៅ ថ្នាក់ទី៧ គឺ ១៥០ ពាក្យ/ ១នាទី
- ការអានស្ទាត់នៅ ថ្នាក់ទី៨ គឺ ១៧៥ ពាក្យ/ ១នាទី

- ការអានស្ទាត់នៅ ថ្នាក់ទី៩ គឺ ២០០ ពាក្យ/ ១នាទី

❖ តើការមិនចេះអានមានផលប៉ះពាល់អ្វីខ្លះដល់កុមារ?

បើកុមាររៀនភាសាខ្សោយះ

- រៀនមុខវិជ្ជាដទៃទៀតក៏ខ្សោយ
- ធុញទ្រាន់នឹងការសិក្សា
- មករៀនមិនទៀងទាត់
- ងាយបោះបង់ការសិក្សា
- មានចំណេះដឹងទាប
- មានជំនាញមិនច្បាស់លាស់
- ធ្វើការដោយប្រើកម្លាំង
- ប្រាក់ចំណូលទាប
- មានជីវភាពក្រខ្សត់
- អនាគតជួបការលំបាក
- ......

❖ តើការចេះអានមានប្រយោជន៍អ្វីខ្លះដល់កុមារ?

បើរៀនភាសាពូកែះ

- រៀនមុខវិជ្ជាដទៃទៀតក៏ពូកែ
- សប្បាយនឹងការសិក្សា
- មករៀនទៀងទាត់
- មិនបោះបង់ការសិក្សា
- មានចំណេះដឹងខ្ពស់
- មានជំនាញច្បាស់លាស់
- មានការងារល្អធ្វើ
- ប្រាក់ចំណូលខ្ពស់
- មានជីវភាពធូរធារ
- អនាគតរុងរឿង

❖ តើធ្វើដូចម្ដេចដើម្បីឆាប់ចេះអាន និងសរសេរ?

ដើម្បីឆាប់ចេះអាន និងសរសេរកុមារត្រូវមានមូលដ្ឋានគ្រឹះក្នុងការរៀនភាសាដោយះ

- អនុវត្តតាមសមាសភាគទាំង៥ នៃអំណាន ( ការស្គាល់សូរ ការស្គាល់តួអក្សរ ការផ្សំប្រកប ដើម្បីអានព្យាង្គនិងពាក្យ ការអានស្ទាត់ និងការអានយល់ន័យ)

- អនុវត្តគោលការណ៍ គ្រូធ្វើជាគំរូ (I do) គ្រូ និងសិស្សហាត់ជាមួយគ្នា (We do) សិស្សហ្វឹកហាត់ជាបុគ្គល /ជាដៃគូ(You do)
- រៀនជាប្រចាំបន្តិចម្តងៗ ( រៀន១តួ ក្នុង១ថ្ងៃ ហ្វឹកហាត់ឱ្យបានច្រើនដង មានពេលវេលាច្រើន ដើម្បីរំឭកអ្វីដែលគេបានរៀនរួច ផ្សារភ្ជាប់ជីវភាពរស់នៅ)

### ២.១.៤ សារៈសំខាន់នៃការមានបំណិនមូលដ្ឋានក្នុងការរៀនអំណាន




រូបនេះ បានបង្ហាញឱ្យឃើញភាពខុសគ្នារវាងកុមារដែលមានបំណិនមូលដ្ឋាន និងកុមារដែលគ្មានបំណិនមូលដ្ឋានក្នុងការអាន។ យើងសង្កេតឃើញថាកុមារដែលមានបំណិនមូលដ្ឋានក្នុងការអាន គឺមានការអភិវឌ្ឍសមត្ថភាពអំណានរបស់ខ្លួនពីមួយឆ្នាំទៅមួយឆ្នាំ (ពណ៌ក្រហម)។ ចំណែកឯក្មេងដែលពុំទទួលបានការបណ្តុះបណ្តាល ឬពង្រឹងបំណិនមូលដ្ឋានទេ ពួកគាត់នឹងមិនទទួលបានការអភិវឌ្ឍសមត្ថភាពអានពីមួយឆ្នាំទៅមួយឆ្នាំដូចគ្នា (ពណ៌ខៀវ)។

### ២.១.៥ លំនាំបង្រៀនអំណានដំបូងថ្នាក់ទី១

ដើម្បីឱ្យការបង្រៀន និងរៀនទទួលបានលទ្ធផលល្អ លោកគ្រូ អ្នកគ្រូត្រូវបង្រៀនតាមសកម្មភាពគោលទាំង៧ដូចខាងក្រោម៖

១. ការស្គាល់សូរ

២. ការស្គាល់តួអក្សរ

៣. ការអានព្យាង្គ និងពាក្យ

៤. វាក្យសព្ទ

៥. ការអានល្បះ

៦. ការអានអត្ថបទ

៧. ការសរសេរ

**ដោយឡែកកាបង្រៀនមេរៀនស្រៈនិស្ស័យបង្រៀនតែសកម្មភាពគោលតែប៉ុណ្ណោះមិនមានសកម្មភាពការអានល្បះទេ។**

សកម្មភាពគោលនីមួយៗ មានសកម្មភាពរងតូចៗជាច្រើនទៀត ដែលយើងនឹងរៀនក្នុងពេលហ្វឹកហាត់។

★ មុននឹងចូលដល់មេរៀនថ្មី គ្រូត្រូវរំឭកមេរៀនចាស់ជាមុនសិន

១. គ្រូចាប់ផ្ដើមមេរៀនថ្មី ដោយណែនាំពីការស្គាល់សូររបស់តួអក្សរថ្មី ដោយធ្វើសកម្មភាពកាយវិការ ប្រើរូបភាព ពណ៌នា និងលេងល្បែងសិក្សាដែលសិស្សហាត់ស្ដាប់សូរថ្មីរបស់តួអក្សរតាមពាក្យដែលគ្រូបន្លឺ(ល្បែងបាទ/ចាស ឬទេ)។ ទាំងនេះគឺជាការស្គាល់សូរ។

២. បន្ទាប់មកគ្រូបង្ហាញរូបរាងតួអក្សរថ្មី។ សកម្មភាពនេះ គឺជាទំនាក់ទំនងរវាងសូរ និងតួអក្សរ។

៣. សកម្មភាពបន្ទាប់ គ្រូ និងសិស្សហ្វឹកហាត់អានព្យាង្គនៅលើក្ដារខៀន និងក្នុងសៀវភៅជំនួយសិស្ស។ ត្រង់សកម្មភាពនេះ កុមារនឹងហ្វឹកហាត់ភ្ជាប់តួអក្សរទៅនឹងរូបរាងរបស់វា។

៤. បន្តមកទៀតគ្រូណែនាំពាក្យថ្មី។ នេះជាសកម្មភាព ការរៀនវាក្យសព្ទដើម្បីយល់ន័យ។

៥. គ្រូបំផុសសំណួរទាក់ទងនឹងខ្លឹមសារល្បះ។ បន្ទាប់មកគ្រូចម្លងល្បះដាក់លើក្ដារខៀន និងឱ្យសិស្សញែកពាក្យក្នុងល្បះ។ គ្រូអានល្បះលើក្ដារខៀនជាគំរូ ដោយចង្អុលចំពាក្យម្ដងមួយៗ។ បន្ទាប់មកគ្រូ និងសិស្សចង្អុលពាក្យក្នុងល្បះនីមួយៗ និងអានព្រមគ្នា។ បន្ទាប់មកទៀត គ្រូចង្អុលពាក្យនីមួយៗក្នុងល្បះឱ្យសិស្សអាន។ រួចគ្រូសួរសំណួរដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅ ដើម្បីឱ្យសិស្សយល់ពីអត្ថន័យនៃល្បះ។ ជាទីបញ្ចប់គ្រូឱ្យសិស្សហ្វឹកហាត់អានល្បះក្នុងសៀវភៅជំនួយសិស្សជាដៃគូ ដោយម្នាក់ចង្អុល ម្នាក់ទៀតអាន រួចប្ដូរវេនគ្នា។

៦. គ្រូ និងសិស្សអានអត្ថបទខ្លី។ មុនដំបូងឱ្យកុមារទស្សន៍ទាយខ្លឹមសារអត្ថបទ។ បន្ទាប់មកគ្រូអានអត្ថបទឮៗជាគំរូដល់កុមារ។ ក្រោយមកកុមារហ្វឹកហាត់អានជាមួយគ្រូ រួចសិស្សអានជាដៃគូ។ ចុងក្រោយ គ្រូសួរសំណួរទាក់ទងនឹងអត្ថបទ។ សកម្មភាពនេះ ជួយកុមារឱ្យហាត់អានស្ទាត់ និងយល់ន័យ ហើយនេះជាផ្នែកមួយដ៏សំខាន់នៃអំណាន។

៧. នៅផ្នែកចុងក្រោយនៃមេរៀន កុមារនឹងហ្វឹកហាត់សរសេរ។

## ៣. លំនាំបង្រៀន

### ៣.១ លំនាំបង្រៀនស្រៈលម្អិតស្រៈ ែ

| លំនាំបង្រៀនលម្អិត | មេរៀនស្រៈ ែ | ៨០ នាទី |
|---|---|---|
| **រំឭកមេរៀន** | | **៥ នាទី** |

◎ **រំឭកព្យញ្ជនៈ និងស្រៈ**

🗐 **អក្សរចល័ត ក្ដារឆ្នួន**

🕒 **៥នាទី**

គ្រូប្រើប័ណ្ណអក្សររូបភាព **ច េ ែ ៀ ឿ** រួចលើកម្ដងមួយតួៗឱ្យសិស្សថានិងធ្វើកាយវិការតាម អក្សរនីមួយៗ។ ឧ.**ស្រៈ ែ ដូចជាពាក្យ ខែ** (កាយវិការ) ឬគ្រូហៅអក្សរទាំងនេះឱ្យសិស្សសរសេរលើក្ដារឆ្នួន រួចគ្រូកែតម្រូវ។

**១- ការស្គាល់សូរអក្សរថ្មី** 🕒 **៥ នាទី**

**១.១- ល្បែងទស្សន៍ទាយ**

◎ **កំណត់សូរស្រៈ ែ**

🗐 វត្ថុជាក់ស្ដែង រូបភាព (អាចជ្រើសរើសបាន)

🕒 ៣នាទី

គ្រូប្រើវត្ថុជាក់ស្ដែង រូបភាព ធ្វើកាយវិការ ឬពណ៌នាដើម្បីឱ្យសិស្សថាព្យាង្គ ឬពាក្យ និងប្រាប់សូរស្រៈ ែ។

- គ្រូ : ធ្វើកាយវិការដូចជាអ្នកមានចៃលើក្បាល ដូចជា អេះក្បាល និងញេចចៃ។ គ្រូសួរថា **តើគ្រូធ្វើអ្វី? (ញេចចៃ)។ តើពាក្យ ចៃ មានសូរចុងអ្វី? (អែ)។ ពាក្យចៃ មានសូរចុង អែ ។**
- គ្រូនិងសិស្ស : ថាទាំងអស់គ្នា **អែ** ។
  សិស្ស : ថាទាំងអស់គ្នា **អែ** ។

**១.២ ល្បែងបាទ ឬចាស និង ទេ**

◎ **កំណត់ពាក្យដែលមានសូរចុង អែ (ស្រៈ ែ)**

🗐 **មិនចាំបាច់**

🕒 **២នាទី**

**ក- បង្រៀនសញ្ញា "បាទ ឬចាស" និង "ទេ"**

- សញ្ញាសម្រាប់ បាទ ឬចាស គឺក្ដាប់ដៃស្ដាំ ហើយធ្វើដូចទៅនឹងការងក់ក្បាល(គ្រូធ្វើសញ្ញា ហើយឱ្យសិស្សធ្វើសញ្ញាជាមួយគ្រូ)។
- សញ្ញាសម្រាប់ ទេ គឺលាបាតដៃ ហើយគ្រវីវាដូចគ្នានឹងគ្រវីក្បាល



(គ្រូធ្វើសញ្ញាបង្ហាញ ហើយឱ្យសិស្សធ្វើសញ្ញាជាមួយគ្រូ)។

**ខ-ពន្យល់អំពីការលេងល្បែង**

**គ្រូនឹងហៅពាក្យមួយ។ ប្រសិនបើពាក្យនោះមានសូរ អែ សិស្សត្រូវធ្វើសញ្ញា "បាទ ឬចាស"។ ប្រសិនបើពាក្យនោះមិនមានសូរ អែ ទេ សិស្សធ្វើសញ្ញា "ទេ"។** គ្រូឱ្យសិស្សបិទភ្នែក។

- គ្រូ : ថាពាក្យ **ដែ ចា** និងធ្វើសញ្ញា "បាទឬចាស" និង "ទេ"។
- គ្រូនិងសិស្ស : គ្រូថាពាក្យ **កែ ខា** គ្រូ និងសិស្សធ្វើសញ្ញា"បាទ ឬចាស" និង "ទេ" រួមគ្នា។
- សិស្ស : គ្រូថាពាក្យ **ចែ ខែ ហោះ ចុះ កែ** ឱ្យសិស្សបិទភ្នែកនិងធ្វើសញ្ញាដោយខ្លួនឯង។

**គន្លឹះត្រូវចងចាំ**

✓ គ្រូគួរចាប់ផ្តើមដោយប្រើកាយវិការ ឬសកម្មភាពដើម្បីទាក់ទាញការចូលរួមរបស់សិស្ស។

✓ ប្រសិនបើសិស្សរកសូរដើមនៃព្យាង្គ ឬពាក្យណាមួយមិនឃើញ គ្រូត្រូវប្រាប់សិស្ស ដើម្បីកាត់បន្ថយពេលវេលា។

✓ គ្រូនាំសិស្សបន្លឺសូរអក្សរនីមួយៗ ដោយអនុវត្តតាមជំហាន គ្រូធ្វើ គ្រូនិងសិស្សធ្វើ និងសិស្សធ្វើ។

✓ ប្រសិនបើសិស្សណាមិនចូលរួម គ្រូត្រូវថាព្យាង្គនោះឱ្យច្បាស់ៗ។ ប្រាកដថាពួកគេផ្តោតមកគ្រូ។ ត្រូវប្រាកដថាសិស្សទាំងអស់អាចឃើញ និងស្តាប់ឮច្បាស់។

✍ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្តារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេស ដោយធានាថាគេអាចមើលឃើញកាយវិការគ្រូច្បាស់។

✍ ទាញចំណាប់អារម្មណ៍សិស្សឱ្យមើលគ្រូខណៈពេលដែលគ្រូបន្លឺសូរ និងអានពាក្យរួមជាមួយការធ្វើកាយវិការ។

## ២ ការស្គាល់តួអក្សរថ្មី ◷ ១០នាទី

### ២.១ ការបង្ហាញតួអក្សរថ្មី

◎ **កំណត់រូបរាងស្រៈ ែ**

▤ **ប័ណ្ណអក្សររូបភាព ែ សៀវភៅជំនួយសិស្ស**

◷ **៣នាទី**

**ក- ការអានស្រៈ ែ**

- គ្រូ : សរសេរ ែ ឱ្យធំលើក្តារខៀន។ គ្រូអានច្បាស់ៗ**ស្រៈ ែ**។
- គ្រូនិងសិស្ស : គ្រូចង្អុល រួចអាន **ស្រៈ** ែ ទាំងអស់គ្នា។
- សិស្ស : គ្រូចង្អុលឱ្យសិស្សអាន **ស្រៈ** ែ ដោយខ្លួនឯង។

**ខ- ការបង្ហាញប័ណ្ណអក្សររូបភាព និងកាយវិការ**



- គ្រូ : បង្ហាញប័ណ្ណអក្សររូបភាព ែ និងប្រាប់សិស្សថានេះគឺ ស្រៈ ែ។ **គ្រូថា ស្រៈ ែ ដូចជាពាក្យ ដែ**។ គ្រូថា **ពាក្យ ដែ មានសូរចុង អែ** (កាយវិការ : លាដៃឆ្វេងហើយផ្តាប់ចុងម្រាមទៅមុខបន្ទាប់មកលាបាត

ដៃស្ដាំផ្ទារដាក់ប៉ះលើដើមដៃឆ្វេងត្រង់ដើមដៃរួចអូសចុះក្រោមដល់ ចុងដៃ) ។

- គ្រូនិងសិស្ស : ធ្វើកាយវិការ និងថា **ពាក្យដែមានសូរចុង អែ**។
- សិស្ស : សិស្សធ្វើកាយវិការ និងថា **ពាក្យដែមានសូរចុង អែ** ដោយខ្លួនឯង។

## ២.២ ការហ្វឹកហាត់សរសេរតួអក្សរថ្មី

◎ **សរសេរ ស្រៈ ែបានត្រឹមត្រូវ**

**មិនចាំបាច់**

**៧នាទី**

- គ្រូ : សរសេរ ែ មួយទៀតដោយថាឮៗ តាមចលនានីមួយៗ និងគូសសញ្ញាព្រួញព្រមគ្នាតាមលេខរៀងចលនា។ សរសេរចប់គ្រូថា **១ ២ ៣ ៤ ៥ ស្រៈែ**។
- គ្រូនិងសិស្ស : គ្រូយកចង្អុលដៃតាមលេខរៀងចលនា ែ លើក្ដារខៀន។ សិស្សដាក់ចង្អុលដៃបើៗលើ ែ និងអូសតាមលេខរៀងចលនា លើសៀវភៅជំនួយសិស្ស។ គ្រូ និងសិស្សថា **១ ២ ៣ ៤ ៥ ស្រៈ ែ**។
- សិស្ស: សិស្សយកចង្អុលដៃគូសតាមលេខរៀងចលនា ែ ក្នុងសៀវភៅជំនួយសិស្ស និងថា **១ ២ ៣ ៤ ៥ ស្រៈ ែ**។ គ្រូដើរពិនិត្យនិងជួយសិស្ស។ សិស្ស: សរសេររួចលើកបង្ហាញគ្រូ រួចអាន **ស្រៈ ែ**។ រួចសរសេរ ែចំនួន**៣**បន្ថែមទៀតដោយសរសេរបណ្ដើរអានបណ្ដើរ **ស្រៈ ែ ែ ែ**។

**គន្លឹះត្រូវចងចាំ**

✓ គ្រូនាំសិស្សអានតួអក្សរនីមួយៗ ដោយអនុវត្តតាមជំហាន គ្រូធ្វើ គ្រូនិងសិស្សធ្វើ និង សិស្សធ្វើ។
✓ ប្រសិនបើសិស្សណាមិនចូលរួម ឬលំបាកក្នុងការអានតួអក្សរ គ្រូត្រូវអានតួអក្សរនោះឱ្យច្បាស់ៗ ដើម្បីទាក់ទាញ ចំណាប់អារម្មណ៍សិស្សឱ្យមើលគ្រូ។
★ គ្រូដើរទៅជិតស្ដាប់សិស្សដែលលំបាកក្នុងការអានតួអក្សរ ដើម្បីជួយពួកគេឱ្យហ្វឹកហាត់បានច្រើនដង។
ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្ដារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេស ដោយធានាថា គេអាចមើលឃើញកាយវិការគ្រូច្បាស់។ ពោលគឺធ្វើដូចគ្នានឹងចំណុចផ្កាយខាងលើ។
គ្រូវប្រាកដថា សិស្សអាចមើលឃើញតួអក្សរ និងឮគ្រូបន្លឺសូរអក្សរច្បាស់។
គ្រូទាញចំណាប់អារម្មណ៍សិស្សឱ្យមើលគ្រូខណៈពេលដែលគ្រូបង្ហាញតួអក្សរនិងអាន។

## ៣- ការអានព្យាង្គ និងពាក្យ ២០នាទី

### ៣.១- ការប្រកបសូរដោយប្រើដៃជាជំនួយ

◎ ផ្សំសូរព្យញ្ជនៈ និងស្រៈ ែ បង្កើតជាព្យាង្គដោយផ្ទាល់មាត់

មិនចាំបាច់

៣នាទី

- គ្រូ : ចាប់ផ្ដើមដោយប្រកបសូរ **ក អែ កែ** ដោយធ្វើដៃក្នុងខ្យល់បង្ហាញសិស្ស។

- គ្រូនិងសិស្ស : ប្រកបសូរ **ខ អែ ខែ** ដោយធ្វើដៃក្នុងខ្យល់ដំណាលគ្នា។
- សិស្ស : គ្រូថាសូរម្តងមួយៗ **ច អែ ឆ អែ**។ សិស្សផ្សំសូរបញ្ចូលគ្នាបណ្តើរទះដៃបណ្តើរ **ច អែ ចែ ឆ អែ ឆែ**។

**៣.២- ការអានព្យាង្គក្នុងសៀវភៅជំនួយសិស្ស**

◎ **ផ្សំអក្សរដើម្បីអានព្យាង្គ**

🗐 **សៀវភៅជំនួយសិស្ស អក្សរចល័ត**

◷ **១២នាទី**

**ក- ការអានព្យាង្គដោយប្រើអក្សរចល័ត**

- គ្រូ : លើកអក្សរចល័ត **ក** ផ្សំនឹងស្រៈ ែ អានថា **កែ** ជាគំរូ **ក អែ កែ**។
- គ្រូនិងសិស្ស : គ្រូលើកអក្សរចល័ត **ខ** ផ្សំជាមួយស្រៈ ែ នាំសិស្សអាន **ខ អែ ខែ**។
- សិស្ស : គ្រូលើកអក្សរចល័តម្តងមួយៗ **ច ឆ** ផ្សំជាមួយស្រៈ ែ សិស្សអាន**ច អែ ចែ ឆ អែ ឆែ**។

**ខ- ការអានព្យាង្គនៅលើក្តារខៀន**

- គ្រូ : ប្រើដីសពណ៌ខុសគ្នារវាងស្រៈ និងព្យញ្ជនៈ សរសេរព្យាង្គ **កែ** លើក្តារខៀន។ រួចអាន **ក អែ កែ** ដោយចង្អុលឱ្យចំតួអក្សរនីមួយៗ ចង្អុលឱ្យចំព្យាង្គ។
- គ្រូ និងសិស្ស : គ្រូសរសេរ **ខែ** រួចចង្អុល និងនាំសិស្សអាន។
- សិស្ស : គ្រូសរសេរ **ចែ ឆែ** រួចចង្អុលឱ្យសិស្សអាន។

**គ- ការអានព្យាង្គក្នុងសៀវភៅជំនួយសិស្ស**

- គ្រូឱ្យសិស្សបើកសៀវភៅជំនួយសិស្សត្រង់តារាងទី១។ គ្រូបើកសៀវភៅជំនួយសិស្សរួចយកដៃចង្អុលនិងអានបណ្តើរ **ក អែ កែ**។ គ្រូឱ្យសិស្សផ្សំ និងអានព្យាង្គជាដៃគូ **កែ ខែ ចែ ឆែ** ដោយម្នាក់ជាអ្នកចង្អុល ម្នាក់ទៀតជាអ្នកអាន រួចប្តូរវេនគ្នា។ គ្រូឱ្យសិស្សអានដោយខ្លួនឯងប្រសិនបើមានពេល។
- គ្រូឱ្យសិស្សផ្សំ និងអានព្យាង្គក្នុងតារាងទី២ពី**កា**ដល់**កែ** ជាដៃគូ ដោយម្នាក់ជាអ្នកចង្អុល ម្នាក់ទៀតជាអ្នកអាន រួចប្តូរវេនគ្នាអាន។ គ្រូឱ្យសិស្សអានដោយខ្លួនឯងប្រសិនបើមានពេល។

**៣.៣- ផ្គូផ្គងពាក្យ នឹងរូបភាព**

◎ **អានពាក្យ និងភ្ជាប់ពាក្យទៅនឹងរូបភាព**

🗐 **សៀវភៅជំនួយសិស្ស**

◷ **៥នាទី**

គ្រូសួរសិស្សថា **តើនេះជារូបអ្វី?** ហើយពន្យល់បន្ថែមឱ្យច្បាស់។ គ្រូពន្យល់សិស្សថា ពួកគេត្រូវប្រើចង្អុលដៃភ្ជាប់ពាក្យទៅនឹងរូបភាពឱ្យបានត្រឹមត្រូវ។

- គ្រូ : ចង្អុល និងអានពាក្យ **ខែ** ដោយអូសដៃភ្ជាប់ទៅនឹងរូបភាព **ខែ**។

- គ្រូ និងសិស្ស : ចង្អុល និងអានពាក្យ **ខែ** ដោយអូសដៃភ្ជាប់ទៅនឹងរូបភាព **ខែ**។
- សិស្ស : ចង្អុល និងអានពាក្យ **ចែ** ដោយអូសដៃភ្ជាប់ទៅនឹងរូបភាព **ចែ**។ សិស្សផ្ទៀងផ្ទាត់ពាក្យ **ខែ ខែ ចែ** និងរូបភាពជាដៃគូ និងអានជាបុគ្គលប្រសិនបើមានពេល។

**គន្លឹះត្រូវចងចាំ**

✓ គ្រូនាំសិស្សអានតួអក្សរនីមួយៗ ដោយអនុវត្តតាមជំហាន គ្រូធ្វើ (គ្រូធ្វើជាគំរូ) គ្រូ និងសិស្ស (គ្រូនិងសិស្សធ្វើជាមួយគ្នា មិនមែនសិស្សថាតាមគ្រូទេ) និង សិស្សធ្វើ (សិស្សធ្វើដោយខ្លួនឯងជាដៃគូ ឬជាបុគ្គល)។

✓ ប្រសិនបើសិស្សណាមិនចូលរួម ឬលំបាកក្នុងការអានតួអក្សរ គ្រូត្រូវអានតួអក្សរនោះឱ្យច្បាស់ៗដើម្បីទាក់ទាញចំណាប់អារម្មណ៍សិស្សឱ្យមើលគ្រូ។

✓ ពេលអានព្យាង្គគ្រូត្រូវចង្អុលតួអក្សរនីមួយៗរួចបន្លឺសូរអក្សរ និងព្យាង្គ។

✓ គ្រូត្រូវធានាថា សិស្សគ្រប់គ្នាបើកសៀវភៅអានចំទំព័រដែលត្រូវអាន។

✓ គ្រូដើរតាមតុសិស្ស ស្តាប់សិស្សអានជាដៃគូ និងជួយកែតម្រូវសិស្សណាអានមិនទាន់ត្រឹមត្រូវ។

★ គ្រូដើរទៅជិតសិស្សដែលជួបការលំបាកក្នុងការអានឱ្យបានញឹកញាប់ និងជួយឱ្យគេហាត់ច្រើនដងតាមដែលអាចធ្វើទៅបាន។

✍ ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្តារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេ និងសិស្សទាំងអស់ជាពិសេសដោយធានាថាសិស្សទាំងអស់អាចមើលឃើញកាយវិការ និងឮគ្រូច្បាស់។ ពេលគឺធ្វើដូចគ្នានឹងចំណុចផ្កាយខាងលើ។

✍ គ្រូត្រូវដើរទៅជិតសិស្ស អានឮៗជាគំរូ ដោយធានាថាសិស្សស្តាប់ឮគ្រូអាន។

## ៤- វាក្យសព្ទ ◷ ៥នាទី

◎ **យល់ន័យ និងប្រើប្រាស់ពាក្យ**

▤ **សៀវភៅសិក្សាគោល**

◷ **៥នាទី**

**ពាក្យ ខែ**

- គ្រូ : សរសេរ ឬគូសវង់ជុំវិញពាក្យ **ខែ** លើក្តារខៀនរួចពន្យល់ថា **ខែ** មានន័យថា ធ្វើឱ្យប្រហោង ឬធ្លុះដោយដែកស្រួច។ ឧ. ពូម៉ៅខែទ្វារដើម្បីជួសជុល។
- គ្រូនិងសិស្ស : គ្រូចង្អុលពាក្យ **ខែ** គ្រូនិងសិស្សអានជាមួយគ្នា។ យើងនឹងបង្កើតល្បះមួយដោយផ្ទាល់មាត់ទាំងអស់គ្នា ដោយប្រើពាក្យ **ខែ**។ គ្រូជាអ្នកផ្តើមល្បះ អ្នកទាំងអស់គ្នាចាំជួយបំពេញល្បះដោយពាក្យ **ខែ**។
- គ្រូថា **តាសំ...បង្អួចដើម្បីជួសជុល** (តាសំ [គ្រូផ្អាកបន្តិច] បង្អួចដើម្បីជួសជុល)។ សិស្សថា **ខែ**។ គ្រូនិងសិស្សថាល្បះពេញលេញជាមួយគ្នា។

- ម្យ៉ាងទៀត គ្រូអាចបំផុសសំណួរដើម្បីនាំសិស្សឱ្យបង្កើតល្បះ។ ឧ.តើអ្នកណាខៃទ្វារ? ខៃដើម្បីធ្វើអ្វី?
- សិស្ស : គ្រូចង្អុលពាក្យ **ខៃ** ឱ្យសិស្សអាន។ គ្រូឱ្យសិស្សបង្កើតល្បះជាមួយពាក្យ **ខៃ** ជាដៃគូដោយផ្ទាល់មាត់។

**គន្លឹះត្រូវចងចាំ**

✓ គ្រូផ្ដល់និយមន័យងាយៗដែលជួយឱ្យសិស្សអាចយល់បាន។
✓ គ្រូស្ដាប់ល្បះដែលសិស្សបង្កើត ដើម្បីធានាថាសិស្សបានយកពាក្យថ្មី មកប្រើប្រាស់ត្រឹមត្រូវ។ ចៀសវាងសើចចំអកសិស្ស។
✓ គ្រូស្ដាប់ល្បះហើយសួរបញ្ជាក់ ប្រសិនល្បះនោះមិនទាន់មានន័យគ្រប់គ្រាន់។
✓ គ្រូត្រូវទុកពេលឱ្យសិស្សក្នុងការហ្វឹកហាត់បង្កើតល្បះថ្មីជាមួយពាក្យថ្មីបានគ្រប់គ្រាន់។
✓ គ្រូត្រូវប្រាកដថា សិស្សទាំងអស់អាចមើលឃើញ និងស្ដាប់ឮគ្រូច្បាស់។
★ គ្រូអាចជ្រើសរើសពាក្យដែលពិបាកយល់ន័យក្នុងសៀវភៅសិក្សាគោល ឬក្នុងអត្ថបទខ្លី មកពន្យល់បន្ថែមទៀត ដោយសរសេរលើក្ដារខៀន ប្រសិនបើមាន។
✎ គ្រូត្រូវដើរទៅជិតសិស្ស នៅពេលគ្រូពន្យល់ និងបង្កើតល្បះជាឧទាហរណ៍ដល់សិស្ស។

## ៥- ការអានអត្ថបទខ្លី ◷ ១៥នាទី

◎ **អានស្ទាត់ និងបង្ហាញការយល់ន័យនៃអត្ថបទ**

**សៀវភៅជំនួយសិស្ស (មេរៀនស្រៈ ៃ)**

◷ **១៥នាទី**

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព និងប្រាប់ចំណងជើងអត្ថបទ។

ខ- គ្រូ ឱ្យសិស្សទស្សន៍ទាយសាច់រឿងថា **តើរឿងនេះនិយាយពីអ្វី?**

- គ្រូ : អានរឿងពីដើមដល់ចប់យឺតៗ ដោយលើកដាក់សំឡេងគោរពតាមសញ្ញាសម្ព័ន្ធ។
- គ្រូ និងសិស្ស : អានអត្ថបទខ្លីជាមួយគ្នា។
- សិស្ស : អានអត្ថបទខ្លីជាដៃគូ។

គ- គ្រូឱ្យសិស្សអានជាបុគ្គល។

ឃ-គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរម្ដងមួយៗ ដោយទុកពេលឱ្យសិស្សគិត និងសម្របសម្រួលចម្លើយរបស់សិស្ស (អានអត្ថបទឡើងវិញ)៖



កី

ឆៃខៃកី។

ឆៃកៃកី។

កីខៃកី។

កីកៃកី។

១- តើឆៃខៃអ្វី?

២- តើនរណាខៃកីជាមួយឆៃ?

៣- តើកូនគិតថា ហេតុអ្វីបានជាពួកគាត់ខែកី?

៤- តើកូនធ្លាប់ឃើញគេខែអ្វីខ្លះទៀត? តើគេខែដើម្បីអ្វី?

**គន្លឹះត្រូវចងចាំ**

- ✓ ក្នុងពេលគ្រូធ្វើ គ្រូត្រូវអានជាគំរូ ដោយមានការលើកដាក់សំឡេងក្នុងល្បឿនសមរម្យ។
- ✓ គ្រូត្រូវប្រាកដថា សិស្សប្រើភ្នែក និងម្រាមដៃរតាមតួអក្សរក្នុងពេលគ្រូនិងសិស្សធ្វើ និងសិស្សធ្វើ។
- ✓ ក្នុងពេលគ្រូនិងសិស្សធ្វើ សិស្សត្រូវអានជាមួយគ្រូ មិនមែនអានតាមគ្រូទេ។
- ✓ ប្រសិនបើមានពេល គ្រូឱ្យសិស្សហាត់អានអត្ថបទឱ្យបានច្រើនដង។
- ✓ សម្រាប់សំណួរដែលមានចម្លើយលើសពីមួយ ទុកពេលសមល្មមឱ្យសិស្សប្រើបទពិសោធ ឬគំនិតផ្ទាល់ខ្លួនពិភាក្សាជាដៃគូ។
- ✓ ប្តូរសំណួរ តែរក្សាន័យដដែល ពេលដែលសិស្សស្តាប់សំណួរគ្រូមិនយល់។
ជួយពួកគេ ដោយប្រើសំណួរប្រជេញ ប្រសិនបើគេនៅតែមិនទាន់យល់សំណួរ។

## ៦- ការសរសេរ ◷ ២០នាទី

### ៦.១- សរសេរតាមអានចម្លង ព្យាង្គ ឬពាក្យ

◎ **សរសេរព្យាង្គ ឬពាក្យបានត្រឹមត្រូវ**

🗐 **មិនចាំបាច់**

◷ **២០នាទី**

ក- ហៅព្យាង្គ ឬពាក្យឱ្យសិស្សសរសេរលើក្តារឆ្នួន។

- គ្រូ : ថា **កែ** ឮៗ រួចគិត និងថាឮៗ **កែ** មាន **ក** ែ ។ គ្រូសរសេរ **កែ** លើក្តារខៀន។
- គ្រូនិងសិស្ស : គ្រូថា **ចែ** ឮៗ។ គ្រូនិងសិស្សគិតនិងថាឮៗជាមួយគ្នា **ចែ មាន ច** ែ។ គ្រូសរសេរ **ចែ** លើក្តារខៀន និងសិស្សសរសេរលើក្តារឆ្នួន។
- សិស្ស : គ្រូហៅ **ខែ** ឮៗ។ សិស្សគិតនិងថាឮៗ **ខែ** មាន **ខ** ែ។ សិស្សសរសេរ **ខែ** លើក្តារឆ្នួន។

ខ- ចំពោះ **ផែ** គ្រូអនុវត្តតាមលំនាំបង្រៀនខាងលើ។

### ៦.២- កិច្ចការផ្ទះ

◎ **ហ្វឹកហាត់អាន សរសេរព្យាង្គ និងពាក្យ**

🗐 **សៀវភៅជំនួយសិស្ស**

- គ្រូឱ្យសិស្សអានក្នុងសៀវភៅជំនួយសិស្ស និងចម្លងព្យាង្គ **កែ ខែ ចែ ផែ** ដាក់ក្នុងសៀវភៅរៀងៗខ្លួន។

**គន្លឹះត្រូវចងចាំ**

✓ ដំណាក់កាលគ្រូធ្វើ គ្រូគប្បីថាពាក្យយឺតៗ ច្បាស់ៗមុនសរសេរស្រះ។
✓ នៅពេលគ្រូហៅឱ្យសិស្សសរសេរ គ្រូគួរហៅពាក្យនីមួយៗ ៣ដងហើយប្រមាណ៣វិនាទីហៅម្តង។
★ គ្រូដើរពិនិត្យពេលសិស្សសរសេរ ហើយជួយកែតម្រូវនៅពេលដែលកំពុងសរសេរ។
☞ ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្តារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេសត្រូវធានាថាសិស្សទាំងអស់អាចមើលឃើញកាយវិការគ្រូ និងឮគ្រូច្បាស់។
☞ ប្រសិនបើសិស្សខ្សោយគំហើញ មានការលំបាកក្នុងការសរសេរ (សរសេរអក្សរទំហំមិនប៉ុនគ្នា មិនត្រង់ជួរ ឬត្រួតលើគ្នា...) គ្រូត្រូវប្រើសៀវភៅសរសេរដែលមានក្រឡាបន្ទាត់ជិតច្បាស់ៗ ឬគ្រូគូសក្រឡាបន្ទាត់ជិតឱ្យសិស្ស។
✌ គ្រូត្រូវដើរទៅជិតសិស្ស ដើម្បីឱ្យសិស្សទាំងអស់បានឮពាក្យនិងឃ្លាដែលគ្រូហៅបានច្បាស់លាស់។

## ៣.២ លំនាំបង្រៀនព្យញ្ជនៈ ក ផ្សំស្រៈ

| **លំនាំបង្រៀន** | **មេរៀនទី៥ ព្យញ្ជនៈ ក ផ្សំស្រៈ** | ◷ **៨០នាទី** |
|---|---|---|
| **រំឭកមេរៀន** | | ◷ **៥នាទី** |

- គ្រូរំឭកពាក្យដែលបានរៀនរួច **ផៅ ខោ កាំ កោះ ឆេះ**។

| ១- ការស្គាល់សូរអក្សរថ្មី | ◷ ៥នាទី |
|---|---|

| ១.១- ល្បែងទស្សន៍ទាយ | | ១.២- ល្បែង បាទឬចាស និង ទេ | |
|---|---|---|---|
| -គ្រូបំផុសរកពាក្យ **កា**។ គ្រូឱ្យសិស្សរកសូរដើមនៃពាក្យ**កា**។ | | គ្រូ | ថា កែ ដូរ និងធ្វើសញ្ញា "បាទ ឬចាស" និង"ទេ" ។ |
| គ្រូ | - បន្លឺសូរ **ក** ។ | គ្រូ និងសិស្ស | ថា កឺ ខំ និងធ្វើសញ្ញា "បាទ ឬចាស" និង"ទេ" ។ |
| គ្រូនិងសិស្ស | - បន្លឺសូរ **ក** ទាំងអស់គ្នា។ | សិស្ស | គ្រូថា **កា ឆា កេះ ចៃ ខះ កាំ** ឱ្យសិស្សធ្វើសញ្ញា។ |
| សិស្ស | - បន្លឺសូរ **ក** ទាំងអស់គ្នា។ | | |

| ២- ការស្គាល់តួអក្សរថ្មី | ◷ ៥នាទី |
|---|---|

២.១- ការបង្ហាញតួអក្សរថ្មី

**ក- ការអាន ក**

គ្រូ	សរសេរ **ក** ឱ្យធំលើក្ដារខៀន។ គ្រូអានច្បាស់ៗ **ក**។

គ្រូនិងសិស្ស	គ្រូចង្អុល រួចអាន **ក** ទាំងអស់គ្នា។

សិស្ស	គ្រូចង្អុលឱ្យសិស្សអាន **ក** ដោយខ្លួនឯង។

**ខ- ការបង្ហាញប័ណ្ណអក្សររូបភាព និងកាយវិការ**

គ្រូ
- បង្ហាញប័ណ្ណអក្សររូបភាព **ក** និងប្រាប់សិស្សថានេះ **ក**។ គ្រូថា **ក ដូចជាពាក្យកង្កែប។**
- ថា **ពាក្យ កង្កែប មានសូរដើម ក និងធ្វើ**កាយវិការ ធ្វើដៃស្ដាំជាក្បង់ផ្កាប់ ចុងម្រាមទៅមុខដោយដាក់នៅខាងស្ដាំ រួចលើកទៅមុខ ពីឆ្វេងទៅស្ដាំ ចំនួនពីរដង តាមចលនាកង្កែបលោត។



គ្រូនិងសិស្ស
- ធ្វើកាយវិការ និងថា **ក ដូចជាពាក្យកង្កែប ពាក្យ កង្កែប មានសូរដើម** ក ។

សិស្ស
- ធ្វើកាយវិការ និងថា **ក ដូចជាពាក្យកង្កែប ពាក្យ កង្កែប មានសូរដើម ក** ។

**២.២- ការហ្វឹកហាត់សរសេរតួអក្សរថ្មី**

គ្រូ
- សរសេរ ក តាមចលនាសញ្ញា។ គ្រូរាប់ចលនាសញ្ញា និងថា **ក**។

គ្រូនិងសិស្ស
- គ្រូយកដៃចង្អុលអូសតាមលេខរៀងចលនា **ក** លើក្ដារខៀន។ សិស្សធ្វើដូចគ្រូលើសៀវភៅសិក្សាគោល។

សិស្ស
- យកដៃចង្អុលអូសតាមលេខរៀងចលនា **ក** លើសៀវភៅសិក្សាគោល។
- សរសេរ **ក** នៅលើក្ដារឆ្នួន លើកបង្ហាញគ្រូ។ រួចសរសេរ **ក** ចំនួន**៣** បន្ថែមទៀតរួចអាន **ក ក ក**។

**៣- ការអានព្យាង្គ និងពាក្យ** ◷ **២០នាទី**

**៣.១- ការប្រកបសូរដោយប្រើដៃជាជំនួយ**

គ្រូ
- ប្រកបសូរដោយធ្វើដៃក្នុងខ្យល់បង្ហាញសិស្ស **ក អុំ កុំ**។

គ្រូនិងសិស្ស
- ប្រកបសូរដោយធ្វើដៃក្នុងខ្យល់ដំណាលគ្នា **ក អុ កុ**។

សិស្ស
- គ្រូថាសូរម្ដងមួយៗ **ក អាំ ក អេះ ក អី** ។ សិស្សផ្សំសូរបញ្ចូលគ្នា **ក អាំ កាំ ក អេះ កេះ ក អី កី**។

**៣.២- ការអានព្យាង្គក្នុងសៀវភៅសិក្សាគោល**

**ក- ការអានព្យាង្គដោយប្រើអក្សរចល័ត**

គ្រូ - យកអក្សរចល័ត **ក** ផ្សំនឹងស្រៈ ុ ហើយអានជាគំរូថា **ក អុ កុ** ។

គ្រូនិងសិស្ស - គ្រូផ្សំអក្សរចល័ត **ក** ជាមួយស្រៈ ី ហើយនាំសិស្សអានជាមួយគ្នាថា **ក អី កី**។

សិស្ស - គ្រូផ្សំអក្សរចល័ត **ក** ជាមួយស្រៈ ាំ ដើម្បីឱ្យសិស្សអានដោយប្រកប **ក អាំ កាំ**។

**ខ- ការអានព្យាង្គនៅលើក្ដារខៀន**

គ្រូ - សរសេរព្យាង្គ កុ លើក្ដារខៀន។ រួចអាន **ក អុ កុ** ដោយចង្អុលឱ្យចំតួអក្សរ និងព្យាង្គនីមួយៗ។

គ្រូ និងសិស្ស - គ្រូសរសេរ **កី** ហើយចង្អុល និងនាំសិស្សអានជាមួយគ្នា **ក អី កី** ។

សិស្ស - អានពី **ក** ដល់ **កោះ** ក្នុងសៀវភៅសិក្សាគោលជាដៃគូដោយប្រកប។

**៣.៣- ការអានពាក្យលើក្ដារខៀន និងសៀវភៅសិក្សាគោល**

គ្រូ - សរសេរពាក្យ **កកេរ** លើក្ដារខៀន។ គ្រូអានពាក្យដោយផ្សំប្រកប **ក ក អេ កេ កេ និង រ កេរ កកេរ**។

គ្រូនិងសិស្ស - គ្រូសរសេរពាក្យ **កកូរ** លើក្ដារខៀន។ គ្រូនិងសិស្សអានពាក្យ **ក ក អូ កូ កូ និង រ កូរ កកូរ**។

សិស្ស - គ្រូសរសេរពាក្យ **កោះ** ។សិស្សអានពាក្យ **ក អោះ កោះ**។ សិស្សអានពាក្យទាំងអស់ក្នុងសៀវភៅសិក្សាគោល។

## ៤- វាក្យសព្ទ ⌚ ៥នាទី

គ្រូ - ពន្យល់ពាក្យ **កកេរ មានន័យថា ខាំរឿយៗ ដើម្បីឱ្យអ្វីមួយដាច់។ ឧ. កណ្ដុរ កកេរ តុ**។

គ្រូនិងសិស្ស - គ្រូតែងល្បះរួមគ្នាដោយផ្ទាល់មាត់ដោយប្រើពាក្យ **កកេរ**។

សិស្ស - បង្កើតល្បះដោយប្រើប្រាស់ពាក្យ **កកេរ**។ ជាដៃគូ។

## ៥- ការអានល្បះ ⌚ ៥នាទី

- គ្រូបំផុសសំណួរទាក់ទងនឹងខ្លឹមសារល្បះ។ គ្រូសរសេរល្បះ **កុំកេះកៃ**។
  រួចនាំសិស្សញែកពាក្យក្នុងល្បះដោយសួរសិស្សថា តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ ? **កុំ/កេះ/កៃ**។

គ្រូ - គ្រូអានល្បះជាគំរូ **កុំកេះកៃ**។

គ្រូនិងសិស្ស - គ្រូនិងសិស្សអានល្បះជាមួយគ្នា **កុំកេះកៃ**។

សិស្ស - សិស្សអានល្បះ **កុំកេះកៃ**។ សិស្សអានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល។

## ៦- ការអានអត្ថបទខ្លី ◷ ១៥នាទី

ក- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។

ខ-គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿង

**តើរឿងនេះនិយាយពីអ្វី?**

គ- គ្រូនិងសិស្សអានតាមលំនាំខាងក្រោម។

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ ឱ្យសិស្សស្ដាប់។ |
| គ្រូ និងសិស្ស | - អានអត្ថបទខ្លីជាមួយគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើសត្វអ្វីកកេរកី?**

**២- តើកុកកកេរអ្វីខ្លះទៀតក្រៅពីកី?**

**៣- តើកូនគិតថា ហេតុអ្វីបានជាកុកកកេរកី?**

**៤- តើកូនធ្លាប់ដឹងថា កណ្ដុរកកេរអ្វីខ្លះទៀត? តើមានអ្វីកើតឡើង ក្រោយពីវាកកេរ?**

## ៧- ការសរសេរ ◷ ២០នាទី

### ៧.១- សរសេរតាមអាន

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **កុ** **ក** ◌ុ រួចសរសេរ **កុ** លើក្ដារខៀន។ |
| គ្រូ និងសិស្ស | - គិត និងថាឮៗ **កី ក** ◌ី រួចគ្រូសរសេរ **កី** លើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **កោះ កាំ កកេរ** ម្ដងមួយៗ។ សិស្សគិត និងថាឮៗ រួចសរសេរពាក្យទាំងនេះលើក្ដារឆ្នួន។ គញ្ជូរសរសេរ កោះ កាំ កកេរ លើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- បំពេញតួអក្សរដើម្បីបង្កើតពាក្យ

- គ្រូសរសេរពាក្យ កី នៅក្ដារខៀន។ គ្រូនិងសិស្សសរសេរពាក្យ កោះ (លើក្ដារខៀន និងក្ដារឆ្នួន)។ សិស្សសរសេរ កាំ។

### ៧.៣ -កិច្ចការផ្ទះ

ក- គ្រូឱ្យសិស្សហ្វឹកហាត់អានខ្លឹមសារមេរៀនព្យញ្ជនៈ ក ក្នុងសៀវភៅសិក្សាគោល។

ខ- គ្រូឱ្យសិស្សចម្លងល្បះពីក្នុងសៀវភៅសិក្សាគោលដាក់ក្នុងសៀវភៅរៀងៗខ្លួន។

## ៣.៣ លំនាំបង្រៀនសញ្ញាម្ញសិកទន្ត និងត្រីស័ព្ទ

### រំឭកមេរៀនចាស់ ◷ ៥នាទី

◎ ការអានពាក្យ **លំនៅ រឹបឺ យីកេ គិរី ភាសា**

❐ បណ្ដាពាក្យបត់ជាពីរផ្នត់ មួយព្យាង្គមួយផ្នត់

◷ ៥ នាទី

គ្រូប្រើបណ្ណពាក្យ ឬសរសេរពាក្យនៅលើក្ដារខៀន **លំនៅ វិថី យីកេ គិរី ភាសា** (អាចបន្ថែមមួយពាក្យ ឬពីរពាក្យទៀត ដែលគ្រូគិតថាសិស្សពិបាកអាន និងសរសេរ )។

- គ្រូបង្ហាញបណ្ណនៃពាក្យ **លំនៅ វិថី យីកេ គិរី ភាសា** ដោយលាម្ដងមួយព្យាង្គៗឱ្យសិស្សអាន **លំនៅ** ឬគ្រូសរសេរពាក្យលើក្ដារខៀន។
- គ្រូចង្អុលឱ្យសិស្សអានដោយមិនបាច់ផ្សំប្រកប **លំនៅ**។
- គ្រូអនុវត្តលំនាំដូចគ្នាចំពោះពាក្យផ្សេងទៀត។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

✓ គ្រូគួរផ្ដើមពីអ្វីដែលងាយស្រួលទៅលំបាក។ នៅពេលណែនាំពាក្យ ក៏គួរផ្ដើមពីពាក្យមួយព្យាង្គមុន បន្ទាប់មកពាក្យពីរព្យាង្គ ឬបីព្យាង្គ។ ធ្វើបែបនេះ គឺជាលំនាំនៃការអភិវឌ្ឍសមត្ថភាពអាន/សរសេររបស់សិស្សបន្តិចម្ដងៗ ដែលធ្វើឱ្យពួកគេបង្កើនទំនុកចិត្តក្នុងការអាន។

✓ សង្កេតមើលថា តើសិស្សអានពាក្យដែលបានរៀនរួច បានត្រឹមត្រូវឬទេ។

✓ គ្រូត្រូវបានលើកទឹកចិត្តឱ្យប្រើប័ណ្ណពាក្យ ជាជាងការសរសេរលើក្ដារខៀន ដើម្បីធ្វើឱ្យសិស្សទាំងអស់ចាប់អារម្មណ៍ និងមើលឃើញច្បាស់។

✓ ត្រូវលើកប័ណ្ណពាក្យឱ្យខ្ពស់ល្មម ឬកាន់ដើរទៅជិតសិស្ស នៅពេលឃើញសិស្សណាម្នាក់ ឬច្រើននាក់ងាកឆ្វេងស្ដាំ មិនផ្ដោតលើមេរៀន។

★ ប្រសិនបើមានសិស្សណាមានការពិបាកក្នុងការអាន គ្រូអានពាក្យនោះច្បាស់ៗ ដោយឱ្យសិស្សមើលគ្រូ ខណៈពេលដែលគ្រូបន្លឺសូរ ផ្សំ ប្រកប អានពាក្យ ឬបំបែកពាក្យ។ គ្រូផ្ដល់ឧទាហរណ៍អំពីការប្រកប ឬបំបែកសូរ តាមរយៈពាក្យងាយៗ ជាមុន ផ្ដើមពីមួយព្យាង្គទៅពីរព្យាង្គ។ ឧទាហរណ៍: **លំនៅ (ល ំ លំ ន ៅ នៅ** អានថា **លំនៅ)**។

★ប្រសិនបើសិស្សមួយចំនួនជួបការលំបាកខ្លាំងជាមួយតួអក្សរ ឬពាក្យណាមួយ ត្រូវហាត់អានអក្សរ ឬពាក្យនោះឱ្យបានច្រើនដងក្នុងមួយថ្ងៃ។ ឧទាហរណ៍: មុន ឬក្រោយម៉ោងចេញលេង នៅពេលលេងល្បែងថាមពល មុនពេលចេញទៅផ្ទះ ឬមុនចូលរៀន។

☞ បង្ហាញបណ្ណពាក្យឱ្យជិតសិស្ស។ បើគ្រូសរសេរនៅលើក្ដារខៀន ត្រូវសួរបញ្ជាក់សិស្សថាតើគេមើលឃើញច្បាស់ឬទេ។ គ្រូអាចប្ដូរសិស្សខ្សោយគំហើញមកអង្គុយតុមុខ។ ទាញចំណាប់អារម្មណ៍សិស្សឱ្យមើលគ្រូ ខណៈពេលដែលគ្រូបន្លឺសូរ និងអានពាក្យរួម ជាមួយការធ្វើកាយវិការ។

**១- ការស្គាល់សូរអក្សរថ្មី** ◷៧នាទី

១.១-ល្បែងទស្សន៍ទាយ

◎ កំណត់ព្យាង្គ ឬពាក្យដែលផ្ដើមដោយព្យញ្ជនៈ ង់

❐ បណ្ណអក្សររូបភាព

◷ ៧ នាទី

គ្រូប្រើរូបភាព ធ្វើកាយវិការ ឬពណ៌នាដើម្បីឱ្យសិស្សថាព្យាង្គ ឬពាក្យ និងប្រាប់សូរ **ង់**។

ឧទាហរណ៍៖

ក- គ្រូ : ធ្វើកាយវិការបើកូនង៉ែត និងគ្រាប់តាមកូនង៉ែតយំ៖ **ង៉ាៗ**។ គ្រូសួរសិស្សថាតើកូនង៉ែតយំឮសូរយ៉ាងម៉េច? គ្រូប្រាប់សិស្សថាកូនង៉ែតយំ**ង៉ាៗ**។ គ្រូបន្លឺថា **ង៉ា** មានសូរដើម **ង៉** ។

ខ- គ្រូ និងសិស្ស : គ្រូនាំសិស្សថា **ង៉** ចំនួន២ដង។

គ- សិស្ស : គ្រូឱ្យសិស្សថា **ង៉** ចំនួន ២-៣ដង។

**១.២-ល្បែងញែកសូរ** (ល្បែងលើកដៃ និងទម្លាក់ដៃ)

◎ កំណត់ព្យាង្គ ឬពាក្យដែលផ្ដើមដោយព្យញ្ជនៈ ង៉

◎ មិនត្រូវការសម្ភារៈ

◷ ៤ នាទី

**ការពន្យល់ពីល្បែង :** គ្រូប្រាប់សិស្សថា : យើងនឹងលេងល្បែងមួយ។ មុនលេងគ្រូរំឭកពីមេរៀនព្យញ្ជនៈផ្សំស្រៈ។ ពេលគេយកព្យញ្ជនៈពួក **អ** ផ្សំជាមួយស្រៈ ា ិ ី នៅឮសូរ អា អិ អី ជដែល ដូចជា កា កិ កី...។ ប្រសិនបើគេយកស្រៈទាំងនោះផ្សំជាមួយព្យញ្ជនៈពួកអ៊ិ វាដូរសូរ ដូចជា គា គិ គី ...។ គ្រូនឹងហៅព្យាង្គម្ដងមួយៗ។ ប្រសិនបើព្យាង្គនោះមានសូរដើម **ង៉** សិស្សត្រូវលើកដៃម្ខាងឡើងលើ។ បើព្យាង្គ ឬពាក្យមិនមែនសូរដើម **ង៉** សិស្សត្រូវទម្លាក់ដៃទៅមុខត្រង់។

**សម្គាល់ :** គ្រូធ្វើបង្ហាញជាគំរូ។គ្រូហៅពាក្យក្នុងប្រអប់ខាងក្រោម។

| គ្រូ: **ង៉ឺ ងឺ** | គ្រូ និងសិស្ស: **ង៉ុំ ងាំ ងឺ ង៉ឺ** | សិស្ស: **ងោះ ង៉ោះ ងៅ ង៉ៅ** |
|---|---|---|
| របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖<br>✓ប្រសិនបើសិស្សណាមិនចូលរួម គ្រូត្រូវថាព្យាង្គនោះឱ្យច្បាស់ៗ។ ប្រាកដថាពួកគេផ្ដោតមកគ្រូ។<br>✍ ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្ដារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេសដោយធានាថាគេអាចមើលឃើញកាយវិការគ្រូច្បាស់។<br>ទាញចំណាប់អារម្មណ៍សិស្សឱ្យមើលគ្រូ ខណៈពេលដែលគ្រូបន្លឺសូរ និងអានពាក្យ រួម ជាមួយការធ្វើកាយវិការ ។ | | |

**២- ការស្គាល់តួអក្សរថ្មី**

◷ ៥នាទី

**២.១ ការបង្ហាញតួអក្សរថ្មី**

◎ កំណត់ព្យាង្គឬពាក្យដែលផ្ដើមដោយព្យញ្ជនៈ ង៉

❒ ដីសពណ៌

◷ ៣ នាទី

គ្រូប្រាប់សិស្សថា ក្នុងចំណោមព្យញ្ជនៈទាំង៣៣តួ តួនីមួយៗមានគូរបស់វាដូចជា **ក** គូនឹង**គ** **ខ** គូនឹង**ឃ**។

គ្រូសរសេរតួអក្សរនីមួយៗលើក្ដារខៀនបណ្ដើរ គូសភ្ជាប់បណ្ដើរ **ក - គ ខ - ឃ**។ គ្រូនិយាយថា ដោយឡែកព្យញ្ជនៈពណ៌ក្រហមមួយចំនួនមិនទាន់មានគូនៅឡើយ។ ថ្ងៃនេះយើងនឹងរៀនពីវិធីដូរពួកពណ៌ក្រហមឱ្យមានគូវាពណ៌ខៀវ។

ក- គ្រូៈសរសេរអក្សរ **ង** ឱ្យធំនៅលើក្ដារខៀន។សួរសិស្សថាព្យញ្ជនៈអ្វី? គ្រូសរសេរ **ង** មួយទៀតក្បែរនោះរួចបន្ថែមសញ្ញាមូសិកទន្ត (៉) នៅលើ **ង** ។ គ្រូប្រាប់ថានេះ សញ្ញាធ្មេញកណ្ដុរ ឬមូសិកទន្ត(៉)។ គេប្រើប្រាស់សម្រាប់បំបែរសូរព្យញ្ជនៈពួក **អ៊** ឱ្យទៅជាពួក **អ** ។

**គ្រូអាចពន្យល់ម្យ៉ាងទៀតថា** : ដោយសារតែ **ង** ពណ៌ក្រហម មិនទាន់មានគូវាពណ៌ខៀវ ទើបយើងត្រូវយកសញ្ញាមូសិកទន្ត(៉) មកដាក់ពីលើវា ដើម្បីឱ្យវាក្លាយជាព្យញ្ជនៈ **ង៉** មានពណ៌ខៀវ។ គ្រូអាន **ង សម្លាប់ពីរ ង៉** ដោយចង្អុលចំតួអក្សរលើក្ដារខៀន ។

ខ- គ្រូ និងសិស្ស : គ្រូនាំសិស្សអាន ង សម្លាប់ពីរ ង៉ ចំនួន២ដង។

គ- សិស្ស: គ្រូឱ្យសិស្សចង្អុលអក្សរ ង៉ ក្នុងសៀវភៅជំនួយសិស្ស ហើយអាន **ង៉** ឮៗចំនួន២-៣ ដង។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្សៈ**

✓ មានវិធីជាច្រើនយ៉ាង ក្នុងការបំផុសរកពាក្យថ្មី។ ក្នុងនោះរួមមាន ការលើកឧទាហរណ៍ ការពិពណ៌នា ការបង្ហាញវត្ថុជាក់ស្ដែង ការបង្ហាញរូបភាព និងការធ្វើកាយវិការ។ល។ វិធីចុងក្រោយ គឺការធ្វើកាយវិការត្រូវបានលើកទឹកចិត្តឱ្យគ្រូប្រើឱ្យបានញឹកញាប់ ព្រោះវាអាចជួយឱ្យមានអន្តរកម្មរវាងគ្រូនិងសិស្ស សិស្សនិងសិស្ស នៅពេលដែលគ្រូធ្វើកាយវិការបង្ហាញសិស្ស ហើយឱ្យសិស្សធ្វើជាមួយគ្រូ។

✓ប្រសិនបើសិស្សណាមិនចូលរួម ឬលំបាកក្នុងការអានពាក្យ គ្រូត្រូវអានពាក្យនោះឱ្យច្បាស់ៗ ដើម្បីទាក់ទាញចំណាប់អារម្មណ៍សិស្សឱ្យមើលគ្រូខណៈពេលដែលគ្រូប្រកបសូរ និងអានពាក្យ។

✓ ពិនិត្យមើលពេលសិស្សផ្សំ ដើម្បីដឹងថាសិស្សណាខ្លះបន្លឺសូរផ្សំ និងអានពាក្យបានត្រឹមត្រូវ សិស្សណាខ្លះដែលត្រូវការជួយបន្ថែម។

✓ លើកទឹកចិត្តសិស្សឱ្យលើកដៃប្រកបដូចដែលគ្រូបានធ្វើឱ្យមើល ដើម្បីឱ្យពួកគេធ្វើចលនាដៃគ្រប់គ្នា និងផ្ដល់អារម្មណ៍ក្នុងសកម្មភាពរៀន។

★ គ្រូដើរទៅជិត ហើយស្ដាប់សិស្សដែលលំបាកក្នុងការបន្លឺសូរថ្មី ដើម្បីជួយពួកគេឱ្យហ្វឹកហាត់បានច្រើនដង។

☞ ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្ដារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេសដោយធានាថាគេអាចមើលឃើញកាយវិការគ្រូច្បាស់។ ពោលគឺធ្វើដូចគ្នានឹងចំណុចផ្កាយខាងលើ។ ត្រូវប្រាកដថា សិស្សអាចមើលគ្រូឃើញច្បាស់។ គ្រូទាញចំណាប់អារម្មណ៍ឱ្យសិស្សមើលគ្រូ ខណៈពេលដែលគ្រូប្រកបសូរ និងអានពាក្យ។

**៣- ការអានព្យាង្គ** ◷ **១៥នាទី**

**៣.១- ការប្រកបសូរដោយប្រើដៃ**

◎ ផ្សំព្យញ្ជនៈ និងស្រៈបង្កើតជាព្យាង្គ
🗍 មិនត្រូវការសម្ភារៈ
🕒 ៥ នាទី

ក-គ្រូៈចាប់ផ្ដើមដោយប្រកបសូរ **ង៉** ា **ង៉ា** ដោយប្រើដៃក្នុងខ្យល់បង្ហាញសិស្ស (តារាងខាងក្រោមប្រអប់ទី១)។

ខ-គ្រូ និងសិស្ស : គ្រូថា **ង៉** ី **ង៉ី** **ង៉** េះ **ង៉េះ** ដោយប្រើដៃក្នុងខ្យល់ (តារាងខាងក្រោមប្រអប់ទី២)

គ-សិស្សៈគ្រូថាសូរអក្សរម្ដងមួយៗ **ង៉** ី **ង៉** ែ **ង៉** ោះ សិស្សប្រកបសូរដោយប្រើដៃក្នុងខ្យល់ **ង៉** ី **ង៉ី** **ង៉** ែ**ង៉ែ** **ង៉** ោះ**ង៉ោះ** (តារាងខាងក្រោមប្រអប់ទី៣)។

| | | |
|---|---|---|
| គ្រូ : **ង៉ា** | គ្រូ និងសិស្ស : **ង៉ី ង៉េះ** | សិស្ស : **ង៉ី ង៉ែ ង៉ោះ** |

## ៣.២- អានព្យាង្គក្នុងសៀវភៅជំនួយសិស្ស

◎ កំណត់ព្យាង្គដែលសរសេរមាន( ៉ ) ដូរមកបុកជើង( ុ ) និងព្យាង្គដែលមិនដូរ។
🗍 ដីសពណ៌សម្រាប់សរសេរ ( ៉ ) និង បុកជើង ុ
🕒 ១០ នាទី

ករណីទូទៅ

ក-គ្រូ : សរសេរព្យាង្គលើក្ដារខៀន **ង៉ា** រួចអាន **ង៉** ា **ង៉ា**។

ខ-គ្រូ និងសិស្ស : គ្រូសរសេរ **ង៉ែ** បន្តក្នុងជួរ រួចនាំសិស្សអានជាមួយគ្នា **ង៉** ែ **ង៉ែ**។

គ-សិស្ស : គ្រូសរសេរ **ង៉ៅ** បន្តក្នុងជួរ ឱ្យសិស្សអាន **ង៉** ៅ **ង៉ៅ**។

**ចំណាំទី១**

ក-គ្រូ : សរសេរ ងិ ខាងក្រោម ង៉ា រួចពន្យល់ថាសញ្ញាធ្មេញកណ្ដុរ ( ៉ ) ឬសញ្ញា អ កាលណាវានៅជាមួយស្រៈមួយចំនួនដែលមានទីតាំងពីលើព្យញ្ជនៈដូចជា ស្រៈ ិ ី ឹ ឺ ើ ៅ វាដូររាងជាបុកជើង ុ វិញ។

- គ្រូគូស **ងិ** **ង៉ុ** ។ រួចគ្រូអាន **ង៉** ិ **ង៉ុ** ។

ខ-គ្រូ និងសិស្ស : គ្រូសរសេរ **ង៉ាំ** ជួរបន្តពី **ង៉ុ** រួចនាំសិស្សអាន **ង៉** ាំ **ង៉ាំ**។

គ-សិស្ស : គ្រូសរសេរ **ង៉ើ** បន្តក្នុងជួរ ឱ្យសិស្សអាន **ង៉** ើ **ង៉ើ** ។

★ ***គ្រូអាចពន្យល់ម្យ៉ាងទៀតដើម្បីឱ្យសិស្សងាយចងចាំៈ*** *ដោយសារតែនៅពីលើ ង មានស្រៈ ី ផង ធ្មេញកណ្ដុរ ( ៉ ) ផងនាំឱ្យវាធ្ងន់ពេក វាក៏សុំឱ្យប្ដូរធ្មេញកណ្ដុរ ( ៉ )ពីលើក្បាលវាមកនៅជាបុកជើងនៅក្រោមវិញ។*

**ចំណាំទី២**

ក-គ្រូ : ពន្យល់ថា ស្រៈចំនួនបី គឺស្រៈ ួ ឿ ៀ មិនចាំបាច់ផ្សំជាមួយ ង៉ ទេ ដោយសារសូរវានៅដដែលទោះបីប្រើជាមួយ ង ឬ ង៉ ក៏ដោយ។សរសេរ ងួ នៅជួរក្រោម ង៉ាំ រួចអាន ង ួ ងួ។

ខ-គ្រូ និងសិស្ស : គ្រូសរសេរ ងឿ បន្ទាប់ពី ងួ រួចនាំសិស្សអានជាមួយគ្នា ង ឿ ងឿ ។

គ-សិស្ស : គ្រូសរសេរ ងៀ ឱ្យសិស្សអាន ង ៀ ងៀ ។ ហ្វឹកហាត់ គ្រូឱ្យសិស្សអានព្យាង្គក្នុងសៀវភៅជំនួយសិស្ស ជាដៃគូដោយម្នាក់អ្នកចង្អុល ម្នាក់ទៀតអ្នកអានរួច ប្តូរវេនគ្នា។

| |
|---|
| របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖<br>✓ គ្រូដើរតាមតុសិស្ស ស្តាប់សិស្សអានជាដៃគូ និងជួយកែតម្រូវសិស្សណាអានមិនទាន់ត្រឹមត្រូវ។<br>✓ គ្រូត្រូវពិនិត្យមើលថាសិស្សគ្រប់គ្នាបើកសៀវភៅចំទំព័រដែលត្រូវអាន។<br>★ គ្រូដើរទៅជិតសិស្សដែលជួបការលំបាកក្នុងការអានឱ្យបានញឹកញាប់ឱ្យគេហាត់ច្រើនដងតាមដែលអាចធ្វើទៅបាន។<br>☙ ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្តារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេសដោយធានាថាគេអាចមើលឃើញកាយវិការគ្រូច្បាស់។ ពេលគឺធ្វើដូចគ្នានឹងចំណុចផ្កាយខាងលើ។ គ្រូត្រូវដើរទៅជិតសិស្ស អានឮៗជាគំរូ ដោយធានាថាសិស្សស្តាប់ឮគ្រូអាន។ |

**៤- ការអានពាក្យ** ◷ **១០នាទី**

**៤.១- វាក្យសព្ទ**

◎ យល់ន័យនៃពាក្យពិបាកតាមរយៈការបង្កើតល្បះដោយផ្ទាល់មាត់

❐ សៀវភៅសិក្សាគោល មេរៀន ង៉

◷ ៥ នាទី

ក-គ្រូ :ពន្យល់ន័យនៃពាក្យ **ង៉េះ** និងបង្កើតល្បះជាគំរូ។ **ង៉េះ** សំឡេងផ្លែយំ ឬកោះ។

**ឧ.អាលូផ្អែខ្ញុំយំង៉េះៗ។**

ខ-គ្រូ និងសិស្ស : គ្រូប្រើសំណួរបំផុសដើម្បីនាំសិស្សបង្កើតល្បះដោយប្រើពាក្យ **ង៉េះ**។

ឧ.តើកូនឮស្នូរឆ្កែយំយ៉ាងដូចម្តេច? វាយំង៉េះៗ។

គ-សិស្ស : គ្រូឱ្យសិស្សបង្កើតល្បះជាមួយពាក្យ**ង៉េះ** ជាដៃគូ ដោយផ្ទាល់មាត់។

**ឧ.អាសំពៅឆ្កែខ្ញុំយំង៉េះៗ ។**

**៤.២-ការអានពាក្យដោយប្រកប និងមិនប្រកប**

◎ អានពាក្យ ង៉ែង៉រ

❐ ប័ណ្ណពាក្យ សៀវភៅសិក្សាគោល មេរៀន **ង៉**

◷ ៥ នាទី

ក-គ្រូ : បង្ហាញប័ណ្ណពាក្យ **ង៉ែង៉រ** ដែលបត់ជាពីរផ្នត់ ដោយបង្ហាញម្តងមួយផ្នត់ៗអាន ង៉ែ ង៉រ ។ រួចលាប័ណ្ណ ហើយអាន ង៉ែង៉រ ឬសរសេរពាក្យ **ង៉ែង៉រ** លើក្តារខៀន រួចអានដោយយកដៃចង្អុល **ង៉ ែ ង៉ែ ង៉និងរ ង៉រ ង៉ែង៉រ** ។

ខ-គ្រូ និងសិស្ស : គ្រូសរសេរ **ង៉ាំ** លើក្តារខៀន រួចនាំសិស្សអានដោយយកម្រាមដៃអូសពីក្រោមពាក្យ។

គ-សិស្ស : គ្រូសរសេរ **ង៉ា** រួចចង្អុលឱ្យសិស្សអាន។

ឃ.គ្រូឱ្យសិស្សអានពាក្យក្នុងសៀវភៅជំនួយសិស្សជាដៃគូ ដោយម្នាក់ចង្អុល ម្នាក់អាន រួចប្តូរវេនគ្នា។

| |
|---|
| របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖<br>★ នៅពេលអានព្យាង្គ ឬពាក្យ ត្រូវចង្អុលបណ្តើរ និងថាសូរអក្សរក្នុងព្យាង្គ ឬពាក្យនីមួយៗបណ្តើរ។<br>✍ ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្តារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេស ដោយធានាថាគេអាចមើលឃើញកាយវិការគ្រូច្បាស់។ ពោលគឺធ្វើដូចគ្នានឹងចំណុចផ្កាយខាងលើ។ គ្រូត្រូវដើរទៅជិតសិស្ស និងជួយសិស្សពេលគេត្រូវការ។ |

**៥- ការអានល្បះ** 🕒 **១០នាទី**

◎ អានស្ទាត់ និងយល់អត្ថន័យល្បះ

🗍 បណ្ណពាក្យ សៀវភៅសិក្សាគោល មេរៀន ង៉

🕒 ៦ នាទី

ក- គ្រូឱ្យសិស្សបើកសៀវភៅសិក្សាគោល និងពិនិត្យរូបភាព **ថៅង៉ូចេះដើរតេះតះ។** បំផុសសំណួរទាក់ទងនឹងល្បះត្រូវរៀន។

ខ- គ្រូចម្លងល្បះ **ថៅង៉ូចេះដើរតេះតះ។** ដាក់លើក្តារខៀនគ្រូសួរសិស្សថាតើក្នុងល្បះនេះមានពាក្យអ្វីខ្លះ ?ពេលសិស្សឆ្លើយគ្រូប្រើសញ្ញាលើល្បះដើម្បីញែកពាក្យក្នុងល្បះ **/ថៅង៉ូ/ចេះ/ដើរ/តេះតះ។**

គ- គ្រូដឹកនាំសិស្សហ្វឹកហាត់អាន៖

- គ្រូ៖ អានល្បះ **ថៅង៉ូចេះដើរតេះតះ។**
- គ្រូ និងសិស្ស៖ អានល្បះព្រមគ្នា **ថៅង៉ូចេះដើរតេះតះ។**
- សិស្ស៖ អានទាំងអស់គ្នា **ថៅង៉ូចេះដើរតេះតះ។**

ឃ- គ្រូអានល្បះលើក្តារខៀនជាគំរូ ដោយចង្អុល ឱ្យចំម្តងមួយពាក្យៗ។

ង- គ្រូសួរសំណួរដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្ស ឱ្យសិស្សយល់ពីអត្ថន័យនៃល្បះ។

១.តើថៅង៉ូដើរដូចម្តេច ?

ច- គ្រូ ឱ្យសិស្សហ្វឹកហាត់អានល្បះនេះនិងល្បះដទៃទៀតដោយប្រើសៀវភៅសិក្សាគោល១ក្បាលពីរនាក់ ម្នាក់ចង្អុល ម្នាក់ទៀតអាន និងប្តូរវេនគ្នា។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

✓គ្រូស្រង់ល្បះមួយពីក្នុងសៀវភៅសិក្សាគោល។ ប្រសិនបើមានរូបភាពក្នុងសៀវភៅនោះ គ្រូលើករូបភាពបង្ហាញ ដើម្បីបំផុសសំណួរដែលទាក់ទងនឹងល្បះដែលត្រូវរៀន។

✓គ្រូសង្កេតមើលសិស្សដែលរៀនយឺតនៅពេលហ្វឹកហាត់អានជាដៃគូ។ ឱ្យសិស្សអានឆ្លាស់គ្នា ម្នាក់ចង្អុល ម្នាក់អាន។

★ គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក (បើមាន)។

★ គ្រូហៅសិស្សរៀនយឺតឡើងអាន។

★ គ្រូឱ្យសិស្សធ្វើកិច្ចការផ្ទះដោយគូររូបភាពជាគំនូរសេរី ទាក់ទងអត្ថន័យល្បះ និងបកស្រាយ។

👓 គ្រូប្រើបណ្ណល្បះ ប័ណ្ណពាក្យសម្រាប់សិស្សខ្សោយគំហើញ។

👂 គ្រូប្រើបណ្ណល្បះ ប័ណ្ណពាក្យសម្រាប់សិស្សដែលមានបញ្ហាក្នុងការស្តាប់។

## ៦- ការអានអត្ថបទខ្លី ◷ ១២ នាទី

◎ ហាត់អានស្ទាត់ និងយល់ន័យខ្លឹមសារអត្ថបទ

❐ សៀវភៅជំនួយសិស្ស មេរៀន ង៉

◷ ១២ នាទី

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព និងចំណងជើងអត្ថបទនៅក្នុងមេរៀន ង៉។

ខ- គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿងថា៖ តើរឿងនេះនិយាយពីអ្វី?

គ- គ្រូអានរឿងពីដើមដល់ចប់យឺតៗ ដោយលើកដាក់សំឡេងគោរពតាមសញ្ញាសម្គាល់។

ឃ- គ្រូ និងសិស្សអានទាំងអស់គ្នា។

ង- គ្រូឱ្យសិស្សហ្វឹកហាត់ជាដៃគូ។

ច- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ឆ- គ្រូសួរសំណួរម្តងមួយៗ ដោយទុកពេលឱ្យសិស្សគិត និងសម្របសម្រួលចម្លើយរបស់សិស្ស (អានអត្ថបទឡើងវិញ)៖

- គ្រូ ឱ្យសិស្សឆ្លើយសំណួរជាបុគ្គល៖

| | |
|---|---|
| ១-តើចៅង៉ូទៅណា? | ចៅង៉ូដើរលេងង៉រ |
| ២-តើអាលូបានទៅជាមួយចៅង៉ូដែរឬទេ? | តាង៉ោហៅចៅង៉ូទៅសាលា។ |
| ៣-តើកូនគិតថាហេតុអ្វីបានជាចៅង៉ូចង់នាំអាលូទៅសាលា? | ចៅង៉ូដើរលេងង៉រ។ |
| | ចៅង៉ូនាំអាលូទៅសាលាដែរ។ |
| ៤-តើកូនចូលចិត្តចិញ្ចឹមឆ្កែឬទេ?ហេតុអ្វី? | តាង៉ោថា កុំនាំអាលូទៅ។ |
| | ចៅង៉ូនិយាយង៉េាះៗ។ |
| | អាលូយំង៉េះៗ។ |

- សម្រាប់សំណួរដែលមានចម្លើយលើសពីមួយ ហើយសិស្សអាចប្រើប្រាស់បទពិសោធ ឬគំនិតផ្ទាល់ខ្លួន
- គ្រូ ឱ្យសិស្សពិភាក្សាជាដៃគូ រួចឱ្យសិស្សពីរ ឬបីនាក់ឡើងចែករំលែករបស់គេក្នុងក្រុមធំ។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

✓សម្រាប់សំណួរដែលមានចម្លើយលើសពីមួយ ទុកពេលសមល្មម ឱ្យសិស្សប្រើបទពិសោធ ឬគំនិតផ្ទាល់ខ្លួន ពិភាក្សាជា ដៃគូ។

✓គ្រូដើរជុំវិញថ្នាក់ តាមតុនីមួយៗស្តាប់សិស្សពិភាក្សាគ្នា នៅពេលចែករំលែកគំនិតផ្ទាល់ខ្លួន។

✓ប្តូរសំណួរ តែរក្សាន័យដដែល ពេលដែលសិស្សស្តាប់សំណួរគ្រូមិនយល់។

✓ជួយពួកគេ ដោយប្រើសំណួរប្រជេញ ប្រសិនបើគេនៅតែមិនទាន់យល់សំណួរ។

## ៧- ការសរសេរ ◷ ២០ នាទី

### ៧.១-ការសរសេរព្យាង្គ និងពាក្យ

◎ សរសេរព្យាង្គ និងពាក្យ

❐ ក្តារឆ្នួន សៀវភៅកិច្ចការសិស្ស និងសៀវភៅសិក្សាគោល

◷ ១២ នាទី

ក- គ្រូ : គ្រូថា **ង៉ែង៉រ** ឮៗ ។ គ្រូថា **ង៉ែង៉រ** ម្តងទៀត និងសរសេរបណ្តើរលើក្តារខៀន **ង៉ែង៉រ** មាន **ង៉** ែ **ង៉** និង **រ**។

ខ- គ្រូ និងសិស្ស : គ្រូបន្លឺ **ចៅង៉ា**ឮៗ និងច្បាស់ៗ រួចសួរសិស្សថា **ចៅង៉ា** មានអក្សរអ្វីខ្លះ ? គ្រូថាបណ្តើរសរសេរ បណ្តើរលើក្តារខៀន **ចៅង៉ា** មាន **ច ៅ ង៉** ា សិស្សថា និងសរសេរលើក្តារឆ្នួន។ គ្រូឱ្យសិស្សបង្ហាញដៃគូ កែលម្អនិងលើកបង្ហាញគ្រូ។

គ- សិស្ស : គ្រូថាពាក្យ **ង៉ាំ** សិស្សថាបណ្តើរ សរសេរបណ្តើរលើក្តារឆ្នួន បង្ហាញមិត្តភក្តិជួយកែ រួចលើកបង្ហាញគ្រូ។គ្រូសរសេរ **ង៉ាំ** លើក្តារខៀនដើម្បីសិស្សផ្ទៀងផ្ទាត់។ អនុវត្តដូចគ្នាចំពោះ **ង៉ៅ តាង៉ៅ** ។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

✓ គ្រូថាសូរយឺតៗ ច្បាស់ៗ និងសរសេរព្យាង្គ / ពាក្យធំៗលើក្តារខៀន ( **ឧ.រង៉ែង៉រ** )។

✓ នៅពេលគ្រូហៅ ឱ្យសិស្សសរសេរ គ្រូគួរហៅព្យាង្គមួយពី ២-៣ដង ហើយប្រមាណ៣វិនាទីហៅម្តង។

★ គ្រូដើរពិនិត្យពេលសិស្សសរសេរ ហើយជួយកែតម្រូវនៅពេលដែលកំពុងសរសេរ។

👓 ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្តារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេស ដោយធានាថាគេអាចមើលឃើញកាយវិការគ្រូច្បាស់។ ពោលគឺធ្វើដូចគ្នានឹងចំណុចផ្កាយខាងលើ។

### ៧.២-ការចម្លងព្យាង្គ ពាក្យ និងឈ្មោះ

◎ កិច្ចការផ្ទះ

❐ សៀវភៅកិច្ចការសិស្ស និងសៀវភៅសិក្សាគោល

◷ ៨ នាទី

គ្រូឱ្យសិស្សចម្លង អក្សរនិងពាក្យនៅលើក្ដារខៀន **ង់ ង៉ែង៉រ ចៅង៉ា ង៉ាំ ង៉ៅ តាង៉ោ** និងល្បះទាំងពីរនៅក្នុងសៀវភៅសិក្សាគោល ចូលសៀវភៅកិច្ចការ។

**កិច្ចការផ្ទះ:**

ប្រសិនបើគ្មានពេលចម្លងពាក្យ និងល្បះខាងលើ សិស្សអាចធ្វើកិច្ចការនេះនៅផ្ទះ។

## ៣.៤ លំនាំបង្រៀនមេរៀនប្រកប

| ក. មេរៀនទី៤២ក | ប្រកបនឹង ◻ក (ព្យញ្ជនៈពួកអ) | ◷ ៨០នាទី |
|---|---|---|

**គន្លឹះត្រូវចងចាំ**

- ✓ គ្រប់សកម្មភាពត្រូវអនុវត្តទៅតាមលំនាំក្នុងសៀវភៅណែនាំគ្រូនិងប្រើប្រាស់ពាក្យពេចន៍ជាអក្សរដិត។
- ✓ ក្នុងពេលអាន សិស្សត្រូវប្រើភ្នែក និងចង្អុលដៃរេតាមតួអក្សរ។
- ✓ គ្រូត្រូវដើរតាមតុសិស្ស ស្ដាប់សិស្សអានជាដៃគូ និងជួយកែតម្រូវសិស្សណាអានមិនទាន់ត្រឹមត្រូវ។
- ✓ ប្រសិនបើសិស្សណាលំបាកអាន គ្រូត្រូវជួយសិស្សនោះ។ គ្រូអាចអានពាក្យជាគំរូ អានពាក្យនោះម្ដងទៀតជាមួយសិស្ស និងឱ្យសិស្សអានពាក្យនោះខ្លួនឯងម្ដងទៀត។
- ✓ ប្រសិនបើសិស្សភាគច្រើនមានការលំបាក គ្រូត្រូវណែនាំឡើងវិញដោយប្រើ វិធីគ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើជាមួយសិស្សទាំងអស់ក្នុងថ្នាក់។
- ✓ សម្រាប់ការបង្រៀនតួអក្សរថ្មី គ្រូត្រូវសរសេរតួអក្សរដែលត្រូវរៀនធំៗលើក្ដារខៀន។
- ✓ អនុវត្ត គ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើ ដូចដែលបានលម្អិតក្នុងសៀវភៅណែនាំគ្រូ។
- ✓ គ្រូដើរតាមតុក្នុងថ្នាក់ ពេលគ្រូនិងសិស្សធ្វើ សិស្សធ្វើ ក្នុងគ្រប់សកម្មភាពអាន និងសរសេរដើម្បីជួយសិស្ស។
- ✓ សម្រាប់សកម្មភាពអាន ឱ្យសិស្សអានលើសពីម្ដង។

☞ ៛ ប្រសិនបើមានសិស្សខ្សោយគំហើញ និងខ្សោយស្ដាប់ រាល់ការបង្ហាញ និងការណែនាំរបស់គ្រូត្រូវប្រាកដថាសិស្សទាំងនោះស្ដាប់ឮ និងឃើញច្បាស់។

☞ ៛ គ្រូប្រើប័ណ្ណពាក្យ ល្បះសម្រាប់សិស្សខ្សោយស្ដាប់ និងខ្សោយគំហើញ។

| លំនឹងថ្នាក់ និង រំឭកមេរៀន | ◷ ៥នាទី |
|---|---|

◎ រំឭកពាក្យដែលបានរៀន

▤ បណ្ណពាក្យ ក្ដារឆ្នួន

◷ ៥ នាទី

គ្រូសរសេរពាក្យ **អ៊ូអរ រអ៊ូ ហ៊ោ តៅហ៊ូ ភាស៊ី** មួយម្ដងៗ ឱ្យសិស្សអាន ឬហៅឱ្យសិស្សសរសេរលើក្ដារឆ្នួនហើយអាន។ គ្រូកែតម្រូវសិស្សដែលអាន ឬសរសេរមិនបានត្រឹមត្រូវ។

**១- ការស្គាល់សូរអក្សរថ្មី** ◷ ៥ នាទី

ការប្រកបសូរដោយប្រើដៃជាជំនួយ

◎ កំណត់សូរព្យាង្គ ឬពាក្យថ្មី ប្រកបនឹង **ក**

🗐 គ្មានសម្ភារៈ

🕐 ៥ នាទី

គ្រូប្រាប់សិស្សថា ថ្ងៃនេះយើងនឹងរៀនសូរថ្មីដែលប្រកបនឹង "ក"។

គ្រូធ្វើកាយវិការ បង្ហាញវត្ថុជាក់ស្តែង រូបភាព ពណ៌នា ឬបំផុសសំណួរ ដើម្បីរកពាក្យ ថាពាក្យ និងប្រាប់សូរនៃពាក្យ (សូរអក្សរថ្មី។

- គ្រូ : ធ្វើកាយវិការបកចេក រួចសួរសិស្សថា **តើគ្រូកំពុងធ្វើអ្វី? (បក)** ។ គ្រូថា **បក** ។
- គ្រូ និងសិស្ស : ថា **បក** ។
- សិស្ស : ថា **បក** ។

**ពេលនេះយើងនឹងហាត់ប្រកបសូរព្យាង្គដោយដៃជំនួយ។**

- គ្រូ : គ្រូលើកដៃម្ខាងឡើងលើថា **ប** លើកដៃម្ខាងទៀតថា **ក** រួច ផ្ដុំបាតដៃទាំងពីរថា **បក** ។
- គ្រូ និងសិស្ស : លើកដៃម្ខាងឡើងលើថា **សា** លើកដៃម្ខាងទៀតថា **ក** រួចផ្ដុំដៃទាំងពីរចូលគ្នាថា **សាក**។
- សិស្ស : គ្រូថាពាក្យ **ចូ និង ក ឆៃ និង ក ដេ និង ក** ម្ដងមួយៗឱ្យសិស្សអនុវត្តផ្សំសូរដោយប្រើដៃដូចខាងលើ។

**គន្លឹះគ្រូវចងចាំ**

★ គ្រូត្រូវបន្លឺសូរដែលត្រូវរៀនឱ្យបានឮៗ និងច្បាស់ៗ។

★ មានវិធីជាច្រើនយ៉ាង ក្នុងការបំផុសរកពាក្យថ្មី ក្នុងនោះរួមមាន ការលើកឧទាហរណ៍ ការពិពណ៌នា ការបង្ហាញវត្ថុជាក់ស្តែង ការបង្ហាញរូបភាព និងការធ្វើកាយវិការ។ល។ ការធ្វើកាយវិការត្រូវបានលើកទឹកចិត្តឱ្យគ្រូប្រើញឹកញាប់ ព្រោះវាអាចជួយឱ្យមានអន្តរកម្មរវាងគ្រូ និងសិស្ស សិស្សនិងសិស្ស ។

★ លើកទឹកចិត្តសិស្សឱ្យលើកដៃប្រកបព្យាង្គ និងពាក្យ ដូចដែលគ្រូបានធ្វើឱ្យមើល ដើម្បីឱ្យពួកគេធ្វើចលនាដៃគ្រប់គ្នា និងផ្ដល់អារម្មណ៍ក្នុងសកម្មភាពរៀន។

✓ ពិនិត្យមើលពេលសិស្សប្រកប ដើម្បីដឹងថាសិស្សណាខ្លះបន្លឺសូរប្រកប និងអានពាក្យបានត្រឹមត្រូវ សិស្សណាខ្លះដែលត្រូវការជួយបន្ថែម។

✓ បង្រៀនទៅតាមពេលវេលាដែលបានកំណត់ ក្នុងសៀវភៅណែនាំគ្រូ ក្នុងសកម្មភាពណែនាំឱ្យសិស្សស្គាល់សូរអក្សរថ្មី។

ℹ ត្រូវប្រាកដថា សិស្សអាចមើលឃើញគ្រូច្បាស់។ គ្រូទាញចំណាប់អារម្មណ៍សិស្សមើលគ្រូនិងចូលរួមអនុវត្តសកម្មភាព។ ខណៈពេលដែលគ្រូប្រកបសូរ និងអានពាក្យ។

## ២- ការស្គាល់តួអក្សរថ្មី ⏱ ៥នាទី

◎ ប្រកបព្យញ្ជនៈពួក "អ" ប្រកបនឹង **ក** ដើម្បីអានព្យាង្គ

🗐 ប័ណ្ណអក្សររូបភាព ឬប័ណ្ណអក្សរដែលសរសេរលើក្រដាស A4

⏱ ៥នាទី

ក- **បក**

**មុននេះយើងទើបនឹងបានឮសូរ បក ឥឡូវយើងនឹងរៀនពីរូបរាងរបស់វា។**

- គ្រូ : សរសេរ **បក** លើក្ដារខៀន។ គ្រូអានដោយចង្អុលចំតួអក្សរហើយប្រកបឮៗ **ប នឹង ក បក**។
- សិស្ស និងគ្រូ : អាន **ប និងក បក**។
- សិស្ស : អាន **ប និងក បក**។

ខ- **សាក**

- គ្រូ : សរសេរ **សាក** លើក្ដារខៀន។ គ្រូអានដោយចង្អុលចំតួអក្សរហើយប្រកបឮៗ **ស អា សា និងក សាក**។
- សិស្ស និងគ្រូ : អាន **ស អា សា និងក សាក**។
- សិស្ស : អាន ស អា សា និងក សាក។

គ- **គ្រូ ចង្អុល ៖**

- **បក** អានថា **បក** ។ **សាក** អានថា **សាក**។
- តើព្យាង្គ **បក** និង**សាក** មានអក្សរអ្វីនៅខាងចុង? (មាន **ក**)។ **ក** នេះហើយជាតួដែលត្រូវប្រកប។ ការប្រកបគឺជាការផ្សំបញ្ចូលគ្នារវាងសូរព្យញ្ជនៈ ស្រៈ ព្យញ្ជនៈឱ្យទៅជាព្យាង្គ ឬពាក្យ ដែលមានសូរលោយចូលគ្នាតែមួយ។
- គ្រូសរសេរចំណងជើងមេរៀនប្រកបនឹង **ក** លើក្ដារខៀន។

## ៣- ការអានព្យាង្គ និងពាក្យ ⏱ ១៨នាទី

៣.១ - ការអានព្យាង្គ

៣.១.១- ការអានព្យាង្គ (ស្រៈកប់តួ)

◎ អានព្យាង្គប្រកបនឹង **ក**

🗐 សៀវភៅជំនួយសិស្ស

⏱ ៨នាទី

- គ្រូ : សរសេរ **ខក** លើក្ដារខៀន។ គ្រូអាន **ខ និង ក ខក** ដោយចង្អុលចំតួអក្សរ និងព្យាង្គ។
- គ្រូ និងសិស្ស : គ្រូសរសេរ **ចក** លើក្ដារខៀន។ គ្រូ និងសិស្សអាន **ច និង ក ចក** ដោយចង្អុលចំតួអក្សរ និងព្យាង្គ។
- សិស្ស :
  - គ្រូសរសេរ **ជក** លើក្ដារខៀន។ គ្រូចង្អុល រួចសិស្សអាន **ជ និង ក ជក** ដោយចង្អុលចំតួអក្សរ និងព្យាង្គ។ ធ្វើដូចគ្នាចំពោះ **សក កក**។
  - អានព្យាង្គទាំងអស់ក្នុងតារាងទី១ជាដៃគូក្នុងសៀវភៅជំនួយសិស្ស ដោយចង្អុលចំតួអក្សរនីមួយៗ និងព្យាង្គ។

៣.១.២- ការអានព្យាង្គ (ស្រះ)

- គ្រូ : សរសេរ **កាក** លើក្ដារខៀន។ គ្រូអាន **ក អា កា និង ក កាក** ដោយចង្អុលចំតួអក្សរនីមួយៗ និងព្យាង្គ។
- គ្រូ និងសិស្ស : គ្រូសរសេរ **ចូក** លើក្ដារខៀន។ គ្រូ និងសិស្សអាន **ច អូ ចូនិង ក ចូក** ដោយចង្អុលចំតួអក្សរ។
- សិស្ស :
  - គ្រូសរសេរ **ដែក** លើក្ដារខៀន។ គ្រូចង្អុល រួចសិស្សអាន **ដ អែ ដែនិង ក ដែក។** ធ្វើដូចគ្នាចំពោះ **បើក ចុក។**
  - អានព្យាង្គទាំងអស់ក្នុងតារាងទី២ជាដៃគូក្នុងសៀវភៅជំនួយសិស្ស ដោយចង្អុលចំតួអក្សរនីមួយៗ និងព្យាង្គ ។

**៣.២- ការអានពាក្យ**

◎ អានពាក្យដោយផ្សំប្រកប

🗐 សៀវភៅជំនួយសិស្ស

🕒 ១០ នាទី

- គ្រូ : សរសេរ **ចចក** លើក្ដារខៀន។ គ្រូអាន **ច ច និងក ចក ចចក** ដោយចង្អុលឱ្យចំតួអក្សរនីមួយៗ និងចំពាក្យ។
- គ្រូ និងសិស្ស : គ្រូសរសេរ **របើក** លើក្ដារខៀន។ គ្រូ និងសិស្សអាន **រ ប អើ បើ និងក បើក របើក**។
- សិស្ស : គ្រូសរសេរ **អំបុក** លើក្ដារខៀន។ គ្រូចង្អុល រួចសិស្សអានដោយចង្អុល **អ អំ អំ ប អុ បុ និងក បុក អំបុក។**
- អានពាក្យទាំងអស់ក្នុងតារាងទី៣ជាដៃគូក្នុងសៀវភៅជំនួយសិស្ស ដោយចង្អុលឱ្យចំតួអក្សរនីមួយៗ និងចំពាក្យ។

| ៤- វាក្យសព្ទ | 🕒 ៨នាទី |
|---|---|

◎ យល់ន័យនៃពាក្យពិបាកតាមរយៈការបង្កើតល្បះដោយផ្ទាល់មាត់

🗐 សៀវភៅជំនួយសិស្ស

🕒 ៨នាទី

- **រាំឡុក**
  - គ្រូ : សរសេរពាក្យ **រាំឡុក** លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ ក្នុងករណីពាក្យត្រូវពន្យល់មានសរសេរលើក្ដារខៀនម្ដងហើយ គ្រាន់តែគូសវង់លើពាក្យនោះក៏បាន។**រាំឡុក មានន័យថា**

**រាំធ្វើមុខក្រមិចក្រមើម ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ រាំឡក។ ពួតេវចេះ រាំឡក គួរឱ្យចង់សើច**

- គ្រូ និងសិស្ស : អានពាក្យ រាំឡក រួមគ្នា។ **ឥឡូវនេះយើងនឹងបង្កើតល្បះមួយ រួមគ្នាដោយប្រើពាក្យ រាំឡក ដោយគ្រូជាអ្នកផ្ដើម ហើយកូនៗជាអ្នកបំពេញ ពេលគ្រូបង្អាក់បន្តិច។** គ្រូថា **សុភាចូលចិត្តមើលគេ ... ធៃយ៉ាំ។** សិស្សថា រាំឡក ។ **ឥឡូវនេះយើងថាល្បះឡើងវិញទាំងអស់គ្នា : សុភាចូលចិត្តមើលគេរាំឡកធៃយ៉ាំ។**
- **សិស្ស** : អានពាក្យ **រាំឡក** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **រាំឡក** ជាដៃគូ។

- **ចំណែក**
  - គ្រូ : សរសេរពាក្យ ចំណែក លើក្ដារខៀន រួចអាន និងពន្យល់ន័យ។ ចំណែក មានន័យថា ភាគដែលចែករួចហើយ ។ គ្រូនឹងបង្កើតល្បះមួយដោយប្រើពាក្យ ចំណែក។ ឧ. ម៉ែពុះនំជាចំណែកស្មើៗគ្នា ចែកឱ្យកូនៗ។
  - គ្រូ និងសិស្ស អានពាក្យ ចំណែក រួមគ្នា។ ឥឡូវនេះយើងនឹងបង្កើតល្បះមួយ រួមគ្នាដោយប្រើពាក្យ ចំណែក ដោយគ្រូជាអ្នកផ្ដើម ហើយកូនៗជាអ្នកបំពេញ ពេលគ្រូបង្អាក់បន្តិច។ គ្រូថា សុភាចែកនំជា ...ដល់មិត្តភក្តិ។ សិស្សថា ចំណែក។ ឥឡូវនេះយើងនឹងថាល្បះឡើងវិញទាំងអស់គ្នា : សុភាចែកនំជាចំណែកដល់មិត្តភក្តិ ។
  - សិស្ស : អានពាក្យ ចំណែក និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ ចំណែក ជាដៃគូ។

**គន្លឹះត្រូវចងចាំ**

✓ សម្រាប់ការបង្រៀនវាក្យសព្ទ គ្រូត្រូវដើរតាមតុ ស្ដាប់សិស្សបង្កើតល្បះជាមួយដៃគូ។
✓ សកម្មភាពនេះទាមទារឱ្យសិស្សស្គាល់សូរ ចេះអានពាក្យយល់ន័យពាក្យ ចេះប្រើប្រាស់ពាក្យបានត្រឹមត្រូវ។ គ្រូ និងសិស្សបង្កើតល្បះដោយផ្ទាល់មាត់ ពុំមានការសរសេរទេ។
✓ ពេលសិស្សបង្កើតល្បះ គ្រូស្ដាប់ហើយសួរបញ្ជាក់ បើល្បះនោះមិនទាន់មានន័យគ្រប់គ្រាន់។
✓ គ្រូត្រូវដើរទៅជិតសិស្ស នៅពេលគ្រូពន្យល់ និងបង្កើតល្បះជាឧទាហរណ៍ដល់សិស្ស។

**៥- ការអានល្បះ** ⏱ ៥ នាទី

◎ អានស្ទាត់ និងយល់អត្ថន័យល្បះ

សៀវភៅសិក្សាគោល

⏱ ៥ នាទី

ក -គ្រូបង្ហាញរូបភាពទាក់ទងនឹងល្បះ ប្រសិនបើមាន។

ខ -គ្រូសរសេរល្បះ **សេកចឹកចេកទុំស៊ីលើសំបុក។** លើក្ដារខៀន។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?** ពេលសិស្សឆ្លើយ គ្រូគូសសញ្ញា ( / ) លើល្បះដើម្បីញែកពាក្យ **សេក/ចឹក/ចេក/ទុំ/ស៊ី/លើ/សំបុក។**

គ- គ្រូនាំសិស្សហ្វឹកហាត់អានៈ

- គ្រូ : អានល្បះ សេកចឹកចេកទុំស៊ីលើសំបុក។
- គ្រូ និងសិស្ស : អានល្បះរួមគ្នា សេកចឹកចេកទុំស៊ីលើសំបុក។
- សិស្ស : អានល្បះទាំងអស់គ្នា សេកចឹកចេកទុំស៊ីលើសំបុក។

ឃ- គ្រូសួរសំណួរដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្ស ដើម្បីឱ្យសិស្សយល់ពីអត្ថន័យនៃល្បះ។

ង- គ្រូឱ្យសិស្សហ្វឹកហាត់អានល្បះទាំងអស់នៅក្នុងសៀវភៅសិក្សាគោល ជាដៃគូ ដោយម្នាក់ចង្អុល ម្នាក់ទៀតអាន រួចប្តូរវេនគ្នា។

**គន្លឹះត្រូវចងចាំ**

✓ គ្រូស្រង់ល្បះមួយ ពីក្នុងសៀវភៅសិក្សាគោល។ ប្រសិនបើមានរូបភាពក្នុងសៀវភៅនោះ គ្រូលើករូបភាពបង្ហាញ ដើម្បីបំផុសសំណួរដែលទាក់ទងនឹងល្បះដែលត្រូវរៀន។

✓ គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក (បើមាន) ។

## ៦- ការអានអត្ថបទខ្លី

🕐 ១២ នាទី

◎ អានស្ទាត់និងយល់អត្ថន័យនៃអត្ថបទទាំងមូល

🗐 សៀវភៅជំនួយសិស្ស អត្ថបទខ្លី **អំបុក** (មេរៀន **ប្រកបនឹង ក**)

🕐 ១២ នាទី

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព។ រួចប្រាប់ចំណងជើងអត្ថបទ។

ខ- គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿងថា : តើរឿងនេះនិយាយអំពីអ្វី?

គ- អានអត្ថបទខ្លី

- គ្រូ : អានរឿងយឺតៗ ដោយលើកដាក់សំឡេងគោរពតាមឃ្លា ល្បះ ក្នុងសាច់រឿង។
- គ្រូនិងសិស្ស : អានរួមគ្នា។
- សិស្ស : ហ្វឹកហាត់អានជាដៃគូ ដោយប្តូរវេនគ្នា ម្នាក់ជាអ្នកចង្អុល ម្នាក់ទៀតជាអ្នកអាន រួចអានជាបុគ្គល។ ប្រសិនបើមានពេល ឱ្យសិស្សអានឱ្យបានច្រើនដង។

ឃ- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ង- គ្រូសួរសំណួរម្តងមួយៗ ដោយទុកពេលឱ្យសិស្សគិត (បើរកចម្លើយមិនឃើញ គ្រូ និងសិស្សអានអត្ថបទរឿងឡើងវិញ)។

**១- តើកុកនិយាយដូចម្តេច នៅពេលចចកនាំវាបុកអំបុក?**

**២- តើសេកចឹកចេកនៅឯណា?**

**៣- តើកូនគិតថា សត្វទាំងអស់ក្នុងរឿងត្រូវជាអ្វីនឹងគ្នា?**

**៤- តើកូនធ្លាប់ស្គាល់សត្វអ្វីខ្លះទៀត?**

**គន្លឹះត្រូវចងចាំ**

★ សកម្មភាពគ្រូធ្វើ គ្រូត្រូវអានស្ទាត់ជាគំរូដល់សិស្ស។
✓ សកម្មភាពគ្រូ និងសិស្សធ្វើ គ្រូនិងសិស្សត្រូវអានរួមគ្នា (មិនមែនសិស្សអានតាមគ្រូទេ)។
✓ សម្រាប់សំណួរ ដែលមានចម្លើយលើសពីមួយទុកពេលសមល្មមឱ្យសិស្សប្រើបទពិសោធ ឬគំនិតផ្ទាល់ខ្លួនពិភាក្សាជាដៃគូ។
✓ ប្តូរសំណួរតែរក្សាន័យដដែល ពេលដែលសិស្សស្តាប់សំណួរគ្រូមិនយល់។
✓ ជួយសិស្ស ដោយប្រើសំណួរប្រដេញ ប្រសិនបើពួកគេនៅតែមិនទាន់យល់សំណួរ។

## ៧- ការសរសេរ ⏱ ១៦នាទី

### ៧.១- ការសរសេរពាក្យ

◎ សរសេរព្យញ្ជនៈ និងពាក្យ

🗐 ក្តារឆ្នួន សៀវភៅកិច្ចការសិស្ស និងសៀវភៅសិក្សាគោល (**មេរៀនទី៤២ ប្រកបនឹង ក ក់**)

⏱ ១១ នាទី

- គ្រូ : គ្រូបន្លឺពាក្យ **ចំណែក** ។ គ្រូគិត និងថាឮៗ **ចំណែក មាន ច ស្រៈ ំ ណ ស្រៈ ែ និង ក។** គ្រូសរសេរ **ចំណែក** លើក្តារខៀន។
- គ្រូ និងសិស្ស : គ្រូបន្លឺពាក្យ **ដំណេក** ។ គ្រូ និងសិស្សគិត និងថាឮៗ **ដំណេក មាន ដ ស្រៈ ំ ណ ស្រៈ េ និង ក** រួចសរសេរ **ដំណេក** លើក្តារខៀន ចំណែកសិស្សសរសេរលើក្តារឆ្នួន។
- សិស្ស : គ្រូបន្លឺពាក្យ **អំបុក** ។ សិស្សគិត និងថាឮៗ **អំបុក មាន អ ស្រៈ ំ ប ស្រៈ ុ និង ក** រួចសរសេរពាក្យ **អំបុក** លើក្តារឆ្នួន។ សិស្សលើកបង្ហាញគ្រូ។ គ្រូសរសេរ **អំបុក** លើក្តារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ គ្រូធ្វើដូចគ្នានឹងពាក្យ **អំបុក** ដែរ ចំពោះពាក្យ **បំបែក សំបុក** ។

### ៧.២- ការសរសេរឃ្លា

◎ សរសេរឃ្លាក្នុងសៀវភៅកិច្ចការបានត្រឹមត្រូវ

🗐 បណ្ណពាក្យ

⏱ ៥ នាទី

គ្រូប្រាប់សិស្សថា **ពេលនេះយើងនឹងហ្វឹកហាត់សរសេរឃ្លា។ គ្រូនឹងហៅឃ្លាយឺតៗចំនួន៣ដងឱ្យកូនសរសេរ។**

ក- គ្រូហៅឃ្លា **ចែកជាចំណែក** គ្រូហៅឃ្លាយឺតៗ ច្បាស់ៗ ចំនួន៣ដង។

ខ- សិស្សសរសេរឃ្លាខាងលើចូលក្នុងសៀវភៅកិច្ចការ។

គ- គ្រូសរសេរឃ្លាលើក្តារខៀន ឱ្យសិស្សផ្ទៀងផ្ទាត់ និងកែតម្រូវ។

**គន្លឹះត្រូវចងចាំ**

- ✓ គ្រូថាពាក្យយឺតៗ ច្បាស់ៗ និងសរសេរធំៗ លើក្ដារខៀន (ខ. ចំណែក) ។
- ✓ នៅពេលគ្រូហៅឱ្យសិស្សសរសេរ គ្រូគួរហៅពាក្យនីមួយៗពី ២-៣ដង ហើយប្រមាណ៣វិនាទីហៅម្ដង។
- ✓ គ្រូដើរពិនិត្យពេលសិស្សសរសេរ ហើយជួយកែតម្រូវនៅពេលដែលកំពុងសរសេរ។

**ការពង្រឹង ឬពង្រីកចំណេះដឹង** ◷ ៦នាទី

- ➢ គ្រូពង្រឹង និងពង្រីកចំណេះដឹងរបស់សិស្សលើការអាន និងការសរសេរ៖
  - ○ ការអាន៖ ឧទាហរណ៍: គ្រូប្រើប័ណ្ណអក្សរ ឬប័ណ្ណពាក្យដែលសិស្សបានរៀន ឱ្យសិស្សអាន ឬឱ្យក្រុមសិស្សរៀបតួអក្សរឱ្យបានជាពាក្យ ឬលេងល្បែងសិក្សានានា...ដែលសំដៅដល់ការពង្រឹង ឬពង្រីកចំណេះដឹងដល់សិស្ស។
  - ○ ការសរសេរ៖ ឧទាហរណ៍: គ្រូអាចហៅពាក្យដែលរៀនរួច ឱ្យសិស្សសរសេរលើក្ដារឆ្នួន ឬសៀវភៅកិច្ចការ...។

**៧.៣ កិច្ចការផ្ទះ**

- ➢ គ្រូដាក់កិច្ចការឱ្យសិស្សធ្វើ៖
  - ○ ឱ្យសិស្សចម្លងស្រៈ ព្យញ្ជនៈ ពាក្យ ឃ្លា ឬល្បះ... ដាក់ក្នុងសៀវភៅសរសេរ។ (ឱ្យសិស្សចម្លងនៅផ្ទះបើគ្មានពេល)
  - ○ ដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។

**ខ. មេរៀនទី ៤២** ប្រកបនឹង □ក់ (ព្យញ្ជនៈពួកអ) ◷ ៨០នាទី

**លំនឹងថ្នាក់ និងរំឭកមេរៀន** ◷ ៥នាទី

- គ្រូរំឭកពាក្យដែលបានរៀនរួច **ចចក អំបុក ភាស៊ី តៅហ៊ូ តវ៉ា** ។

**១- ការស្គាល់សូរអក្សរថ្មី** ◷ ៥នាទី

- គ្រូបំផុសរកពាក្យ **បក់**។ គ្រូបន្លឺ **បក់**។ គ្រូនិងសិស្សថា **បក់** ។ សិស្សថា **បក់** ។

| | |
|---|---|
| គ្រូ | - លើកដៃម្ខាងឡើងលើ ថា **ប** លើកដៃម្ខាងទៀតថា **ក** **បក បន្ដក់មួយ** រួចផ្គុំបាតដៃទាំងពីរថា **បក់** ។ |
| គ្រូ និងសិស្ស | - លើកដៃម្ខាងឡើងលើថា **ដា** លើកដៃម្ខាងទៀតថា **ក** **ដាក បន្ដក់មួយ** រួចផ្គុំបាតដៃទាំងពីរថា **ដាក់**។ |
| សិស្ស | - គ្រូថា **ចា និង ក ចាក បន្ដក់មួយ បា និង ក បាក បន្ដក់មួយ កា និង ក កាក បន្ដក់មួយ** ម្ដងមួយៗ ឱ្យសិស្សផ្សំសូរដោយប្រើដៃដូចខាងលើ។ |

## ២- ការស្គាល់តួអក្សរថ្មី ◷ ៥នាទី

ក- **បក់**

| | |
|---|---|
| គ្រូ | - សរសេរ **បក់** លើក្ដារខៀនរួចចង្អុលនិងអាន **ប និង ក បក បន្តក់មួយ បក់**។ |
| គ្រូ និងសិស្ស | - អាន **បក់** រួមគ្នាដោយផ្ទំប្រកប។ |
| សិស្ស | - អាន **បក់** ដោយផ្ទំប្រកប។ |

**ខ- ដាក់**

| | |
|---|---|
| គ្រូ | - សរសេរ **ដាក់** លើក្ដារខៀនរួចចង្អុលនិងអាន **ដ អា ដា និង ក ដាក បន្តក់មួយ ដាក់**។ |
| គ្រូ និងសិស្ស | - អាន **ដាក់** រួមគ្នាដោយផ្ទំប្រកប។ |
| សិស្ស | - អាន **ដាក់** ដោយផ្ទំប្រកប។ |

**គ- សញ្ញា (់) សម្រាប់កាត់សូរវែងឱ្យខ្លី។ នេះជាមេរៀនប្រកបនឹងក់។** គ្រូសរសេរចំណងជើងមេរៀនលើក្ដារខៀន ។

## ៣- ការអានព្យាង្គនិងពាក្យ ◷ ១៨នាទី

### ៣.១ - ការអានព្យាង្គ

### ៣.១.១ - ការអានព្យាង្គ (ស្រៈកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ដក់** លើក្ដារខៀនរួចចង្អុលនិងអាន **ដ និង ក ដក បន្តក់មួយ ដក់** ។ |
| គ្រូ និងសិស្ស | - គ្រូសរសេរ **សក់** រួចចង្អុលនិងអានរួមគ្នាដោយផ្ទំប្រកប។ |
| សិស្ស | - អាន **ខក់ តក់ កក់** ដោយផ្ទំប្រកប។<br>- អានព្យាង្គក្នុងតារាងទី១នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

### ៣.១.២ - ការអានព្យាង្គ (ស្រៈមិនកប់តួ)

| | |
|---|---|
| គ្រូ | - សរសេរ **ចាក់** លើក្ដារខៀនរួចចង្អុលនិងអាន **ច អា ចា និង ក ចាក បន្តក់មួយ ចាក់** ។ |
| គ្រូ និងសិស្ស | - គ្រូសរសេរ **កាក់** រួចចង្អុលនិងអានរួមគ្នាដោយផ្ទំប្រកប។ |
| សិស្ស | - អាន **ដាក់ សាក់ ចាក់** ដោយផ្ទំប្រកប។<br>- អានព្យាង្គក្នុងតារាងទី២នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

៣.២- ការអានពាក្យ

| | |
|---|---|
| គ្រូ | - គ្រូសរសេរ **ឡុកឡាក់** លើក្តារខៀនរួចចង្អុលនិងអាន **ឡ អុ ឡុ និង ក ឡុក ឡ អា ឡា និង ក ឡាក បន្តក់មួយ ឡាក់ ឡុកឡាក់** ។ |
| គ្រូ និងសិស្ស | - គ្រូសរសេរ **បោកបក់** លើក្តារខៀនរួចចង្អុលនាំសិស្សអានដោយផ្សំប្រកប។ |
| សិស្ស | - អាន **សំណាក់** ដោយផ្សំប្រកប។<br>អានពាក្យក្នុងតារាងទី៣នៃសៀវភៅជំនួយសិស្សជាដៃគូ។ |

## ៤- វាក្យសព្ទ ◷ ៨នាទី

**ក- ដំអក់**

| | |
|---|---|
| គ្រូ | - គ្រូពន្យល់ពាក្យ **ដំអក់ មានន័យថា អែអង់ អេរង់**។ គ្រូបង្កើតល្បះ **សុផាត ដេកដំអក់ យូរ**។ |
| គ្រូ និងសិស្ស | - អានពាក្យ **ដំអក់** រួមគ្នា។ គ្រូផ្តើម **សំណាងអង្គុយ ... លើផ្ទះ**។ សិស្សថា **ដំអក់** រួចថាល្បះពេញលេញរួមគ្នា |
| សិស្ស | - អានពាក្យ **ដំអក់** និងបង្កើតល្បះដោយប្រើប្រាស់ពាក្យ **ដំអក់** ជាដៃគូ។ |

ខ- **ដក់** បង្រៀនដូចពាក្យខាងលើ។ **ដក់ មានន័យថា មាននៅ តាំងនៅ**។ ឧ. **ភ្លៀងធ្លាក់ មានទឹកដក់** ។

## ៥- ការអានល្បះ ◷ ៥នាទី

- គ្រូបង្ហាញរូបភាពទាក់ទងនឹងខ្លឹមសារល្បះប្រសិនបើមាន។
- គ្រូសរសេរល្បះ **នារីកក់សក់**។ គ្រូសួរសិស្សថា **តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ?**
- គ្រូគូសសញ្ញា (/) លើល្បះដើម្បីញែកពាក្យ **នារី/កក់/សក់**។

| | |
|---|---|
| គ្រូ | - គ្រូអាន **នារីកក់សក់**។ |
| គ្រូនិងសិស្ស | - អានរួមគ្នា **នារីកក់សក់**។ |
| សិស្ស | - សិស្សអាន **នារីកក់សក់**។ |

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

- គ្រូសួរសំណួរទាក់ទងរូបភាព និងប្រាប់ចំណងជើង។
- គ្រូសួរសិស្ស **តើរឿងនេះនិយាយពីអ្វី?**
- គ្រូ និងសិស្សអនុវត្តតាមលំនាំខាងក្រោម ៖

| | |
|---|---|
| គ្រូ | - អានអត្ថបទខ្លីជាគំរូ។ |
| គ្រូនិងសិស្ស | - អានអត្ថបទខ្លីរួមគ្នា។ |
| សិស្ស | - អានអត្ថបទខ្លីជាដៃគូ។ |

- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។
- គ្រូសួរសំណួរ និងសម្របសម្រួលចម្លើយរបស់សិស្ស។

**១- តើចៅណាក់កំពុងចាំនរណា?**

**២- តើចៅចក់កក់សក់ដូចម្តេច?**

**៣- តើកូនគិតថា ហេតុអ្វីបានជាចៅណាក់ប្រាប់ចៅចក់ថា កុំ កក់សក់ដំអក់យូរពេក?**

**៤- នៅពេលកក់សក់ម្តងៗ តើកូនធ្លាប់ធ្វើ ដូចម្តេចខ្លះ?**

## ៧- ការសរសេរ ◷ ១៦នាទី

### ៧.១- ការសរសេរពាក្យ

| | |
|---|---|
| គ្រូ | - គិត និងថាឮៗ **ឡិកឡក់** **ឡ ិ ក ឡ ក ់** រួចសរសេរ **ឡិកឡក់** លើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គិត និងថាឮៗ **បែកបាក់** **ប ែ ក ប ា ក ់** រួចគ្រូសរសេរលើក្ដារខៀន។ សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថា **កំបាក់ ប៉ាក់ប៉ើក ដំណាក់** ម្ដងមួយពាក្យៗ។ សិស្សគិតនិងថាឮៗ រួចសរសេរលើក្ដារឆ្នួន។<br>- គ្រូសរសេរពាក្យទាំងនេះលើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ |

### ៧.២- ការសរសេរឃ្លា

- គ្រូហៅឃ្លា **ដេកដំអក់** ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរៀងៗខ្លួន

## ការពង្រឹង ឬពង្រីកចំណេះដឹង និងកិច្ចការផ្ទះ ◷ ៦នាទី

សូមមើលក្នុងលំនាំបង្រៀនលម្អិត

## ៣.៥ លំនាំបង្រៀនស្រៈពេញតួ

**លំនាំបង្រៀន** **មេរៀនទី៦៥ ស្រៈពេញតួ អ អា ឥ ឦ ឧ ឩ ឪ**

### រំឭកមេរៀនចាស់

◉ រំឭកតួអក្សរ និង សូរព្យញ្ជនៈទាំង ១០ តួ

❐ អក្សរចល័ត

◷ ៣ នាទី

គ្រូប្រើប័ណ្ណពាក្យ ឬសរសេរពាក្យដែលប្រកបនឹង **ល ល់ វ ស ស់ (ជួសជុល អំពាវនាវ នោស់ ឈើគូស ចៀសវាង វល់ ដៀល)** នៅលើក្ដារខៀន ម្ដងមួយពាក្យៗរួចឱ្យសិស្សអាន។ ជម្រើសមួយផ្សេងទៀត គ្រូអាចហៅឱ្យសិស្សសរសេរពាក្យទាំងនោះនៅលើក្ដារឆ្នួនម្ដងមួយពាក្យៗ។ រួចប្រាប់សិស្សឱ្យជួយកែតម្រូវពាក្យដែលសរសេរខុសជាដៃគូ។ បន្ទាប់មកឱ្យសិស្សលើកក្ដារឆ្នួនបង្ហាញគ្រូ ដើម្បីឱ្យគ្រូជួយកែតម្រូវដោយសរសេរពាក្យទាំងនោះលើក្ដារខៀន រួចនាំសិស្សអាន ។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស ៖**

✓ សង្កេតមើលថា តើសិស្សអាចអាន ឬសរសេរតួអក្សរដែលបានរៀនរួចបានត្រឹមត្រូវឬទេ។

★ ប្រសិនបើមានសិស្សណាដែលមានការពិបាកក្នុងការអាន គ្រូអានអក្សរនោះយឺតៗ ដោយឱ្យសិស្សមើលនិងស្ដាប់គ្រូខណៈពេលដែលគ្រូបន្លឺសូរ និងអានព្យាង្គ។

★ ឱ្យសិស្សហាត់អាន និងសរសេរពាក្យពិបាកៗ ឱ្យបានច្រើនដង។ ប្រសិនបើសិស្សមួយចំនួនជួបការលំបាកខ្លាំងជាមួយពាក្យណាមួយ គ្រូត្រូវឱ្យសិស្សហាត់អាន និងសរសេរពាក្យនោះឱ្យបានច្រើនដងក្នុងមួយថ្ងៃ និងរៀងរាល់ថ្ងៃ។ ឧទាហរណ៍ មុន ឬក្រោយម៉ោងចេញលេង ឬនៅពេលលេងល្បែងថាមពល។

∽ បង្ហាញតួបណ្ណពាក្យឱ្យជិតសិស្ស។ សួរសិស្សថា រវាងប័ណ្ណពាក្យនិងពាក្យដែលសរសេរធំៗនៅលើក្ដារខៀនតើមួយណាងាយអានជាង។ គ្រូធ្វើតាមតម្រូវការរបស់សិស្ស។

✐ ទាញចំណាប់អារម្មណ៍សិស្សឱ្យមើលនិងស្ដាប់គ្រូខណៈពេលដែលគ្រូបន្លឺសូរ និងអានអក្សរ និងធ្វើកាយវិការ។

## ១- ការស្គាល់សូរអក្សរថ្មី

### ១.១- ល្បែងទស្សន៍ទាយ

◎ កំណត់ព្យាង្គឬពាក្យដែលផ្ដើមដោយស្រៈ **អ អា ឥ ឦ ឧ ឩ ឪ**

❐ វត្ថុជាក់ស្ដែង រូបភាព សកម្មភាព ពណ៌នាអំពីអ្វីមួយ (អាចជ្រើសរើសបាន)

◷ ៥នាទី

គ្រូបង្ហាញវត្ថុជាក់ស្ដែង រូបភាព សកម្មភាព ពណ៌នាអំពីអ្វីមួយ ទាក់ទងនឹងព្យាង្គ/ពាក្យ ដែលត្រូវរៀន ដើម្បីឱ្យសិស្ស ទស្សន៍ទាយសូរព្យាង្គ/ពាក្យដែលត្រូវរៀន។ **ឧទាហរណ៍** : ស្រៈពេញតួ **អ**

- គ្រូបង្ហាញរូប **អគារ** រួចគ្រូសួរសិស្សថាតើនេះគឺជារូបអ្វី ?
- គ្រូបន្លឺពាក្យ **អគារ** ។ **អគារ** ខាងដើមមានសូរ **អ (អាក់)**
- **គ្រូ និងសិស្ស** : តោះយើងថាទាំងអស់គ្នា **អ** (អាក់)
- **សិស្ស** : គ្រូឱ្យសិស្សថា **អ (អាក់) ចំនួន ២ដង។**

## ២- ការស្គាល់តួអក្សរថ្មី

### ២.១-ការបង្ហាញតួអក្សរថ្មី

◎ កំណត់ព្យាង្គ ឬពាក្យដែលផ្ដើមដោយស្រៈ **អ អា ឥ ឦ ឧ ឩ ឪ**

❐ ប័ណ្ណរូបភាព

◷ ១២នាទី

អ(អាក់)

- **គ្រូ** : សរសេរអក្សរ **អ** ឱ្យធំល្មមនៅផ្នែកខាងលើក្ដារខៀន និងថាបណ្ដើរ **អ** (អាក់)
- **គ្រូនិងសិស្ស** : អានថា **អ** (អាក់)។
- **សិស្ស** : គ្រូឱ្យសិស្សអានដោយខ្លួនឯង **អ**(អាក់) ចំនួន២ដង។

អា(អា)

- **គ្រូ**និយាយថា យើងនៅកន្លែងដែលមាន វាលធំ មានខ្យល់ គេហៅ **អាកាស** ។ គ្រូថា **អាកាស** មាន **អា** ខាងដើម ។
- **គ្រូ និងសិស្ស**ថា **អា** ជាមួយគ្នា។
- **សិស្ស**: គ្រូឱ្យសិស្សអាន **អា** ចំនួន ២ដង។ **គ្រូ**សរសេរ **អា** លើក្ដារខៀន និងអាន។

ឥ(អិ)

- គ្រូបង្ហាញរូបភាព ឬដុំ**ឥដ្ឋ** ។ រួចសួរសិស្សថា តើនេះជាអ្វី? (**ឥដ្ឋ**)។
- **គ្រូ និងសិស្ស**ថា **ឥ** (**អិ**)ជាមួយគ្នា ។
- **សិស្ស**: គ្រូឱ្យសិស្សអានថា **ឥ** (**អិ**) ចំនួន ២ដង។ គ្រូសរសេរ ឥ លើក្ដារខៀន និងអាន (**អិ**)។

*សម្គាល់ : ក្រៅពីសូរ **អិ** ស្រៈពេញតួ ឥ នេះមានសូរបីទៀតគឺ **អី អុិ អុី**។*

ឦ (**អី**)

- គ្រូចង្អុលទៅទិស**ឦសាន** និងនិយាយថា ទិសនេះគឺទិស **ឦសាន**។ គ្រូថា **ឦសាន** មានសូរ **ឦ** (**អី**) ខាងដើម។
- គ្រូ និងសិស្សថា **ឦ** (**អី**) ជាមួយគ្នា ។
- សិស្ស : គ្រូឱ្យសិស្សថា **ឦ** (**អី**) ចំនួន ២ដង។ គ្រូសរសេរ **ឦ** នៅលើក្ដារខៀន និងអាន (**អី**)។

ឧ(**អុិ**)

- គ្រូ : គ្រូអាចបំផុសសំណួរដើម្បីទាញរកពាក្យ**ឧស្សាហ៍**។គ្រូថា **ឧស្សាហ៍** មាន សូរដើម **ឧ**(**អុិ**)។
- គ្រូ និងសិស្ស : គ្រូ និងសិស្សថា **ឧ**(**អុិ**) ជាមួយគ្នា ។
- សិស្ស : គ្រូឱ្យសិស្សថា **ឧ** (**អុ**) ចំនួន ២ដង។ គ្រូសរសេរ **ឧ** លើក្ដារខៀន និងអាន (**អុិ**)។

*សម្គាល់ : ក្រៅពីសូរ **អុិ** ស្រៈពេញតួ **ឧ** នេះមានសូរមួយទៀត គឺ **អុ***

ឩ (**អូ**)

- គ្រូបង្ហាញរូបភាព**ឩដ្ឋ**(**អូដ្ឋ**) ប្រាប់សិស្សថានេះ **ជាឩដ្ឋ**(**អូដ្ឋ**)។ គ្រូថា **ឩដ្ឋ** មានសូរដើម **ឩ**(**អូ**) ។ គ្រូ និងសិស្សថា **ឩ**(**អូ**) ជាមួយគ្នា ។
- សិស្ស : គ្រូឱ្យសិស្សថា **ឩ** (**អូ**) ចំនួន ២ដង។ គ្រូសរសេរ **ឩ** លើក្ដារខៀន និងអាន (**អូ**)។

ឪ(**អូវ**)

- គ្រូបង្ហាញរូបភាព **ឪឡឹក** ឬផ្លែ**ឪឡឹក**។ គ្រូថា **ឪឡឹក** មានសូរដើម **ឪ**។
- គ្រូ និងសិស្សថា **ឪ** ជាមួយគ្នា (**អូវ**)។

- សិស្ស : គ្រូឱ្យសិស្សថា ឪ (អូវ) ចំនួន ២ដង។ គ្រូសរសេរ ឪ (អូវ)លើក្ដារខៀន និងអាន។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

✓ ប្រសិនបើសិស្សណាមិនចូលរួម ឬលំបាកក្នុងការអានពាក្យ ឬបន្ទឹស្សូរ
សូមអានពាក្យនោះយឺតៗទាញចំណាប់អារម្មណ៍សិស្សឱ្យមើល និងស្ដាប់គ្រូខណៈពេលដែលគ្រូបន្លឺសូរ និងអានអក្សរ រួចហើយបំបែកពាក្យទៅជាព្យាង្គ ប្រសិនបើមានពាក្យលើសពីមួយព្យាង្គ។

★ ប្រសិនបើគ្រូរៀបរាប់ ឬបង្ហាញរូបភាព អ្វីមួយ គ្រូគួរតែព្យាយាមធ្វើសកម្មភាពជាមួយផងដែរ ដើម្បីឱ្យមានអន្តរកម្មរវាងគ្រូ និងសិស្ស ។

★ បើសិស្សមានការលំបាកក្នុងការបើកឱ្យចំមេរៀន គ្រូគួរ៖
- បង្ហាញមេរៀនស្រៈពេញតួក្នុងសៀវភៅជំនួយសិស្ស ហើយឱ្យពួកគេស្វែងរកទំព័រដែលមានអក្សរស្រៈពេញតួ។
- ឱ្យសិស្សដែលអង្គុយក្បែរជួយសិស្សមានការលំបាក។
- ប្រាប់ទំព័រទៅដល់សិស្ស។
- ដើរទៅជួយសិស្ស នៅតាមតុសិស្ស នាំពួកគេរកទំព័រមេរៀនស្រៈពេញតួ ។
- ចំពោះសិស្សណាដែលជួបការលំបាកគ្រប់ពេល ប្រើខ្សែ ឬអ្វីផ្សេងទៀតសម្រាប់ចំណាំទំព័រក្នុងសៀវភៅ។

★ ព្យាយាមប្រើពាក្យសាមញ្ញៗ ដែលសិស្សធ្លាប់ប្រើប្រាស់ញឹកញាប់។

☞ បង្ហាញវត្ថុជាក់ស្ដែង និងរូបភាពឱ្យជិតសិស្ស។ គ្រូឱ្យសិស្សប៉ះ ឬស្ទាបវត្ថុនោះ។
គ្រូពណ៌នាអំពីសកម្មភាពនានាដែលគ្រូកំពុងធ្វើ។

✐ ត្រូវប្រាកដថា សិស្សអាចមើលគ្រូឃើញច្បាស់។ គ្រូទាញចំណាប់អារម្មណ៍ឱ្យ សិស្សមើល និង ស្ដាប់គ្រូខណៈពេលដែលគ្រូបន្លឺសូរ និងអានពាក្យ។

## ៣- ការអានព្យាង្គ

### ៣.១- អានស្រៈពេញតួ

◎ កំណត់ និងអានស្រៈពេញតួ **អ អា ឥ ឦ ឧ ឩ ឪ** ។

❐ សៀវភៅសិក្សាគោល មេរៀនស្រៈពេញតួ

◷ ៥នាទី

- គ្រូ : អាន **អ អា ឥ ឦ ឧ ឩ ឪ** នៅលើក្ដារខៀន ។
- គ្រូ និងសិស្ស : អាន **អ អា ឥ ឦ ឧ ឩ ឪ** នៅលើក្ដារខៀន ។
- សិស្ស : គ្រូឱ្យសិស្សអានស្រៈពេញតួ **អ អា ឥ ឦ ឧ ឩ ឪ** ក្នុងសៀវភៅសិក្សាគោល ជាដៃគូដោយម្នាក់អ្នកចង្អុល ម្នាក់ទៀតអ្នកអាន និងប្ដូរវេនគ្នាពី **អ** ដល់ **ឪ**។

## ៤- ការអានពាក្យ

### ៤.១- វាក្យសព្ទ

◎ យល់ន័យនៃពាក្យពិបាកតាមរយៈការបង្កើតល្បះដោយផ្ទាល់មាត់

🗍 សៀវភៅសិក្សាគោល មេរៀនស្រៈពេញតួ

🕒 ៥នាទី

គ្រូពន្យល់ន័យពាក្យពិបាក ១ ឬ ២ និងបង្កើតល្បះជាគំរូះ

**ពាក្យទី១ ឪម៉ាល់**

- គ្រូពន្យល់ន័យនៃពាក្យ **ឪម៉ាល់** និងបង្កើតល្បះជាគំរូ។ **ឪម៉ាល់** គឺជាឈ្មោះសត្វល្អិតមួយប្រភេទមានពិស រស់នៅជាសំបុកជារន្ធតូចៗនៅរួមគ្នា។ ឧ. **ឪម៉ាល់** ហើរដេញទិចកូនអាំ។
- គ្រូប្រើសំណួរបំផុសដើម្បីនាំសិស្សបង្កើតល្បះដោយប្រើពាក្យ **ឪម៉ាល់**។ ឧ. តើកូនដឹងឬទេថាឪម៉ាល់រស់នៅឯណា?	ឧ. ខ្ញុំឃើញឪម៉ាល់នៅលើដើមឈើ។
- គ្រូឱ្យសិស្សបង្កើតល្បះជាមួយពាក្យ ឪម៉ាល់ ជាដៃគូ ដោយផ្ទាល់មាត់។ ឧ. កុំលេងក្បែរសំបុកឪម៉ាល់ប្រយ័ត្នវាទិច។

**ពាក្យទី២ ឥឡូវ**

- គ្រូពន្យល់ពាក្យ **ឥឡូវ** គឺពេលនេះ វេលានេះ។ ឧ. យើងនឹងចេញលេងឥឡូវនេះ។
- គ្រូប្រើសំណួរបំផុសដើម្បីនាំសិស្សបង្កើតល្បះដោយប្រើពាក្យ**ឥឡូវ**។ ឧ.តើយើងនឹងធ្វើអ្វី**ឥឡូវ**នេះ?
- គ្រូឱ្យសិស្សបង្កើតល្បះជាមួយពាក្យ **ឥឡូវ** ជាដៃគូ ដោយផ្ទាល់មាត់។ ឧ. ឥឡូវនេះ............។

### ៤.២- ការអានពាក្យដោយប្រកប

◎ អានពាក្យ

🗍 ប័ណ្ណពាក្យ ឬពាក្យក្នុងសៀវភៅសិក្សាគោល មេរៀនស្រៈពេញតួ

🕒 ១០ នាទី

១-គ្រូបង្ហាញប័ណ្ណពាក្យបត់ជាពីរផ្នត់ ឬសរសេរពាក្យ **អគារ** ដោយបង្ហាញម្តងមួយផ្នត់ៗ រួចអានថា **អគារ** (**អាក់គារ**)។ គ្រូអានម្តងទៀត **អគារ**។

២-គ្រូបង្រៀនអានពាក្យ**ឥឡូវ** ដូចលំនាំខាងលើ។

៣-គ្រូឱ្យសិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ ចាប់ពីពាក្យ **អាកាស** ដល់**ឪម៉ាល់** ដោយម្នាក់ជាអ្នកចង្អុល ម្នាក់ជាអ្នកអានរួចប្តូរវេនគ្នាម្តងម្នាក់។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

★ គ្រូអាចជ្រើសរើសពាក្យដែលពិបាកយល់ន័យក្នុងអត្ថបទមកពន្យល់បន្ថែមទៀត។
★ គ្រូអាចឱ្យសិស្សជ្រើសរើសពាក្យពិបាកដោយខ្លួនឯងរួចគ្រូសរសេរពាក្យនោះនៅលើក្ដារខៀន
★ ការពន្យល់និងការបង្កើតល្បះអាចធ្វើលំនាំដូចខាងលើ។
√ គ្រូគួរជ្រើសរើសពាក្យណាដែលអាចជួយគ្រូក្នុងការវាយតម្លៃថា តើសិស្សពិតជាយល់ន័យនៃពាក្យនោះបានច្បាស់ហើយឬនៅ?

## ៥- ការអានល្បះ

◎ អានស្ទាត់ និងយល់អត្ថន័យល្បះ
❐ ល្បះក្នុងមេរៀនស្រះពេញតួ
◷ ៥ នាទី

១- គ្រូចម្លងល្បះ **ឥឡូវនេះជំនោរបក់មកពីទិសឦសាន។** ដាក់លើក្ដារខៀន។

២- គ្រូនាំសិស្សញែកពាក្យក្នុងល្បះដោយសួរថា តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ? [ **ឥឡូវ-នេះ-ជំនោរ-បក់-មកពី-ទិស-ឦសាន]** ។

៣- គ្រូអានល្បះលើក្ដារខៀនជាគំរូ។

៤- គ្រូឱ្យសិស្សហ្វឹកហាត់អានជាដៃគូនូវល្បះខាងលើ និង ល្បះផ្សេងទៀតក្នុងសៀវភៅសិក្សាគោលដោយម្នាក់ចង្អុល ម្នាក់ទៀតអាន និងប្ដូរវេនគ្នា។

៥- ប្រសិនបើមានពាក្យពិបាក គ្រូសរសេរពាក្យពិបាកនោះនៅលើក្ដារខៀន និងពន្យល់សិស្ស។

៦- គ្រូបំផុសសំណួរឱ្យសិស្សយល់ពីអត្ថន័យនៃល្បះនិងសួរសំណួរដោយផ្សារភ្ជាប់នឹងជីវភាពជាក់ស្ដែងរបស់សិស្ស។

## ៦- ការអានអត្ថបទខ្លី

◎ អានស្ទាត់ និងយល់អត្ថន័យល្បះ
❐ សៀវភៅជំនួយសិស្ស មេរៀនស្រះពេញតួ
◷ ១៥នាទី

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព និងប្រាប់ចំណងជើងអត្ថបទក្នុងសៀវភៅជំនួយសិស្ស។
ខ- គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿងថា តើរឿងនេះនិយាយពីអ្វី?
គ- គ្រូអានរឿងពីដើមដល់ចប់យឺតៗ ដោយលើកដាក់សំឡេង និងគោរពតាមសញ្ញាសម្គាល់។
ឃ- គ្រូ និងសិស្សអានទាំងអស់គ្នា។
ង- គ្រូឱ្យសិស្សហ្វឹកហាត់អានជាដៃគូ។
ច- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។
ឆ- គ្រូសួរសំណួរម្ដងមួយៗដោយទុកពេលឱ្យសិស្សគិត(អានអត្ថបទឡើងវិញ)៖

- តើឪពុកអាំដាំអ្វី? ដាំនៅខែណា?
- តើឪពុកនាំអាំទៅបេះអ្វី? បេះយកមកធ្វើអ្វី?
- ហេតុអ្វីបានឪម៉ាល់ហើរដេញអាំ?
- តើកូនៗនិងធ្វើដូចម្ដេចពេលឃើញឪម៉ាល់?

ខែឧសភា ឪពុកអាំដាំឪឡឹក។
គាត់ដាំឪឡឹកនៅទិសឦសាន។
ឥឡូវគាត់នាំអាំទៅបេះឪឡឹក។
ឪម៉ាល់ហើរដេញអាំ។
អាំនិងឪពុកហូបឪឡឹកទុំ។

ជ- សម្រាប់សំណួរដែលមានចម្លើយលើសពីមួយ សិស្សអាចប្រើប្រាស់បទពិសោធ ឬគំនិតផ្ទាល់ខ្លួន។ គ្រូឱ្យសិស្សពិភាក្សាជាដៃគូ រួចឱ្យសិស្សពីរឬបីនាក់ឡើងចែករំលែកចម្លើយក្នុងក្រុមធំ។ គ្រូសម្របសម្រួលចម្លើយសិស្ស។

## ៧- ការសរសេរ ⏲ ២០នាទី

### ៧.១- ការសរសេរព្យាង្គ និងពាក្យលើក្ដារឆ្នួន

◎ សរសេរព្យាង្គ និងពាក្យ

🗇 ក្ដារឆ្នួន សៀវភៅកិច្ចការសិស្ស និងសៀវភៅសិក្សាគោល

⏲ ១២ នាទី

ក- គ្រូៈ គ្រូថា **ឪពុក** ព្យាង្គ ។ គ្រូថា **ឪពុក** ម្ដងទៀតរួចសរសេរបណ្ដើរលើក្ដារខៀន **ឪពុក** មាន **ឪ ព** ុ និង**ក**។

ខ- គ្រូនិងសិស្ស : គ្រូបន្លឺ **ឪម៉ាល់** ព្យាង្គ និងច្បាស់ៗ រួចសួរសិស្សថា មានអក្សរអ្វីខ្លះ? គ្រូថាបណ្ដើរ សរសេរបណ្ដើរលើក្ដារខៀន **ឪម៉ាល់** មាន **ឪ ម៉** ា និង **ល់**។ រីឯសិស្សថា និងសរសេរលើក្ដារឆ្នួនស្របពេលដែលគ្រូសរសេរ។ គ្រូឱ្យសិស្សបង្ហាញដៃគូ កែលម្អនិងលើកបង្ហាញគ្រូ។ គ្រូកែលម្អ។

គ- សិស្សៈ គ្រូថា **ឧទាន ឧសភា ឥឡូវ** ម្ដងមួយៗ ។សិស្សថាបណ្ដើរ សរសេរបណ្ដើរលើក្ដារឆ្នួន។ គ្រូឱ្យសិស្សបង្ហាញដៃគូ កែលម្អនិងលើកបង្ហាញគ្រូ។ គ្រូកែលម្អ។ គ្រូសរសេរលើក្ដារខៀន **ឧទាន ឧសភា ឥឡូវ** ដើម្បីសិស្សផ្ទៀងផ្ទាត់។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្សៈ**

✓ គ្រូ ថាពាក្យយឺតៗ ច្បាស់ៗ និងសរសេរធំៗ លើក្ដារខៀន .ខ **ចំណែក**។

✓ នៅពេលគ្រូហៅ ឱ្យសិស្សសរសេរ គ្រូគួរហៅពាក្យនីមួយៗពី ២-៣ដង ហើយប្រមាណ៣វិនាទីហៅម្ដង។

★ គ្រូដើរពិនិត្យពេលសិស្សសរសេរ ហើយជួយកែតម្រូវនៅពេលដែលកំពុងសរសេរ។

☙ ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្ដារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេសដោយធានាថាគេអាចមើលឃើញកាយវិការគ្រូច្បាស់។ ពោលគឺធ្វើដូចគ្នានឹងចំណុចផ្កាយខាងលើ។

### ៧២.- សរសេរតាមអានដាក់ចូលសៀវភៅ

◎ សរសេរតាមអាន

🗇 សៀវភៅកិច្ចការសិស្ស សៀវភៅសិក្សាគោល

⏲ ៨ នាទី

គ្រូឱ្យសិស្សសរសេរតាមអានដាក់ក្នុងសៀវភៅកិច្ចការ ដោយហៅឃ្លាដូចខាងក្រោម៖

**ចំការឪឡឹក អគារចាស់**

**កិច្ចការផ្ទះ**

គ្រូឱ្យសិស្សចម្លងល្បះពីក្នុងសៀវភៅសិក្សាគោល ដាក់ក្នុងសៀវភៅកិច្ចការ។

**ឧបសម្ព័ន្ធ៖ តារាងស្រៈពេញតួនិងរបៀបអាន**

| ល.រ | សំណេរ (សញ្ញា) | អាន (សូរ) | ឧទាហរណ៍ |
|---|---|---|---|
| ១ | អ | [អៈ] | អគារ [អៈគា] អវយវៈ [អៈវៈយៈវៈ] |
| ២ | អា | [អា] | អាកាស [អាកាស] អាឃាត [អាឃាត] |
| ៣ | ឥ | [អិ] | ឥដ្ឋ [អិត] ឥន្ទ [អិន] |
| | | [អី] | ឥឡូវ [អីឡូវ] ឥសី [អីសី/អ៊ិសី] |
| | | [អ៊ិ] | ឥច្ឆា [អ៊ិចឆា] |
| ៤ | ឦ | [អី] | ឦសូរ [អីសូ] |
| | | [អ៊ី] | ឦសាន អ៊ីសាន]] |
| ៥ | ឧ | [អុ] | ឧស [ អុស] |
| | | [អ៊ុ] | ឧសភា [អ៊ុសៈភា] ឧទាន [អ៊ុទាន]<br>ឧទាហរណ៍ [អ៊ុទា-ហ] ឧណ្ហ [អ៊ុន] |
| ៦ | ឩ | [អូ] | ឩដ្ឋ [អូដ្ឋ] ឩន [អូន] |
| | | [អ៊ូ] | ឩរុ [អ៊ូរ] |
| ៧ | ឪ | [អូវ] | ឪពុក [អូវពុក] ឪម៉ាល់ [អូវម៉ាល់] ឪឡឹក [អូវឡឹក] |
| ៨ | ឫ | [រឹ] | ឫក [រឹក] ឫកពា [រឹកពា] ឫស្សី [រឹស-សី] |
| ៩ | ឬ | [រឺ] | ឬ [រឺ] |
| ១០ | ឭ | [លឹ] | ឭក [លឹក] |
| ១១ | ឮ | [លឺ] | ឮ [លឺ] |

| | | | |
|---|---|---|---|
| ១២ | ឯ | [អែ] | ឯង [អែង]  ឯណា [អែណា] |
| ១៣ | ឰ | [អៃ] | ឰដ៏ [អៃ-ដ] |
| ១៤ | ឱ | [អោ] | ឱកាស [អោកាស]  ឱសថ [អោសត់]<br>ឱវាទ[អោវ៉ាត]  ឱ៉ាល់ [អោវ៉ាល់]  ឲ្យ [អោយ] |
| ១៥ | ឳ | [អៅ] | ក្រឳឈូក  [ក្រអៅឈូក] |

យើងគួរអានស្រៈពេញតួនីមួយៗតាមទម្លាប់ដូចខាងក្រោម៖

| អក្សរ | អ | អា | ឥ | ឦ | ឧ | ឩ | ឪ | ឫ | ឬ | ឭ | ឮ | ឯ | ឰ | ឱ | ឳ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សូរ | អឬអៈ | អា | អិ | អី | អុ | អូ | អូវ | រឹ | រឺ | លឹ | លឺ | អែ | អៃ | អោ | អៅ |

## ៣.៦ លំនាំបង្រៀនព្យញ្ជនៈ និងជើងព្យញ្ជនៈ

**លំនាំបង្រៀន  មេរៀនទី៦៧  ព្យញ្ជនៈ និងជើងព្យញ្ជនៈ ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ**  ⏲ ៨០នាទី

**រំឭកមេរៀនចាស់** ⏲ ១០នាទី

- គ្រូរំឭកព្យញ្ជនៈចំនួន ១០តួ **ក ខ គ ឃ ង ច ឆ ជ ឈ ញ**

**១- ការស្គាល់សូរ និងតួអក្សរថ្មី** ⏲ ៤០នាទី

**១.១- ការណែនាំអំពីព្យញ្ជនៈ និងជើងព្យញ្ជនៈ**

- គ្រូៈ សរសេរអក្សរ **ក** ឱ្យធំល្មមនៅផ្នែកខាងលើក្ដារខៀន និងថាបណ្ដើរ **ក**។ បន្ទាប់មកគ្រូសរសេរជើង (្ក) នៅពីក្រោម **ក** (**ក្ក**) រួចគ្រូអានថា **ក** ជើង ្ក (**ក្ក**) ចំនួន ២ដង។
- គ្រូពន្យល់ៈ  គ្រប់ជើងព្យញ្ជនៈទាំងអស់ មានសូរសំឡេងដូចតួរបស់វាដែរ។
- គ្រូនិងសិស្សៈ  អានថា **ក** ជើង ្ក (**ក្ក**)  ជាមួយគ្នា ចំនួន២ដង។
- សិស្សៈ គ្រូឱ្យសិស្សអានដោយខ្លួនឯង **ក** ជើង ្ក (**ក្ក**)  ចំនួន២ដង។

| | | |
|---|---|---|
| <u>គ្រូៈ</u> **ខ្ខ** | <u>គ្រូ និងសិស្សៈ</u> **គ្គ** | <u>សិស្សៈ</u> **ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ** |

**២- ការអានព្យញ្ជនៈ និងជើងព្យញ្ជនៈ** ២៥ នាទី⏲

**២.១- ការអានព្យញ្ជនៈ និងជើងព្យញ្ជនៈ**

- គ្រូប្រាប់សិស្សឱ្យហាត់អានព្យញ្ជនៈ  និងជើងព្យញ្ជនៈនៅក្នុងសៀវភៅជំនួយសិស្សជាដៃគូដោយម្នាក់អាន និងម្នាក់ទៀតជាអ្នកចង្អុលឱ្យចំតួនិងជើងអក្សរនីមួយៗចាប់ពី **ក្ក** រហូតដល់ **ញ្ញ**។ បន្ទាប់មកសិស្សផ្លាស់ប្ដូរវេនគ្នាអានម្ដងម្នាក់។

### ២.១- ការភ្ជាប់ព្យញ្ជនៈ និងជើងព្យញ្ជនៈ

| | | |
|---|---|---|
| គ្រូ: ភ្ជាប់ព្យញ្ជនៈ ក ទៅនឹងជើងរបស់វា ្ក ដោយប្រើចង្អុលដៃដើម្បីគូសភ្ជាប់ពីតួព្យញ្ជនៈទៅជើងរបស់វា។ | គ្រូ និងសិស្ស: ភ្ជាប់ព្យញ្ជនៈ ខ ទៅនឹងជើងរបស់វា ខ ដោយប្រើចង្អុលដៃដើម្បីគូសភ្ជាប់ពីតួព្យញ្ជនៈទៅជើងរបស់វា។ | សិស្ស: ភ្ជាប់ព្យញ្ជនៈទាំង ១០តួ (ក ខ គ ឃ ង ច ឆ ជ ឈ ញ) ទៅនឹងជើងរបស់វាដោយប្រើចង្អុល ដៃដើម្បីគូសភ្ជាប់។ |

## ៣- ការសរសេរព្យញ្ជនៈ និងជើងព្យញ្ជនៈ ២០ នាទី

### ៣.១- ការសរសេរជើងព្យញ្ជនៈ

| | | |
|---|---|---|
| គ្រូ : ហៅជើងព្យញ្ជនៈនិងសរសេរ ក្ក លើក្ដារខៀន។ (អក្ខរវិញ្ញាស) | គ្រូ និង សិស្ស: គ្រូហៅ និងសរសេរជើងព្យញ្ជនៈ ខ្ខ លើក្ដារខៀន សិស្សសរសេរលើក្ដារឆ្នួន។ (អក្ខរវិញ្ញាស) | សិស្ស : គ្រូហៅជើងព្យញ្ជនៈម្ដងមួយៗ (ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ) ឱ្យសិស្សសរសេរលើក្ដារឆ្នួន។ បន្ទាប់មកគ្រូសរសេរជើងទាំងអស់លើក្ដារខៀន។ |

### ៣.២- កិច្ចការផ្ទះ

គ្រូឱ្យសិស្សចម្លង ជើងព្យញ្ជនៈនៅលើក្ដារខៀនពី ក្ក ដល់ ញ្ញ ចូលសៀវភៅកិច្ចការ។ ប្រសិនបើគ្មានពេល សិស្សអាចធ្វើកិច្ចនេះនៅផ្ទះ។

### ៣.៧ លំនាំបង្រៀនធ្វើជើង

**រំឭកមេរៀនចាស់** ៥នាទី

◎ អាន ឬសរសេរជើងព្យញ្ជនៈ ្ញ ្ឆ ្ឈ ្រ ្ល

❐ ក្ដារខៀន ឬក្ដារឆ្នួន

៥ នាទី

១- គ្រូសរសេរជើងព្យញ្ជនៈ ្ញ ្ឆ ្ឈ ្រ ្ល មួយម្ដងៗ ឱ្យសិស្សអាន ឬហៅឱ្យសរសេរលើក្ដារឆ្នួន។

២- គ្រូកែតម្រូវសិស្សដែល អាន ឬសរសេរមិនបានត្រឹមត្រូវ។

### ១- ការស្គាល់សូរអក្សរថ្មី ៨នាទី

### ១.១- ល្បែងទស្សន៍ទាយ

◎ កំណត់ពាក្យដែលផ្ដើមដោយសូរព្យញ្ជនៈ ភ្ញ ភ្ឆ ភ្ឈ ក្រ ភ្ល

❐ វត្ថុជាក់ស្ដែង រូបភាព (អាចជ្រើសរើសបាន)

៨ នាទី

គ្រូបំផុសសំណួរទាក់ទងនឹងសកម្មភាព វត្ថុជាក់ស្ដែង រូបភាព ឬដោយការពណ៌នា ដើម្បីឱ្យសិស្ស៖

- រកពាក្យ

- ថាពាក្យតាមគ្រូ

- ប្រាប់សូរ

គ្រូឱ្យសិស្សទស្សន៍ទាយពាក្យមួយចំនួន ដោយៈ

បង្ហាញរូបភាព ឧ .បង្ហាញរូបភាព ក្ងោក ក្នុងសៀវភៅសិក្សាគោល (ទំព័រ៨៦) និងពន្យល់បន្ថែម ឈ្មោះសត្វស្លាបធំមួយប្រភេទ មានរោមស្លាបដុះនៅលើក្បាលដូចជាផុក មានកន្ទុយធំវែងចម្រុះពណ៌។ តើវាជាសត្វអ្វី? **(ក្ងោក)**។ គ្រូឱ្យសិស្សថាពាក្យ **ក្ងោក** តាមគ្រូ ដោយសួរសិស្សថាៈ តើ**ក្ងោក** មានសូរដើមអ្វី? **(ក្ង)**។

សកម្មភាព ឬកាយវិការ ឧ.គ្រូធ្វើសកម្មភាពដើរចេញក្រៅថ្នាក់ ហើយដើរចូលមកក្នុងថ្នាក់វិញដើម្បីរកពាក្យ ។

- គ្រូសួរថា : តើគ្រូធ្វើអ្វី? (គ្រូដើរចេញក្រៅ ហើយដើរចូលមកក្នុងថ្នាក់វិញ)
- គ្រូសួរបន្ត : តើកូនៗទាំងអស់គ្នាកំពុងនៅទីណា? (ក្នុងថ្នាក់)
- ឱ្យសិស្សថាពាក្យ **ក្នុង** តាមគ្រូ ដោយសួរសិស្សថាៈ តើក្នុងមានសូរដើមអ្វី? **(ក្ន)**
- គ្រូឱ្យសិស្សប្រាប់សូរដើមនៃពាក្យ ក្នុង មានសូរដើម **(ក្ន)**
- គ្រូឱ្យសិស្សថាតាមគ្រូ ក្នុង មានសូរដើម **(ក្ន)**។

គ្រូធ្វើដូចលំនាំខាងលើ សម្រាប់ពាក្យ ក្រៅ ។

វត្ថុជាក់ស្តែង ឧ. គ្រូសួរសិស្សថា : តើកូនៗដឹងទេថាកូនមានអាយុប៉ុន្មានឆ្នាំ? អ្នកដែលមានអាយុតិចដូចជា កូនៗ គេហៅថាអ្វី? (ក្មេង)

- គ្រូឱ្យសិស្សថាពាក្យក្មេង តាមគ្រូ។
- គ្រូឱ្យសិស្សប្រាប់សូរដើមនៃពាក្យ ក្មេង ។ សិស្សប្រាប់ថា ក្មេង មានសូរដើម( ក្ម) ។

ពណ៌នា ឧ. គ្រូនិយាយថា នៅលើមុខយើង មានមាត់ ភ្នែក ត្រចៀក និងច្រមុះ វាមានមុខងារខុសៗគ្នា។ តើច្រមុះមនុស្សយើងប្រើសម្រាប់ធ្វើអ្វីខ្លះ? (ដកដង្ហើម ស្រូបយកក្លិន)

- បន្ទាប់មក គ្រូឱ្យសិស្សថាពាក្យ ក្លិន តាមគ្រូ ។

គ្រូឱ្យសិស្សប្រាប់សូរដើមនៃពាក្យ ក្លិន មានសូរដើម (ក្ល)។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្សៈ**

✓ ប្រសិនបើសិស្សណាមិនចូលរួម ឬលំបាកក្នុងការអានពាក្យ ឬបន្លឺសូរ គ្រូត្រូវអានពាក្យនោះឡើងវិញឱ្យ ច្បាស់ៗ ទាញចំណាប់អារម្មណ៍សិស្សឱ្យមើលគ្រូខណៈពេលដែលគ្រូបន្លឺសូរ និងអានពាក្យ រួចហើយបំបែកពាក្យទៅជាព្យាង្គ ។

★ ប្រសិនបើគ្រូរៀបរាប់ ឬបង្ហាញរូបភាព អ្វីមួយ គ្រូគួរតែព្យាយាមធ្វើសកម្មភាពជាមួយផងដែរ ដើម្បីឱ្យមានអន្តរកម្ម រវាងគ្រូ និងសិស្ស។

ចំពោះមេរៀន ឬពាក្យណាដែលត្រូវបង្ហាញវត្ថុជាក់ស្តែង និងរូបភាពក្នុងសៀវភៅគោល ត្រូវធានាថាសិស្សអាចមើលឃើញច្បាស់។ គ្រូអាចឱ្យសិស្សប៉ះ ឬស្ទាបវត្ថុនោះ។ គ្រូពណ៌នាអំពីសកម្មភាពនានាដែលគ្រូកំពុងធ្វើ ដូចជាដើរចូលក្នុង ចេញក្រៅ ជាដើម។

ត្រូវប្រាកដថា សិស្សអាចមើលគ្រូឃើញច្បាស់។ គ្រូទាញចំណាប់អារម្មណ៍ឱ្យសិស្សមើលគ្រូខណៈពេលដែលគ្រូបន្លឺសូរ និងអានពាក្យ។

## ២- ការស្គាល់តួអក្សរថ្មី ⏱ ៧នាទី

### ២.១- ការបង្ហាញតួអក្សរថ្មី

◎ កំណត់រូបរាងតួអក្សរ **ក្វ ក្ន ក្ម ក្រ ក្ល**

🗇 គ្មាន

⏱ ៧ នាទី

គ្រូរំឭកពាក្យនីមួយៗ និងសូរដើមរបស់វា ដែលបានបំផុសសិស្សពីសកម្មភាពមុន ហើយសរសេរតួអក្សរទាំងអស់លើក្ដារខៀន **ក្វ ក្ន ក្ម ក្រ ក្ល ឧ. ក្វាកមានសូរដើម (ក្វ)**

ក. គ្រូ: អាន **ក្វ ក្ន ក្ម ក្រ ក្ល**

ខ. គ្រូ និងសិស្ស : រួមគ្នា **ក្វ ក្ន ក្ម ក្រ ក្ល**

គ. សិស្ស : គ្រូចង្អុលឱ្យសិស្សអាន **ក្វ ក្ន ក្ម ក្រ ក្ល** ។

## ៣- ការអានព្យាង្គ ⏱ ១០នាទី

### ៣.១-ការអានព្យាង្គ

◎ ផ្សំសូរដើម្បីអានព្យាង្គ

🗇 សៀវភៅជំនួយសិស្ស ក្ដារខៀន

⏱ ១០ នាទី

១-គ្រូសរសេរព្យាង្គម្ដងមួយៗ លើក្ដារខៀន ក្វា ក្ន ក្មេ ក្រ ក្លិ ដូចសកម្មភាពខាងក្រោម៖

ក- គ្រូ : គ្រូសរសេរ ក្វា រួចអានដោយប្រកបជាគំរូ ក ្វ ោ ក្វា

ខ- គ្រូ និងសិស្ស : គ្រូសរសេរម្ដងមួយៗ ក្ន ក្មេ និងចង្អុលនាំសិស្សអានដោយប្រកបដូចខាងលើ។

គ- សិស្ស : គ្រូសរសេរម្ដងមួយៗ ក្រ ក្លិ និងចង្អុលឱ្យសិស្សអានដោយប្រកប។

២- គ្រូឱ្យសិស្សអានព្យាង្គ ក្នុងសៀវភៅជំនួយសិស្ស ក្នុងតារាងទី១ ជាដៃគូដោយប្រកប ប្ដូរវេនគ្នាម្នាក់ចង្អុលម្នាក់អាន។ គ្រូដើរពិនិត្យ និងជួយកែតម្រូវបើចាំបាច់។

| | | |
|---|---|---|
| ក្វ | ក្វែ | ក្វា |
| ក្ន | ក្នៅ | ក្រាំ |
| ក្លិ | ក្លែ | ក្រោះ |

## ៤- ការអានពាក្យ ⏱ ១៣នាទី

### ៤.១ វាក្យសព្ទ

◎ យល់ន័យនៃពាក្យពិបាកតាមរយៈការបង្កើតល្បះដោយផ្ទាល់មាត់

🗇 សៀវភៅសិក្សាគោល (មេរៀនទី ៦៩)

⏱ ៥ នាទី

១- គ្រូពន្យល់ន័យនៃពាក្យ ក្និកក្នក់ និងបង្កើតល្បះជាគំរូ៖

**ក្និកក្នក់** មានន័យថា ដែលមានមាយាង៉ិកង៉ក់ កកិចកកុកភ្លាមៗគឺ បើឥតខឹងក៏ធ្វើជាខឹង។

ឧទាហរណ៍: ប្អូនខ្ញុំធ្វើឫកក្និកក្នក់គួរឱ្យក្នាញ់ ព្រោះវាចង់ញ៉ាំនំ។

២- ប្រើសំណួរបំផុសដើម្បីនាំសិស្សបង្កើតល្បះដោយប្រើពាក្យ **ក្និកក្នក់** ។

ឧទាហរណ៍: តើកូនៗធ្លាប់ដែលក្និកក្នក់ដែរឬទេ? ដាក់អ្នកណា? ព្រោះអ្វី? ខ្ញុំធ្លាប់ក្និកក្នក់ដាក់ម៉ាក់ ព្រោះចង់ឱ្យម៉ាក់លួងលោម។

៣- គ្រូឱ្យសិស្ស បង្កើតល្បះជាមួយពាក្យ **ក្និកក្នក់** ជាដៃគូ ដោយផ្ទាល់មាត់តាមលំនាំគំរូដូចខាងក្រោម៖

................(អ្នកណា)..................ក្និកក្នក់..................(ដាក់អ្នកណា)..............(ព្រោះអ្វី).........។

គ្រូបង្រៀនដូចលំនាំខាងលើ ចំពោះពាក្យ **ក្ញិចក្ញក់**។ **ក្ញិចក្ញក់** មានន័យថាដែលរៀចកុងចុះកុងឡើង។

១ .ឈើរៀចក្ញិចក្ញក់។

២. ក្មានធ្វើកក្ញិចក្ញក់។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

★គ្រូអាចជ្រើសរើសពាក្យដែលពិបាកយល់ន័យក្នុងអត្ថបទមកពន្យល់បន្ថែមទៀត។

★គ្រូអាចឱ្យសិស្សជ្រើសរើសពាក្យពិបាកដោយខ្លួនឯង រួចគ្រូសរសេរពាក្យនោះនៅលើក្តារខៀន។

★ ការពន្យល់ និងការបង្កើតល្បះអាចធ្វើលំនាំដូចខាងលើ។

√គ្រូគួរជ្រើសរើសល្បះណាដែលអាចជួយគ្រូក្នុងការវាយតម្លៃថា តើសិស្សពិតជាយល់ន័យនៃពាក្យនោះបានច្បាស់ហើយឬនៅ ?

### ៤.២- ការអានពាក្យមួយព្យាង្គក្នុងសៀវភៅជំនួយសិស្ស ដោយប្រកប

◎ អានពាក្យមួយព្យាង្គ

🗇 ក្តារខៀន សៀវភៅជំនួយសិស្ស

🕐 ៤នាទី

១- គ្រូសរសេរពាក្យម្តងមួយៗ លើក្តារខៀន ក្ងោក

ក- គ្រូ : គ្រូសរសេរ ក្ងោក រួចអានដោយប្រកប ជាគំរូ **ក្ង ោ** និង **ក ក្ងោក** ។

ខ- គ្រូ និងសិស្ស :គ្រូសរសេរម្តងមួយៗ **ក្នុង** នាំសិស្សអានដោយប្រកបដូចខាងលើ ។

គ- សិស្ស : គ្រូសរសេរពាក្យ **ក្រៅ ក្មេង ក្លិន** និងចង្អុលឱ្យសិស្សអានដោយប្រកប។

១- គ្រូឱ្យសិស្សអានពាក្យ ក្នុងសៀវភៅជំនួយសិស្សតារាងទី២ ជាដៃគូ ដោយប្រកប ប្តូរវេនគ្នាម្នាក់ចង្អុលម្នាក់អាន។

### ៤.៣- ការអានពាក្យពីរព្យាង្គក្នុងសៀវភៅសិក្សាគោលដោយប្រកប និងមិនប្រកប

◎ អានពាក្យពីរព្យាង្គ

🗇 ក្តារខៀន សៀវភៅសិក្សាគោល

🕐 ៤នាទី

ក- គ្រូសរសេរពាក្យ **ក្ញិចក្ញក់** លើក្តារខៀន ។ គ្រូប្រាប់សិស្សថាពាក្យ **ក្ញិចក្ញក់** មានពីរព្យាង្គ។ ព្យាង្គទីមួយគឺ **ក្ញិច** ព្យាង្គទីពីរគឺ **ក្ញក់**។ គ្រូអានពាក្យ **ក្ញិចក្ញក់** ពីរៗម្តងទៀត។

ខ- គ្រូសរសេរពាក្យ **ក្មេងក្មាង** លើក្ដារខៀន។ គ្រូសួរសិស្សថាតើពាក្យក្មេងក្មាង មានប៉ុន្មានព្យាង្គ? អ្វីខ្លះ? គ្រូនាំសិស្សអានពាក្យក្មេងក្មាង ។

គ- គ្រូសរសេរពាក្យ **ក្រអូប** ។ គ្រូចង្អុលឱ្យសិស្សអានពាក្យ **ក្រអូប** ។ គ្រូឱ្យសិស្សអានពាក្យពីរព្យាង្គ ក្នុងសៀវភៅសិក្សាគោល ជាដៃគូ ប្ដូរវេនគ្នាម្ដងម្នាក់។

**៥- ការអានល្បះ** ⏲ ៥នាទី

◎ អានស្ទាត់ និងយល់អត្ថន័យល្បះ

❐ សៀវភៅសិក្សាគោល រូបភាព

⏲ ៥ នាទី

ក- គ្រូបង្ហាញរូបភាព ឬពន្យល់ពាក្យ **ក្ងាន** (សត្វស្លាបមួយបែបដែលមានសណ្ឋានស្រដៀងទា តែវាមានកវែង រូបរាងវាធំជាងទា ហើយស្លាបពោមពណ៌ស) បំផុសសំណួរដែលទាក់ទងនឹងល្បះដែលត្រូវរៀន។

ខ- គ្រូសរសេរល្បះ **ក្ងានដើរដកកក្ងិចក្ងក់** នៅលើក្ដារខៀន។

គ- គ្រូដឹកនាំសិស្សញែកពាក្យក្នុងល្បះខាងលើក្នុងសៀវភៅសិក្សាគោល ដោយសួរថា : តើក្នុងល្បះនេះមានពាក្យអ្វីខ្លះ? **[ក្ងាន/ដើរ/ដកក/ក្ងិចក្ងក់]** ។

*បញ្ជាក់សម្រាប់គ្រូ: **ក្ងិចក្ងក់** មានន័យថាវៀចកុងចុះ កុងឡើង។*

ឃ- គ្រូអានល្បះនៅលើក្ដារខៀន ជាគំរូ។ គ្រូនាំសិស្សអាន រួចឱ្យសិស្សអានល្បះនេះឡើងវិញ។

ង- គ្រូសួរសំណួរដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្ស ឱ្យសិស្សយល់ពីអត្ថន័យនៃល្បះ។ **តើសត្វក្ងានមានរូបរាងដូចសត្វទាត្រង់ចំណុចណាខ្លះ ? តើកូនចូលចិត្តចិញ្ចឹមក្ងានដែរឬទេ? ព្រោះអ្វី?**

ច- គ្រូឱ្យសិស្សហ្វឹកហាត់អានល្បះទាំងអស់ជាដៃគូ ក្នុងសៀវភៅសិក្សាគោល ដោយប្រើសៀវភៅតែមួយក្បាល ដោយម្នាក់ចង្អុល ម្នាក់ទៀតអាន ធ្វើសកម្មភាពឆ្លាស់គ្នាម្ដងម្នាក់។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស**

✓ គ្រូស្រង់ល្បះមួយពីក្នុងសៀវភៅសិក្សាគោល។ ប្រសិនបើមានរូបភាពក្នុងសៀវភៅនោះ គ្រូលើករូបភាពបង្ហាញ ដើម្បីបំផុសសំណួរដែលទាក់ទងនឹងល្បះដែលត្រូវរៀន។

✓ គ្រូសង្កេតមើលសិស្សដែលរៀនយឺតនៅពេលហ្វឹកហាត់អានជាដៃគូ។ ឱ្យសិស្សអានឆ្លាស់គ្នា ម្នាក់ចង្អុល ម្នាក់អាន។

★ គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក (បើមាន) ។

★ គ្រូហៅសិស្សរៀនយឺតឡើងអាន។

★ គ្រូឱ្យសិស្សធ្វើកិច្ចការផ្ទះដោយគូររូបភាពជាគំនូរសេរី ទាក់ទងអត្ថន័យល្បះ និងបកស្រាយ។

✍ គ្រូប្រើប័ណ្ណល្បះ ប័ណ្ណពាក្យសម្រាប់សិស្សខ្សោយគំហើញ។

✆ គ្រូប្រើបណ្ណល្បះ ប័ណ្ណពាក្យសម្រាប់សិស្សដែលមានបញ្ហាក្នុងការស្ដាប់។

## ៦- ការអានអត្ថបទខ្លី ⏱ ១២នាទី

◎ អានស្ទាត់ និងបង្ហាញការយល់អត្ថន័យនៃអត្ថបទ

🗇 សៀវភៅជំនួយសិស្ស អត្ថបទខ្លី

⏱ ១២ នាទី

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព និងចំណងជើងអត្ថបទ

ខ- គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿងថា : តើរឿងនេះនិយាយអំពីអ្វី?

គ- គ្រូអានរឿងទាំងមូលយឺតៗ ដោយលើកដាក់សំឡេងគោរពតាមឃ្លា ល្បះ ក្នុងសាច់រឿង។

ឃ- គ្រូ និងសិស្ស អានទាំងអស់គ្នា។

ង- គ្រូឱ្យសិស្សហ្វឹកហាត់អានជាដៃគូ។

ច- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ឆ- គ្រូសួរសំណួរម្តងមួយៗ ដោយទុកពេលឱ្យសិស្សគិត (អានអត្ថបទរឿងឡើងវិញ)

- គ្រូឱ្យសិស្សឆ្លើយសំណួរជាបុគ្គលៈ

| | |
|---|---|
| ១- តើក្ងានយំនៅឯណា? | **ក្មេងៗដេញក្ងាន** |
| ២- តើអ្នកណាទៅដេញក្ងាននៅពេលវាយំ? | ក្ងានយំឯរោងក្បែរដើមក្រូច។ |
| ៣- កូនគិតថា ហេតុអ្វីបានជាក្រសារហក់ជួយក្ងាន? | ក្មេងៗដើរក្រោមដើមក្រាក ទៅដេញ |
| ៤- តើកូនៗធ្លាប់បានជួយមិត្តភក្តិយើងដូចក្រសារជួយ | ក្ងាន។ក្រសារក្រោកឈរដេកកក្និចក្ងក់។ |
| ក្ងានដែរឬទេ? នៅពេលណា? ហើយជួយដូចម្តេច? | ក្រសារក្លាហានហក់ជួយក្ងាន។ ក្មេងក្មាង |
| | ភ្ញាក់ក្តិកក្អក់ខឹងនឹងក្រសារ។ |

- សម្រាប់សំណួរដែលមានចម្លើយលើសពីមួយ ដែលសិស្សអាចប្រើបទពិសោធ ឬគំនិតផ្ទាល់ខ្លួន គ្រូឱ្យសិស្សពិភាក្សាជាដៃគូ ហើយហៅសិស្សពីរ ឬបីនាក់ឡើងចែករំលែកចម្លើយរបស់ពួកគេក្នុងក្រុមធំ ។

ជ- គ្រូសម្របសម្រួលចម្លើយសិស្ស។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្សៈ**

✓ សម្រាប់សំណួរដែលមានចម្លើយលើសពីមួយទុកពេលសមល្មមឱ្យសិស្សប្រើបទពិសោធឬគំនិតផ្ទាល់ខ្លួនពិភាក្សាជាដៃគូ។

✓ គ្រូដើរជុំវិញថ្នាក់ តាមតុនីមួយៗស្តាប់សិស្សពិភាក្សាគ្នា នៅពេលចែករំលែកគំនិតផ្ទាល់ខ្លួន។

✓ ប្តូរសំណួរ តែរក្សាន័យដដែល ពេលដែលសិស្សស្តាប់សំណួរគ្រូមិនយល់។

✓ ជួយពួកគេ ដោយប្រើសំណួរប្រជេញ ប្រសិនបើគេនៅតែមិនទាន់យល់សំណួរ។

## ៧- ការសរសេរ ◷ ២០នាទី

### ៧.១- ការសរសេរព្យាង្គ និងពាក្យលើក្ដារឆ្នួន

◎ សរសេរព្យាង្គ និងពាក្យ

❐ ក្ដារឆ្នួន សៀវភៅកិច្ចការសិស្ស

◷ ១២ នាទី

៧.១.១ គ្រូសរសេរជាគំរូលើក្ដារខៀន សិស្សសរសេរលើក្ដារឆ្នួន

ក- គ្រូ: គ្រូថា **ក្វិកក្វក់** ឮៗ។ ប្រាប់សិស្សថាពាក្យនេះមានពីរព្យាង្គ។ គ្រូថាពាក្យម្ដងទៀត និងសរសេរបណ្ដើរលើក្ដារខៀន **ក្វិកក្វក់** មាន **ក្វ** ស្រៈ ិ និង **ក** **ក្វិក** **ក្វ** នឹង **ក** បន្ដក់ **ក្វក់**។

ខ- គ្រូនិងសិស្ស: គ្រូបន្លឺ **ក្មេងក្មាង** ឮៗ និងច្បាស់ៗ រួចសួរសិស្សថា **ក្មេងក្មាង** មានអ្វីខ្លះ? ធ្វើដូចខាងលើគឺគ្រូថាបណ្ដើរសរសេរបណ្ដើរលើក្ដារខៀន រីឯសិស្សថា និងសរសេរលើក្ដារឆ្នួន ស្របពេលដែលគ្រូសរសេរ គ្រូឱ្យសិស្សបង្ហាញដៃគូ កែលម្អនិងលើកបង្ហាញគ្រូ។ គ្រូកែលម្អ។

គ- សិស្ស: គ្រូថាពាក្យ **ក្រអូប** ឱ្យសិស្សសរសេរលើក្ដារឆ្នួន។ គ្រូឱ្យសិស្សបង្ហាញដៃគូ កែលម្អនិងលើកបង្ហាញគ្រូ។ គ្រូសរសេរ **ក្រអូប** លើក្ដារខៀនដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់។ អនុវត្តដូចគ្នា ចំពោះពាក្យ **ក្និកក្នក់** ក្រចេះ ។

៧.១.២ គ្រូសរសេរលើក្ដារខៀន ដើម្បីសិស្សផ្ទៀងផ្ទាត់ បន្ទាប់ពីគ្រូឱ្យសិស្សលើកក្ដារឆ្នួនក្រោយពីសរសេររួច។

| **របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖** |
|---|
| ✓ គ្រូ ថាពាក្យយឺតៗ ច្បាស់ៗ និងសរសេរធំៗ លើក្ដារខៀន។ ឧ. ក្ដោះ |
| ✓ នៅពេលគ្រូហៅ ឱ្យសិស្សសរសេរ គ្រូគួរហៅពាក្យនីមួយៗពី ២-៣ដង ហើយប្រមាណ៣វិនាទីហៅម្ដង។ |
| ★ គ្រូដើរពិនិត្យពេលសិស្សសរសេរ ហើយជួយកែតម្រូវនៅពេលដែលកំពុងសរសេរ។ |
| ☙ ក្រៅពីការដាក់ឱ្យពួកគេអង្គុយតុមុខជិតក្ដារខៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ចំពោះពួកគេជាពិសេស ដោយធានាថាគេអាចមើលឃើញកាយវិការគ្រូច្បាស់។ពេលគឺធ្វើដូចគ្នានឹងចំណុចផ្កាយខាងលើ។ |

### ៧.២ សរសេរតាមអានដាក់ចូលសៀវភៅ

◎ សរសេរតាមអាន

❐ សៀវភៅសិក្សាគោលមេរៀន ទី៦៩ (**ក្វ ក្ន ក្ម ក្រ ក្ល**)

◷ ៨ នាទី

គ្រូឱ្យសិស្សសរសេរតាមអានដាក់ក្នុងសៀវភៅកិច្ចការ ដោយហៅឃ្លាដូចខាងក្រោម៖

**ក្វានដកកក្វិកក្វក់ ក្រោមដើមក្រូក**

---

**កិច្ចការផ្ទះ:** គ្រូឱ្យសិស្សចម្លងល្បះពីក្នុងសៀវភៅសិក្សាគោល ដាក់ក្នុងសៀវភៅកិច្ចការ។

## ៣.៨ លំនាំបង្រៀនមេរៀនព្យាង្គតម្រួត ន្ទ ខ្ទ ឡ្យ ន្ទ្រ ន្ធ

## រំឭកមេរៀនចាស់ ◷ ៥នាទី

◎ ការអាន ឬសរសេរពាក្យ **ល្ហោនខោល ស្បែកជើង ស្តឹមស្តែ ស្អាតបាត ស្លូតបូត**

❒ បណ្ណពាក្យ

◷ ៥ នាទី

- គ្រូ៖សរសេរពាក្យនៅលើក្ដារខៀន **ល្ហោនខោល ស្បែកជើង ស្តឹមស្តែ ស្អាតបាត ស្លូតបូត** (អាចបន្ថែមមួយពាក្យ ឬពីរពាក្យទៀត ដែលគ្រូគិតថាសិស្សពិបាកអាន និងសរសេរ )។
- គ្រូនិងសិស្ស៖ គ្រូសរសេរពាក្យលើក្ដារខៀនឱ្យសិស្សអានដោយប្រកប ម្ដងមួយពាក្យៗ រួចចង្អុលម្ដងមួយព្យាង្គៗ ឱ្យសិស្សអាន **ល្ហោនខោល [ល្ហោន-ខោល]** ។
- សិស្ស៖ គ្រូចង្អុលឱ្យសិស្សអានដោយមិនបាច់ផ្សំប្រកប **ល្ហោនខោល**។

អនុវត្តលំនាំដូចគ្នាចំពោះ **ស្បែកជើង ស្តឹមស្តែ ស្អាតបាត ស្លូតបូត** ។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

★ ប្រសិនបើមានសិស្សណាមានការពិបាកក្នុងការអាន គ្រូអានពាក្យនោះច្បាស់ៗ ដោយឱ្យសិស្សមើលគ្រូ ខណៈពេលដែលគ្រូបន្លឺសូរ ផ្សំ ប្រកប អានពាក្យ ឬបំបែកពាក្យ។ គ្រូផ្ដល់ឧទាហរណ៍អំពីការប្រកបឬបំបែកសូរ តាមរយៈពាក្យងាយៗជាមុន ផ្ដើមពីមួយព្យាង្គទៅពីរព្យាង្គ ។ ឧទាហរណ៍ : (**ល្ហោន**) **ល-្ហ-ល្ហោ-ន-ល្ហោន** (**ខោល**) **ខ-ោ-ល-ខោល** (បន្ទាប់មកអាន **ល្ហោនខោល** ។

★ប្រសិនបើសិស្សមួយចំនួនជួបការលំបាកខ្លាំងជាមួយតួអក្សរ ឬពាក្យណាមួយ ត្រូវហាត់អានអក្សរ ឬពាក្យនោះឱ្យបានច្រើនដងក្នុងមួយថ្ងៃ។ ឧទាហរណ៍: មុន ឬក្រោយម៉ោងចេញលេង នៅពេលលេងល្បែងថាមពល មុនពេលចេញទៅផ្ទះ ឬមុនចូលរៀន។

👓 បង្ហាញប័ណ្ណពាក្យឱ្យជិតសិស្ស។បើគ្រូសរសេរនៅលើក្ដារខៀន ត្រូវសួរបញ្ជាក់សិស្សថាតើគេមើលឃើញច្បាស់ឬទេ។គ្រូអាចប្ដូរសិស្សខ្សោយតំហើញមកអង្គុយតុមុខ។ គ្រូធ្វើតាមតម្រូវការរបស់សិស្ស ។

👂 ទាញចំណាប់អារម្មណ៍សិស្សឱ្យមើលគ្រូ ខណៈពេលដែលគ្រូបន្លឺសូរ និងអានពាក្យរួម ជាមួយការធ្វើកាយវិការ ។

## ១-ការស្គាល់សូរ និងតួអក្សរថ្មី ◷ ១០នាទី

◎ កំណត់សូរនិងព្យាង្គពាក្យ ចង្កេះ បង្ខំ វង្វេង សង្ស័យ កង្ហារ បង្អួច

❒ សៀវភៅជំនួយសិស្ស

◷ ១០ នាទី

**ក-** គ្រូ: ថ្ងៃនេះយើង នឹងរៀនអំពីព្យាង្គតម្រួត។

- គ្រូចង្អុល និងយកដៃទាំងពីរប្រត់ចង្កេះហើយថា **ចង្កេះ** ។គ្រូថាពាក្យនិងទះដៃតាមព្យាង្គ

**ចង់**( ទះដៃ )

**កេះ**( ទះដៃ )។

- គ្រូប្រាប់សិស្សថា ពាក្យ ចង្កេះ មានពីរព្យាង្គ។

- គ្រូសរសេរពាក្យ **ចង្កេះ** លើក្ដារខៀនដោយប្រើដីសពណ៌ខុសគ្នាសម្រាប់ព្យាង្គទី១និងទី២។

ចង្កេះ [ចង់ កេះ] (របៀបអាន)

-គ្រូគូសព្យាង្គទាំងពីរឱ្យដាច់ពីគ្នារួចអាន ចនិង ង **ចង់** (ព្យាង្គទី១) ្ក េះ **កេះ** (ព្យាង្គទី២) **ចង្កេះ**

- គ្រូប្រាប់សិស្សថា ព្យាង្គទី១ ត្រូវអានដូចមានបន្តក់ដែរ ដោយសារមានជើងក នៅក្រោម។ ព្យាង្គទី២ អាន **កេះ** ដោយសារ ្ក សូរដូចព្យញ្ជនៈ ក ដែរ។

- អនុវត្តដូចលំនាំបង្រៀនដូចខាងលើចំពោះពាក្យ **បង្ខំ** ។

ខ- គ្រូ និងសិស្ស : គ្រូសរសេររួចនាំសិស្សអាន **វង្វេង សង្ស័យ** *(ស័ និង យ ស័យ ជំនួសស្រៈ ៃ)* ។

គ- សិស្ស : គ្រូសរសេររួចចង្អុលឱ្យសិស្សអាន **កង្ហារ បង្អួច** ។

| | | |
|---|---|---|
| គ្រូ: **ចង្កេះ បង្ខំ** | គ្រូនិងសិស្ស: **វង្វេង សង្ស័យ** | សិស្ស: **កង្ហារ បង្អួច** |

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស**

★ ត្រង់សកម្មភាពគ្រូធ្វើ គ្រូត្រូវប្រើដីសពណ៌សរសេរព្យាង្គទាំងពីរឱ្យខុសពីគ្នា ចង្អុលព្យាង្គនីមួយៗឱ្យដាច់ពីគ្នា ដើម្បីអានពាក្យ រួចសរសេររបៀបអានដូចការពន្យល់(ចង្កេះ បង្ខំ) ខាងលើ។ ចាប់ផ្ដើមពីគ្រូ-សិស្ស និងសិស្ស ធ្វើតទៅគ្រូគ្រាន់តែសរសេរពាក្យរួចចង្អុលព្យាង្គនីមួយៗដើម្បីអាន ដោយមិនចាំបាច់សរសេរពីរបៀបអាន នៅក្បែរពាក្យទាំងនោះទេ ប្រសិនបើមិនចាំបាច់។

## ៤- ការអានពាក្យ ◷ ២៥នាទី

### ៤.១-វាក្យសព្ទ

◎ យល់ន័យនៃពាក្យពិបាកតាមរយៈការបង្កើតល្បះដោយផ្ទាល់មាត់

❐ សៀវភៅសិក្សាគោល

◷ ១០ នាទី

- **សង្ស័យ**

ក- គ្រូ: គ្រូបន្លឺពាក្យ **សង្ស័យ** ។គ្រូពន្យល់ថា: **សង្ស័យ** គឺ សេចក្ដីឆ្ងល់ មិនអស់មិនហើយក្នុងចិត្ត។ បង្កើតល្បះជាគំរូដែលមានពាក្យសង្ស័យ។ឱ.**ខ្ញុំសង្ស័យថាកុសលបងប្អូនជាមួយសុខា**។

ខ- គ្រូនិងសិស្ស: គ្រូប្រើសំណួរបំផុសដើម្បីនាំសិស្សបង្កើតល្បះដោយប្រើពាក្យ **សង្ស័យ**។ ឱ.តើកូនកំពុង**សង្ស័យ** លើអ្វីខ្លះ?

គ- សិស្ស: គ្រូឱ្យសិស្សបង្កើតល្បះជាមួយពាក្យ**សង្ស័យ**ជាដៃគូ ដោយផ្ទាល់មាត់។ ឱ. **ខ្ញុំសង្ស័យមិត្តភក្តិខ្ញុំម្នាក់មករៀនមិនទាន់គេ** ។

- **បង្អង់**

ក- គ្រូ : គ្រូបន្លឺពាក្យ **បង្អង់** ។ គ្រូពន្យល់ថា: **បង្អង់** គឺ អែអង់ រវង់ ឈប់ចាំ ។ គ្រូបង្កើតល្បះជាគំរូដែលមានពាក្យ **បង្អង់** ។ ឱ. **សិស្សទាំងអស់គ្នាកុំដើរលឿនពេក បង្អង់ចាំគ្រូផង**។

ខ- គ្រូនិងសិស្ស : គ្រូប្រើសំណួរបំផុសដើម្បីនាំសិស្សបង្កើតល្បះដោយប្រើពាក្យ **បង្អង់**។ ឱ. ប្រសិនបើមិត្តភក្តិកូន ដើរមិនទាន់កូន តើកូនធ្វើដូចម្ដេច? (**បង្អង់**)

គ- សិស្ស: គ្រូឱ្យសិស្សបង្កើតល្បះជាមួយពាក្យ**បង្អង់** ជាដៃគូ ដោយផ្ទាល់មាត់។ ឧ.**ជីតាបង្អង់ចាំខ្ញុំ** ។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស**

★ ប្រើងាយៗដែលសិស្សអាចយល់បាន។

★ ស្តាប់ល្បះដែលសិស្សបានបង្កើតដើម្បីប្រាកដថា សិស្សបានយកពាក្យថ្មីទៅប្រើប្រាស់បានត្រឹមត្រូវ។

★ ត្រូវដើរជិតសិស្សដើម្បីប្រាកដថា ដៃគូបានស្តាប់ឮល្បះដែលមិត្តភក្តិបង្កើតនោះច្បាស់ៗ។

**៤.២-ការអានពាក្យដោយប្រកប**

◎ អានពាក្យ អង្វរ វង្សត្រកូល អង្សា

❐ សៀវភៅសិក្សាគោល

◷ ១៥ នាទី

ក- គ្រូៈសរសេរពាក្យ **អង្វរ** លើក្តារខៀន រួចអានដោយយកដៃចង្អុល**អង្វរ** (**អ និង ង អង់ វ៉ និង រ អានថា វ៉ អង្វរ**)។

ខ- គ្រូនិងសិស្សៈ គ្រូសរសេរ **វង្សត្រកូល** លើក្តារខៀន រួចនាំសិស្សអានដោយយកម្រាមចង្អុលពាក្យ។

គ- សិស្សៈ គ្រូសរសេរ **អង្សា** រួចចង្អុលឱ្យសិស្សអាន។

គ្រូឱ្យសិស្សអានពាក្យក្នុងសៀវភៅសិក្សាគោលជាដៃគូ ដោយម្នាក់ចង្អុល ម្នាក់អាន រួចប្តូរវេនគ្នា។

**សម្គាល់** : ***សង្ស័យ*** *[អានថា សង់ សៃ ]* ***ស័ និង យ ស័យ ជំនួសស្រៈ ៃ*** ។

***អង្វរ*** *[អានថា អង់ វ៉] ដោយសារព្យញ្ជនៈ វ ដួលសូរតាមព្យញ្ជនៈ អ ខាងដើម។*

*តែគ្រូគប្បីប្រាប់ឱ្យសិស្សចំណាំ មិនចាំបាច់ពន្យល់អំពីទំនាញសូរទេ។*

**៥- ការអានល្បះ** ◷ **៨នាទី**

◎ អានស្ទាត់ និងយល់អត្ថន័យល្បះ

❐ សៀវភៅសិក្សាគោល

◷ ៨ នាទី

ក- គ្រូបំផុសសំណួរទាក់ទងនឹងល្បះត្រូវរៀន។ ឧ.កូនធ្លាប់ស្គាល់សត្វបង្កួយឬទេ ? វាធ្លាប់នៅកន្លែងណាខ្លះ ? ពេលនេះយើងនឹងអានល្បះមួយទាក់ទងនឹងពាក្យបង្កួយ។

ខ- គ្រូចម្លងល្បះ **សង្ខាសង្ខាតសិក្សាមិនបង្អង់។** ដាក់លើក្តារខៀន។

គ- គ្រូសួរសិស្សថាតើក្នុងល្បះនេះមានពាក្យអ្វីខ្លះ ? គ្រូគូសបន្ទាត់ពីក្រោម ឬសញ្ញា / [សង្ខា/បង្អង់/មិន/សិក្សា/សង្ខាត]។

ឃ- គ្រូអានល្បះលើក្តារខៀនជាគំរូ ដោយចង្អុល ឱ្យចំម្តងមួយពាក្យៗ។

ង- គ្រូសួរសំណួរដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្ស ឱ្យសិស្សយល់ពីអត្ថន័យនៃល្បះ។ **ឧ.តើសង្ខាសិក្សាយ៉ាងដូចម្តេច ? បើចង់រៀនពូកែកូនត្រូវធ្វើដូចម្តេច ?**

ច- គ្រូឱ្យសិស្សហ្វឹកហាត់អានល្បះទាំងអស់ជាដៃគូ ក្នុងសៀវភៅសិក្សាគោល ដោយប្រើសៀវភៅតែមួយក្បាលដោយម្នាក់ចង្អុល ម្នាក់ទៀតអាន ធ្វើសកម្មភាពផ្លាស់គ្នាម្តងម្នាក់។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

✓ គ្រូស្រង់ល្បះមួយក្នុងសៀវភៅសិក្សាគោល។ ប្រសិនបើមានរូបភាពក្នុងសៀវភៅនោះ គ្រូលើករូបភាពបង្ហាញ ដើម្បីបំផុសសំណួរដែលទាក់ទងនឹងល្បះដែលត្រូវរៀន។

✓ គ្រូសង្កេតមើលសិស្សដែលរៀនយឺតនៅពេលហ្វឹតហាត់អានជាដៃគូ។ ឱ្យសិស្សអានឆ្លាស់គ្នា ម្នាក់ចង្អុល ម្នាក់អាន។

★ គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក (បើមាន) ។

★ គ្រូហៅសិស្សរៀនយឺតឡើងអាន។

★ គ្រូឱ្យសិស្សធ្វើកិច្ចការផ្ទះដោយគូររូបភាពជាគំនូរសេរី ទាក់ទងអត្ថន័យល្បះ និងបកស្រាយ។

✍ គ្រូប្រើប័ណ្ណល្បះ បណ្ណពាក្យសម្រាប់សិស្សខ្សោយគំហើញ។

🦻 គ្រូប្រើប័ណ្ណល្បះ បណ្ណពាក្យសម្រាប់សិស្សដែលមានបញ្ហាក្នុងការស្តាប់។

## ៦- ការអានអត្ថបទខ្លី ◷ ១២នាទី

◎ អានស្ទាត់ និងយល់អត្ថន័យល្បះ

❐ សៀវភៅជំនួយសិស្ស

◷ ១២ នាទី

ក- គ្រូសួរសំណួរទាក់ទងនឹងរូបភាព និងចំណងជើងអត្ថបទនៅក្នុងសៀវភៅជំនួយសិស្ស មេរៀន ង្គ។

ខ- គ្រូឱ្យសិស្សទស្សន៍ទាយសាច់រឿងថា៖ តើរឿងនេះនិយាយពីអ្វី?

គ- គ្រូអានរឿងពីដើមដល់ចប់យឺតៗ ដោយលើកដាក់សំឡេងគោរពតាមសញ្ញាសម្ព័ន្ធ។

ឃ- គ្រូ និងសិស្សអានទាំងអស់គ្នា។

ង- គ្រូ ឱ្យសិស្សហ្វឹកហាត់ជាដៃគូ។

ច- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ឆ- គ្រូសួរសំណួរម្តងមួយៗ ដោយទុកពេល ឱ្យសិស្សគិត និងសម្របសម្រួលចម្លើយរបស់សិស្ស (អានអត្ថបទឡើងវិញ)។

- គ្រូ ឱ្យសិស្សឆ្លើយសំណួរជាបុគ្គល៖

| | |
|---|---|
| | កង្កែបជួយបង្កួយ |
| ១. តើបង្កួយតោងអ្វី? | បង្កួយតោងចង្កៀង។ |
| ២.ពេលឃើញបង្កួយធ្លាក់លើចង្អេរ តើកបង្កែបធ្វើដូចម្តេច? | វាធ្លាក់ក្នុងចង្អេរអង្ករ។<br>កង្កែបទល់ចង្កា មើលតាមបង្អួច។ |
| ៣.តើកង្កែបជាសត្វដូចម្តេច? | កង្កែបបង្ហិលខ្លួនលោតផ្លោត លើកង្ហារ។ |
| ៤.តើកូនធ្លាប់បានជួយអ្នកខ្លះ? ជួយដូចម្តេច? | កង្កែប លោតកាត់ចង្អើរទៅជួយបង្កួយ។ |

- សម្រាប់សំណួរដែលមានចម្លើយលើសពីមួយ ឱ្យសិស្សប្រើប្រាស់បទពិសោធ ឬគំនិតផ្ទាល់ខ្លួន

- គ្រូ ឱ្យសិស្សពិភាក្សាជាដៃគូ រួច ឱ្យសិស្សពីរឬបីនាក់ឡើងចែករំលែកគំនិតរបស់គេក្នុងក្រុមធំ។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

✓ សម្រាប់សំណួរដែលមានចម្លើយលើសពីមួយ ទុកពេលសមល្មម ឱ្យសិស្សប្រើបទពិសោធ ឬគំនិតផ្ទាល់ខ្លួនពិភាក្សាជាដៃគូ។

✓ គ្រូដើរជុំវិញថ្នាក់ តាមតុនីមួយៗស្ដាប់សិស្សពិភាក្សាគ្នា នៅពេលចែករំលែកគំនិតផ្ទាល់ខ្លួន។

✓ ប្ដូរសំណួរ តែរក្សាន័យដដែល ពេលដែលសិស្សស្ដាប់សំណួរគ្រូមិនយល់។

✓ ជួយពួកគេ ដោយប្រើសំណួរប្រជេញ ប្រសិនបើគេនៅតែមិនទាន់យល់សំណួរ។

## ៧- ការសរសេរ ◷ ២០នាទី

### ៧.១-ការសរសេរពាក្យលើក្ដារឆ្នួន

◎ សរសេរព្យាង្គ និងពាក្យ

🗇 ក្ដារឆ្នួន សៀវភៅកិច្ចការសិស្ស និងសៀវភៅសិក្សាគោល

◷ ១២ នាទី

ក- គ្រូ : ថា**សង្ហារ** ៗៗ **សង្ហារ** មាន **ស** និង **ង** **ជើង** ្ហ ា **និង** **រ** និងសរសេរបណ្ដើរ**សង្ហារ**លើក្ដារខៀន។

ខ- គ្រូ និងសិស្ស : គ្រូបន្លឺ **ចង្អេរ** ម្ដងមួយព្យាង្គៗច្បាស់ៗ រួចសួរសិស្សថាពាក្យ **ចង្អេរ** មានអ្វីខ្លះ?

គ្រូផ្ដើម **ចង្អេរ** មាន **ច ង** ្អ េ **និង** **រ** សរសេរលើក្ដារខៀន សិស្សថានិងសរសេរ **ចង្អេរ** លើក្ដារឆ្នួន។

គ្រូឱ្យសិស្សបង្ហាញដៃគូ កែលម្អ និងលើកបង្ហាញគ្រូ។

គ- សិស្ស : គ្រូថាពាក្យ **បង្កើត បង្ខំ អង្ក្រា** ម្ដងមួយៗ ។សិស្សថាបណ្ដើរ សរសេរបណ្ដើរលើក្ដារឆ្នួន។

គ្រូឱ្យសិស្សបង្ហាញដៃគូ កែលម្អនិងលើកបង្ហាញគ្រូ។ គ្រូកែលម្អ។

គ្រូសរសេរលើក្ដារខៀន **បង្កើត បង្ខំ អង្ក្រា** ដើម្បីសិស្សផ្ទៀងផ្ទាត់ បន្ទាប់ពីគ្រូឱ្យសិស្សលើកក្ដារឆ្នួនក្រោយពីសរសេររួច។

**របៀបដែលគ្រូពិនិត្យការយល់ដឹងរបស់សិស្ស និងជួយគាំទ្រសិស្ស៖**

✓ គ្រូ ថាសូរឃើតៗ ច្បាស់ៗ និងសរសេរពាក្យ លើក្ដារខៀន ( **សង្ហារ ហៅ សង់ ខា** )។

✓ នៅពេលគ្រូហៅ ឱ្យសិស្សសរសេរ គ្រូគួរហៅព្យាង្គមួយពី ២-៣ដង ហើយប្រមាណ៥វិនាទីហៅម្ដង ឬទុកពេលឱ្យសិស្សសរសេរ៣០វិនាទីក្នុងមួយពាក្យ។

★ គ្រូដើរពិនិត្យពេលសិស្សសរសេរ ហើយជួយកែតម្រូវនៅពេលដែលកំពុងសរសេរ។

### ៧.២ ការសរសេរឃ្លា

◎ សរសេរតាមអាន

🗇 សៀវភៅកិច្ចការសិស្ស សៀវភៅសិក្សាគោល

◷ ៨ នាទី

ក. គ្រូប្រាប់សិស្សថា**ពេលពេលនេះយើងនឹងហ្វឹកហាត់សរសេរឃ្លា។ គ្រូនឹងហៅឃ្លាឃើតៗចំនួនបីដងឱ្យកូនសរសេរ។**

ខ. **គ្រូហៅឃ្លាចង្អេរឬស្សី**ឃើតៗឱ្យសិស្សសរសេរចូលក្នុងសៀវភៅរៀងៗខ្លួន

គ. គ្រូឱ្យសិស្សបង្ហាញដៃគូកែលម្អជាមុន។ គ្រូសរសេរឃ្លានេះលើក្ដារខៀន និងឱ្យសិស្សផ្ទៀងផ្ទាត់។

**កិច្ចការផ្ទះ**

គ្រូឱ្យសិស្សចម្លងល្បះពីក្នុងសៀវភៅសិក្សាគោល ដាក់ក្នុងសៀវភៅកិច្ចការ។ ប្រសិនមិនមានពេល ពួកគេអាចធ្វើកិច្ចការនេះនៅផ្ទះ។

## ៣.៩ លំនាំបង្រៀនអំណាន

| | |
|---|---|
| **ក. មេរៀនទី ៣២ អំណាន បវេសនកាល (ថ្ងៃ ទី១)** | **៨០ នាទី** |
| **១- លំនឹងថ្នាក់ និងរំឭកមេរៀន** | **៧នាទី** |

◎ រំឭកពាក្យ

🗐 ក្ដារឆ្នួន ឬប័ណ្ណពាក្យ

🕒 ៧ នាទី

គ្រូបង្ហាញប័ណ្ណពាក្យ **កញ្ច្រែង បង្គ្រប់ ឥន្ទ្រី កន្ត្រៃ ចម្លាក់** ឱ្យសិស្សអាន ឬហៅឱ្យសិស្សសរសេរលើក្ដារឆ្នួនម្ដងមួយៗ យ៉ាងតិច៣ពាក្យ។ (គ្រូអាចរំឭកពាក្យដទៃទៀតតាមការចាំបាច់ តែមិនឱ្យលើសពីម៉ោងកំណត់។)

**ការត្រៀមអាន**

| | |
|---|---|
| **២-ការអានពាក្យ** | **១៥ នាទី** |

◎ សិស្សអានពាក្យបានត្រឹមត្រូវដោយមិនផ្សំប្រកប

🗐 សៀវភៅសិក្សាគោល

🕒 ១៥ នាទី

គ្រូថា ថ្ងៃនេះយើងរៀនមេរៀនអំណាន។ មុននឹងយើងអានអំណាន យើងសិក្សាពាក្យពិបាកជាមុនសិន។ គ្រូសរសេរពាក្យពិបាក **បវេសនកាល អញ្ជើញ ព្រលឹម ស្លៀកពាក់ ភ្ញាក់** លើក្ដារខៀន។

គ្រូឱ្យសិស្សអានអត្ថបទស្ងាត់ជាបុគ្គល ដើម្បីផ្ទៀងផ្ទាត់រកពាក្យពិបាកទាំងនោះ។

| | |
|---|---|
| **គ្រូ** | ▪ **អានពាក្យទាំង៥ជាគំរូដោយមិនផ្សំប្រកប។** |
| **គ្រូ និងសិស្ស** | ▪ អានពាក្យទាំង៥ ជាមួយគ្នាដោយមិនផ្សំប្រកប។ |
| **សិស្ស** | ▪ អានពាក្យទាំង៥ ទាំងអស់គ្នាដោយមិនផ្សំប្រកប។ |

| | |
|---|---|
| **៣- វាក្យសព្ទ** | **២៥ នាទី** |

**៣.១- ពន្យល់ពាក្យ**

◎ យល់ន័យនិងប្រើប្រាស់ពាក្យ

🗐 សៀវភៅសិក្សាគោល

🕒 ១៥នាទី

ក- បវេសនកាល

| | |
|---|---|
| គ្រូ | ▪ សរសេរពាក្យ បវេសនកាល លើក្ដារខៀន។<br>▪ អាន បវេសនកាល។ បវេសនកាល មានន័យថា ថ្ងៃចូលរៀនដំបូងនៅដើមឆ្នាំ។<br>▪ គ្រូបង្កើតល្បះជាគំរូ។ ឧ. ថ្ងៃបវេសនកាល មានសិស្សអ៊ូអរនៅសាលារៀន។ |
| គ្រូនិងសិស្ស | ▪ អានពាក្យ **បវេសនកាល** រួចបង្កើតល្បះរួមគ្នា ដោយគ្រូសួរសំណួរបំផុសថា តើថ្ងៃចូលរៀនដំបូងនៃឆ្នាំសិក្សាថ្មីជាថ្ងៃអ្វី? (បវេសនកាល)។<br>▪ គ្រូនិងសិស្សថាល្បះរួមគ្នា ថ្ងៃចូលរៀនដំបូងនៃឆ្នាំសិក្សាថ្មីជាថ្ងៃបវេសនកាល។ |
| សិស្ស | ▪ អាន **បវេសនកាល** ដោយខ្លួនឯង ហើយបង្កើតល្បះជាដៃគូដោយប្ដូរវេនគ្នា។ |

ខ- អញ្ជើញ

| | |
|---|---|
| គ្រូ | ▪ សរសេរពាក្យ អញ្ជើញ លើក្ដារខៀន។<br>▪ អានពាក្យ អញ្ជើញ។ អញ្ជើញ មានន័យថា ជូនដំណឹង ឬហៅដោយគោរព។<br>▪ គ្រូបង្កើតល្បះជា គំរូ ។ឧ . ម្ដាយខ្ញុំអញ្ជើញភ្ញៀវពិសាបាយ។ |
| គ្រូនិងសិស្ស | ▪ អានពាក្យ **អញ្ជើញ** រួចបង្កើតល្បះរួមគ្នា ដោយគ្រូសួរសំណួរបំផុសថា តើនាយកធ្វើដូចម្ដេច ដើម្បីបានឪពុកម្ដាយសិស្សចូលរួមប្រជុំ? (អញ្ជើញ)។<br>▪ គ្រូនិងសិស្សថាល្បះរួមគ្នា **នាយកអញ្ជើញឪពុកម្ដាយសិស្សចូលរួមប្រជុំ។** |
| សិស្ស | ▪ អានពាក្យ **អញ្ជើញ** ដោយខ្លួនឯង ហើយបង្កើតល្បះជាដៃគូដោយប្ដូរវេនគ្នា។ |

### ៣.២- ពាក្យដែលមានន័យដូច និងន័យផ្ទុយ

◎ កំណត់ពាក្យដែលមានន័យដូច និងន័យផ្ទុយ

🗐 សៀវភៅសិក្សាគោល

🕒 ១០ នាទី

ក-ពាក្យន័យដូច

| | |
|---|---|
| គ្រូ | ▪ ពាក្យន័យដូច គឺជាពាក្យមានន័យដូចគ្នាតែសរសេរខុសគ្នា ។ ឥឡូវនេះយើងនឹងរកពាក្យន័យដូចនឹងពាក្យ ម៉ាក់។<br>▪ សរសេរពាក្យ ម៉ាក់ លើក្ដារខៀនរួចប្រាប់សិស្សថា ពាក្យដែលមានន័យដូចនឹងពាក្យ ម៉ាក់ គឺ មាតា។ គ្រូសរសេរពាក្យ មាតា បន្ទាប់ពីពាក្យ ម៉ាក់ ។ |
| សិស្ស | ▪ គ្រូថា **កូនៗទាំងអស់គ្នារកពាក្យផ្សេងទៀតដែលមានន័យដូចនឹងពាក្យ ម៉ាក់ រួចថាពាក្យនោះប្រាប់ដៃគូម្ដងម្នាក់ៗ។**<br>▪ សិស្ស រកពាក្យផ្សេងទៀតដែលមានន័យដូចពាក្យ **ម៉ាក់** ជាដៃគូ។<br>▪ គ្រូឱ្យសិស្សស្ម័គ្រចិត្ត ចែករំលែកពាក្យដែលមានន័យដូចនឹងពាក្យ **ម៉ាក់**។<br>▪ គ្រូសរសេរពាក្យទាំងនោះលើក្ដារខៀនបន្ទាប់ពីពាក្យ **មាតា** ( **ម៉ែ ម្ដាយ** )។ |

ខ- ពាក្យផ្ទុយ

| | | |
|---|---|---|
| **គ្រូ** | ▪ | **ឥឡូវយើងរកពាក្យផ្ទុយម្តង។ ពាក្យផ្ទុយ គឺជាពាក្យដែលមានន័យផ្ទុយគ្នា (បញ្ច្រាសគ្នា)។ ឧ. ទាប ផ្ទុយនឹង ខ្ពស់។** |
| | ▪ | **គ្រូសរសេរពាក្យបវេសនកាលលើក្តារខៀន។គ្រូថា ពាក្យផ្ទុយនឹង បវេសនកាល គឺ វិស្សមកាល** |
| | ▪ | **សរសេរ បវេសនកាល ≠ វិស្សមកាល លើក្តារខៀន។ សញ្ញានេះ ( ≠ ) ហៅថា សញ្ញាផ្ទុយ។** |
| **សិស្ស** | ▪ | គ្រូសរសេរពាក្យ **រីករាយ** ≠ … លើក្តារខៀន។ |
| | ▪ | រកពាក្យផ្ទុយនឹងពាក្យ **រីករាយ** និងថាពាក្យនោះប្រាប់គ្នាជាដៃគូ។ |
| | ▪ | គ្រូឱ្យសិស្សស្ម័គ្រចិត្តចែករំលែកពាក្យដែលមានន័យផ្ទុយនឹងពាក្យ **រីករាយ**។ |
| | ▪ | គ្រូសរសេរពាក្យ **កើតទុក្ខ** បន្តពីសញ្ញា (≠) លើក្តារខៀន ( **រីករាយ ≠ កើតទុក្ខ**(។ |

## ៤- អានអត្ថបទអំណានលើកទី១ ◷ ៣០នាទី

◎ ហ្វឹកហាត់អាននិងយល់ន័យអត្ថបទ

🗐 សៀវភៅសិក្សាគោល

◷ ៣០នាទី

**ក- មុនពេលអាន**

- គ្រូឱ្យសិស្សបើកសៀវភៅសិក្សាគោលទំព័រទី៣២ ហើយមើលរូបភាព។ គ្រូសួរ **តើកូនៗឃើញអ្វីខ្លះក្នុងរូបភាពនេះ?**
- សិស្ស ២ ទៅ ៣ នាក់ឆ្លើយ។ គ្រូសម្របសម្រួលចម្លើយរបស់សិស្ស។
- គ្រូប្រាប់ចំណងជើងអត្ថបទ និងសរសេរចំណងជើងដាក់លើក្តារខៀន។
- គ្រូឱ្យសិស្សទស្សន៍ទាយថាតើអត្ថបទនេះនិយាយអំពីអ្វី?
- សិស្ស ២ ទៅ ៣ នាក់ឆ្លើយ។

**ខ- អំឡុងពេលអាន**

| | |
|---|---|
| **គ្រូ** | ▪ **អានអត្ថបទពីដើមដល់ចប់ដោយល្បឿនសមរម្យ និងលើកដាក់សំឡេងតាមសញ្ញាសម្ល័ន្ធ។** |
| **គ្រូ និងសិស្ស** | ▪ គ្រូ និងសិស្ស អានអត្ថបទជាមួយគ្នាដោយសិស្សយកម្រាមដៃអូសពីក្រោមពាក្យទាំងនេះ។ |
| **សិស្ស** | ▪ អានអត្ថបទខ្លីជាដៃគូម្នាក់ជាអ្នកចង្អុល និងម្នាក់ជាអ្នកអានរួចផ្លាស់ប្តូរគ្នាអាន។ សិស្សអានជាបុគ្គល (ប្រសិនបើមានពេល)។ គ្រូដើរស្តាប់សិស្សអាន។ |

គ- ក្រោយពេលអាន

- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស (ចម្លើយអាចមានលើសពីមួយ)។
- គ្រូសួរសំណួរក្នុងអត្ថបទ ដោយទុកពេលឱ្យសិស្សគិត មុននឹងឆ្លើយ ៖

**១- តើនៅថ្ងៃបវេសនកាល សុភីទៅរៀនជាមួយនរណា?**

២- តើម្ដាយសុភីផ្ដាំសុភីឱ្យធ្វើអ្វី?

៣- មុននឹងទៅសាលារៀន តើសុភី និងប្អូនធ្វើអ្វីខ្លះ?

**៥- កិច្ចការផ្ទះ និងបណ្ដាំផ្ញើ** ៣នាទី

- គ្រូដាក់កិច្ចការតាមសមត្ថភាពសិស្ស ដើម្បីហ្វឹកហាត់នៅផ្ទះ។
  នៅក្នុងមេរៀននេះគ្រូគួរអោយសិស្សចម្លង **ពន្យល់ពាក្យ ពាក្យន័យដូច** និង **ពាក្យផ្ទុយ** ទាំងនោះដាក់ក្នុងសៀវភៅ។

**ខ.មេរៀនទី ៣២ អំណាន បវេសនកាល (ថ្ងៃទី២)** ៨០ នាទី

**១- លំនឹងថ្នាក់ និងរំឭកមេរៀន** ៧នាទី

◎ រំឭកពាក្យ

ក្ដារឆ្នួន ឬប័ណ្ណពាក្យ

៧ នាទី

គ្រូបង្ហាញប័ណ្ណពាក្យ **បវេសនកាល អញ្ជើញ ភ្ញាក់ រីករាយ ស្លៀកពាក់** ម្ដងមួយឱ្យសិស្សអាន ឬហៅឱ្យសិស្សសរសេរលើក្ដារឆ្នួនយ៉ាងតិច៣ពាក្យ។ (គ្រូអាចរំឭកពាក្យដទៃទៀតតាមការចាំបាច់ តែមិនឱ្យលើសពីម៉ោងកំណត់។)

**២- ការអានអត្ថបទលើកទី២** ២០ នាទី

◎ ហ្វឹកហាត់អានអត្ថបទ និងធ្វើលំហាត់

សៀវភៅសិក្សាគោល

២០នាទី

**ក- មុនពេលអាន**

- គ្រូសួររំឭកថា **តើកូនៗនៅចាំបានទេថា អត្ថបទដែលបានរៀនពីម្សិលមិញមានចំណងជើងដូចម្ដេច? ហើយនិយាយអំពីអ្វី?**
- សិស្ស ២ ទៅ ៣ នាក់ឆ្លើយ។ គ្រូសម្របសម្រួលចម្លើយសិស្ស។

**ខ- អំឡុងពេលអាន**

- គ្រូឱ្យសិស្សអានអត្ថបទឡើងវិញឮៗ ជាដៃគូ ឬជាបុគ្គល។

**គ- ក្រោយពេលអាន**

- គ្រូសួរសំណួរទាក់ទងនឹងជីវភាពរស់នៅ ៖

  **១- តើកូនបានចូលរៀនដំបូងនៅខែណា?**

  **២- តើកូនត្រូវការសម្ភារៈសិក្សាអ្វីខ្លះដើម្បីរៀនសូត្រ?**

  **៣- ហេតុអ្វីបានជាកូនៗត្រូវមករៀនឱ្យបានទៀងទាត់?**

▪ លំហាត់

**ក- ការអានពាក្យដោយមិនផ្សំប្រកប**

| | |
|---|---|
| គ្រូ | - អានពាក្យ **ព្រលឹម សាលារៀន បវេសនកាល អញ្ជើញ ស្លៀកពាក់ ម្ដាយ ឪពុក** |
| គ្រូនិងសិស្ស | - អានពាក្យ **ព្រលឹម សាលារៀន បវេសនកាល អញ្ជើញ ស្លៀកពាក់ ម្ដាយ ឪពុក** ជាមួយគ្នា។ |
| សិស្ស | - អានពាក្យ ព្រលឹម សាលារៀន បវេសនកាល អញ្ជើញ ស្លៀកពាក់ ម្ដាយ ឪពុក ជាដៃគូ ដោយម្នាក់ជាអ្នកចង្អុល ម្នាក់ជាអ្នកអានរួចផ្លាស់ប្ដូរវេនគ្នាអាន។ សិស្សអានជាបុគ្គល (ប្រសិនបើមានពេល)។ |

**ខ- ការអានឈ្មោះ និងប្រាប់ពីវត្ថុ និងមនុស្ស**

គ្រូ

▪គូសតារាងខាងក្រោមលើក្ដារខៀន។

| | |
|---|---|
| មនុស្ស | |
| វត្ថុ | |

▪ អានឃ្លាទី១ **សុភី និងប្អូន** រួចពន្យល់ **សុភី និងប្អូន ជាពាក្យសម្គាល់ មនុស្ស។**

▪ គ្រូសរសេរពាក្យ **សុភី ប្អូន** លើក្ដារខៀននៅជួរជាមួយពាក្យ មនុស្ស។

| | |
|---|---|
| មនុស្ស | **សុភី ប្អូន** |
| វត្ថុ | |

គ្រូនិងសិស្ស

▪ អានឃ្លាទី២ **ទៅងូតទឹក** ទាំងអស់គ្នា ហើយកំណត់ពាក្យសម្គាល់**មនុស្ស** និង**វត្ថុ**។ **ទឹក ជាពាក្យសម្គាល់វត្ថុ**។

▪ គ្រូសរសេរពាក្យ **ទឹក** បន្ទាត់ខាងក្រោមក្នុងជួរជាមួយពាក្យ វត្ថុ លើក្ដារខៀន។

| | |
|---|---|
| មនុស្ស | **សុភី ប្អូន** |
| វត្ថុ | **ទឹក** |

សិស្ស

▪ អានឃ្លាដែលនៅសល់ទាំងអស់ជាដៃគូ។ គ្រូទុកពេលឱ្យសិស្សអាន។ គ្រូដើរស្ដាប់សិស្សអាននិងជួយសិស្ស។

▪ សិស្សស្ម័គ្រចិត្តអានឃ្លាទី៣: **រួចស្លៀកពាក់**។

▪ គ្រូសួរថា **តើមានពាក្យណាខ្លះដែលសម្គាល់មនុស្ស វត្ថុ ឬគ្មានទាំងពីរ? (គ្មានទាំងពីរ)**។ គ្រូប្រាប់ថា **ក្នុងឃ្លានេះគឺគ្មាន ពាក្យសម្គាល់មនុស្ស និង វត្ថុទេ។**

▪ ធ្វើដូចគ្នាចំពោះឃ្លាទី៤ និង ទី៥

**៣- សំណេរ** ⏱ **៥០ នាទី**

◎ សរសេរពាក្យ និងបំពេញល្បះបានត្រឹមត្រូវ

🗐 សៀវភៅសិក្សាគោល

🕒 ៥០នាទី

**ក- សរសេរតាមអាន**

| | |
|---|---|
| គ្រូ | - គ្រូគិត និងថាឮៗពាក្យ **ព្រលឹម** មានអក្សរ **ព ្រ ល ឹ ម** រួចសរសេរលើក្ដារខៀន។ |
| គ្រូនិងសិស្ស | - គ្រូនាំសិស្ស គិតនិងថាឮៗពាក្យ **សាលារៀន** មានអក្សរ **ស ា ល ា រ ៀ ន** រួចគ្រូសរសេរលើក្ដារ ខៀន សិស្សសរសេរលើក្ដារឆ្នួន។ |
| សិស្ស | - គ្រូថាពាក្យ **បវេសនកាល** ឱ្យសិស្សគិតនិងថាឮៗ ពាក្យ **បវេសនកាល** មានអក្សរ **ប វ េ ស ន ក ា ល** រួចឱ្យសិស្សសរសេរលើក្ដារឆ្នួន។<br>គ្រូសរសេរពាក្យលើក្ដារខៀនឱ្យសិស្សកែតម្រូវ។<br>- គ្រូហៅពាក្យ **ព្រលឹម បវេសនកាល សាលារៀន អញ្ជើញ គ្រែ ប្រញាប់ ស្លៀកពាក់ ម្ដាយ សំពះ ឪពុក** មិនតាមលំដាប់លំដោយម្ដងមួយៗឱ្យសិស្សសរសេរចូលក្នុងសៀវភៅកិច្ចការ។ គ្រូសរសេរពាក្យទាំងអស់នៅលើក្ដារខៀនឱ្យសិស្សផ្ទៀងផ្ទាត់។ |

**ខ- បំពេញពាក្យក្នុងល្បះ**

លំហាត់ទី១

| | |
|---|---|
| គ្រូ | ▪ ណែនាំឱ្យសិស្សបើកសៀវភៅទំព័រទី ៣៤ (លំហាត់ ទី១)។ គ្រូប្រាប់សិស្សថា ដើម្បីបំពេញល្បះមានន័យពេញលេញគ្រប់គ្រាន់ យើងត្រូវអានល្បះ និងជ្រើសរើសពាក្យត្រឹមត្រូវក្នុងប្រអប់មកបំពេញល្បះ។<br>▪ សរសេរ និងអានពាក្យក្នុងប្រអប់ ធំៗ ចម្រុះពណ៌ ពណ៌ក្រហម ។<br>▪ សរសេរ និងអានល្បះទី១ ឮៗ សាលារៀនខ្ញុំសង់អំពីឈើប្រក់ក្បឿង........។<br>▪ ប្រាប់សិស្សថាពាក្យដែលត្រឹមត្រូវយកមកបំពេញគឺ ពណ៌ក្រហម។<br>▪ យកពាក្យ ពណ៌ក្រហម ទៅបំពេញល្បះ និងអានល្បះឡើងវិញ សាលារៀនខ្ញុំសង់អំពីឈើប្រក់ក្បឿងពណ៌ក្រហម។ |
| គ្រូនិងសិស្ស | ▪ គ្រូសរសេរល្បះទី ២ **នៅជុំវិញសាលារៀន មានដើមឈើ ...... ជាច្រើន។**<br>▪ អានល្បះទី ២ **នៅជុំវិញសាលារៀន មានដើមឈើ ...... ជាច្រើន។**<br>▪ អានពាក្យក្នុងប្រអប់ខាងលើដើម្បីជ្រើសរើសពាក្យមកបំពេញ។<br>▪ អានល្បះទី២ឡើងវិញ **នៅជុំវិញសាលារៀនមានដើមឈើ ធំៗជាច្រើន។** |
| សិស្ស | ▪ គ្រូសរសេរល្បះទី ៣ **នៅក្នុងសួនច្បារមានផ្កា។.........**<br>▪ បំពេញល្បះទី៣ ដោយយកពាក្យ **ចម្រុះពណ៌** ពីក្នុងប្រអប់ខាងលើ។<br>▪ សិស្សអានល្បះទី៣ឡើងវិញទាំងអស់គ្នា **នៅក្នុងសួនច្បារមានផ្កាចម្រុះពណ៌។**<br>▪ សិស្សចម្លងពាក្យ **ពណ៌ក្រហម ធំៗ ចម្រុះពណ៌** នៅលើក្ដារខៀនដាក់ចូលក្នុងសៀវភៅកិច្ចការ។ |

លំហាត់ទី២ និង លំហាត់ទី៣ គ្រូណែនាំឱ្យសិស្សហ្វឹកហាត់បំពេញល្បះជាដៃគូ និងចម្លងពាក្យចូលក្នុងសៀវភៅ។

- លំហាត់ទី២ : ១- ទង់ជាតិ ២- បក់រវិចៗ ៣- ខៀវ ក្រហម ប្រាសាទ ស
- លំហាត់ទី៣ : ១- ធំ ខ្ពស់ ២- ញញឹម ៣- ស្លូតបូត

គ- អក្សរផ្ចង់ អំពីពាក្យ "សាលា"

គ្រូបង្រៀនតាមលំនាំក្នុងសៀវភៅសិក្សាគោលថ្នាក់ទី២ (ប្រសិនបើមិនមានពេលគ្រប់គ្រាន់គ្រូអាចបង្រៀននៅម៉ោងបត់បែន)។

**៤- កិច្ចការផ្ទះ និង បណ្ដាំផ្ញើ** ⏱ ៣នាទី

- គ្រូដាក់កិច្ចការតាមសមត្ថភាពសិស្ស ដើម្បីហ្វឹកហាត់នៅផ្ទះ។ ក្នុងមេរៀននេះគ្រូគួរឱ្យសិស្សចម្លងល្បះពេញលេញទាំងអស់ក្នុងលំហាត់ ខ ផ្នែកសំណេរដាក់ចូលក្នុងសៀវភៅ។

## ៣.១០ លំនាំបង្រៀននិយាយ

**ក. មេរៀនទី៣៥ ការនិយាយថ្ងៃទី១ ការណែនាំមិត្តឱ្យស្គាល់គ្នា** ⏱ ៤០នាទី

**១- លំនឹងថ្នាក់ និងរំឭកមេរៀន** ⏱ ៧នាទី

◎ រំឭកពាក្យ

🗐 ក្ដារខ្ៀន

🕒 ៧ នាទី

គ្រូរំឭកពាក្យដែលបានរៀនរួច ២ ទៅ៣ ពាក្យ។ គ្រូសរសេរពាក្យទាំងនេះ ម្ដងមួយៗ។ រួចឱ្យសិស្សពន្យល់ន័យនៃពាក្យនោះ រួចបង្កើតល្បះដោយផ្ទាល់មាត់។

**ការត្រៀមនិយាយ**

**២- វាក្យសព្ទ** ⏱ ១០នាទី

◎ ប្រាប់ន័យនៃពាក្យ និងប្រើប្រាស់ពាក្យ

🗐 សៀវភៅសិក្សាគោល

🕒 ១០នាទី

សេចក្ដីផ្ដើម : គ្រូប្រាប់សិស្សថា ថ្ងៃនេះយើងនឹងរៀនពីការសន្ទនា។

**៣- ការអានអត្ថបទសន្ទនា** ⏱ ៣៥ នាទី

◎ អានស្ទាត់ និងអានយល់ន័យ

🗐 សៀវភៅសិក្សាគោល

🕒 ៣៥នាទី

**៣.១ មុនពេលសន្ទនា(៥នាទី)**

ក- គ្រូបង្ហាញរូបភាពក្នុងសៀវភៅសិក្សាគោល (ទំព័រ៤១) និងសួរសំណួរទាក់ទងនឹងរូបភាព ។ ប្រាប់ចំណងជើងអត្ថបទ (ការណែនាំមិត្តឱ្យស្គាល់គ្នា)។

ខ- គ្រូ ឱ្យសិស្សទស្សន៍ទាយសាច់រឿងដោយបំផុសសំណួរ : **តើពួកគេទាំងបីនាក់កំពុងសន្ទនា គ្នា (និយាយគ្នា) អំពីអ្វី?**

**៣.២ អំឡុងពេលសន្ទនា (១៥នាទី)**

គ្រូប្រាប់សិស្សថា ពេលនេះ យើងនឹងហាត់អានអត្ថបទជាមួយគ្នា។ អត្ថបទនេះជាការសន្ទនា ឬនិយាយគ្នារវាងកុមារបីនាក់។ គ្រូឱ្យសិស្សបើកសៀវភៅសិក្សាគោល ទំព័រ៤១ ទាំងអស់គ្នា។

- គ្រូ : អានអត្ថបទពីដើមដល់ចប់ ដោយលើកដាក់សំឡេងគោរពតាមសញ្ញាសម្ព័ន្ធ។
- គ្រូនិងសិស្ស : អានអត្ថបទព្រមគ្នា។
- សិស្ស : អានអត្ថបទជាដៃគូ។ សិស្សអានជាបុគ្គល ។

**៣.៣ ក្រោយពេសន្ទនា (១០នាទី)**

ក- គ្រូសម្របសម្រួលចម្លើយទស្សន៍ទាយរបស់សិស្ស។

ខ- គ្រូសួរសំណួរដែលមានក្នុងសៀវភៅសិក្សាគោលម្តងមួយៗ ដោយទុកពេល ឱ្យសិស្សគិតនិងសម្របសម្រួលចម្លើយរបស់សិស្ស ( ឱ្យសិស្សអានអត្ថបទឡើងវិញ ប្រសិនបើមិនចងចាំ)។

**១- តើបូណាណែនាំនរណាឱ្យស្គាល់នរណា?**

**២- តើតារាជាមិត្តអ្នកណា?**

**៣- តើសុភីនិយាយដូចម្តេចទៅកាន់តារា?**

**៤- តើសុភីសួរតារាដូចម្តេច?**

**៣.៤ គ្រូសួរសំណួរទាក់ទង នឹងរបៀបនិយាយ ឬពាក្យ ឃ្លាចាំបាច់ (សំនួនពាក្យ)**

ឧទាហរណ៍ទី១ : គ្រូនិយាយថា តារាជាមិត្តរបស់សុភី។ ពេលជួបសុភី តារានិយាយទៅកាន់សុភីថា សួស្តី សុភី !...បន្ទាប់មកសួរសិស្សថា តើសុភីត្រូវឆ្លើយតបទៅតារាវិញថាដូចម្តេច?ពាក្យ (សួស្តី តារា!)។ សរសេរពាក្យ **សួស្តី** លើក្តារខៀន។

ឧទាហរណ៍ទី២ : សួរសិស្សថា ពេលយើងជួបអ៊ំប្រុសម្នាក់ ជាការគួរសមចំពោះគាត់ តើយើងត្រូវនិយាយពាក្យអ្វី? (ជម្រាបសួរ លោកអ៊ំ!)។ គ្រូសរសេរពាក្យ ជម្រាបសួរ លើក្តារខៀន។

**៣.៥- អានអត្ថបទ ដោយសម្តែងតួ(៥នាទី)**

- គ្រូឱ្យសិស្សអានអត្ថបទ ក្នុងក្រុមដែលមានគ្នា៣នាក់ (ចំនួនតួអង្គក្នុងការសន្ទនា) ដោយលើកដាក់សំឡេងតាមតួអង្គដូចជាការសម្លែងតួ។
- សិស្សសម្តែងតួ ក្នុងក្រុម (៣នាក់) ដោយដោយប្រើឈ្មោះផ្ទាល់ខ្លួន។
- ក្រុមសិស្សស្ម័គ្រចិត្តឡើងសម្តែងតួក្នុងក្រុមធំ។

| **៤- លំហាត់** | ⏱ ៣៥ នាទី |
|---|---|

◎ ហាត់និយាយតាមក្រុមតូច

🗐 សៀវភៅសិក្សាគោល

◷ ៣៥នាទី

ការបំពេញសម្ដីសន្ទនាតាមរូបភាព ដោយប្រើឈ្មោះផ្ទាល់ខ្លួន

- សិស្សអានអត្ថបទលំហាត់ (ក្នុងទំព័រ៤២) ជាបុគ្គល។
- សិស្សអានអត្ថបទ ក្នុងក្រុមដែលមានគ្នា៣នាក់ ដោយលើកដាក់សម្លេងតាមតួអង្គដូចជាការសម្ដែងតួ។
- សិស្សសម្ដែងតួ ក្នុងក្រុម (៣នាក់) ដោយប្រើឈ្មោះផ្ទាល់ខ្លួន។
- ក្រុមសិស្សស្ម័គ្រចិត្ត ឡើងសម្ដែងតួក្នុងក្រុមធំ។

**៥- កិច្ចការផ្ទះ** ⏱ ៣ នាទី

គ្រូដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។

**ខ. មេរៀនទី៣៥ ការនិយាយថ្ងៃទី២ ការណែនាំមិត្តឱ្យស្គាល់គ្នា ⏱ ៨០នាទី**

**១- លំនឹងថ្នាក់ និងរំឭកវាក្យសព្ទ** ⏱ ៧នាទី

- ប្រាប់ឡើងវិញន័យនៃពាក្យ និងប្រើប្រាស់ពាក្យ
- សៀវភៅសិក្សាគោល
- ៧នាទី

គ្រូរំឭកពាក្យដែលបានរៀនរួច ២ ទៅ៣ ពាក្យ។ គ្រូសរសេរពាក្យទាំងនេះ ម្ដងមួយៗ។ រួចឱ្យសិស្សពន្យល់ន័យនៃពាក្យនោះ។

**២- ការសន្ទនាដោយប្រើឈ្មោះផ្ទាល់ខ្លួន** ⏱ ១៥នាទី

- ហាត់សន្ទនា
- សៀវភៅសិក្សាគោល (ទំព័រ៤២)
- ១៥នាទី

- គ្រូសួរសិស្ស រំឭកពីការសន្ទនានៅថ្ងៃទី១ (តើការសន្ទនាពីម្សិលមិញ មានមនុស្សប៉ុន្មាននាក់? តើពួកគេនិយាយអំពីអ្វី?)
- គ្រូឱ្យសិស្សអានអត្ថបទត្រង់ទំព័រទី៤២ ដោយស្ងាត់ៗ ជាបុគ្គល។
- គ្រូជ្រើសរើសសិស្ស ៣នាក់ឡើងសន្ទនា ដោយប្រើឈ្មោះផ្ទាល់ខ្លួន តាមខ្លឹមសារមេរៀនសន្ទនា ។

**៣- សំណេរ** ⏱ ៥៥នាទី

- សរសេរពាក្យបានត្រឹមត្រូវ
- សៀវភៅសិក្សាគោល
- ៥៥នាទី

**ក-សរសេរតាមអាន**

| | |
|---|---|
| **គ្រូ** | - **គ្រូអានជាគំរូក្នុងសៀវភៅសិក្សាគោល សួស្ដី មិត្ត រីករាយ ឯង ធម្មតា រៀន ស្គាល់ ថ្នាក់ សុខសប្បាយ អរគុណ។**<br>- **គ្រូគិត និងថាឮៗពាក្យ សួស្ដី មានអក្សរ ស ្ួ ស ្ដ ី រួចសរសេរលើក្ដារខៀន។** |

| | | |
|---|---|---|
| **គ្រូនិងសិស្ស** | - | គ្រូនិងសិស្សអានពាក្យក្នុងសៀវភៅសិក្សាគោល **សួស្តី មិត្ត រីករាយ ឯង ធម្មតា រៀន ស្គាល់ ថ្នាក់ សុខសប្បាយ អរគុណ**។<br>- គ្រូ នាំសិស្ស គិត និងថាឮៗ ពាក្យ **មិត្ត** មានអក្សរ **ម ិ ត ្ត** រួចគ្រូសរសេរលើក្ដារខៀន សិស្សសរសេរលើក្ដារឆ្នួន។ |
| **សិស្ស** | - | គ្រូឱ្យសិស្សអានពាក្យក្នុងសៀវភៅសិក្សាគោល **សួស្តី មិត្ត រីករាយ ឯង ធម្មតា រៀន ស្គាល់ ថ្នាក់ សុខសប្បាយ អរគុណ** ។<br>- គ្រូឱ្យសិស្ស គិត និងថាឮៗ ពាក្យ **ឯង** មានអក្សរ **ឯ ង** រួចឱ្យសិស្សសរសេរលើក្ដារឆ្នួន។ គ្រូសរសេរពាក្យលើក្ដារខៀនឱ្យសិស្សកែតម្រូវ។<br>- គ្រូហៅពាក្យ**សួស្តី មិត្ត រីករាយ ឯង ធម្មតា រៀន ស្គាល់ ថ្នាក់ សុខសប្បាយ អរគុណ** មិនតាមលំដាប់ ឱ្យសិស្សសរសេរចូលក្នុងសៀវភៅកិច្ចការ ដោយឱ្យសិស្សគិត និងថាឮៗ ម្ដងមួយពាក្យៗ (១ពាក្យហៅ៣ដង)។<br>*(អាចឱ្យកុមារមើលសៀវភៅគោលសិក្សាគោលរៀងៗខ្លួនបាន)* |

គ្រូអាចហៅពាក្យឆ្លាស់គ្នាឱ្យសិស្សសរសេរ។ គ្រូអានពាក្យទាំងអស់ឡើងវិញ ឱ្យសិស្សផ្ទៀង។ គ្រូទុកពេលសមល្មមឱ្យសិស្សពិនិត្យ និងកែកំហុស។ គ្រូឱ្យសិស្សប្ដូរគ្នាកែ ដោយផ្ទៀងផ្ទាត់ជាមួយពាក្យក្នុងសៀវភៅ ឬប្រមូលសៀវភៅសិស្សកែដាក់ពិន្ទុ។

**ខ- ការបំពេញពាក្យក្នុងអត្ថបទ**

សេចក្តីផ្តើម: គ្រូប្រាប់សិស្សថា **យើងនឹងត្រូវបំពេញពាក្យក្នុងអត្ថបទសន្ទនា។ ពាក្យដែលត្រូវយកទៅបំពេញ ក្នុងអត្ថបទ គឺជាពាក្យដែលមានក្នុងប្រអប់នៅផ្នែកខាងលើនៃអត្ថបទនោះ។ ដើម្បីបំពេញពាក្យបានត្រឹមត្រូវ យើងត្រូវអានពាក្យទាំងអស់ និងអត្ថបទនេះ ឱ្យយល់ជាមុនសិន។**

| | | |
|---|---|---|
| **គ្រូ** | ▪ | **ប្រាប់សិស្សថាគ្រូអានពាក្យក្នុងប្រអប់ទី១ ដោយមិនប្រកប។ គ្រូអាន ល្អណាស់។** |
| **គ្រូនិងសិស្ស** | ▪ | គ្រូនាំសិស្សអានពាក្យក្នុងប្រអប់ទី២ **រៀន** ។ |
| **សិស្ស** | ▪ | អានពាក្យក្នុងប្រអប់ទី៣ **លោកអ៊ំ** ប្រអប់ទី៤ **អរគុណ** និងទី៥ **ជម្រាបសួរ**។<br>គ្រូជួយកែតម្រូវ បើចាំបាច់។ |

គ្រូប្រាប់សិស្សថា **យើងនឹងរៀនបំពេញពាក្យ ។**

| | | |
|---|---|---|
| **គ្រូ** | ▪ | **សរសេរពាក្យ ជម្រាបសួរ លើក្ដារខៀន ដោយប្រាប់សិស្សថា ពាក្យនេះត្រូវបំពេញក្នុងជួរទី២ នៃអត្ថបទសន្ទនា។ វាជាសម្ដីរបស់សុភី។ សុភី) :.... ជម្រាបសួរ លោកអ៊ំ។........** |
| **គ្រូនិងសិស្ស** | ▪ | គ្រូនាំសិស្ស បំពេញជួរទី៣ ក្នុងល្បះទី១ ជាមួយពាក្យ **អរគុណ**។ ឪពុកបូណា : បាទ! **អរគុណ............ក្មួយ។.........** |
| **សិស្ស** | ▪ | អានល្បះដែលនៅសល់ ហើយបំពេញល្បះដែលនៅសល់ទាំងនោះ។ ល្បះទី២ ជួរទី៣ តើក្មួយ...................(រៀន)..........ថ្នាក់ទីប៉ុន្មាន? |

- ជួរទី៤ : បាស !............ (លោកអ៊ំ)............ខ្ញុំរៀនថ្នាក់ទី២។
- ជួរទី៥: ឪពុកបូណា : ................ ល្អណាស់.............! អ៊ំសុខសប្បាយទេ។
  គ្រូសរសេរពាក្យទាំងនោះលើក្ដារខៀនតាមលំដាប់ : ជម្រាបសួរ អរគុណ រៀន លោកអ៊ំ ល្អណាស់។ សិស្សផ្ទៀងផ្ទាត់ និងកែតម្រូវ។
- សិស្សអានជាបុគ្គល។
- សិស្សចម្លងអត្ថបទសន្ទនាពេញលេញចូលក្នុងសៀវភៅរៀងៗខ្លួន។

**គ- ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "រីករាយ"**

- សូមមើលលំនាំបង្រៀនអក្សរផ្ចង់ ត្រង់សេចក្ដីណែនាំក្នុងសៀវភៅសិក្សាគោល។

**៤- កិច្ចការផ្ទះ** ៣ នាទី

គ្រូដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។

## ៣.១១ លំនាំបង្រៀនស្ដាប់

| ក. មេរៀនទី ៨ | ការស្ដាប់ | ក្អែកការកូន (ថ្ងៃទី១) | ៨០ នាទី |
|---|---|---|---|

**១- លំនឹងថ្នាក់ និងរំឭកមេរៀន** ៧ នាទី

◎ រំឭកពាក្យ

ក្ដារខៀន

៧ នាទី

គ្រូរំឭកពាក្យដែលបានរៀនរួច ២ ទៅ ៣ ពាក្យ។

**២- ការរៀនវាក្យសព្ទ** ១០ នាទី

◎ យល់ន័យនិងប្រើប្រាស់ពាក្យ

សៀវភៅសិក្សាគោល

១០ នាទី

សេចក្ដីផ្ដើម : **ជាបន្តយើងនឹងរៀនពីន័យរបស់ពាក្យ និងហ្វឹកហាត់ប្រើប្រាស់ពាក្យមួយចំនួនដែលមាននៅក្នុងអត្ថបទ។**

**ក- អាស្រ័យ**

| | |
|---|---|
| **គ្រូ** | - សរសេរពាក្យ **អាស្រ័យ** លើក្ដារខៀន រួចអាន និងពន្យល់ន័យ<br>- ពាក្យ **អាស្រ័យ** មានន័យថា **ទីនៅ ទីជ្រក** ។ ឧ. សត្វជ្រឹងអាស្រ័យលើចុងត្នោត។ |
| **គ្រូនិងសិស្ស** | - អានពាក្យ **អាស្រ័យ** ព្រមគ្នា។<br>- គ្រូសួរសំណួរថា **តើកូនដឹងទេ សត្វចាបវាអាស្រ័យនៅឯណា? (លើចុងឈើ)** ។<br>- គ្រូនិងសិស្សថាឡើងវិញទាំងអស់គ្នា : **សត្វចាបអាស្រ័យនៅលើចុងឈើ។** |
| **សិស្ស** | - គ្រូចង្អុលពាក្យឱ្យសិស្សអានរួចបង្កើតល្បះដោយប្រើពាក្យ **អាស្រ័យ** ជាដៃគូ។ |

ខ- ពល

| | | |
|---|---|---|
| **គ្រូ** | - | សរសេរពាក្យ **ពល** លើក្ដារខៀន រួចអាន និងពន្យល់ន័យ ពាក្យ **ពល** មានន័យថា **សេនា ទាហាន**។ ឧ. មេទ័ពកំពុងដើរត្រួតពល។ |
| **គ្រូនិងសិស្ស** | - | អានពាក្យ **ពល** ព្រមគ្នា។<br>- គ្រូសួរថា **តើនរណាជាអ្នកការពារទឹកដី?(ពលទាហាន)**។ គ្រូសួរបន្ត **តើពលទាហានធ្វើអ្វី? (ការពារទឹកដី)**<br>- គ្រូនិងសិស្សថាល្បះរួមគ្នា : **ពលទាហានការពារទឹកដី។** |
| **សិស្ស** | - | គ្រូចង្អុលពាក្យឱ្យសិស្សអាន រួចបង្កើតល្បះដោយប្រើពាក្យ **ពល** ជាដៃគូ។ |

## ៣- ការស្ដាប់ ⏱ ៦០នាទី

◎ សិស្សមានបំណិនស្ដាប់ ចងចាំ ត្រិះរិះ និងសង្ខេបរឿង

🗐 សៀវភៅសិក្សាគោល

🕒 ៦០នាទី

### ៣.១ ការស្ដាប់រឿង

#### ក- មុនពេលស្ដាប់

- គ្រូ: សួរសំណួរបំផុស **តើកូនធ្លាប់ស្ដាប់រឿងនិទានពីសត្វអ្វីខ្លះ?** កូនៗបើកសៀវភៅគោល ទំព័រទី៥០ ហើយមើលរូបភាពក្នុងអត្ថបទនេះ។ **តើកូនៗឃើញអ្វីខ្លះក្នុងរូបភាពនេះ?**
- សិស្ស : សិស្ស ២ ទៅ ៣ នាក់ឆ្លើយ។ គ្រូទទួលចម្លើយសិស្ស។
- គ្រូ : អត្ថបទរឿងនេះមានចំណងជើង ក្អែកការកូន ។ **តើអ្នកទាំងអស់គ្នាគិតថា រឿងនេះនិយាយអំពីអ្វី?**
- សិស្ស : សិស្ស ២ ទៅ ៣ នាក់ឆ្លើយ។ គ្រូទទួលចម្លើយ។
- គ្រូ៖ គ្រូនឹងនិទានរឿងនេះឱ្យកូនស្ដាប់ ថា**តើការទស្សន៍ទាយរបស់កូនត្រឹមត្រូវឬទេ**។

#### ខ- អំឡុងពេលស្ដាប់

- គ្រូ : គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សជាមុនសិន។
- គ្រូ : ពេលនេះគ្រូនិទានរឿង សូមកូនៗស្ដាប់ដោយយកចិត្តទុកដាក់។ និទានរឿងនៅទំព័រ XXI ពីដើមដល់ចប់ក្នុងល្បឿនសមស្រប ដោយលើកដាក់សំឡេងគោរពតាមសញ្ញាសម្ព័ន្ធ ធ្វើកាយវិការ និងប្រើទឹកមុខសមស្របទៅនឹងសាច់រឿង។
- សិស្ស: ស្ដាប់ដោយយកចិត្តទុកដាក់។

#### គ- ក្រោយពេលស្ដាប់

- គ្រូ សួរថា **តើរឿងនេះដូចនឹងការទស្សន៍ទាយរបស់កូនៗដែរ ឬទេ? តើរឿងនេះនិយាយអំពីអ្វី?**
- សិស្ស : ២ ទៅ ៣ នាក់ឆ្លើយ។
- គ្រូ : សម្របសម្រួលចម្លើយ (ចម្លើយអាចមានលើសពីមួយ)។

### ៣.២- ការសួរសំណួរ

- គ្រូសួរសំណួរម្តងមួយៗដោយទុកពេលឱ្យសិស្សគិត។ បើសិស្សឆ្លើយសំណួរណាមួយមិនបាន គ្រូត្រូវនិទានរឿងត្រង់ផ្នែកនោះឱ្យសិស្សស្តាប់ឡើងវិញ ។

**សំណួរ**

១. តើស្តេចក្អែករៀបការកូននៅកន្លែងណា?

២. ហេតុអ្វីបានជាអណ្តើកមកដល់ក្រោយគេ?

៣. ហេតុអ្វីបានជាអណ្តើកធ្លាក់ចុះមកដល់ដីវិញ?

- គ្រូសួរសំណួរផ្សារភ្ជាប់បទពិសោធពីជីវភាពរស់នៅទៅនឹងដំណើររឿង។ **៤. តើកូនធ្លាប់ចូលរួមក្នុងពិធីការដែរឬទេ? តើកូនឃើញអ្វីខ្លះ?**

### ៣.៣ ការរៀបលំដាប់ព្រឹត្តិការណ៍រឿងឡើងវិញ

| | |
|---|---|
| **គ្រូ** | - រឿងក្អែកការកូន មានព្រឹត្តិការណ៍ចំនួន៤ ដែលមិនទាន់មានលំដាប់លំដោយនៅឡើយ។ យើងត្រូវរៀបលំដាប់លំដោយព្រឹត្តិការណ៍ដោយបង់លេខ ពីលេខ១ដល់លេខ៤។ ដើម្បីរៀបលំដាប់ព្រឹត្តិការណ៍រឿងឱ្យបានត្រឹមត្រូវ ដំបូងយើងត្រូវអានល្បះជាមុន។ គ្រូនឹងអានល្បះហើយបង់លេខជាគំរូ។ យើងបើកសៀវភៅសិក្សាគោលទំព័រទី៥០។<br>- គ្រូអានល្បះទាំងអស់ និងប្រាប់ឱ្យសិស្សយកដៃចង្អុលតាមល្បះដែលគ្រូអាន។<br>- អានល្បះទី១ ក្នុងល្បឿនសមស្របនិងលើកដាក់សំឡេង។<br>- ប្រាប់សិស្សថា ល្បះនេះគឺជាព្រឹត្តិការណ៍ចុងបញ្ចប់នៃរឿង។<br>- គ្រូប្រាប់សិស្ស ដូចនេះយើងបង់លេខរៀងទី៤។<br>- គ្រូសរសេរលេខ៤ ក្នុងប្រអប់លើគេ។ |
| **គ្រូនិងសិស្ស** | - អានល្បះទី២ទាំងអស់គ្នា។<br>- ទុកពេលឱ្យសិស្សគិតបន្តិច។<br>- **ល្បះនេះជាការចាប់ផ្តើមនៃរឿង។ ដូចនេះយើងត្រូវបង់លេខ១។**<br>- គ្រូសរសេរលេខ១ ក្នុងប្រអប់បន្ត ។ |
| **សិស្ស** | - សិស្សអានល្បះទី៣និងទី៤ជាដៃគូ ដើម្បីបង់លេខក្នុងសៀវភៅកិច្ចការ។<br>- គ្រូដើរស្តាប់និងសិស្ស។ គ្រូឱ្យសិស្ស២ឬ៣នាក់ពីដៃគូផ្សេងគ្នាចែករំលែកចម្លើយ។<br>- សិស្សឆ្លើយ **ល្បះទី៣គឺបង់លេខ ៣ ល្បះលេខ៤ បង់លេខ២។**<br>- គ្រូថា **ត្រឹមត្រូវហើយ ។**<br>- គ្រូសរសេរលេខ៣ ក្នុងប្រអប់ទី៣ លេខ៤ក្នុងប្រអប់ទី២ ។<br>- សិស្សសរសេរលេខ៣ ក្នុងប្រអប់ទី៣ លេខ៤ ប្រអប់ទី២ក្នុងសៀវភៅកិច្ចការ។ |
| **សិស្ស** | - សិស្សអានល្បះទាំង៤ដែលបានរៀបតាមលំដាប់លំដោយឡើងវិញ។ |

៣.៤ សិស្សហ្វឹកហាត់និទានរឿង

- គ្រូសួរសំណួរបញ្ជាក់ដើម្បីជួយសិស្សក្នុងការនិទានរឿងឡើងវិញ។ ឧ. តើស្តេចក្អែកការកូននៅឯណា? តើអ្នកណាខ្លះមកចូលរួមពិធីរៀបការកូនស្តេចក្អែក?
- គ្រូឱ្យសិស្សធ្វើការជាដៃគូ ក្រុមតូច សង្ខេបរឿងប្រាប់គ្នា។ ឱ្យសិស្ស១ ឬ២នាក់សង្ខេបរឿងឡើងវិញ។

**៤- កិច្ចការផ្ទះ** ◷ ៣នាទី

គ្រូដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។

| ខ. មេរៀនទី ៣៨ | ការស្តាប់ | ក្អែកការកូន (ថ្ងៃទី២) | ◷ ៤០ នាទី |
|---|---|---|---|

**១- លំនឹងថ្នាក់ និងរំឭកមេរៀន** ◷ ៧ នាទី

◎ រំឭកពាក្យ

🗐 ក្តារឆ្នួន ឬប័ណ្ណពាក្យ

◷ ៧ នាទី

គ្រូរំឭកវាក្យសព្ទដែលបានរៀនរួចចំនួន២-៣ពាក្យដោយគ្រូសរសេរពាក្យទាំងនោះម្តងមួយៗ រួចឱ្យសិស្សពន្យល់ន័យនៃពាក្យនោះ រួចបង្កើតល្បះដោយផ្ទាល់មាត់។

**២- រំឭកវាក្យសព្ទ** ◷ ៧ នាទី

◎ យល់ន័យនិងប្រើប្រាស់ពាក្យ

🗐 សៀវភៅសិក្សាគោល

◷ ៧ នាទី

សេចក្តីផ្តើម : ជាបន្តយើងនឹងរំឭកពីន័យនៃពាក្យមួយចំនួនដែលបានរៀនពីថ្ងៃមុន។

ក- អាស្រ័យ

| | |
|---|---|
| គ្រូ | ▪ **តើពាក្យ អាស្រ័យ មានន័យដូចម្តេច?** |
| សិស្ស | ▪ ចែករំលែក២ឬ៣នាក់ ។ **ពាក្យ អាស្រ័យ មានន័យថា ទីនៅ ទីជ្រក** ។ |
| គ្រូ | ▪ **តើអ្នកណាអាចបង្កើតល្បះមួយដោយប្រើប្រាស់ពាក្យ អាស្រ័យ បាន?** |
| សិស្ស | ▪ ចែករំលែក២ឬ៣នាក់។ |

ខ- ពល

| | |
|---|---|
| គ្រូ | ▪ **តើពាក្យ ពល មានន័យដូចម្តេច?** |
| សិស្ស | ▪ ចែករំលែក២ឬ៣នាក់។ **ពាក្យ ពល មានន័យថា មានន័យថា សេនា ទាហាន។** |
| គ្រូ | ▪ **តើអ្នកណាអាចបង្កើតល្បះមួយដោយប្រើប្រាស់ពាក្យ ពល បាន?** |
| សិស្ស | ▪ ចែករំលែក២ឬ៣នាក់។ |

## ៣- ការស្ដាប់រឿងឡើងវិញ ២០ នាទី

◎ ហ្វឹកហាត់ស្ដាប់

សៀវភៅសិក្សាគោល

២០នាទី

៣.១-ការស្ដាប់រឿងលើកទី២

**ក- មុនពេលស្ដាប់**

| | |
|---|---|
| **គ្រូ** | ▪ **ម្សិញមិញយើងបានស្ដាប់រឿងដែលមានចំណងជើងថា «ក្អែកការកូ» ។ តើកូនៗណានៅចាំរឿងនេះនិយាយអំពីអ្វី?** |
| **សិស្ស** | ▪ សិស្ស ២ ទៅ ៣ នាក់ឆ្លើយ។ គ្រូសម្របសម្រួលចម្លើយសិស្ស។ |

**ខ- អំឡុងពេលស្ដាប់**

| | |
|---|---|
| **គ្រូ** | ▪ **ដើម្បីឱ្យយល់កាន់តែច្បាស់ ថ្ងៃនេះ យើងនឹងស្ដាប់រឿងនេះឡើងវិញម្ដងទៀត។ ដូចមុនដែរ គ្រូជាអ្នកនិទាន កូនៗចាំស្ដាប់ ដោយយកចិត្តទុកដាក់។**<br>▪ **និទានរឿងពីដើមដល់ចប់ដោយល្បឿនសមរម្យ និងលើកដាក់សំឡេងតាមសញ្ញាសម្គាល់ ធ្វើកាយវិការ និងប្រើទឹកមុខសមស្របនឹងសាច់រឿង។** |
| **សិស្ស** | ▪ ស្ដាប់ដោយយកចិត្តទុកដាក់។ |

**គ- ក្រោយពេលស្ដាប់**

- គ្រូសួរសំណួរទី១: **ហេតុអ្វីបានជាអណ្ដើកមិនចងចាំសម្ដីពស់ដែលប្រាប់ថាខាំកន្ទុយឱ្យជាប់?**
  - សិស្សនិយាយប្រាប់គ្នានូវចម្លើយជាដៃគូទៅវិញទៅមក តាមការយល់ឃើញរបស់ខ្លួន។
  - គ្រូឱ្យសិស្ស ១ ទៅ ២ គូរចែករំលែកចម្លើយ។ គ្រូសម្របសម្រួលសម្លើយរបស់សិស្ស។
- គ្រូសួរសំណួរទី២: **ប្រសិនបើកូនជាអណ្ដើក តើកូននៅតែប្រថុយខាំកន្ទុយពស់ឡើងដើមត្នោតដែរទេ? ហេតុអ្វី?**
  - សិស្សនិយាយប្រាប់គ្នានូវចម្លើយជាដៃគូទៅវិញទៅមក តាមការយល់ឃើញរបស់ខ្លួន។
  - គ្រូឱ្យសិស្ស ១ ទៅ ២ គូរចែករំលែកចម្លើយ។ គ្រូសម្របសម្រួលសម្លើយរបស់សិស្ស។
- គ្រូសួរសំណួរទីបី: **តើកូនៗធ្លាប់បានឃើញអ្វីខ្លះក្នុងពិធីការញាតិមិត្ត?**
  - សិស្សនិយាយប្រាប់គ្នានូវចម្លើយជាដៃគូទៅវិញទៅមក តាមការយល់ឃើញរបស់ខ្លួន។
  - គ្រូឱ្យសិស្ស ១ ទៅ ២ គូចែករំលែកចម្លើយ ។ យ។ គ្រូសម្របសម្រួលសម្លើយរបស់សិស្ស។

៣.២ - ការសម្ដែងតួ

| | |
|---|---|
| **គ្រូនិងសិស្ស** | - **សង្ខេបរឿងដោយគ្រូចាប់ផ្ដើមល្បះដំបូង។ ១. ស្ដេចក្អែកអញ្ជើញមិត្តជាច្រើនស៊ីការកូននៅលើចុងត្នោត។ រួចសួរសំណួរប្រដេញដើម្បីឱ្យសិស្សឆ្លើយខ្លឹមសាររឿងដោយសង្ខេប។**<br>- **គ្រូនាំសិស្សសម្ដែងតួ។** |

| | | |
|---|---|---|
| សិស្ស | - | សិស្សសម្ដែងតួជាដៃគូ ឬជាក្រុម។ |

## ៤- សំណេរ ⏱ ៤៣ នាទី

◎ ហ្វឹកហាត់បំពេញល្បះ សរសេរពាក្យ និងល្បះ

🗐 សៀវភៅសិក្សាគោល

🕒 ៤៣នាទី

**ក-សរសេរតាមអានត្រួតពិនិត្យពាក្យ និងល្បះ**

| | | |
|---|---|---|
| គ្រូ | - | គ្រូអានពាក្យ **ភ្ញៀវ បម្រុង ផ្សំផ្គុំ អណ្ដើក កន្ទុយ អណ្ដើករបូតមាត់ពីកន្ទុយពស់ធ្លាក់ខ្ពោកមកលើដី។** |
| គ្រូនិងសិស្ស | - | គ្រូ និងសិស្សអានពាក្យ **ភ្ញៀវ បម្រុង ផ្សំផ្គុំ អណ្ដើក កន្ទុយ អណ្ដើករបូតមាត់ពីកន្ទុយពស់ធ្លាក់ខ្ពោកមកលើដី។** |
| សិស្ស | - | សិស្សអានពាក្យ **ភ្ញៀវ បម្រុង ផ្សំផ្គុំ អណ្ដើក កន្ទុយ អណ្ដើករបូតមាត់ពីកន្ទុយពស់ធ្លាក់ខ្ពោកមកលើដី។** |

| | | |
|---|---|---|
| គ្រូ | - | គ្រូចាត់តាំងសិស្ស២នាក់ថាតាមក្រោយគ្រូ **ភ្ញៀវ** ដោយសិស្សម្នាក់ថាមុននឹងខ្លួនសរសេរ ហើយម្នាក់ទៀតថាបន្ទាប់ពីខ្លួនសរសេររួច។ |
| | - | គ្រូហៅពាក្យ **ភ្ញៀវ** សិស្សទី១ថា **ភ្ញៀវ**(មុនសរសេរ) សិស្សទី២ថា **ភ្ញៀវ**(សរសេររួច)។ |
| សិស្ស | - | សិស្សសរសេរពាក្យ **ភ្ញៀវ** ចូលសៀវភៅ។ |
| | - | គ្រូហៅ **បម្រុង ផ្សំផ្គុំ អណ្ដើក កន្ទុយ អណ្ដើករបូតមាត់ពីកន្ទុយពស់ធ្លាក់ខ្ពោកមកលើដី** ម្ដងមួយៗរហូតដល់ចប់ ដោយអនុវត្តតាមលំនាំពាក្យ **ភ្ញៀវ**។ |
| | - | គ្រូអានពាក្យ ឃ្លា ឱ្យសិស្សផ្ទៀងផ្ទាត់ដើម្បីកែតម្រូវ |
| | - | សិស្សប្រមូលកិច្ចការឱ្យគ្រូដាក់ពិន្ទុ។ |

**ខ- ជ្រើសរើសពាក្យក្នុងប្រអប់មកបំពេញល្បះ**

◎ ពន្យល់អត្ថន័យ និងការប្រើប្រាស់ពាក្យ

🗐 សៀវភៅសិក្សាគោល

🕒 ១៥នាទី

| | | |
|---|---|---|
| គ្រូ | - | **ឱ្យសិស្សបើកសៀវភៅទំព័រទី ៥១ សំណេរ ខ** |
| | - | **យើងនឹងយកពាក្យ ក្នុងប្រអប់ កន្ទុយ អណ្ដើក ភ្ញៀវ ស្នាម ក្អែក ហាម ខំរារ ឃើញ មកបំពេញល្បះ ឱ្យបានត្រឹមត្រូវ។ ចាំមើលគ្រូធ្វើបង្ហាញក្នុងការបំពេញល្បះទី១។** |
| | - | **អានល្បះទី១ ឮៗ : មានស្ដេច... មួយចាត់ឱ្យពួកពលហើរហៅ ... ទាំងអស់មកស៊ីការកូន។** |
| | - | **អានពាក្យក្នុងប្រអប់ : កន្ទុយ អណ្ដើក ភ្ញៀវ ស្នាម ក្អែក ហាម ខំរារ ឃើញ ។** |
| | - | **ប្រាប់សិស្សថា : ពាក្យដែលត្រូវយកមកបំពេញចន្លោះទី១គឺ ក្អែក ចន្លោះទី២គឺ ភ្ញៀវ។** |

| | |
|---|---|
| | - អានល្បះឡើងវិញ : មានស្តេចក្អែកមួយចាត់ឱ្យពួកពលហើរហៅភ្ញៀវទាំងអស់មកស៊ីការកូន។<br>- គ្រូសរសេរពាក្យ : ក្អែក ភ្ញៀវ។ |
| គ្រូនិងសិស្ស | - គ្រូ : **យើងនឹងបំពេញល្បះទី២ទាំងអស់គ្នា។ ដើម្បីបំពេញបាន យើងត្រូវអានល្បះដែលមិនទាន់ពេញលេញជាមុន រួចអានពាក្យក្នុងប្រអប់តាមក្រោយ។**<br>- គ្រូនិងសិស្សអាន: **ស្តេចអណ្តើក......ទៅនឹងគេដែរ តែទៅដល់ក្រោយគេក៏ប្រទះ ......ពស់កំពុងលូនបម្រុងនឹងទៅស៊ីការកូនស្តេចក្អែកដែរ។**<br>- គ្រូនិងសិស្សអានពាក្យក្នុងប្រអប់ : **កន្ទុយ អណ្តើក ភ្ញៀវ ស្នាម ក្អែក ហាម ខំវារ ឃើញ។**<br>- គ្រូនិងសិស្សអានល្បះទី២ឡើងវិញ : **ស្តេចអណ្តើកខំវារទៅនឹងគេដែរ តែទៅដល់ក្រោយគេក៏ប្រទះ ឃើញពស់កំពុងលូនបម្រុងនឹងទៅស៊ីការកូនស្តេចក្អែកដែរ។**<br>- គ្រូសរសេរពាក្យ **ខំវារ ឃើញ** លើក្តារខៀន ហើយសិស្សសរសេរចូលក្នុងសៀវភៅ។ |
| សិស្ស | - គ្រូ: **កូនៗអាន និងជ្រើសរើសពាក្យមកបំពេញល្បះទី៣ ដៃគូ រួចសរសេរចម្លើយដាក់ក្នុងសៀវភៅ។**<br>- សិស្ស: អានល្បះទី៣ និងរកពាក្យមកបំពេញជាដៃគូ។<br>- គ្រូ៖ ហៅសិស្ស ១ ទៅ ២នាក់ ចែករំលែកចម្លើយរបស់ពួកគេ។<br>- គ្រូថាចម្លើយត្រឹមត្រូវវិញ: **ពាក្យដែលត្រូវបំពេញគឺ អណ្តើក ហាម។**<br>- សិស្សអានល្បះទី៣ឡើងវិញទាំងអស់គ្នា : **ពេលនោះ ពស់ក៏ឱ្យស្តេចអណ្តើកខាំកន្ទុយ ហើយលូនយោងឡើងទៅលើដោយហាម ឱ្យប្រយ័ត្នមាត់។**<br>- សិស្សសរសេរពាក្យ **អណ្តើក ហាម** ហើយគ្រូសរសេរវាលើក្តារខៀន។ |
| សិស្ស | - គ្រូ: **កូនៗអាន និងជ្រើសរើសពាក្យមកបំពេញល្បះទី៤ ដៃគូ រួចសរសេរចម្លើយដាក់ក្នុងសៀវភៅ។**<br>- សិស្ស: អានល្បះទី៤ និងរកពាក្យមកបំពេញជាដៃគូ។<br>- គ្រូ៖ ហៅសិស្ស ១ ទៅ ២នាក់ ចែករំលែកចម្លើយរបស់ពួកគេ។<br>- គ្រូថាចម្លើយត្រឹមត្រូវវិញ: **ពាក្យដែលត្រូវបំពេញគឺ កន្ទុយ ស្នាម។**<br>- សិស្សអានល្បះទី៣ឡើងវិញទាំងអស់គ្នា : **មួយរំពេចនោះ អណ្តើកក៏របូតមាត់ពីកន្ទុយពស់ ធ្លាក់ ខ្ទោកមកលើដីបណ្តាលឱ្យស្រាំស្នូកនៅជាប់ស្នាមរហូតមកដល់សព្វថ្ងៃនេះ។**<br>- សិស្សសរសេរពាក្យ **កន្ទុយ ស្នាម** ហើយគ្រូសរសេរវាលើក្តារខៀន។ |

គ- បំពេញល្បះតាមរូបភាព

រូបភាពទី១

- គ្រូសួរ តើលំហាត់នេះចង់ឱ្យកូនធ្វើអ្វី?(តែងល្បះតាមរូបភាព)។ គ្រូឱ្យសិស្សសង្កេតរូបភាពនីមួយៗ។ តើនេះជារូបអ្វី? ។ រួចសួរសំណួរប្រដេញ តើពស់កំពុងធ្វើអ្វី? នៅឯណា? សិស្សគិត និងឆ្លើយ។ (លូន)
- គ្រូឱ្យសិស្សគិត និងថាឮ **លូន** មាន **ល ូ ន** រួចសរសេរលើក្ដារឆ្នួន។ គ្រូសរសេរលើក្ដារខៀនរួចកែតម្រូវចម្លើយ។
- សិស្សតែងល្បះដោយផ្ទាល់មាត់ទាក់ទងរូបភាពទី១។ (ពស់កំពុងលូន)
- គ្រូឱ្យសិស្សសរសេរល្បះចូលសៀវភៅ។

**រូបភាពទី២**

- ឱ្យសិស្សនិយាយផ្ទាល់មាត់តាមរូបភាព និងសរសេរបំពេញក្នុងល្បះ ជាដៃគូ ឬក្រុមតូច។
- គ្រូដើរសម្របសម្រួលចម្លើយសិស្ស។ ឱសិស្ស២ ឬ៣នាក់ចែករំលែកចម្លើយ។

**៤- កិច្ចការផ្ទះ** ◷ ៣ នាទី

- គ្រូដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។

## ៤. សន្និដ្ឋាន

ដូចនេះលោកគ្រូអ្នកគ្រូឧទ្ទេសតោងចងចាំថា ការអនុវត្តការបង្រៀនភាសាខ្មែរថ្នាក់ទី១ និងទី២គឺត្រូវប្រើប្រាស់ឯកសារដូចជា សៀវភៅសិក្សាគោល សៀវភៅជំនួយសិស្ស និងសៀវភៅណែនាំការបង្រៀនភាសាខ្មែរថ្នាក់ទី១ និងទី២ ហើយចាប់ផ្ដើមការបង្រៀនទៅតាមលំណែនាំដែលមាននៅក្នុងកាលវិភាគ និងម៉ោងសិក្សាលម្អិតក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនភាសាខ្មែរថ្នាក់ទី១ និងទី២។ កត្តាសំខាន់ គ្រូឧទ្ទេសត្រូវដឹកនាំគរុសិស្សអនុវត្តសាកល្បងសកម្មភាពបង្រៀន ទៅតាមសកម្មភាពក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១ និងទី២ នៅក្នុងម៉ោងបង្រៀនដើម្បីឱ្យមានភាពស្ទាត់ជំនាញមុនពេលចុះកម្មសិក្សា។

★ **សម្រាប់ថ្នាក់ទី៣៖ គ្រូឧទ្ទេសត្រូវអនុវត្តតាមលំនាំបង្រៀនដែលមាននៅក្នុងសៀវភៅសិក្សាគោល។**

## ✳ ស្វែងយល់បន្ថែមលើ ការប្រកប និងអក្ខរាវិរុទ្ធ

### ១. ការប្រកប

ជាការផ្សំសួររវាងព្យញ្ជនៈនឹងស្រៈបង្កើតបានជាសួរថ្មីមួយទៀតក្នុងការអានព្យាង្គ ឬពាក្យ។ ការប្រកបជួយសិស្សឱ្យចេះផ្សំ និងញែកសួរបានត្រឹមត្រូវ។

**ឧទាហរណ៍: ដើរ**

- ដើរ អានថា ដ ើ ដើ → ដើ នឹង រ → ដើរ

### ២. អក្ខរាវិរុទ្ធ

ជាការរាប់តួអក្សរក្នុងព្យាង្គ ឬពាក្យតាមលំដាប់ទីតាំងសូររបស់តួអក្សរនីមួយៗ។ ការធ្វើអក្ខរាវិរុទ្ធ ជួយសិស្សឱ្យសរសេរបានត្រឹមត្រូវ។

**ឧទាហរណ៍:**

- ○ កា (មាន)តួអក្សរ ក ស្រៈា(អា)
- ○ គា (មាន)តួអក្សរ គ ស្រៈា(អា)
- ○ ដើរ (មាន)តួអក្សរ ដ ស្រៈ ើ (អើ) និង រ

★ **ចំណាំ ៖** ចំពោះពាក្យចំណាំ ពាក្យកម្ចី ដូចជា៖

**ក. ទំនាញសូរ** : ចម្លើយ សាលា តម្លៃ បន្លែ បន្លា ជំហរ អារាម កម្រ ក្រមា..ឧ.ប្រកប : ចម្លើយ ច និង ម ចំ ល ជា ឡ ឡ អើ ឡើ និង យ ឡើយ [ចំ-ឡើយ] (ក្នុងករណីនេះគួរមិនបាច់នាំប្រកបទេ គួរនាំ អានតែម្ដង ចំ ឡើយ, សា ឡា, តំ ឡៃ,... )

ឧ.អក្ខរាវិរុទ្ធ: ចម្លើយ មានអក្សរ ច ម ជើង ្ល ស្រៈ ើ និង យ

**ខ. ពាក្យប្រកបនឹង រ ហើយមិនអាន** ដូចជា កក្កុរ ការ ដែរ...

ឧ. ប្រកប កក្កុរ អានថា ក ក អុ ក្កុ ក្កុ និង រ ក្កុ [ក - ក្កុ]

ឧ. អក្ខរាវិរុទ្ធ: កក្កុរ មានតួអក្សរ ក ក ស្រៈ ុ និង រ

**គ. ចំពោះពាក្យសរសេរផ្សេងអានផ្សេង**

ខ្មុរ និរតី បិតា ហេតុ កុរ ធីតា ខេត្ត ធម្មជាតិ ទមិឡ ចេតិយ ព្រហ្ម ... មិនបាច់ប្រកបទេ ត្រូវនាំកុមារអានតាមសូរដើមតែម្ដង។

ឧ. ប្រកប បិតា អានថា [ បិ - ដា ] . ខេត្ត អានថា [ខែត ] . ចេតិយ [ចេដី ឬ ចៃដី]

ឧ. អក្ខរាវិរុទ្ធ បិតា មានតួអក្សរ ប ស្រៈ ិ ត ស្រៈ ា

**ឃ. ការធ្វើអក្ខរាវិរុទ្ធ** មិនគួរថាបណ្ដើរសរសេរបណ្ដើរនោះទេ គួរឱ្យកុមារថាតួអក្សររួចរាល់ ទើបចាប់ផ្ដើមសរសេរជាក្រោយតាមទិសសំណេរពីឆ្វេងទៅស្ដាំ។

ឧ. កកេរ មានតួអក្សរ ក ក ស្រៈ េ និង រ រួចផ្ដើមសរសេរ កកេរ។ ធ្វើបែបនេះ ដើម្បីចៀស វាងការច្រឡំទីតាំងតួអក្សរចំពោះពាក្យមួយចំនួនដែលមានស្រៈពីមុខមានស្រៈ េ, ៃ.

**៣. របៀបសរសេរភាសាខ្មែរដោយដៃ** Cambodian System Of Writing

ក្នុងការសរសេរភាសាខ្មែរ គឺយើងត្រូវសរសេររៀងតាមលំដាប់ពីឆ្វេង ទៅស្ដាំជានិច្ច។ ចំពោះជើង ្រ ត្រូវសរសេរឱ្យធំនៅពេលព្យញ្ជនៈខ្លះមានជើងមួយទៀត ឧ. ន្ត្រ ញ្ជ្រ ...។

(តាមឯកសារ វិជ្ជាខេមរភាសា បោះពុម្ពឆ្នាំ ១៩៧០)

| | | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|---|
| ១. | ដៃ | ◌ៃ | ដ | ដៃ | | |
| ២. | ប្ដី | ប | ប្ដ | ប្ដី | | |
| ៣. | ស្ដាប់ | ស | សា | ស្ដា | ស្ដាប | ស្ដាប់ |
| ៤. | បង្ខូច | ប | បង | បង្ខ | បង្ខូ | បង្ខូច |
| ៥. | បង្កើត | ប | ប ◌េ | បងើ | បង្កើ | បង្កើត |
| ១. | ស្រី | ស | ស្រ | ស្រី | | |
| ២. | ច្រើន | ◌េ | ចេ | ច្រេ | ច្រើ | ច្រើន |
| ៣. | សម្រាប់ | ស | សមា | សម្រា | សម្រាប | សម្រាប់ |
| ៤. | តន្ត្រី | ត | តន | តន្ត | តន្ត្រ | តន្ត្រី |
| ១. | ប្រុស | ប | ប្រ | ប្រុ | ប្រុស | |
| ២. | ត្រូវ | | ត | ត្រ | ត្រូ | ត្រូវ |
| ៣. | ប្រៀប | ◌េ | បេ | ប្រេ | ប្រៀ | ប្រៀប |
| ៤. | គ្រឿង | ◌េ | គេ | គ្រេ | គ្រឿ | គ្រឿង |
| ១. | បញ្ចោញ | ប | ប ◌េ | បពោ | បញ្ចោ | បញ្ចោញ |
| ២. | សង្គ្រាម | ស | សងា | សង្គា | សង្គ្រា | សង្គ្រាម |
| ៣. | សង្គ្រោះ | ស | ស ◌េ | សង្គោ | សង្គ្រោ | សង្គ្រោះ |
| ៤. | កញ្ជ្រោក | ក | ក ◌េ | កញ្ជោ | កញ្ជ្រោ | កញ្ជ្រោក |

# មេរៀនទី៣
# វិធីបង្រៀនថ្នាក់ទី៤ ទី៥ ទី៦

## ១. វត្ថុបំណងមេរៀន

- ផ្ដល់នូវលំនាំបង្រៀនភាសាខ្មែរកម្រិតខ្ពស់នៅបឋមសិក្សាមួយចំនួន ដែលពាក់ព័ន្ធទៅនឹងសមត្ថភាពទាំង៤។
- ស្វែងយល់ពីវិធីមួយចំនួន ដែលគាំទ្រដល់លំនាំបង្រៀនសមត្ថភាពនីមួយៗ ព្រោះជាគន្លឹះបន្ថែមជួយគ្រូបង្រៀនភាសាទទួលបានជោគជ័យ

## ២. ខ្លឹមសារមេរៀន

### ២.១ លំនាំបង្រៀនសមត្ថភាពស្ដាប់

#### ២.១.១ ការដឹកនាំសកម្មភាពស្ដាប់ទៅតាមដំណាក់ធំៗបី៖

**ក. មុនស្ដាប់ ឬការត្រៀមស្ដាប់**: គឺជាដំណាក់ត្រៀមខ្លួនដើម្បីស្ដាប់ ក្នុងនោះគេត្រូវ៖

- បង្ហាញមូលហេតុ និងគោលបំណងនៃការស្ដាប់
- បំផុសសិស្សឱ្យចាប់អារម្មណ៍លើអ្វី ដែលគេនឹងស្ដាប់
- បង្ហាញប្រធានបទ ឬរូបភាពឱ្យសិស្សវិភាគតាមផ្នែក ឬរូបភាពទាំងមូលដោយផ្ដើមចេញពីចំណេះដឹងមូលដ្ឋានរបស់សិស្ស
- បង្ហាញពាក្យថ្មី ពាក្យពិបាក និងកន្សោមពាក្យ (ក្នុងករណីចាំបាច់)
- ផ្ដល់កិច្ចការជាក់ស្ដែងឱ្យសិស្សអនុវត្ត ។

ខ. ពេលស្ដាប់: គឺជាដំណាក់ដឹកនាំសិស្សឱ្យចេះស្ដាប់និងធ្វើលំហាត់ស្ដាប់ក្នុងដំណាក់នេះគ្រូត្រូវ៖

- អាន និទាន ឬចាក់ខ្សែអាត់នូវខ្លឹមសារ ដែលត្រូវបង្រៀន
- ឱ្យសិស្សស្ដាប់លើកទី១ដើម្បីស្វែងយល់គំនិតទូទៅនៃខ្លឹមសារមេរៀន
- ឱ្យសិស្សស្ដាប់លើកទី២ បន្ទាប់មកត្រួតពិនិត្យការយល់ដឹងលើខ្លឹមសារមេរៀន(បើខ្លឹមសារខ្លីៗអាចស្ដាប់តែ១ដងក៏បាន)
- ផ្ដល់ឱកាសឱ្យសិស្សធ្វើលំហាត់ស្ដាប់ ដោយឱ្យសិស្សឆ្លើយនឹងសំណួរដែលពាក់ព័ន្ធដល់ខ្លឹមសារដែលបានស្ដាប់តាមវិធីជាក់ស្ដែងមួយចំនួនដូចជា: ចេះចង្អុលរូបភាពឱ្យត្រូវតាមការស្ដាប់ឮចេះបំពេញល្បះ ឆ្លើយជាលាយលក្ខណ៍អក្សរ ឬឆ្លើយសំណួរផ្ទាល់មាត់តាមសំណួរផ្សេងៗ

**គ. ក្រោយការស្ដាប់**: គឺជាសកម្មភាពដែលគ្រូនិងសិស្សត្រូវអនុវត្តក្រោយពីបានស្ដាប់រួចៗ ដំណាក់កាលនេះគ្រូត្រូវ៖

- ត្រួតពិនិត្យប្រតិកម្មសិស្សលើខ្លឹមសារដែលបានស្ដាប់
- បំផុសសំណួរត្រិះរិះ ដើម្បីលើកទឹកចិត្តសិស្សឱ្យពិនិត្យពិចារណាលើខ្លឹមសារដែលបានស្ដាប់ ហើយដែលអាចទាញយកជាឧត្តមគតិសម្រាប់ខ្លួនគេផ្ទាល់។

- ចាត់តាំងសកម្មភាព និយាយ អាន ឬសរសេរ ដោយផ្អែកលើខ្លឹមសារដែលបានស្ដាប់។

**ឧទាហរណ៍៖** បង្កើតការសន្ទនាជាដៃគូឱ្យសរសេរឬនិយាយសង្ខេបឡើងវិញនូវអ្វីដែលទើបបានស្ដាប់

*** លំនាំបង្រៀនការស្ដាប់ "រឿងនិទាន"**

**ក. ទំនាក់ទំនងមេរៀន(មុនពេលស្ដាប់)**

- គ្រូបំផុសសំណួរទាក់ទងទៅនឹងចំណងជើងមេរៀន
- បង្ហាញរូបភាព និងសួរសំណួរទាក់ទងនឹងរូបភាព
- ឱ្យសិស្សធ្វើការប៉ាន់ស្មានខ្លឹមសាររឿងតាមរយៈរូបភាព ឬចំណងជើង។ គ្រូចម្លងចម្លើយប៉ាន់ស្មានដាក់លើក្ដារខៀនទុកផ្ទៀងផ្ទាត់។

**ខ. ការស្ដាប់គ្រូនិទានរឿង(ពេលស្ដាប់)**

- ឱ្យសិស្សអានកម្រងសំណួរក្នុងសៀវភៅសិក្សាគោលដើម្បីត្រៀមឆ្លើយពេលស្ដាប់រឿងចប់។
- គ្រូនិទានរឿងឱ្យសិស្សស្ដាប់មួយចប់
- ឱ្យសិស្សនិទានរឿងឡើងវិញ

**គ. លំហាត់(ក្រោយពេលស្ដាប់)**

- គ្រូសម្របសម្រួលចម្លើយប៉ាន់ស្មានរបស់សិស្ស។
- ឱ្យសិស្សឆ្លើយសំណួរអំពីខ្លឹមសារអត្ថបទ (បើសិស្សឆ្លើយមិនបានត្រឹមត្រូវចំណុចណាមួយ គ្រូត្រូវនិទានចំណុចនោះឡើងវិញ)។
- និទានរឿងទាំងមូល ឬផ្នែកណាមួយនៃរឿងឡើងវិញ។
- គ្រូជួយបំពេញបន្ថែមរាល់ចំណុចខ្វះខាត និងធ្វើការកែលម្អ។

**ឃ. វាយតម្លៃ**

- ឱ្យសិស្សម្នាក់ៗធ្វើលំហាត់ក្នុងសៀវភៅសិក្សាគោលចូលក្នុងសៀវភៅកិច្ចការរបស់ខ្លួន
- ធ្វើកំណែលើក្ដារខៀន
- សិស្សប្ដូរកិច្ចការគ្នាកែ
- គ្រូប្រមូលកិច្ចការសិស្សកែដាក់ពិន្ទុ

**ង. កិច្ចការផ្ទះ**

- ឱ្យសិស្សសង្ខេបរឿងដែលសិក្សានេះដាក់សៀវភៅ

**២.១.២ ចេះជ្រើសរើសលំហាត់ស្ដាប់ដោយមានទម្រង់ប្លែកៗសម្រាប់សិស្សអនុវត្ត ដូចជា៖**

ក. លំហាត់ប្រៀបធៀប ឬញែកឱ្យឃើញភាពប្លែកគ្នា៖ នេះគឺជាការជ្រើសរើសចម្លើយមួយក្នុងសំណេរ ឬអត្ថបទជារូបភាពដែលសមស្របទៅនឹងអ្វីដែលបានស្ដាប់។

ខ. លំហាត់ប្ដូរទម្រង់៖ គឺការទទួលព័ត៌មានក្នុងទម្រង់មួយរួចហើយប្ដូរព័ត៌មាននោះទាំងស្រុង ឬមួយផ្នែកឱ្យទៅជាទម្រង់មួយផ្សេងទៀត។

**គ. លំហាត់សរសេរ៖** គឺការស្ដាប់ បន្ទាប់មកសរសេរនូវអ្វីដែលបានស្ដាប់។

ឧទាហរណ៍៖ សរសេរតាមអាន ជាសកម្មភាពយ៉ាងល្អប្រសើរក្នុងលំហាត់នេះ។

**ឃ. លំហាត់វិភាគឬពិនិត្យឡើងវិញ៖** គឺការដកស្រង់ចំណុចផ្សេងៗយកមកវិភាគឡើងវិញជាលំដាប់លំដោយ ដើម្បីរកឱ្យឃើញផ្នែកដែលត្រឹមត្រូវនៅក្នុងព័ត៌មាន។

**ង. លំហាត់ពង្រីកគំនិត៖** គឺជាការបំបែកខ្លឹមសារឱ្យបានលើសពីអ្វីដែលបានព្រមព្រៀងគ្នាហើយ។ ជាធម្មតាការពង្រីកគំនិតមានសារៈសំខាន់នៅក្រោយពេលអាន ឬស្តាប់។

**ច. លំហាត់សង្ខេបលើខ្លឹមសារ៖** គឺការបំព្រួញអ្វីដែលបានស្តាប់ ដើម្បីដកស្រង់យកចំណុចសំខាន់ៗ។

**ឆ. លំហាត់ឆ្លើយសំណួរ៖** គឺការឆ្លើយសំណួរដែលបានមកពីខ្លឹមសារដែលបានស្តាប់។

**ជ. លំហាត់ប៉ាន់ស្មានជាមុន៖** គឺការប្រមើលមើលវិភាគមូលហេតុទំនាក់ទំនងជាដើមដោយផ្អែកលើព័ត៌មានដែលមានបង្ហាញនៅក្នុងការសន្ទនា ឬការនិទានរឿង។

### ២.១.៣ ចេះជ្រើសរើសលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃលំហាត់និងសកម្មភាពស្តាប់៖

ដើម្បីវាយតម្លៃលំហាត់ និងសកម្មភាពស្តាប់គ្រូត្រូវចេះពិនិត្យ និងការពិចារណាលើចំណុច និងសំណួរដូចខាងក្រោម៖

**ក. តម្លៃខ្លឹមសារ**

- តើលំហាត់ និងសកម្មភាពស្តាប់គ្រាន់តែជាការអនុវត្តកម្រិតយល់ដឹងរបស់សិស្សលើការស្តាប់ ឬក៏មានបញ្ហាអ្វីផ្សេងទៀតដែរ?
- តើលំហាត់ដែលដាក់ឱ្យសិស្សអនុវត្ត មានទំនាក់ទំនងយ៉ាងណាខ្លះទៅនឹងបំណិនរបស់សិស្សដែលទទួលបានគន្លងមក?

**ខ. តើស្តាប់ដើម្បីយល់ខ្លឹមសារ ឬក៏ដើម្បីចងចាំទុក?**

ជាបឋមសកម្មភាពស្តាប់ត្រូវបានសង្កត់ធ្ងន់លើការយល់ដឹងខ្លឹមសារ ឬដំណើររឿង( ស្តាប់ដើម្បីយល់ ) បន្ទាប់មកទើបឈានទៅរកការចងចាំបានយូរអង្វែង។

**គ. គោលបំណងពេញលេញនិងការបំប្លែង៖គឺ**

ការស្តាប់ដើម្បីសម្រេចគោលបំណងអ្វីមួយរួចបំប្លែងយកទៅប្រើប្រាស់ក្នុងជីវភាពជាក់ស្តែង។ គ្រូត្រូវពិចារណា៖

- តើសកម្មភាពស្តាប់បានឆ្លុះបញ្ចាំងគោលបំណងមួយសមស្រប ដូចការស្តាប់ក្នុងជីវភាពរស់នៅជាក់ស្តែងក្នុងសង្គមដែរឬទេ?
- តើបំណិន និង ការពង្រីកលំហាត់ស្តាប់អាចបំប្លែងយកទៅប្រើប្រាស់ក្នុងជីវភាពជាក់ស្តែងបានឬទេ? ឬមួយគ្រាន់តែសម្រាប់ឱ្យសិស្សមានការងាយស្រួលកសាងបំណិននៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ?

**ឃ. តើនេះជាតេស្ត ឬការបង្រៀន?**

គ្រូត្រូវញែកឱ្យបានច្បាស់លាស់រវាងតេស្ត និងការបង្រៀនៈក្នុងការស្ទាបស្ទង់សន្និដ្ឋាន ឬវាយតម្លៃកម្រិតយល់ដឹង និងបំណិនផ្នែកណាមួយដែលសិស្សមានរួចហើយ គេអនុវត្តការធ្វើតេស្ត។ ផ្ទុយទៅវិញ បើគ្រូសន្និដ្ឋានថាសិស្សពុំមានចំណេះដឹង ឬបំណិននោះទេ ហើយគ្រូចង់សាកល្បងជួយពួកគេឱ្យទទួលបានចំណេះដឹង ឬបំណិន គេអនុវត្តការបង្រៀន។

**ង. ភាពត្រឹមត្រូវនៃការស្តាប់**

- តើអត្ថបទដែលបានស្តាប់មានលក្ខណៈដូចសុន្ទរកថាជាធម្មតាក្នុងកម្រិតណា?
- ជាទូទៅឯកសារដែលបានត្រៀមឱ្យសិស្សស្តាប់ ត្រូវមានគោលបំណងទាក់ទងទៅនឹងអ្វីមួយ ដែលកើតមាននៅក្នុងជីវភាពជាក់ស្តែងនៃសង្គម។

**២.១.៤ ចេះដឹកនាំល្បែងស្តាប់(Listening Games):**

ល្បែងស្តាប់គឺជាសកម្មភាពដែលគ្រូត្រូវយកទៅប្រើប្រាស់ ដើម្បីបណ្តុះបំណិនស្តាប់ដល់សិស្ស ព្រមទាំងអាចបង្កើតការសប្បាយរបស់សិស្សផង។ ល្បែងស្តាប់មានរូបភាពច្រើនយ៉ាង ក្នុងនោះល្បែងសំខាន់ៗមានៈ

**ក. ល្បែងគ្រាប់តាមការស្តាប់**

គឺជាប្រភេទល្បែងដែលអ្នកលេង (អ្នកអនុវត្ត និងអ្នកបញ្ជា)ធ្វើសកម្មភាពព្រមគ្នាៗក្នុងពេលតែមួយ។ អ្នកអនុវត្តធ្វើសកម្មភាពតាមការស្តាប់ឮ។ អ្នកបញ្ជាអាចជាសិស្ស ឬអាចជាគ្រូ។
ឧទាហរណ៍:

- ចេញទៅក្រៅបន្ទប់! បត់ឆ្វេង!
- ដើរប្រាំជំហានទៅមុខ! ត្រឡប់ក្រោយវិញ!
- ចូរនិយាយថា " អរុណសួស្តី ឱ្យបានបីដង!..." អ្នកអនុវត្តសកម្មភាពទាំងនេះបានត្រឹមត្រូវ កាលណាគេស្តាប់បញ្ជាបាន។

**ខ. ល្បែងគ្រាប់តាមការបញ្ជា ឬការណែនាំ**

ល្បែងមានលក្ខណៈប្រហាក់ប្រហែលល្បែងមុនដែរ តែអ្នកចូលរួមសកម្មភាព(គ្រូ សិស្ស) ដែលជាអ្នកមានតួនាទីបញ្ចេញសកម្មភាពតែងមានការណែនាំ ឬបទបញ្ជាផ្ទុយគ្នា។ ចំពោះអ្នកអនុវត្តត្រូវធ្វើតាមបញ្ជាដែលបានកំណត់ទុក ដូចជាបទបញ្ជាថា « ចូរធ្វើតាមសុភាពនិយាយ »....។

**ឧទាហរណ៍:** សុភាពណែនាំថា «ចូរអ្នកមករៀននៅម៉ោង២កន្លះ» សិស្សត្រូវមករៀននៅម៉ោង២កន្លះ។ បន្ទាប់គ្រូថា «អ្នកត្រូវឈប់សម្រាកនៅរសៀលនេះ» បញ្ជាចុងក្រោយនេះមិនត្រូវអនុវត្តទេ ពីព្រោះវាខុសគោលការណ៍ថា «ធ្វើតាមសុភាព»។

**គ. ល្បែងខ្សឹប**

**<u>របៀបលេង:</u>** ត្រូវរៀបចំសិស្សជាក្រុមបណ្តាក់គ្នាពីមួយទៅមួយ

- តំណាងទី១ ក្នុងក្រុមនីមួយៗត្រូវទៅជួបគ្រូដែលខ្សឹបប្រាប់ព័ត៌មានមួយ

- តំណាងក្រុមនីមួយៗនោះត្រូវពាំនាំខ្សឹបរបស់គ្រូប្រាប់សមាជិកខ្លួនតៗគ្នា
- តំណាងចុងក្រោយរបស់ក្រុមនីមួយៗត្រូវយកព័ត៌មានដែលខ្លួនបានស្តាប់បានទៅប្រាប់គ្រូវិញ
- ផ្តល់ពិន្ទុល្អដល់ក្រុមណាដែលបានផ្តល់ព័ត៌មានត្រឹមត្រូវតាមពត៌មានដើម។

**ឃ. ល្បែងចងចាំៈ**

<u>**របៀបលេងៈ**</u> បែងចែកសិស្សជាក្រុមតាមលទ្ធភាពជាក់ស្តែង

- ក្រុមនីមួយៗអង្គុយជារង្វង់
- សមាជិកក្រុមម្នាក់ឡើងនិយាយ ដូចជាៈ

- ម្សិលមិញខ្ញុំបានទៅផ្សារ ហើយបានទិញ.............។
- ម្សិលមិញខ្ញុំបានទៅដើរលេង ហើយបានញ៉ាំ.........។
- អាទិត្យមុនខ្ញុំបានទៅសួនសត្វ ហើយខ្ញុំបានឃើញ.....។

- សមាជិកតាមរង្វង់នីមួយៗថាតាមពាក្យដែលបានស្តាប់ឮតាមវេន បន្ថែមពាក្យក្នុងល្បះដែលមិនទាន់ចប់នោះ ដើម្បីបង្កើតអត្ថន័យត្រឹមត្រូវ និងល្បះពេញលេញណាមួយ។

**ង. ល្បែងទះដៃៈ** គ្រូទះដៃតាមចង្វាក់មួយ សិស្សទាំងអស់ទះដៃតាមចង្វាក់នោះ។

**ច. ល្បែងព្រៃកសួរ**

**របៀបលេង**

- គ្រូចាត់តាំងសិស្សម្នាក់ជាសម្ងាត់ ដោយលាក់ខ្លួនពុំឱ្យសិស្សដ៏ទៃទៀតឃើញ
- សិស្សនេះត្រូវបង្កើតឱ្យមានសូរមួយ ដោយប្រើវត្ថុដែលបានត្រៀមទុក
- ឱ្យសិស្សផ្សេងនៅក្នុងថ្នាក់រៀបរាប់ និងពន្យល់ថាតើសូរនេះជាសូរអ្វី? វាបង្កើតឡើងដោយវត្ថុអ្វី?

គួរចាប់អារម្មណ៍ថានៅក្នុងលំហាត់ដឹកនាំល្បែងស្តីពីការស្តាប់ ដែលបានរៀបរាប់ខាងលើ គ្រូគួរចេះដឹកនាំល្បែងដើម្បីបង្កើនសមត្ថភាពស្តាប់តាមរយៈល្បែងប្រពៃណីខ្មែរ មួយចំនួនដូចខាងក្រោមៈ

- ល្បែងរាំវង់បង្គង
- ល្បែងលាក់មាន់
- ល្បែងស្តេចចង់....។ល។

## ២.២ លំនាំបង្រៀននិយាយ

ផ្តើមចេញពីការចេះស្តាប់ កុមារបញ្ចេញប្រតិកម្មទៅនឹងអ្វីដែលពួកគេបានឮ។ ការពង្រីកសមត្ថភាពនិយាយដល់សិស្សជាការងារសំខាន់តាំងពីមត្តេយ្យសិក្សារហូតបឋមសិក្សា។ មានសមត្ថភាពនិយាយរឹងមាំក្នុងភាសាបានជះឥទ្ធិពលយ៉ាងខ្លាំងក្លាដល់ការសិក្សា ផ្នែកភាសារបស់សិស្ស។ ដូចនេះជានិច្ចកាលគួរបង្កបរិយាកាសសន្ទនារវាង គ្រូ និងសិស្ស រវាងសិស្ស និងសិស្សជាប្រចាំ។

❖ ដើម្បីពង្រឹងសមត្ថភាពនិយាយរបស់សិស្សគ្រូអាចបង្កើតសកម្មភាពសំខាន់ៗដូចខាងក្រោម៖

ក. ឱ្យសិស្សធ្វើការសន្ទនាជុំវិញបញ្ហា ឬប្រធានបទណាមួយ(ធ្វើលំហាត់ភាសា)

ខ. ជម្រាបសួរ និងជម្រាបលា

ខ. លំហាត់ភាសាដោយឱ្យឆ្លើយសំណួរ

គ. លំហាត់និទានរឿង

ឃ. បង្កើតសកម្មភាពផ្សេងៗក្នុងម៉ោងបង្រៀនគ្រប់មុខវិជ្ជា

**២.២.១. ការអនុវត្តលំនាំបង្រៀននិយាយ**

**២.២.១.១ ទំនាក់ទំនងមេរៀន**

- បង្ហាញមូលហេតុ និងគោលបំណងនៃការស្ដាប់
- បំផុសសិស្សឱ្យចាប់អារម្មណ៍លើអ្វី ដែលគេគ្រូនឹងនិយាយ
- បង្ហាញរូបភាព និងសួរសំណួរទាក់ទងនឹងរូបភាព
- បង្ហាញពាក្យថ្មី ពាក្យពិបាក និងកន្សោមពាក្យ (ក្នុងករណីចាំបាច់

**២.២.១.២ ការសន្ទនាគំរូលើកទី១**

- គ្រូឱ្យសិស្សសន្ទនាតាមអត្ថបទគំរូ ដើម្បីឱ្យសិស្សស្វែងយល់ខ្លឹមសារអត្ថបទ ក្នុងនោះមានសំណួរសំខាន់ៗ ដែលសិស្សត្រូវចងចាំ និងលំដាប់លំដោយនៃខ្លឹមសារ។

- គ្រូសួរសំណួរស្ទាបស្ទង់ការយល់ដឹងរបស់សិស្ស។

**២.២.១.៣ ការសន្ទនាគំរូលើកទី២**

ឱ្យសិស្សនិយាយតាមអត្ថបទគំរូឡើងវិញ។ ក្នុងការនិយាយ ត្រូវឱ្យសិស្សចេះលើកដាក់សំឡេង និង ធ្វើកាយវិការតាមខ្លឹមសារអត្ថបទ។

**២.២.១.៤ លំហាត់សន្ទនាសិស្សសន្ទនាតាមអត្ថបទគំរូក្នុងក្រុម។**

**២.២.១.៥ ការអនុវត្ត**

- គ្រូផ្ដល់ប្រធានបទថ្មី(លំហាត់ក្នុងសៀវភៅសិស្ស)ឱ្យសិស្សបង្កើតអត្ថបទសន្ទនា និងឱ្យតំណាងក្រុម ឡើងសន្ទនា។
- ឱ្យសិស្សខ្សោយ និងសិស្សពុំសូវមានសកម្មភាពឡើងនិយាយតាមលទ្ធភាពរបស់គេ។

**២.២.២ ក្នុងការបង្រៀនភាសាគ្រូត្រូវមានសមត្ថភាពពង្រឹងសមត្ថភាពនិយាយដល់សិស្សដូចជា៖**

**២.២.២.១ ចេះដឹកនាំសំវាទវិធី**

ក. ***សារៈសំខាននៃសំវាទវិធី៖*** គឺជាវិធីសន្ទនាមួយយ៉ាងខ្លីរវាងមនុស្សពីនាក់ តាមភាសានិយាយ។ ពេលសន្ទនាដៃគូត្រូវសម្ដែងចេញភាសាច្បាស់លាស់តាមប្រធានបទ និងពាក្យសម្ដីដែលគេប្រើប្រាស់ញឹកញាប់។ ការសន្ទនាជាមធ្យោបាយយ៉ាងសំខាន់ដែលអាចឱ្យអ្នកសិក្សាអនុវត្តជាក់ស្ដែង ដើម្បីបង្កើនសមត្ថភាពនិយាយ។ម្យ៉ាងទៀតការសន្ទនាក៏ជាមធ្យោបាយមួយធ្វើឱ្យទំនាក់ទំនងរវាងភាសា និងហេតុការណ៍មានភាពរឹងមាំផងដែរ។ សំវាទវិធីក៏អាចឱ្យសិស្សចូលរួមយ៉ាងសកម្មក្នុងមេរៀនទៀតផង។

ខ. ចេះដឹកនាំធ្វើសង្វាទវិធីទៅតាមដំណាក់ដូចខាងក្រោម៖

- ដំណាក់សំខាន់ៗនៃសំវាទវិធីមាន៖
  - បង្កើតស្ថានភាពឱ្យមានការសន្ទនា
  - ត្រូវចាប់ផ្តើមពីការបង្ហាញរូបភាពតាមផ្ទៃកនីមួយៗ ដូចជារូបភាពតុក្កតាឬតារាងរូបភាពដល់សិស្សឱ្យពិនិត្យ រួចធ្វើការពន្យល់ខ្លះក្នុងករណីចាំបាច់។ គ្រូអាចប្រើឧបករណ៍បង្ហាញដោយផ្ទាល់ដើម្បីបំផុសការសន្ទនា។
  - ពន្យល់ពាក្យពិបាក «ពាក្យថ្មីពាក្យប្លែកដែលសិស្សមិនស្គាល់ និងកន្សោមពាក្យខ្លះៗក្នុងករណីចាំបាច់»។
  - ទុកពេលឱ្យសិស្សស្ដាប់ការសន្ទនា។ គ្រូអាចចង្អុលរូបតុក្កតា ឬរូបភាពតាមផ្ទៃកនីមួយៗ ដោយនិយាយទៅកាន់សិស្សដើម្បីឱ្យគេពិនិត្យ និងឆ្លើយតប។
  - ត្រួតពិនិត្យការយល់ដឹងរបស់សិស្ស តាមរយៈសំណួរមួយចំនួនដែលអាចកំណត់ពីការយល់ដឹងទូទៅរបស់សិស្សក្នុងការសន្ទនា។
  - ទុកពេលឱ្យសិស្សស្ដាប់ការសន្ទនាម្ដងទៀត បន្ទាប់មកចោទសួរសិស្សនូវសំណួរដែលតម្រូវឱ្យប្រើប្រាស់ពាក្យដែលទទួលបាន មកពីការសន្ទនាត្រូវប្រើប្រាស់ក្នុងការសិក្សាប្រធានបទផ្សេងៗគ្នា។
  - ជំរុញសិស្សឱ្យថាឡើងវិញនូវពាក្យដែលមានក្នុងការសន្ទនាតាមក្រុម បន្ទាប់មកតាមរយៈដៃគូរសន្ទនា។
  - បែងចែកសិស្សជាក្រុមតូចៗ ដើម្បីឱ្យអនុវត្តការសន្ទនាតាមគំនិតគេផ្ទាល់ និងដើម្បីឱ្យគេមាន លទ្ធភាពធ្វើការសន្ទនានៅពេលក្រោយៗទៀត។
- **ដំណាក់បន្ទាប់បន្សំខ្លះទៀតមានដូចជាៈ**
  - រិះរកវិធីពង្រឹងខ្លឹមសារឱ្យបានច្រើនទៀតដើម្បីឱ្យសិស្សរៀន និងអនុវត្តជាក់ស្ដែងមិនត្រឹមតែផ្នែកនៃភាសាដែលប្រើប្រាស់ក្នុងពេលសន្ទនាប៉ុណ្ណោះទេ ប៉ុន្តែត្រូវយករបៀបផ្សេងៗទៀតសម្រាប់រៀនផងដែរ។
  - បង្កើតបរិបទសមស្របផ្សេងគ្នាសម្រាប់សិស្សអនុវត្តដើម្បីរៀបចំជាប្រព័ន្ធមួយ។
  - ឱ្យសិស្សធ្វើការសន្ទនាតាមរូបភាពផ្សេងៗ ដោយឱ្យគេបញ្ចេញយោបល់តាមគំនិតគេផ្ទាល់ ឬទៅតាមដំណើររឿងដែលមានជាក់ស្ដែងក្នុងមូលដ្ឋានរបស់គេផ្ទាល់។
    ឧទាហរណ៍ៈ សន្ទនាពីរឿងរ៉ាវរបស់គេ ក្នុងគ្រួសារផ្ទាល់ ឬមូលដ្ឋានរបស់គេផ្ទាល់។
  - កំណត់ការសន្ទនាដោយបង្កើតតួអង្គនៅក្នុងអត្ថបទ អក្សរសិល្ប៍តាមគំនិតអត្ថបទ ឬទៅតាមការបញ្ចេញមតិផ្ទាល់របស់ខ្លួន។

**២.២.២.២ ចេះដឹកនាំសកម្មភាពធ្វើសម្ភាសន៍៖**

- គ្រូត្រូវជ្រើសរើសសិស្សម្នាក់ធ្វើជាតួអង្គឱ្យគេធ្វើសម្ភាសន៍

- សិស្សឯទៀតជាអ្នកសង្កេតការណ៍ ឬទុកដូចជាអ្នកការសែតជាដើម។ សិស្សទាំងនេះជាអ្នកដាក់សំណួរដើម្បីឱ្យតំណាងឆ្លើយ
- គ្រូជាអ្នកសម្របសម្រួលការងារនិងវាយតម្លៃសកម្មភាពសម្ភាសន៍
- បទសម្ភាសន៍ត្រូវផ្តោតការយកចិត្តទុកដាក់លើខ្លឹមសារលើអត្ថបទ ឬព្រឹត្តការណ៍ផ្សេងៗដែលពាក់ព័ន្ធដល់ការសិក្សា ឬអត្តចរិករបស់តួអង្គក្នុងរឿងណាមួយ។

ឧទាហរណ៍៖

- ហេតុដូចម្តេចបានជាតួអង្គនេះប្រព្រឹត្តិដូចនេះ ?
- តើអ្នកយល់យ៉ាងណាចំពោះសកម្មភាពបែបនេះ ?

**២.២.២.៣ ចេះដឹកនាំសកម្មភាពល្បែងដែលពាក់ព័ន្ធដល់ការនិយាយនិងស្តាប់**

ឧទាហរណ៍:

- ល្បែងរបាំង ល្បែងប្រភេទនេះអាចលើកទឹកចិត្ត ឬជំរុញសិស្សឱ្យប្រើប្រាស់និការយាយដើម្បីទាក់ទងជាមួយសិស្សផ្សេងៗក្នុងថ្នាក់រៀន។
- របៀបដឹកនាំសកម្មភាបល្បែងមាន៖
  - ជ្រើសរើសសិស្សពីរនាក់ ឧទាហរណ៍ សុភាពនិងនារី
  - យករនាំងមួយដាក់ចន្លោះសិស្សពីនាក់ ដើម្បីកុំឱ្យជួបគ្នាផ្ទាល់។
  - សុភាពជាអ្នកផ្តល់ព័ត៌មាន ឯនារីជាអ្នកស្វែងរកព័ត៌មាន ឬស្វែងរកចម្លើយ
  - សុភាពផ្តល់ព័ត៌មានតាមបែប ជាបទពណ៌នា ជាបទបញ្ជា ជាទម្រង់បែបបទជាសេចក្តីពន្យល់ ឬជាសំណួរ។
- **ខ្លឹមសារអនុវត្តមួយចំនួន:**

- ការពណ៌នា និងគូរ **សុភាព** ធ្វើការពណ៌នាពីព័ត៌មាន **នារី** គូរតាមការស្តាប់បាន
- បទបញ្ជានិងការរៀបជាលំដាប់៖ **សុភាព**បញ្ជា**នារី**ឱ្យរៀបចំវត្ថុមួយចំនួនទៅតាមលំដាប់សមហេតុផល។ **នារី**ត្រូវរៀបចំតាមបញ្ជានេះ ។
- ការកំណត់ទិសដៅ**សុភាព**និង**នារី**មានផែនទីមួយដូចគ្នា។ **សុភាព**ប្រាប់**នារី**ឱ្យចង្អុលតាមចាប់តាំងចាប់ផ្តើម រហូតដល់ទិសដៅ។
- សំណួរ៖ **សុភាព** និង**នារី**មានរូបភាពមួយដូចគ្នាតែក្នុងរូបភាពទាំងនោះមានចំណុចខុសគ្នាមួយចំនួន។ សិស្សទាំងពីរសួរគ្នាទៅវិញទៅមកដើម្បីរកឱ្យឃើញចំណុចខុសគ្នានៃរូបទាំងនោះ។

## ២.៣ លំនាំបង្រៀនសមត្ថភាពអាន

### ២.៣.១ ទំនាក់ទំនងមេរៀន

ក. គ្រូបំផុសសំណួរទាក់ទង់ទៅនឹងចំណងជើងមេរៀន

ខ. បង្ហាញរូបភាព និងសួរសំណួរទាក់ទងនឹងរូបភាព

គ. បង្ហាញចំណងជើងឱ្យសិស្សប៉ាន់ស្មានខ្លឹមសារមេរៀន គ្រូចម្លងចម្លើយសិស្សដាក់លើក្តារខៀន

**២.៣.២ អំណានស្ងាត់លើកទី១**

ឱ្យសិស្សអានស្ងាត់ដើម្បីស្វែងយល់ពីអត្ថន័យនិងស្រង់ពាក្យពិបាកក្នុងអត្ថបទ

**២.៣.៣ ពន្យល់ពាក្យពិបាក**

- ពាក្យពិបាកអានគ្រូណែនាំសិស្សអានឱ្យបានត្រឹមត្រូវតាម ការពែ្រកញ្ញក រូបភាពឬស័ព្ទសាស្ត្រ
- ពន្យល់ពាក្យ

**២.៣.៤ អំណានស្ងាត់លើកទី២**

- នាំសិស្សអានសំណួរនៅក្នុងសៀវភៅសិក្សាគោល
- ឱ្យសិស្សអានស្ងាត់ រួចឆ្លើយសំណួរខាងលើ
- ណែនាំសិស្សផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មាន

**២.៣.៥ លំហាត់អាន(អំណានឮ)**

- សិស្សម្នាក់អានអត្ថបទជាគំរូ
- គ្រូចែកសិស្សជាក្រុមដើម្បីអាន និងធ្វើលំហាត់

**២.៣.៦ ការពង្រឹងចំណេះដឹង**

- សិស្សមធ្យមឬខ្សោយអានអត្ថបទទាំងមូលឬផ្នែកណាមួយ
- គ្រូបំផុសសំណួរផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ

**២.៣.៧ វង្វាយតម្លៃ**

- ឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិក្សាគោលជាបុគ្គល ឬជាក្រុម
- តំណាងក្រុមឡើងរាយការណ៍ក្រុម សិស្សផ្សេងទៀតជួយកែលម្អ
- ឱ្យសិស្សអានបណ្តាក់គ្នា ឬសង្ខេបខ្លឹមសារអត្ថបទឡើងវិញ

**២.៣.៨ កិច្ចការផ្ទះ**

ឱ្យសិស្សផ្តល់ចម្លើយមួយ ឬពីរដែលកម្រិតខ្ពស់ជាងលំហាត់ក្នុងថ្នាក់។

**✳ អំណានដោយម្ចាស់ការ (លំហាត់អាន)៖**

គ្រូត្រូវណែនាំសិស្សអានដោយម្ចាស់ការ។ អំណានម្ចាស់ការអាចមានរូបភាពជាអំណានស្ងាត់ ឬអំណានឮ។ អំណានស្ងាត់ ឬអំណានឮសិស្សអានតែម្នាក់ឯង ឬអានទាំងអស់គ្នា។ ក្នុងអំណានឮគ្រូត្រូវណែនាំសិស្សឱ្យអានបានរត់មាត់ និងមានបែបបទត្រឹមត្រូវ។ អំណានរត់មាត់អាចប្រព្រឹត្តទៅបានកាលណាសិស្សអានអត្ថបទមួយដោយមានការយល់ច្បាស់លាស់យ៉ាងតិច ៩៥% ។ សិស្សត្រូវអានជាមធ្យម ១៩ពាក្យ

ក្នុងចំណោម២០ ពាក្យនៃល្បះ ឬវគ្គក្នុងអត្ថបទមួយ។ ក្នុងអំណានម្ចាស់ការសិស្សត្រូវអានឱ្យបានច្រើនសារ អានហើយអានទៀតដើម្បីកុំឱ្យមានការរអាក់រអួលប្រកបដោយបែបបទត្រឹមត្រូវ។

អំណានម្ចាស់ការក៏មានគោលបំណងដកបទពិសោធក្នុងការអានឱ្យល្អផងដែរ។លទ្ធផលដែលទទួលបានពីការអាននេះ គឺសិស្សត្រូវទទួលបានការលើកទឹកចិត្តឱ្យចេះកសាងអត្ថបទផ្ទាល់ខ្លួន និងអត្ថបទផ្សេងៗ អានកំណត់ហេតុ ឬសារព័ត៌មាន...។

⁕ ចេះអានឯកសារយោងផ្សេងៗដើម្បីទទួលព័ត៌មាន ត្រូវណែនាំសិស្សឱ្យចេះ៖

**ក. ស្វែងយល់និងចេះប្រើប្រាស់ព័ត៌មាន តាមរយៈផ្នែកផ្សេងៗនៃសៀវភៅ:**

- ក្របមុខ ក្របក្រោយ
- ទំព័រមាតិការឿង ដើម្បីស្វែងរកផ្នែកអត្ថបទដែលត្រូវការអានគឺលេខរៀងអត្ថបទតាមទំព័រក្នុងសៀវភៅ
- សទានុក្រម ដើម្បីយល់ពាក្យគឺបញ្ជីពាក្យក្នុងអត្ថបទដែលអ្នកនិពន្ធលើកយកមកពន្យល់ភាគច្រើនដាក់ភាគខាងចុងសៀវភៅ
- បញ្ជីពាក្យខុស ពាក្យត្រូវ គឺបញ្ជីពាក្យដែលអ្នកនិពន្ធបន្ថែមលើអត្ថបទ ដើម្បីកែតម្រូវពាក្យខ្លះដែលមិនត្រូវ ពិសេសផ្នែកអក្ខរាវិរុទ្ធ
- ឯកសារពិគ្រោះ គឺអាចនិយាយបានថាជាប្រភេទឯកសារផ្សេងៗ ដែលគេបានប្រើប្រាស់ និងស្រាវជ្រាវយកមកប្រើប្រាស់ក្នុងការតាក់តែងអត្ថបទ។
- អារម្ភកថា

អារម្ភកថា គឺជាសេចក្តីផ្តើមឬចំណាប់អារម្មណ៍មួយយ៉ាងខ្លីដែលអាចបង្ហាញអ្នកអានឱ្យបានដឹងជាងមុន នូវគោលបំណងរបស់អ្នកនិពន្ធ ទំនាក់ទំនងព្រឹត្តការណ៍ ឬព័ត៌មានក្នុងប្រធានបទមួយ។ ដើម្បីសរសេរអារម្ភកថាមួយគេត្រូវរំឭកឡើងវិញនូវអ្វីៗ ដែលគេចង់បង្ហាញខ្លឹមសារដែលចង់បកស្រាយ។បន្ទាប់មកទើបគេចាប់ផ្តើមសរសេរប្រធានបទតែម្តង។ និយាយរួមអារម្ភកថាគឺចំណាប់អារម្មណ៍ដំបូងរបស់អ្នកនិពន្ធក្នុងការសរសេរអត្ថបទ។ អារម្ភកថាអាចជាភាសានិយាយ ឬជាភាសាសរសេរ ទៅតាមកាលៈទេសៈ និងខ្លឹមសារនៃប្រធានបទ។

**ខ.ចេះប្រើប្រាស់វចនានុក្រមដើម្បី:**

- រកអត្ថន័យពាក្យដែលមិនទាន់យល់ច្បាស់លាស់
- ពិនិត្យរបៀបអានពាក្យ (បន្លឺសូរ...) ស្គាល់អក្ខរាវិរុទ្ធ ស្គាល់ថ្នាក់ពាក្យ....

**⁕ ចេះនិយាយរៀបរាប់ឡើងវិញបន្ទាប់ពីអានបាន**

ការនិយាយរៀបរាប់ឡើងវិញ គឺជាវិធីមួយយ៉ាងសំខាន់ដែលទាក់ទងដល់អំណានស្ងាត់ និងអំណានឮដែលក្នុងនោះគ្រូតម្រូវឱ្យសិស្សនិយាយរៀបរាប់ឡើងវិញ នូវហេតុការណ៍ទាំងឡាយដែលមាននៅក្នុងប្រធានបទ។ ក្នុងការរៀបរាប់ឡើងវិញសិស្សតែងបង្ហាញឱ្យឃើញនូវផ្នែកខ្លះនៃអត្ថបទដែលមានអត្ថន័យ

សំខាន់ ចំពោះរូបគេបន្ទាប់មកទើបគេរៀបរាប់ដំណើររឿងតាមលំដាប់លំដោយរហូតដល់ចប់។ ធ្វើរបៀបនេះ សិស្សអាចហាត់កសាងអត្ថបទមួយថ្មី ឱ្យយកលំនាំតាមអត្ថបទចាស់។

ពេលអាន និងរៀបរាប់ឡើងវិញគ្រូអាចចូលរួមកែលម្អឃ្លា ប្រយោគ ដើម្បីឱ្យអត្ថបទមានទំនាក់ទំនងគ្នាបានសមរម្យ។ ជំនួយនេះអាចអនុវត្តនៅពេលសិស្សកំពុងអាន ឬកំពុងរៀបរាប់ឡើងវិញក៏បានដែរ។

## ២.៤ លំនាំបង្រៀនសមត្ថភាពសរសេរ

➢ **លំនាំបង្រៀនអក្សរផ្ចង់**

### ១. វត្ថុបំណង

- កំណត់បានច្បាស់ពីរូបរាងព្យញ្ជនៈ និងពាក្យដែលត្រូវសរសេរ។
- សរសេរអក្សរ និងពាក្យនីមួយៗបានស្អាត ច្បាស់ ទៅតាមទំហំ និងទម្រង់អក្សរ(អក្សរជ្រៀង) តាមរយៈការហ្វឹកហាត់សរសេរអក្សរផ្ចង់។
- មានទម្លាប់ធ្វើកិច្ចការដោយផ្ចិតផ្ចង់ អំណត់ ព្យាយាម មានបម្រុងប្រយ័ត្នក្នុងការសរសេរ និងស្រឡាញ់សោភ័ណ(ភាពស្អាតនៃអក្សរ)។

### ២. លំនាំបង្រៀន

គ្រូគូសបន្ទាត់ផ្ដេកនៅលើក្ដារខៀនតាមទម្រង់ ១/២ ដូចគំរូខាងក្រោម៖

- គ្រូណែនាំសិស្សអំពីរបៀបគូសបន្ទាត់ តាមគំរូខាងក្រោម។ នៅក្នុងសៀវភៅសិស្សមានក្រឡាបន្ទាត់ស្រេចហើយ គ្រូគ្រាន់តែនាំសិស្សគូសបន្ទាត់ទ្រេតតាមក្រឡាបន្ទាត់ ក្នុងសៀវភៅសិស្សតែប៉ុណ្ណោះ
- គ្រូសរសេរអក្សរគំរូនៅលើក្ដារខៀនយឺតៗតាមចលនានីមួយៗឱ្យសិស្សសង្កេត។ ដំបូងគ្រូសរសេរអក្សរ **អ** ដោយកំណត់កម្ពស់ ៤/៤(ពេញបន្ទាត់) ទទឹង ២/៣ ជួរទី១ បន្ទាប់មកសរសេរតួអក្សរ **អ** ដោយកំណត់យកកម្ពស់ ២/៤ ទទឹង ១/៣។ ជួរទី៣ សរសេរតួអក្សរ **អ** ដោយកំណត់កម្ពស់ ១/៤ ទទឹង....
- គ្រូឱ្យសិស្សហាត់សរសេរអក្សរនៅលើក្ដារឆ្នួនតាមគំរូនៅលើក្ដារខៀន។ គ្រូត្រួតពិនិត្យ និងកែលម្អ
- គ្រូឱ្យសិស្សហាត់សរសេរអក្សរផ្ចង់នៅក្នុងសៀវភៅរៀងៗខ្លួន
- គ្រូប្រមូលសៀវភៅមកកែដាក់ពិន្ទុ។



## ➢ លំនាំបង្រៀនសរសេរតាមអាន

### ១.វត្ថុបំណង

- កំណត់បានសូរអក្សរ និងន័យរបស់ពាក្យបានត្រឹមត្រូវ។
- សរសេរពាក្យ កន្សោមពាក្យ ល្បះ និងអត្ថបទខ្លីៗតាមអក្ខរាវិរុទ្ធ និងក្បួនវេយ្យាករណ៍បានត្រឹមត្រូវ តាមរយៈការហៅរបស់គ្រូ និងការហ្វឹកហាត់សរសេរលើក្ដារឆ្នួន។
- មានទម្លាប់ចំណាំពាក្យ និងន័យរបស់ពាក្យដែលបានរៀនរួច។

### ២. លំនាំបង្រៀន

### ២.១ សរសេរតាមអានចម្លង(ពាក្យ កន្សោមពាក្យ ល្បះនិងអត្ថបទ)

- ឱ្យសិស្សម្នាក់អានពាក្យក្នុងសៀវភៅឬគ្រូបិទពាក្យដែលត្រូវបង្រៀនដាក់លើក្ដាខៀន។
- គ្រូអាន និងចង្អុលពាក្យម្ដងមួយឱ្យបានច្បាស់ៗរួចឱ្យសិស្សៗចង្អុលនិងអានពាក្យនោះ។
- គ្រូចង្អុលពាក្យទី១ហើយអានម្ដងទៀត ដោយឱ្យសិស្សថាតាមរួចធ្វើអក្ខរាវិញ្ញាសពាក្យនោះ។
- គ្រូឱ្យសិស្សសរសេរពាក្យនោះនៅលើក្ដារឆ្នួនទាំងអស់គ្នា រួចពិនិត្យកែតម្រូវពាក្យនោះឡើងវិញ។
- ចង្អុលពាក្យទី២ និងពាក្យបន្តបន្ទាប់ដោយធ្វើតាមលំនាំបង្រៀនពាក្យទី១ដែរ។
- គ្រូហៅពាក្យឆ្លាស់គ្នាឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរបស់គេ រួចអានពាក្យទាំងនោះឱ្យសិស្សអានឡើងវិញ ដោយទុកពេលសមល្មមឱ្យសិស្សពិនិត្យ និងកែកំហុស។
- គ្រូប្រមូលសៀវភៅសិស្សកែដាក់ពិន្ទុ ឬឱ្យសិស្សប្ដូរគ្នាកែផ្ទៀងជាមួយពាក្យក្នុងសៀវភៅមេរៀនដោយប្រើខ្មៅដៃគូសក្រោមពាក្យខុស។
- គ្រូណែនាំឱ្យសិស្សប្រគល់សៀវភៅទៅម្ចាស់ដើមវិញ ដើម្បីឆូតពាក្យខុសហើយសរសេរពាក្យត្រូវពីលើពាក្យនោះវិញ។
- គ្រូឱ្យសិស្សដែលសរសេរខុសលើសពី៥ពាក្យចម្លងពាក្យទាំងនោះឡើងវិញទាំងអស់។

### ២.២-លំនាំបង្រៀនសរសេរតាមអានរៀបចំ

- គ្រូបិទអត្ថបទដាក់លើក្ដារខៀន។
- គ្រូអានពាក្យពិបាក ឬពាក្យគន្លឹះ រួចឱ្យសិស្សអានតាម។
- គ្រូអានអត្ថបទដោយយឺតៗ ច្បាស់ៗ រួចឱ្យសិស្សអានឡើងវិញ។
- គ្រូឱ្យសិស្សពន្យល់ពាក្យពិបាក រួចឱ្យសិស្សធ្វើអក្ខរាវិញ្ញាស។
- គ្រូហៅពាក្យពិបាកៗឱ្យសិស្សសរសេរលើក្ដារឆ្នួន។
- គ្រូលាក់អត្ថបទ រួចហៅឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅ មួយឃ្លាម្ដងៗរហូតដល់ចប់។ បន្ទាប់ហៅសំណួរឱ្យសិស្សសរសេរ។
- គ្រូអានអត្ថបទឡើងវិញឱ្យសិស្សស្ដាប់ និងផ្ទៀងផ្ទាត់ រួចទុកពេលឱ្យសិស្សពិនិត្យនិងកែកំហុសរៀងៗខ្លួន។
- គ្រូឱ្យសិស្សពន្យល់ពាក្យ រួចឆ្លើយសំណួរ។
- គ្រូឱ្យសិស្សប្ដូរសៀវភៅគ្នា កែតាមអត្ថបទបង្ហាញនៅលើក្ដារខៀន។

- គ្រូប្រមូលសៀវភៅកិច្ចការសិស្សកែដាក់ពិន្ទុ។

**២.៣លំនាំបង្រៀនសរសេរតាមអានត្រួតពិនិត្យ**

- គ្រូអានពាក្យ កន្សោមពាក្យ កថាខណ្ឌ ឬអត្ថបទឱ្យសិស្សស្ដាប់។
- គ្រូហៅពាក្យ កន្សោមពាក្យ ឃ្លាខ្លីៗចំនួនបីដងឱ្យសិស្សសរសេរតាម ម្ដងមួយៗរហូតដល់ចប់។
- ឱ្យសិស្ស២នាក់ជួយថាតាម បន្ទាប់ពីគ្រូអាន ដោយសិស្សម្នាក់ថាមុន នឹងខ្លួនសរសេរ ហើយសិស្សម្នាក់ទៀតថាតាមក្រោយបន្ទាប់ពីខ្លួនសរសេររួច។
- គ្រូអានឱ្យសិស្សស្ដាប់ឡើងវិញយឺតៗ និងច្បាស់ៗ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់ឡើងវិញ និងទុកពេលឱ្យសិស្សកែកំហុស។
- ប្រមូលកិច្ចការសិស្សកែដាក់ពិន្ទុ។

**កំណត់សម្គាល់៖** ចំពោះថ្នាក់ទី៤ដល់ទី៦ យើងបង្រៀនតែសរសេរតាមអានត្រួតពិនិត្យទេ។

## ➢ លំនាំបង្រៀនជ្រើសរើសពាក្យបំពេញល្បះ

**១. វត្ថុបំណង**

- កំណត់ន័យរបស់ពាក្យ និងរបស់ឡ្បះនាបត្រឹមត្រូវ តាមរយៈការអានពាក្យក្នុងប្រអប់ល្បះគំរូ។
- បំពេញល្បះបានត្រឹមត្រូវ មានន័យពេញលេញ តាមរយៈសំណួររបស់គ្រូ និងការហ្វឹកហ្វាត់បំពេញល្បះជាបុគ្គល ដៃគូ ឬក្រុម។
- មានទំនុកចិត្តក្នុងការជ្រើសរើសពាក្យបំពេញល្បះ។

**២ . លំនាំបង្រៀន**

- គ្រូចម្លងល្បះទី១ ដាក់លើក្ដារខៀន ( ល្បះដែលត្រូវបំពេញ )
- គ្រូឱ្យសិស្សអានការណែនាំលំហាត់ក្នុងសៀវភៅសិស្ស រួចគ្រូសួរ៖ តើលំហាត់នេះចង់ឱ្យកូនធ្វើអ្វី?
- គ្រូឱ្យសិស្សអានពាក្យនៅក្នុងប្រអប់ ( ពាក្យដែលត្រូវជ្រើសរើស ) នៅពីលើល្បះ
- គ្រូប្រាប់សិស្សថា ពាក្យទាំងនេះដកចេញពីល្បះនេះ ។ តើអ្នកណាអាចរកកន្លែងត្រឹមត្រូវដើម្បីបំពេញពាក្យទាំងនេះបានដែរ ឬទេ?
- គ្រូអានល្បះទី១ រួចឱ្យសិស្សទាំងអស់គ្នាអានល្បះនេះ
- គ្រូសួរ ៖ តើល្បះនេះមានន័យស្ដាប់បានហើយឬនៅ?
- គ្រូឱ្យសិស្សមើលពាក្យនៅក្នុងប្រអប់សៀវភៅសិស្ស រួចជ្រើសរើសពាក្យណាមួយដែលមានន័យត្រូវនឹងល្បះនោះ រួចឱ្យសិស្សសរសេរពាក្យដែលខ្លួនបានជ្រើសរើសនៅលើក្ដារឆ្នួន។
- គ្រូនាំសិស្សបំពេញល្បះទី១ គំរូ ដោយគ្រូយកពាក្យទី១ មកបំពេញល្បះ រួចសួរសិស្ស ៖ តើល្បះនេះមានន័យគ្រប់គ្រាន់ស្ដាប់បានហើយ ឬនៅ ? គ្រូធ្វើដូចគ្នាចំពោះពាក្យទី២ ទី៣ ...រហូតទាល់តែសិស្ស ឆ្លើយថា ល្បះនេះមានន័យត្រឹមត្រូវហើយ ទើបឈប់
- គ្រូឱ្យសិស្សអានល្បះដែលបំពេញរួចនេះទាំងអស់គ្នា។

ការហ្វឹកហាត់

- គ្រូឱ្យសិស្សបំពេញឈ្មោះផ្សេងទៀត ជាដៃគូ ឬជាបុគ្គល ដាក់ក្នុងសៀវភៅសិស្សកិច្ចការសិស្ស ។
- គ្រូដើរមើល និងជួយសិស្សជួបការលំបាក ។ គ្រូអាចឱ្យសិស្សផ្តល់ចម្លើយ ដោយគ្រាន់តែសរសេរលេខ ឈ្មោះ និងពាក្យដែលត្រូវបំពេញ ប្រសិនបើមានពេលគ្រប់គ្រាន់
- គ្រូឱ្យសិស្សដូរសៀវភៅគ្នា ដើម្បីផ្ទៀងផ្ទាត់ចម្លើយគ្នាទៅវិញទៅមក
- គ្រូឱ្យសិស្សអានឈ្មោះដែលបំពេញបានត្រឹមត្រូវជាដៃគូ។ ប្រាប់ឱ្យសិសស្សចម្លងឈ្មោះដាក់ក្នុងសៀវភៅរៀងខ្លួន ពេលត្រឡប់ទៅផ្ទះវិញ។

**បញ្ជាក់** ៖ ចំពោះការបំពេញឈ្មោះតាមរូបភាព គ្រូត្រូវណែនាំសិស្សឱ្យអានឈ្មោះ រួចមើលរូបភាព ដើម្បីឱ្យដឹងថា រូបភាពនេះនិយាយអំពីអ្វីខ្លះ ហើយត្រូវយកពាក្យអ្វីទៅបំពេញឈ្មោះទាំងនោះ ។

## ➢ លំនាំបង្រៀនតែងឈ្មោះតាមរូបភាព

### ១ . វត្ថុបំណង

- ប្រាប់សកម្មភាពក្នុងរូបភាពបានច្បាស់លាស់ តាមរយៈការសង្កេតរូបភាព និងសំណួររបស់គ្រូ។
- តែងឈ្មោះតាមរូបភាពបានសមស្របតាមរយៈការហ្វឹកហ្វាត់តែងជាបុគ្គល ដៃគូ ឬជាក្រុម។
- មានទំនុកចិត្តក្នុងការសរសេរបកស្រាយរូបភាពងាយៗ ជាឈ្មោះមានន័យពេញលេញ។

### ២ . លំនាំបង្រៀន

- គ្រូប្រាប់សិស្សថា ពួកគេនឹងហ្វឹកហ្វាត់សរសេរឈ្មោះតាមរូបភាព
- គ្រូបង្ហាញរូបភាព រួចសួរសំណួរបំផុសរកពាក្យគន្លឹះ ដោយសរសេរពាក្យនោះនៅលើក្តារខៀន ឧទាហរណ៍ ៖ តើកូនឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ ? តើមនុស្សនៅក្នុងរូបភាពកំពុងធ្វើអ្វី ?
- គ្រូធ្វើដូចគ្នានឹងរូបភាពទី១ ដែរ សម្រាប់រូបភាញផ្សេងទៀត(ប្រសិនបើមានរូបភាពច្រើន)
- គ្រូបំផុសសំណួរបន្ថែម ដើម្បីបង្កើតឈ្មោះសម្រាប់រូបភាពទី១

  ឧទាហរណ៍ ៖ រូបភាពបុរសម្នាក់កំពុងស្ទូចត្រី ។

  គ្រូសួរ : តើបុរសនេះកំពុងធ្វើអ្វី ?

  សិស្សឆ្លើយ : ស្ទូចត្រី ។

  គ្រូថាឡើងវិញ : គាត់កំពុងស្ទូចត្រី ។

  សិស្សថាតាម : គាត់កំពុងស្ទូចត្រី ។

  គ្រូសួរ : តើគាត់កំពុងស្ទូចត្រីនៅឯណា ?

  សិស្សឆ្លើយ : នៅមាត់ទន្លេ។

  គ្រូអាចនិយាយថា : តើយើងអាចតម្រៀបពាក្យទាំងនេះ ជាឈ្មោះយ៉ាងដូចម្តេច ?

  គាត់កំពុងស្ទូចត្រីនៅមាត់ទន្លេ ។

- គ្រូធ្វើជាគំរូក្នុងការសរសេរ និងតែងល្បះ
- គ្រូនិយាយ ៖ ឥឡូវនេះយើងនាំគ្នាសាកល្បងសរសេរល្បះនេះ
- គ្រូសរសេរល្បះនៅលើក្តារខៀនឱ្យសិស្សមើល
- គ្រូឱ្យសិស្សអានល្បះទាំងអស់គ្នានៅពេលគ្រូសរសេរចប់។
- គ្រូនាំសិស្សធ្វើការហ្វឹកហាត់សរសេរពាក្យក្នុងល្បះ
- គ្រូជួយសិស្សក្នុងការសរសេរទាំងអស់គ្នា

គ្រូថា: ឥឡូវនេះកូនទាំងអស់គ្នាសាកល្បងសរសេរ ។

គ្រូថា: តើពាក្យទី១ ជាពាក្យអ្វី ?

សិស្សឆ្លើយ: គាត់

គ្រូសួរ: តើកូនសរសេរពាក្យនេះដូចម្តេច ? តើពាក្យ គាត់ មានអក្សរអ្វីខ្លះ ?

- គ្រូអាចឱ្យសិស្សទះដៃតាមចំនួនព្យាង្គ
- គ្រូនាំសិស្សធ្វើបន្តសម្រាប់ពាក្យដទៃទៀតនៅក្នុងល្បះ « គាត់កំពុងស្ទូចត្រីនៅឯមាត់ទន្លេ»
- គ្រូលើកទឹកចិត្តឱ្យសិស្សអានពាក្យ ខណៈដែលសរសេរពាក្យនីមួយៗ ។
- គ្រូឱ្យសិស្សអានល្បះដែលបានសរសេររួចទាំងអស់គ្នា
- គ្រូលុបពាក្យលើក្តារខៀន រួចឱ្យសិស្សសាកល្បងសរសេរល្បះឡើងវិញដោយខ្លួនឯងដាក់ក្នុងសៀវភៅរបស់គេ។

**ការហ្វឹកហាត់**

- គ្រូឱ្យសិស្សពិភាក្សាគ្នាពីរូបភាពដដែល ឬរូបភាពផ្សេងៗទៀតជាដៃគូ ។ បន្ទាប់មកសរសេរល្បះដោយប្រើពាក្យគន្លឹះ ដែលមានន័យទាក់ទងនឹងរូបភាព
- គ្រូដើរជួយសម្របសម្រួលនៅពេលសិស្សសរសេរ
- គ្រូឱ្យសិស្សអានល្បះដែលសរសេររួច ជាដៃគូ រួចជាបុគ្គល
- គ្រូឱ្យសិស្សដើរមើលកិច្ចការមិត្តភក្តិផ្សេងៗទៀត
- គ្រូ និងសិស្សអាចបន្ថែមគំនិត រួចកែកំហុស។

## ➢ លំនាំបង្រៀនសំណេរកថាខណ្ឌ

### ក . គោលបំណង

- សិស្សប្រមូលគំនិតបានត្រឹមត្រូវតាមប្រធានបទដែលបានកំណត់
- សិស្សចេះរៀបចំគំនិតតាមលំដាប់លំដោយ
- ឱ្យសិស្សយកគំនិតនីមួយៗ មកសរសេរពង្រីកជាល្បះ
- ឱ្យសិស្សសរសេរសំណេរកថាខណ្ឌឱ្យបានត្រឹមត្រូវ

### ខ . និយមន័យ

- កថាខណ្ឌគឺ ជាល្បះមួយចំនួនដែលសរសេរអំពីប្រធានបទមួយ ឬល្បះមួយក្រុមដែលមានទំនាក់ទំនងគ្នាហើយនិយាយ អំពីគោលគំនិតណាមួយ ។

- ការចាប់ផ្តើមបន្ទាត់គឺជាការចាប់ផ្តើមនៃកថាខណ្ឌ ។ សំណេរកថាខណ្ឌមិនចាំបាច់ចុះបន្ទាត់ទេ គឺចូលបន្ទាត់តែម្តងហើយសរសេរជាប់គ្នារហូត។

**គ . សិក្សាបញ្ញត្តិ ឬកថាខណ្ឌគំរូ**

- ស្វែងយល់កថាខណ្ឌគំរូក្នុងសៀវភៅសិស្ស (ឬកថាខណ្ឌបង្កើតថ្មី)
- ឱ្យសិស្សអានកថាខណ្ឌ២ ទៅ ៣នាក់
- ឱ្យសិស្សរកគំនិតសំខាន់ក្នុងកថាខណ្ឌគំរូ
- ឱ្យសិស្សរកសេចក្តីលម្អិត ដែលគាំទ្រគំនិតសំខាន់
- បើមានសំណួរឱ្យសិស្សធ្វើតាមក្រុមរួចឡើងរាយការណ៍
- ឱ្យសិស្សចម្លងកថាខណ្ឌដាក់ក្នុងសៀវភៅរៀងៗខ្លួន

**ឃ . លំហាត់**

ដើម្បីសរសេរកថាខណ្ឌគ្រូ ត្រូវអនុវត្តតាមលំនាំនីមួយៗដូចខាងក្រោម ៖

❖ **ការប្រមូលគំនិត**

- គ្រូបំផុសសំណួររកប្រធានបទ
- គ្រូសរសេរប្រធានបទដាក់លើក្តារខៀន
- ឱ្យសិស្សអានប្រធានបទ រួចរកពាក្យគន្លឹះដើម្បីងាយយល់ រួចគូសពីក្រោមពាក្យនោះ
- ឱ្យសិស្សពន្យល់ពាក្យគន្លឹះ
- គ្រូនាំសិស្សប្រមូលគំនិត (ផ្សល់គំនិតទាក់ទង នឹងប្រធានបទដែលត្រូវសរសេរ ) តាមរយៈសំណួរបំផុសរបស់គ្រូ)
- គ្រូ ឬសិស្សសរសេរ គំនិតគោលៗដែលសិស្សប្រមូលបានដាក់លើក្តារខៀន ឬឱ្យសិស្សសរសេរគំនិតទាំងនោះដាក់ក្នុងក្រដាស់ព្រាងដោយមិនបាច់គិតតាមលំដាប់លំដោយនៅទេ

❖ **សំណេរព្រាង**

- គ្រូនាំសិស្សពិនិតគំនិតទាំងនោះឡើងវិញ ដើម្បីឱ្យដឹងថាតើគំនិតមួយណាដែលបានបញ្ចេញមកគ្រប់គ្រាន់ហើយឬនៅ បើនៅមានខ្វះខាតគ្រូប្រើសំណួរបំផុសបន្ថែមដើម្បីរកគំនិតបន្ថែម
- ឱ្យសិស្សពិនិតមើល និងជ្រើសរើសយកតែគំនិតណាដែលទាក់ទង នឹងប្រធានបទ ហើយគំនិតណាដែលមិនទាក់ទងលុបចោល
- គ្រូឱ្យសិស្សរៀបគំនិតទាំងនោះតាមលំដាប់លំដោយ(មុន ក្រោយ និងបន្ទាប់)
- ឱ្យសិស្សយកគំនិតនីមួយៗមកសរសេរពង្រីកជាល្បះពេញលេញ
- គ្រូប្រាប់សិស្សឱ្យសរសេរដាក់ក្រដាស់ព្រាង ហើយគ្រូដើរពិនិត្យ និងជួយផ្តល់ជាគំនិតខ្លះៗចំពោះសិស្សណាដែលសរសេរមិនបាន (សរសេជាក្រុមក៏បាន)

❖ **កំណែលម្អ**

- គ្រូនាំសិស្សពិនិត្យសំណេររបស់ខ្លួន ឡើងវិញដោយស្ងៀមស្ងាត់
- សួរសិស្សពីលំដាប់លំដោយនៃគំនិត អក្ខរាវិរុទ្ធ និងសំណេរខុសក្បួនវេយ្យាករណ៍
- ឱ្យសិស្សពិនិត្យ និងកែលម្អកិច្ចការ (សំណេរព្រាង) ដោយខ្លួនឯង បន្ទាប់មកប្ដូរគ្នាកែ
- ពេលសិស្សកំពុងកែគ្រូដើរពិនិត្យមើល

❖ **សំណេរសម្រេច**

- គ្រូឱ្យសិស្សចម្លងកិច្ចការឡើងវិញឱ្យបានស្អាតហើយមានទម្រង់ជាកថាខណ្ឌ
- គ្រូប្រមូលដាក់ពិន្ទុ ។ រួចជ្រើសរើសសំណេរខ្លះៗឱ្យម្ចាស់សំណេរអាន ២ ទៅ ៣នាក់អានឱ្យមិត្តភក្តិស្ដាប់
- ឱ្យសិស្សដែលសរសេរស្អាត និងត្រឹមត្រូវ យកទៅបិទនិងជញ្ជាំងដើម្បីជាស្នាដៃគំរូ
- ចំពោះសំណេរណាដែលមិនត្រឹមត្រូវតាមកថាខណ្ឌ ត្រូវសរសេរឡើងវិញ។

➢ **លំនាំបង្រៀនតែងសេចក្ដីបែបពណ៌នា**

**ក . វត្ថុបំណង**

- ប្រាប់បានពីគំនិតសំខាន់ ឬខ្លឹមសារសម្រាប់ពណ៌នាអំពីមនុស្ស សត្វ ទីកន្លែង និងព្រឹត្តិការណ៍តាមរយៈការសិក្សាអត្ថបទគំរូ និងសំណួររបស់គ្រូ។
- សរសេរតែងសេចក្តីពណ៌នាអំពីមនុស្ស សត្វ ទីកន្លែង និងព្រឹត្តិការណ៍ផ្សេៗបានត្រឹមត្រូវតាមរយៈការហ្វឹកហាត់រៀបរាប់ដោយមាត់ទទេ និងដោយសរសេរតាមគម្រោងតែង។
- មានទំនុកចិត្តក្នុងការសរសេរតែងសេចក្ដីបែបពណ៌នាអំពីមនុស្ស សត្វ ទីកន្លែង និងព្រឹត្តិការណ៍ផ្សេងៗដោយប្រើគំនិតផ្ទាល់ខ្លួន។

**ខ . ការសិក្សាអត្ថបទគំរូ**

- គ្រូសួរសំណួរផ្សារភ្ជាប់ចំណេះដឹងមានស្រាប់ ឬបទពិសោធរបស់សិស្សទៅនឹងមេរៀនថ្មី គ្រូត្រូវសរសេរចំណងជើងដាក់លើក្ដារខៀន ។ គ្រូឱ្យសិស្សអានចំណងជើង រួចសួរសិស្សអំពីអត្ថន័យនៃចំណងជើងនោះ។
- គ្រូឱ្យសិស្សសង្កេតរូបភាពនៅក្នុងសៀវភៅសិស្ស រួចក៏សួរសំណួរមួយចំនួនអំពីរូបភាពនោះ។
- គ្រូឱ្យសិស្សប៉ាន់ស្មានខ្លឹមសារអត្ថបទដោយសួរសិស្សថា ៖ តើអត្ថបទនេះនិយាយអំពីអ្វី? គ្រូឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ និងរហ័សបំផុត ដើម្បីរកពាក្យពិបាកអាន និងពិបាកយល់ន័យ។ បន្ទាប់មក គ្រូ ឬសិស្សឡើងសរសេរពាក្យទាំងនោះនៅលើក្ដារខៀន។
- គ្រូដឹកនាំសិស្សធ្វើការហ្វឹកហាត់អានពាក្យ ពន្យល់ន័យនៃពាក្យទាំងនោះ
- គ្រូ ឬសិស្សអានអត្ថបទជាគំរូ

- គ្រូដឹកនាំសិស្សហ្វឹកហាត់អាន ជារួម បុគ្គល ដៃគូ និងជាក្រុម ដោយផ្ដោតលើបែបបទការចេះលើកដាក់សំឡេង ការគោរពសញ្ញាសម្គន្ធ និងការធ្វើកាយវិការបានត្រឹមត្រូវ។
- គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅរបស់សិស្ស ។ គ្រូបញ្ជាក់ប្រាប់សិស្សថា សិស្សនឹងត្រូវឆ្លើយសំណួរទាំងអស់នៅពេលអានអត្ថបទចប់។
- គ្រូឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ដើម្បីស្វែងយល់ខ្លឹមសារអត្ថបទ។ ក្នុងការអានស្ងាត់នេះ គ្រូត្រូវកំណត់ពេលវេលាសម្រាប់ឱ្យសិស្សអានឱ្យបានច្បាស់។
- គ្រូសួរសំណួរក្នុងសៀវភៅសិស្សឱ្យសិស្សឆ្លើយ ដើម្បីបញ្ជាក់ពីការយល់ខ្លឹមសារអត្ថបទរបស់សិស្ស។ មុនពេលសួរសំណួរគ្រូឱ្យសិស្សបិទសៀវភៅ។ ប្រសិនបើមានសំណួរណាសិស្សឆ្លើយខុស គ្រូឱ្យសិស្សបើកសៀវភៅអានផ្ទៀងផ្ទាត់ចំណុចនោះឡើងវិញ។
- គ្រូសួរសំណួរដើម្បីទាញរកខ្លឹមសារអត្ថបទមកបញ្ចូលក្នុងគម្រោងតែងសេចក្ដី ៖
    - តើផ្នែកទី១នៃអត្ថបទគេពណ៌នាអ្វីខ្លះ? តើផ្នែកទី១ នេះគេហៅថាអ្វី? (សេចក្ដីផ្ដើម)
    - តើផ្នែកទី២នៃអត្ថបទគេពណ៌នាអំពីអ្វី? តើផ្នែកទី២ នេះគេហៅថាអ្វី? (តួសេចក្ដី)
    - តើផ្នែកទី៣នៃអត្ថបទគេពណ៌នាអំពីអ្វី ? តើផ្នែកទី៣ នេះគេហៅថាអ្វី? (សេចក្ដីបញ្ចប់)
- គ្រូឱ្យសិស្សសង្ខេបខ្លឹមសារមេរៀនឡើងវិញ
- គ្រូធ្វើការបូកសរុប និងសង្ខេបខ្លឹមសារមេរៀនឡើងវិញ
- គ្រូឱ្យសិស្សចម្លងមេរៀនដាក់ក្នុងសៀវភៅរៀងៗខ្លួន។

**គ . ការសិក្សាគម្រោង**

- គ្រូសរសេរប្រធានបទតែងសេចក្ដីដាក់លើក្ដារខៀន ។ គូសពីក្រោមពាក្យ ឬឃ្លាសំខាន់ៗ។
- គ្រូហៅសិស្សអានប្រធានបទ២ទៅ៣នាក់។ គ្រូសួរសំណួរ៖ តើប្រធានបទនេះចង់ឱ្យអ្នកធ្វើអ្វី? (ចម្លើយ ៖ ពណ៌នាអំពី......)។ គ្រូប្រាប់សិស្សថា តែងសេចក្ដីបែបពណ៌នា គឺជាការរៀបរាប់ ឬនិយាយអំពីអ្វីមួយឱ្យបានគ្រប់ជ្រុងជ្រោយ ដោយចងក្រងជាអត្ថបទមួយពេញលេញដែលមានផ្នែកធំៗ៣គឺ **សេចក្ដីផ្ដើម តួសេចក្ដី** និង**សេចក្ដីបញ្ចប់** ។ ថ្ងៃនេះកូននឹងរៀនពណ៌នាអំពី......។
- គ្រូឱ្យសិស្សអានអត្ថបទគំរូជាដៃគូ
- គ្រូសួរសំណួរដើម្បីបង្កើតគម្រោងតែង ហើយសរសេរចម្លើយដាក់ក្នុងគម្រោងបណ្ដើរៗទៅតាមផ្នែកនីមួយៗ។ ឧទាហរណ៍ ៖ ការពណ៌នាអំពីមនុស្ស ។
- គ្រូសួរសិស្សដើម្បីប្រមូលគំនិត ៖
    - តើសំណេរនេះចែកចេញជាប៉ុន្មានផ្នែក?
    - តើផ្នែកទី១ គេប្រាប់អំពីអ្វី? ( ប្រាប់ឈ្មោះ អាយុ ទីកន្លែង )

- តើផ្នែកទី១ នេះគេហៅថាអ្វី? ( សេចក្តីផ្តើម )
- គ្រូសរសេរនៅក្នុងគម្រោង
- គ្រូសួរសំណួរបន្ត ៖
  - តើក្នុងផ្នែកទី២គេប្រាប់អ្វីខ្លះក្នុងល្បះដំបូង?(មាឌ កម្ពស់ សម្បុរ សក់ ច្រមុះ ភ្នែក ដៃ ជើង...)
  - តើបន្ទាប់មកគេប្រាប់អ្វីខ្លះទៀត? (គុណសម្បត្តិ និងគុណវិបត្តិ )
  - តើក្នុងផ្នែកទី២គេហៅថាអ្វី? ( តួសេចក្តី )
  - តើក្នុងផ្នែកទី៣គេប្រាប់អ្វី? (ប្រាប់ចំណាប់អារម្មណ៍របស់អ្នកសរសេរ ឬទឹកចិត្តអ្នកសរសេរ)
  - តើក្នុងផ្នែកទី៣គេហៅថាអ្វី ? ( សេចក្តីបញ្ចប់ )

## ឃ . ការហ្វឹកហាត់

- គ្រូសរសេរប្រធានបទតែងសេចក្តីដាក់លើក្តារខៀនហើយគូសពីក្រោមឃ្លាសំខាន់ឬពាក្យគន្លឹះ។
- គ្រូឱ្យសិស្សអានប្រធានបទ ២ ទៅ ៣នាក់ ។ គ្រូសួរ តើប្រធានបទនេះ តម្រូវឱ្យប្អូនសរសេរអំពីអ្វី?
- គ្រូសួររំឭកឡើងវិញ អំពីគម្រោងតែងសេចក្តី ហើយសរសេរចម្លើយ ឬបិទផ្ទាំងគម្រោងដែលបានសរសេរពីថ្ងៃមុនលើក្តារខៀន ។
- គ្រូនាំសិស្សបង្កើតសេចក្តីផ្តើមដោយសរសេរលើក្រដាសព្រាង។ គ្រូឱ្យសិស្សគិតគ្នាជាដៃគូ រួចគ្រូហៅដៃគូនីមួយៗនិយាយរៀបរាប់តាមគំនិតរបស់ពួកគេ ដោយផ្អែកលើគម្រោង។ គ្រូជួយកែតម្រូវ ឬបំពេញបន្ថែមឱ្យបានល្អប្រសើរ ប្រសិនបើការរៀបរាប់របស់ពួកគេមិនបានត្រឹមត្រូវ។
- គ្រូឱ្យសិស្សសាកល្បងសរសេរសេចក្តីផ្តើមជាដៃគូតាមលំដាប់លំដោយ នៃចំណុចដែលមាននៅក្នុងគម្រោង ។ គ្រូដើរជួយសម្របសម្រួល ពិសេសសិស្សដែលជួបការលំបាក។
- គ្រូនាំសិស្សសរសេរតួសេចក្តី គ្រូឱ្យសិស្សហាត់រៀបរាប់ជាដៃគូដោយផ្ទាល់មាត់ ផ្អែកលើគម្រោង។ គ្រូហៅសិស្សឱ្យនិយាយ និងគ្រូជួយកែលម្អបន្ថែម។
- គ្រូឱ្យសិស្សសាកល្បងសរសេរតួសេចក្តី តាមលំដាប់លំដោយនៃចំណុចដែលមាននៅក្នុងគម្រោង។ គ្រូដើរពិនិត្យ និងជួយកែសម្របសម្រួល។
- គ្រូឱ្យសិស្សបន្តធ្វើផ្នែកទី៣ ឬសេចក្តីបញ្ចប់ទៀត។ គ្រូឱ្យសិស្សហាត់រៀបរាប់ជាដៃគូដោយផ្ទាល់មាត់ផ្អែកលើគម្រោង ។ គ្រូហៅសិស្សឱ្យនិយាយ ហើយជួយកែលម្អ។
- ឱ្យសិស្សសរសេរសេចក្តីបញ្ចប់ តាមលំដាប់លំដោយនៃចំណុចដែលមាននៅក្នុងគម្រោង។ គ្រូដើរពិនិត្យ និងជួយកែលម្អ។
- គ្រូឱ្យសិស្សដែលជាដៃគូពិនិត្យអត្ថបទរបស់ខ្លួនឡើងវិញ ទៅតាមសំណួររបស់គ្រូ ឬគ្រូអាចសរសេរនៅលើផ្ទាំងក្រដាស់ធំ ដើម្បីឱ្យសិស្សមើល ហើយផ្ទៀងផ្ទាត់តាម ៖

- តើអត្ថបទរបស់កូនមានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ហើយឬនៅ?
- តើផ្នែកនីមួយៗមានចូលបន្ទាត់ដែរឬទេ ? តើមានចុះបន្ទាត់ដែរឬទេ ?
- តើក្នុងផ្នែកនីមួយៗ មានគ្រប់ចំណុចដូចគម្រោងហើយឬនៅ?
- តើល្បះនីមួយៗមានសញ្ញាខណ្ឌដែរឬទេ?
- តើមានពាក្យណាខ្លះដែលប្អូនមិនទាន់ចេះសរសេរ? ប្រសិនបើមានគ្រូប្រាប់។

- គ្រូឱ្យសិស្សអានស្ងាត់ៗម្តងទៀត។
- គ្រូហៅសិស្សដែលតែងបានល្អ អានអត្ថបទទាំងមូលឱ្យសិស្សទាំងអស់គ្នាស្តាប់។ គ្រូប្រមូលកិច្ចការសិស្សដាក់ពិន្ទុ ហើយបិទដាក់ជញ្ជាំង។

## ២.៥ លំនាំបង្រៀនវេយ្យាករណ៍

### ២.៥.១. ទំនាក់ទំនងមេរៀន

- គ្រូបំផុសសំណួរទាក់ទងទៅនឹងចំណងជើងមេរៀន

### ២.៥.២ ការសិក្សាឧទាហរណ៍

- ឱ្យសិស្សអានឧទាហរណ៍ក្នុងសៀវភៅសិស្សឬឧទាហរណ៍លើក្តារខៀនដើម្បីការសង្កេត
- ចោទសួរសំណួរលើឧទាហរណ៍មួយៗនិងគូសបញ្ជាក់ន័យក្នុងឧទាហរណ៍នោះ
- គ្រូបញ្ជាក់ខ្លឹមសារបន្ថែមរបស់មេរៀន

### ២.៥.៣ ការសិក្សាបញ្ញត្តិ

- នាំសិស្សទាញរកបញ្ញត្តិ
- គ្រូបំផុសសំណួរដោយផ្អែកលើគំនិតគោលដៅរបស់មេរៀន

### ២.៥.៤ លំហាត់

- ចែកសិស្សជាក្រុមរួចណែនាំឱ្យសិស្សធ្វើលំហាត់
- ដើរពិនិត្យជួយសម្រួលកិច្ចការក្នុងក្រុម

### ២.៥.៥ ការពង្រឹងចំណេះដឹង

- សិស្សក្នុងក្រុមធ្វើលំហាត់ស្វែងរកចម្លើយ

### ២.៥.៦ វាយតម្លៃ

- តំណាងក្រុមឡើងរាយការណ៍ ក្រុមឯទៀតជួយលម្អ
- ឱ្យសិស្សម្នាក់ៗធ្វើលំហាត់
- ណែនាំសិស្សដូរកិច្ចការគ្នាកែ
- គ្រូធ្វើកំណែនៅលើក្តារខៀន
- ឱ្យសិស្សចម្លងមេរៀនចូលសៀវភៅ

### ២.៥.៧ កិច្ចការផ្ទះ

- ដាក់សំណួរទៅតាមខ្លឹមសារមេរៀនឬធ្វើលំហាត់ដែលនៅសល់ក្នុងសៀវភៅសិស្ស

## ២.៦ លំនាំបង្រៀនចំណិន

### ២.៦.១ ទំនាក់ទំនងមេរៀន

គ្រូបំផុសសំណួរទាក់ទងទៅនឹងចំណងជើងមេរៀន

### ២.៦.២ ការសិក្សាឧទាហរណ៍

- ឱ្យសិស្សអានឧទាហរណ៍ (អត្ថបទ)ក្នុងសៀវភៅសិស្សស្វែងយល់អត្ថន័យឧទាហរណ៍ខ្លួនឯងដើម្បីការសង្កេត
- ចោទសួរសំណួរលើឧទាហរណ៍ និងពន្យល់បញ្ជាក់ន័យក្នុងឧទាហរណ៍ ដើម្បីបញ្ជាក់ខ្លឹមសាររបស់មេរៀន

### ២.៦.៣ ការសិក្សាបញ្ញត្តិ

- នាំសិស្សទាញរកបញ្ញត្តិ
- ស្វែងរកចម្លើយតាមការសួរសំណួរបំផុសដោយផ្អែកលើគំនិតគោលដៅរបស់មេរៀន
- ឱ្យសិស្សអានមេរៀន រួចចម្លងមេរៀន

### ២.៦.៤ លំហាត់

- ចែកសិស្សជាក្រុមរួចណែនាំឱ្យសិស្សធ្វើលំហាត់
- ដើរពិនិត្យរាល់កិច្ចការរបស់សិស្សនិង ជួយសម្រួលកិច្ចការក្នុងក្រុម
- តំណាងក្រុមរាយការណ៍

### ២.៦.៥ ការពង្រឹងចំណេះដឹង

- សិស្សម្នាក់ៗធ្វើលំហាត់នៅសល់រួចប្តូរកិច្ចការគ្នាកែ
- នាំសិស្សធ្វើកំណែនៅលើក្តារខៀន
- គ្រូបំផុសសំណួរផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្តែង

### ២.៦.៦ កិច្ចការផ្ទះ

## ៣. សន្និដ្ឋាន

សរុបសេចក្តីមកខ្លឹមសារ វិធីសាស្ត្របង្រៀន១២ + ២ នេះត្រូវបានចងក្រងជាមេរៀន វិធីសាស្ត្របង្រៀនភាសាខ្មែរ ចាប់ពីថ្នាក់ ដំបូងដល់ថ្នាក់ទី៦ (ថ្នាក់ទី១ ដល់ទី៦ )សម្រាប់ជួយដល់ គ្រូឧទ្ទេស និងគរុសិស្សនៅតាមសាលាគរុកោសល្យ និងវិក្រឹតការ រាជធានី ខេត្ត ក្នុងការបង្រៀន និងរៀន សិក្សាស្រាវជ្រាវ និងប្រើប្រាស់តាមតម្រូវការកម្មវិធីបណ្តុះបណ្តាល ប្រកបដោយគុណភាព និងប្រសិទ្ធភាព លើការបង្រៀនមុខវិជ្ជាភាសាខ្មែរនៅបឋមសិក្សានាពេលបច្ចុប្បន្ន និងទៅអនាគត។

# ឯកសារពិគ្រោះ


- សៀវភៅសិក្សាគោលភាសាខ្មែរថ្នាក់ទី១ដល់ទី៦
- វិធីសាស្ត្របង្រៀន នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ១៩៩៥-១៩៩៦
- សមត្ថភាពការប្រើប្រាស់កម្មវិធីសៀវភៅសិក្សាថ្មី និងវិធីសាស្ត្របង្រៀន(ឯកសារសម្រាប់បំប៉នគ្រូឧទ្ទេសសាលាគរុកោសល្យ) ២០០០-២០០១
- សមត្ថភាពមូលដ្ឋានគ្រូបឋមសិក្សាផ្នែកវិធីសាស្ត្របង្រៀនភាសាខ្មែរ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ១៩៩៧-១៩៩៨
- ប្រវត្តិសាស្ត្រខ្មែរត្រឹង ងា បោះពុម្ពឆ្នាំ១៩៧៣
- អក្សរសិល្ប៍ប្រជាប្រិយ(សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ពន់ ឆាយ
- អក្សរសិល្ប៍ប្រជាប្រិយ(សាកលវិទ្យាល័យខេមរៈ ឆ្នាំបោះពុម្ព២០១៧)
- ប្រវត្តិអក្សរសិល្ប៍(សាកលវិទ្យាល័យបៀលប្រាយ បោះពុម្ពឆ្នាំ២០១៦)
- ប្រវត្តិអក្សរសិល្ប៍(សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បោះពុម្ពឆ្នាំ២០១៦)
- ទ្រឹស្តីអក្សរសិល្ប៍(សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ពៅ សាមី បោះពុម្ពឆ្នាំ)
- ភាសាវិទ្យា(សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បោះពុម្ពឆ្នាំ)
- សមត្ថភាពការប្រើប្រាស់កម្មវិធីសៀវភៅសិក្សាថ្មី និងវិធីសាស្ត្របង្រៀន(ឯកសារសម្រាប់បំប៉នសមត្ថភាពគ្រូឧទ្ទេសសាលាគរុកោសល្យ)
- វិធីសាស្ត្របង្រៀន(នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ១៩៩៥-១៩៩៦)
- សៀវភៅណែនាំគ្រូសម្រាប់ថ្នាក់ទី១ និងទី២ (អ.យ.ក បោះពុម្ពឆ្នាំ២០១៩)
- សៀវភៅជំនួយសិស្ស(អ.យ.ក បោះពុម្ពឆ្នាំ២០១៩)